# ការអនុវត្តអភិបាលកិច្ចលើសិទ្ធិកាន់កាប់ធនធាន ក្នុងវិស័យនេសាទ

## មគ្គុទ្ទេសក៍បច្ចេកទេស ដើម្បីផ្តល់ការគាំទ្រដល់ការអនុវត្តសេចក្តីណែនាំស្ម័គ្រចិត្តស្តីពីអភិបាលកិច្ច ប្រកបដោយការទទួលខុសត្រូវលើសិទ្ធិកាន់កាប់ដីធ្លី ធនធានទេសាទ និងធនធានព្រៃឈើ នៅក្នុងបរិបទ សន្តិសុខស្បៀង



ការជ្រើសរើសប្រទេស ដែនដី ទីក្រុង ឬតំបន់ និងការបង្ហាញពីឯកសារនានា នៅក្នុងផលិតផលព័ត៌មាននេះ មិនមានន័យថាជាការបង្ហាញពីទស្សនៈយល់ឃើញអ្វីមួយរបស់អង្គការស្បៀង និងកសិកម្មរបស់សហប្រជាជាតិ (FAO) ពាក់ព័ន្ធជាមួយនឹងស្ថានភាពស្របច្បាប់ ឬស្ថានភាពនៃការអភិវឌ្ឍរបស់ប្រទេស ដែនដី ទីក្រុង ឬតំបន់ណាមួយ ឬអាជ្ញាធររបស់ប្រទេស ដែនដី ទីក្រុង ឬតំបន់នោះឡើយ ឬពាក់ព័ន្ធជាមួយនឹងការកំណត់ព្រំប្រទល់ ឬព្រំដែនរបស់ប្រទេស ដែនដី ទីក្រុង ឬតំបន់នោះដែរ។ ការលើកឡើងពីក្រុមហ៊ុន ឬផលិតផលរបស់ក្រុមហ៊ុនផលិត មិនថាផលិតផលទាំងនេះមានប្រកាសនិយបត្រគាំទ្រឬអត់នោះទេ មិនមានន័យថា ក្រុមហ៊ុន ឬផលិតផលទាំងនេះ បានទទួលការគាំទ្រ ឬផ្តល់ជាអនុសាសន៍ដោយអង្គការ FAO ជាងក្រុមហ៊ុន ឬផលិតផលឯទៀតស្រដៀងគ្នានេះ ដែលមិនត្រូវបានលើកឡើងនោះទេ។

ទស្សនៈយល់ឃើញ នៅក្នុងផលិតផលព័ត៌មាននេះ គឺជាទស្សនៈយល់ឃើញរបស់អ្នកនិពន្ធ ហើយមិនឆ្លុះបញ្ចាំងជាចាំបាច់ពីទស្សនៈយល់ឃើញ ឬគោលនយោបាយរបស់ FAO ឡើយ។

ISBN 978-92-5-107900-3 (បោះពុម្ព)

E-ISBN 978-92-5-107901-0 (PDF)

© FAO, 2013

FAO លើកទឹកចិត្តឱ្យមានការប្រើប្រាស់ ការផលិតឡើងវិញ និងការផ្សព្វផ្សាយឯកសារ ដែលមាននៅក្នុងផលិតផលព័ត៌មាននេះ។ វៀរលែងតែមានការលើកឡើងផ្សេងទៀត គេអាចចម្លង ដោនឡូត និងបោះពុម្ពឯកសារ នានាសម្រាប់ការសិក្សាជាលក្ខណៈឯកជន ស្រាវជ្រាវ និងបង្រៀន ឬសម្រាប់ប្រើប្រាស់ក្នុងផលិតផល ឬសេវា ដែលមិនមានលក្ខណៈពាណិជ្ជកម្ម ដរាបណាមានការថ្លែងអំណរគុណសមស្របចំពោះ FAO ដែលជាប្រភព និងជាអ្នកកាន់កាប់សិទ្ធិចម្លង ហើយមិនមានការសន្និដ្ឋានថា FAO ជាអ្នកផ្តល់ការគាំទ្រដល់ទស្សនៈយល់ឃើញរបស់អ្នកប្រើប្រាស់ផលិតផល ឬសេវានានា។

គ្រប់សំណើសុំសិទ្ធិបកប្រែ និងកែសម្រួលទាំងអស់ និងសម្រាប់សិទ្ធិលក់បន្ត និងសិទ្ធិប្រើប្រាស់ជាលក្ខណៈពាណិជ្ជកម្មដទៃទៀត គួរធ្វើឡើង តាមរយៈ www.fao.org/contact-us/licencerequest ឬផ្ញើទៅកាន់ copyright@fao.org។

ផលិតផលព័ត៌មានរបស់ FAO អាចរកបានលើគេហទំព័ររបស់ FAO (www.fao.org/publications) និងអាចជាវបាន តាមរយៈ publications-sales@fao.org។

*រូបថតគំរបមុខ*

ដោយ Nicole Franz

## បុព្វកថា

ឯកសារនេះត្រូវបានរៀបចំឡើង ដើម្បីផ្តល់ការគាំទ្រដល់ការអនុវត្តសេចក្តីណែនាំស្ម័គ្រចិត្តស្តីពីអភិបាលកិច្ច ប្រកបដោយការទទួលខុសត្រូវលើសិទ្ធិកាន់កាប់ដីធ្លី ធនធាននេសាទ និងធនធានព្រៃឈើ នៅក្នុងបរិបទសន្តិសុខស្បៀង (VGGT) សម្រាប់វិស័យនេសាទ ដោយផ្តោតសំខាន់លើវិស័យខ្នាតតូច។

ការអនុម័តលើសេចក្តីណែនាំស្ម័គ្រចិត្តអំពីអភិបាលកិច្ច ប្រកបដោយការទទួលខុសត្រូវ លើសិទ្ធិកាន់កាប់ (VGGT) ដោយគណៈកម្មាធិការសន្តិសុខស្បៀងពិភពលោក (CFS) កាលពីខែ ឧសភា ឆ្នាំ ២០១២ គឺជាសមិទ្ធផលដ៏ធំមួយ។ ការទទួលស្គាល់ពីសារៈសំខាន់នៃលទ្ធភាពប្រើប្រាស់ធនធានធម្មជាតិបានជាប់លាប់ និងប្រកបដោយសមធម៌ ដើម្បីធានាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងការប្រកបរបរចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព ដែលមានបង្ហាញនៅក្នុង VGGT នេះ មានសារៈសំខាន់យ៉ាងខ្លាំងចំពោះសហគមន៍នេសាទ ជាពិសេស ក្រុមងាយរងគ្រោះ និងក្រុមដែលជួបប្រទះការលំបាក។ VGGT បានឆ្លងកាត់ដំណើរការពិគ្រោះយោបល់ និងចរចាយ៉ាងល្អិតល្អន់ ដោយមានការចូលរួមពីមន្ត្រីរដ្ឋាភិបាល អង្គការសង្គមស៊ីវិល តំណាងវិស័យឯកជន អង្គការអន្តរជាតិ និងស្ថាប័នសិក្សាស្រាវជ្រាវនានា។ ការចូលរួមនៅក្នុងដំណើរការនេះពីសំណាក់មនុស្ស ដែល VGGT មានគោលបំណងផ្តល់ការគាំទ្រទៅឱ្យ ដូចជា កសិករខ្នាតតូច សហគមន៍នេសាទ និងអ្នកប្រកបរបរស្រែចំការ អាចធានាបានថា បញ្ហា និងសំណើនានា បានទទួលការឆ្លើយតប ស្របតាមតថភាព ក្នុងជីវិតជាក់ស្តែង និងធានាឱ្យមានការឆ្លើយតបចំពោះក្តីបារម្ភពិតប្រាកដ។ VGGT មានមូលដ្ឋានផ្អែកលើស្តង់ដាសិទ្ធិ មនុស្សអន្តរជាតិសំខាន់ៗ និងជាឧបករណ៍ដ៏មានអានុភាពមួយ សម្រាប់លើកកម្ពស់ជីវភាពរស់នៅរបស់មនុស្សរាប់លាន នាក់។

ដើម្បីឱ្យ VGGT មានផលជាវិជ្ជមាន ដែលចង់សម្រេច ការគាំទ្រចំពោះការអនុវត្តសេចក្តីណែនាំនេះ មានសារៈសំខាន់បំផុត។ ចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងរួមគ្នា ដើម្បីធានាយ៉ាងណាឱ្យគោលការណ៍ និងស្តង់ដានានារបស់ VGGT ត្រូវបានដាក់បញ្ចូលទៅក្នុងគោលនយោបាយ និងផែនការនានា និងត្រូវបានប្រើប្រាស់ ដើម្បីលើកកម្ពស់អភិបាលកិច្ចលើសិទ្ធិកាន់កាប់ ដើម្បីជាប្រយោជន៍ដល់ប្រជាជនដែលងាយរងគ្រោះ និងបាត់បង់ឱកាស និងដើម្បីសម្រេចឱ្យបាននូវការកាត់បន្ថយភាពក្រីក្រ និងសន្តិសុខស្បៀងសម្រាប់ទាំងអស់គ្នា។ មគ្គុទេសក៍សម្រាប់អនុវត្ត

អភិបាលកិច្ចលើសិទ្ធិកាន់កាប់ឱ្យបានប្រសើរជាងមុនសម្រាប់វិស័យនេសាទនេះ ផ្តល់ការគាំទ្រដល់ដំណើរការខាងលើនេះ ក៏ដូចជាដល់កិច្ចខិតខំប្រឹងប្រែងនានា ដើម្បីផ្តល់នូវដំបូន្មាន និងកំណត់ទិសដៅ សម្រាប់វិស័យនេសាទ។ ឯកសារនេះគួរអានសម្រាប់ជាការបំពេញបន្ថែមដល់ VGGT និងយកទៅធ្វើការពិចារណា នៅក្នុងបរិបទនៃឧបករណ៍អន្តរជាតិដទៃទៀត ដែលផ្តោតសំខាន់ លើការអភិវឌ្ឍប្រកបដោយចីរភាព ដូចជា ក្រមសីលធម៌ស្តីពីវិស័យនេសាទប្រកបដោយការទទួលខុសត្រូវ (១៩៩៥) របស់ FAO សេចក្តីណែនាំស្ម័គ្រចិត្តអំពីសិទ្ធទទួលបានស្បៀង (២០០៥) របស់ FAO និងសេចក្តីណែនាំស្ម័គ្រចិត្តស្តីពីការ ធានានិរន្តភាពនៃការងារនេសាទខ្នាតតូច នៅក្នុងបរិបទសន្តិសុខស្បៀង និងការលុបបំបាត់ភាពក្រីក្រ។[1]

[1] កិច្ចប្រជុំលើកទី ២៩ របស់គណៈកម្មាធិការទទួលបន្ទុកការងារនេសាទ (COFI) របស់ FAO ដែលរៀបចំឡើង ក្នុងខែ កុម្ភៈ ឆ្នាំ ២០១១ បានផ្តល់ជាអនុសាសន៍ ឱ្យមានការរៀបចំឧបករណ៍អន្តរជាតិមួយស្តីពីការងារនេសាទខ្នាតតូច (សេចក្តីណែនាំអំពីការងារនេសាទខ្នាតតូច)។ នៅពេលដែលមគ្គុទេសក៍នេះត្រូវបាន រៀបចំឡើង សេចក្តីណែនាំអំពីការងារនេសាទខ្នាតតូចកំពុងរៀបចំនៅឡើយ - សូមមើល www.fao.org/fishery/ssf/guidelines/en។

## ការរៀបចំឯកសារនេះ

ជាផ្នែកមួយនៃដំណើរការពិគ្រោះយោបល់លើសេចក្ដីណែនាំស្ម័គ្រចិត្តស្ដីពីអភិបាលកិច្ច ប្រកបដោយការទទួលខុសត្រូវលើសិទ្ធិកាន់កាប់ដីធ្លី ធនធាននេសាទ និងធនធានព្រៃឈើ នៅក្នុងបរិបទសន្តិសុខស្បៀងរបស់ជាតិ (VGGT) មានករណីសិក្សាជាច្រើនត្រូវបានរៀបចំឡើងអំពីអភិបាលកិច្ចលើសិទ្ធិកាន់កាប់ធនធាននេសាទ។ ករណីសិក្សាទាំងនេះគ្របដណ្តប់លើប្រទេស និងបរិយាកាសនេសាទជាច្រើន ហើយបានស្វែងយល់ពីអត្ថន័យនៃអភិបាលកិច្ចលើសិទ្ធិកាន់កាប់ ធនធាននេសាទ។ ករណីសិក្សាជាច្រើនក្នុងចំណោមករណីសិក្សាទាំងនេះ កំពុងត្រូវបានបោះពុម្ពផ្សាយ នៅក្នុងព្រឹត្តបត្រ ស្តីពីសិទ្ធិកាន់កាប់ដីធ្លីរបស់ FAO ត្រង់ប្រធានបទវិស័យនេសាទ នៅក្នុងឆ្នាំ ២០១៣។ FAO បានរៀបចំសិក្ខាសាលាមួយ នៅក្នុងខែ កក្កដា ឆ្នាំ ២០១១ ដើម្បីពិភាក្សាពីអភិបាលកិច្ចលើសិទ្ធិកាន់កាប់ សម្រាប់ការប្រកបរបរនេសាទប្រកបដោយការទទួលខុសត្រូវ ដោយប្រើប្រាស់លទ្ធផលរបស់ករណីសិក្សាទាំងនេះ និងគំនិតផ្តួចផ្តើម "សម្លេងប្រជានេសាទ" ដែលជាគម្រោងមួយអនុវត្ត ដោយសហការជាមួយនឹងបណ្តាញអន្តរជាតិគាំទ្រដល់អ្នកធ្វើការងារក្នុងវិស័យនេសាទ ហើយបានបង្ហាញនូវសក្ខីកម្មអំពីបញ្ហាអភិបាលកិច្ចលើសិទ្ធិកាន់កាប់ ដែលលើកឡើងដោយប្រជានេសាទ។ ឯកសារនេះ ដែលមានចំណងជើងថា ការអនុវត្តអភិបាលកិច្ចលើសិទ្ធិកាន់កាប់ធនធាន ក្នុងវិស័យនេសាទ ៖ មគ្គុទេសក៍បច្ចេកទេស ដើម្បីផ្តល់ការគាំទ្រដល់ការអនុវត្តសេចក្តីណែនាំស្ម័គ្រចិត្តស្តីពីអភិបាលកិច្ច ប្រកបដោយការទទួលខុសត្រូវ លើសិទ្ធិកាន់កាប់ដីធ្លី ធនធាននេសាទ និងធនធានព្រៃឈើ នៅក្នុងបរិបទសន្តិសុខស្បៀង (ហៅកាត់ថា "មគ្គុទេសក៍") គឺផ្អែកទៅតាមលទ្ធផលទាំងនេះ។ មគ្គុទេសក៍នេះក៏ពិចារណាផងដែរលើលទ្ធផល និងព័ត៌មាននានា ដែលប្រមូលបានពីដំណើរការពាក់ព័ន្ធដទៃទៀត ជាពិសេស ការពិគ្រោះយោបល់ ដែលធ្វើឡើង នៅក្នុងបរិបទនៃការរៀបចំសេចក្តីណែនាំស្ម័គ្រចិត្តអំពីការធានានិរន្តរភាពការងារនេសាទខ្នាតតូច នៅក្នុងបរិបទសន្តិសុខស្បៀង និងការលុបបំបាត់ភាពក្រីក្រ។

ឯកសារនេះត្រូវបានរៀបចំឡើង ដោយនាយកដ្ឋានជលផល និងវារីវប្បកម្មរបស់ FAO។ អត្ថបទនេះត្រូវបានព្រាងដំបូងដោយ Lena Westlun (ទីប្រឹក្សារបស់ FAO) ជាមួយនឹងធាតុចូលសំខាន់ៗពីមន្ត្រីរបស់ ដូចជា Nicole Franz, Carlos Fuentevilla, Rebecca Metzner, Francesca Romano, Margret Vidar និង Rolf Willmann

ជាដើម។ យើងខ្ញុំសូមថ្លែងអំណរគុណផងដែរចំពោះអ្នកខាងក្រៅ ដែលរួមចំណែកជួយពិនិត្យឯកសារនេះ ដូចជា Svein Jentoft, John Kurien, Patrick McConney និង Jackie Sunde ជាដើម។ សំណៅចុងក្រោយរបស់ឯកសារនេះ នឹងមានក្រោយពេលមានការពិភាក្សាបន្ថែម និងពិនិត្យឡើងវិញ នៅក្នុងឆ្នាំ ២០១៤ រួច។

ការបោះពុម្ពឯកសារនេះអាចធ្វើទៅបាន ដោយមានការផ្តល់មូលនិធិពីក្រសួងស្បៀង កសិកម្ម និងការពារអ្នកប្រើប្រាស់សហព័ន្ធរបស់ប្រទេសអាល្លឺម៉ង់ និងមូលនិធិពីប្រទេសស៊ុយអែត តាមរយៈយន្តការគាំទ្រកម្មវិធីពហុភាគី (FMM)។

**សម្រាប់ព័ត៌មានបន្ថែម ឬដើម្បីផ្តល់ជាយោបល់ សូមទាក់ទង ៖**


Rebecca Metzner
*នាយកដ្ឋានជលផល និងវារីវប្បកម្ម*
FAO
Rebecca.Metzner@fao.org

Nicole Franz
*នាយកដ្ឋានជលផល និងវារីវប្បកម្ម*
FAO
Nicole.Franz@fao.org

Francesca Romano
*ផ្នែកសិទ្ធិកាន់កាប់ អាកាសធាតុ និងថាមពល*
FAO
Francesca.Romano@fao.org



FAO. 2013.
Implementing improved tenure governance in fisheries – A technical guide to support the implementation of the voluntary guidelines on the responsible governance of tenure of land, fisheries and forests in the context of national food security. Preliminary version, September 2013. Rome. 71 pp.

## មាតិកា


បុព្វកថា ........................................................................................................ ៣

ការរៀបចំឯកសារនេះ ............................................................................................ ៥

មាតិកា ........................................................................................................ ៧

បញ្ជីតារាង ........................................................................................................ ៩

បញ្ជីរូបភាព ........................................................................................................ ៩

បញ្ជីប្រអប់ ........................................................................................................ ៩

អក្សរកាត់ និងពាក្យកាត់........................................................................................ ១១

សេចក្តីផ្តើម ........................................................................................................ ១៤

សាវតារ ........................................................................................................ ១៤

គោលបំណង និងវិសាលភាពនៃមគ្គុទេសក៍នេះ ............................................................ ១៧

ផ្នែកទី ១ ៖ លក្ខណៈរបស់អភិបាលកិច្ចលើសិទ្ធិកាន់កាប់ធនធានប្រកបដោយការទទួលខុសត្រូវ នៅក្នុងវិស័យនេសាទ ........................................................................................ ១៩

តើសិទ្ធិកាន់កាប់ និងអភិបាលកិច្ចលើសិទ្ធិកាន់កាប់ មានន័យយ៉ាងដូចម្តេច នៅក្នុងបរិបទនៃ វិស័យនេសាទ? ........................................................................................ ១៩

ហេតុអ្វីបានជាចាំបាច់ត្រូវមានអភិបាលកិច្ចលើសិទ្ធិកាន់កាប់ប្រកបដោយការទទួលខុសត្រូវ នៅក្នុង វិស័យនេសាទ? ........................................................................................ ២២

សន្តិសុខជីវភាពរស់នៅ និងសុខុមាលភាពសង្គម .................................................... ២៣

ការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាពសេដ្ឋកិច្ច និងអាចធានាបាននូវនិរន្តរភាពនៃប្រព័ន្ធ ជីវសាស្ត្រ ........................................................................................ ២៤

តើអ្នកណាដែលមានសិទ្ធិទទួលបានធនធាននេសាទ និងថាតើមានការទទួលខុសត្រូវពាក់ព័ន្ធអ្វីខ្លះ? .................... ២៦

តើគេអាចគ្រប់គ្រងធនធាននេសាទប្រកបដោយនិរន្តរភាព ក្នុងនាមជាទ្រព្យសម្បត្តិរួម បានដែរឬទេ? ................ ៣០

ហេតុអ្វីបានជាគេគួរប្រើប្រាស់អភិក្រមសិទ្ធិមនុស្ស នៅក្នុងអភិបាលកិច្ច និងការអភិវឌ្ឍសហគមន៍ភាព

នេសាទខ្នាតតូច? ........................................................................................................ ៣៣
តើសិទ្ធិកាន់កាប់ផ្លូវការ នៅក្នុងវិស័យនេសាទ មានប្រភេទផ្សេងៗគ្នាអ្វីខ្លះ? ............................................. ៣៦
តើមានសិទ្ធិកាន់កាប់បែបទំនៀមទម្លាប់ និងក្រៅផ្លូវការអ្វីខ្លះ? ........................................................ ៤២
តើមានអ្វីខ្លះកើតមានឡើង ចំពោះធនធាននេសាទរួម និងធនធាននេសាទ នៅក្នុងដែនទឹកអន្តរជាតិ? .................. ៤៦
តើមានក្របខ័ណ្ឌច្បាប់ និងគោលនយោបាយអន្តរជាតិ ពាក់ព័ន្ធជាមួយនឹងអភិបាលកិច្ចលើសិទ្ធិកាន់កាប់
ធនធាននេសាទ ដែរឬទេ? ............................................................................................ ៤៨
តើគេអាចកំណត់តម្លៃរបស់សិទ្ធិកាន់កាប់ ដោយរបៀបណា? ............................................................ ៥១
តើមានបញ្ហាថ្មីៗអ្វីខ្លះ ដែលចាំបាច់ត្រូវយកមកធ្វើការពិចារណា នាពេលអនាគត? ...................................... ៥៥
ផ្នែកទី ២ ៖ ការអនុវត្តសិទ្ធិកាន់កាប់ប្រកបដោយការទទួលខុសត្រូវ នៅក្នុងវិស័យនេសាទ.................................. ៥៩
បរិបទនៃការអនុវត្ត.................................................................................................. ៥៩
គោលការណ៍ទូទៅ...................................................................................................... ៦២
ការកំណត់គោលបំណង................................................................................................ ៦៦
ការបង្កើនចំណេះដឹង.................................................................................................. ៦៩
អ្នកពាក់ព័ន្ធ និងសិទ្ធិកាន់កាប់ដែលមានស្រាប់................................................................... ៦៩
ការប៉ាន់ប្រមាណពីតម្លៃរបស់សិទ្ធិកាន់កាប់.......................................................................... ៧៥
ការវិនិយោគ.......................................................................................................... ៧៧
ការបែងចែកសិទ្ធិ...................................................................................................... ៧៩
ដំណើរការនៃការបែងចែក.......................................................................................... ៧៩
ការបែងចែកសិទ្ធិកាន់កាប់ឡើងវិញ និងការប្រកួតប្រជែងគ្នា ក្នុងចំណោមអ្នកប្រើប្រាស់....................... ៨៨
ការគ្រប់គ្រងលើសិទ្ធិកាន់កាប់......................................................................................... ៩៣
សេវារដ្ឋបាល និងសេវាពាក់ព័ន្ធ ដែលផ្តល់ដោយរដ្ឋាភិបាល........................................................ ៩៣
សមត្ថភាព និងរចនាសម្ព័ន្ធស្ថាប័ន................................................................................... ៩៦
បញ្ជិកា កំណត់ត្រា និងព័ត៌មានអំពីសិទ្ធិ............................................................................. ១០១
យន្តការដោះស្រាយវិវាទ............................................................................................. ១០៣

កត្តាពិសេសៗ ដែលត្រូវយកមកធ្វើការពិចារណា ៖ ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយធម្មជាតិ......... ១០៧
ការពិនិត្យតាមដាន និងវាយតម្លៃ និងភាពអនុលោម.................................................................. ១១០
ឯកសារយោង ........................................................................................................ ១១៤
ឧបសម្ព័ន្ធទី ១ ៖ សន្ទានុក្រម..................................................................................... ១២០
ឧបសម្ព័ន្ធទី ២ ៖ អភិក្រម និងឧបករណ៍នានា................................................................... ១២៣

## បញ្ជីតារាង

តារាងទី ១៖ ប្រភេទប្រព័ន្ធគ្រប់គ្រង ដោយយកសិទ្ធិធ្វើជាមូលដ្ឋាន - ឧទាហរណ៍ដែលមាននៅតាមប្រទេស OECD ........ ៤០

## បញ្ជីរូបភាព

រូបភាពទី ១ ៖ បរិបទ និងដំណើរការនៃការអនុវត្តសិទ្ធិកាន់កាប់ប្រកបដោយការទទួលខុសត្រូវ ..................... ៦២

## បញ្ជីប្រអប់

ប្រអប់ទី ១ ៖ អ្វីទៅដែលហៅថាអភិបាលកិច្ចលើសិទ្ធិកាន់កាប់ និងហេតុអ្វីបានជាវាមានសារៈសំខាន់? ...................... ១៤
ប្រអប់ទី ២ ៖ នេសាទក្នុងទ្រង់ទ្រាយតូច ........................................................................ ១៨
ប្រអប់ទី ៣ ៖ អ្វីទៅដែលហៅថាអភិបាលកិច្ច? ..................................................................... ២០
ប្រអប់ទី ៤ ៖ អ្វីទៅជាការគ្រប់គ្រងធនធាននេសាទ? ............................................................. ២៧
ប្រអប់ទី ៥ ៖ បុរស និងស្ត្រី នៅក្នុងវិស័យនេសាទ................................................................ ៣៥
ប្រអប់ទី ៦ ៖ អ្វីទៅជាការរៀបចំផែនការទីតាំង ដែលមានលក្ខណៈសមាហរណកម្ម? ......................................... ៣៨
ប្រអប់ទី ៧ ៖ របនាសម្ព័ន្ធគ្រប់គ្រងរួមគ្នា នៅក្នុងប្រទេស Burkina Faso.................................................... ៣៩
ប្រអប់ទី ៨ ៖ អ្នកនេសាទ និងកម្មករនេសាទចំណាកស្រុក និងសិទ្ធិក្រៅផ្លូវការ................................................ ៤៣
ប្រអប់ទី ៩ ៖ ការបំពេញសិទ្ធិបែបទំនៀមទម្លាប់ នៅអាហ្វ្រិចខាងត្បូង.......................................................... ៤៥
ប្រអប់ទី ១០ ៖ លិខិតុបករណ៍អន្តរជាតិមួយចំនួន.................................................................. ៤៩
ប្រអប់ទី ១១ ៖ ភាពពាក់ព័ន្ធនៃគោលនយោបាយស្តីពីតំបន់បម្រុង ក្រោយគ្រោះមហន្តរាយស៊ូណាមិ ឆ្នាំ ២០០៤............ ៥៧

ប្រអប់ទី ១២ ៖ ការរៀបចំអភិបាលកិច្ច និងការគ្រប់គ្រងវិស័យនេសាទនៅមូលដ្ឋាន ក្នុងប្រទេសហ្វីលីពីន.................... ៦៣
ប្រអប់ទី ១៣ ៖ ការដាក់បញ្ចូលសិទ្ធិបែបប្រពៃណី........................................................................... ៧៣
ប្រអប់ទី ១៤ ៖ ករណីតំបន់ការពារក្នុងដែនសមុទ្ទ (MPAs) ..................................................................... ៧៤
ប្រអប់ទី ១៥ ៖ ប្រព័ន្ធ “parcela” របស់អ្នកប្រមូលសារាយសមុទ្ទនៅប្រទេសឈីលី......................................... ៨១
ប្រអប់ទី ១៦ ៖ លក្ខណៈវិនិច្ឆ័យរបស់ ICCAT សម្រាប់ធ្វើការបែងចែកលទ្ធភាពនេសាទ.................................... ៨៣
ប្រអប់ទី ១៧ ៖ លទ្ធភាពអាចផ្ទេរបាននូវសិទ្ធិនេសាទជាលក្ខណៈពាណិជ្ជកម្មរបស់ប្រជុំកោះ Galapgos ................. ៨៥
ប្រអប់ទី ១៨ ៖ សហគមន៍នេសាទ នៅក្នុងប្រព័ន្ធបឹង Patos ក្នុងប្រទេសប្រេស៊ីល .......................................... ១០៩

## អក្សរកាត់ និងពាក្យកាត់

| | | |
|---|---|---|
| ABNJ | areas beyond national jurisdiction | តំបន់នៅខាងក្រៅយុត្តាធិការជាតិ |
| ADR | alternative dispute resolution | ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ |
| CBA | cost–benefit analysis | ការវិភាគចំណាយ និងប្រយោជន៍ដែលទទួលបាន |
| CBD | Convention on Biological Diversity | អនុសញ្ញាស្តីពីជីវចម្រុះ |
| CBM | community-based ecological monitoring | ការពិនិត្យតាមដានបរិស្ថាននៅតាមសហគមន៍ |
| CBO | community-based organization | អង្គការសហគមន៍ |
| CCA | climate change adaptation | ការបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ |
| CEDAW | Convention on the Elimination of All Forms of Discrimination against Women | អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងចំពោះស្ត្រី |
| CFS | Committee on World Food Security | គណៈកម្មាធិការសន្តិសុខស្បៀងពិភពលោក |
| COFI | Committee on Fisheries (FAO) | គណៈកម្មាធិការទទួលបន្ទុកការងារនេសាទ (FAO) |
| CSO | civil society organization | អង្គការសង្គមស៊ីវិល |
| CVM | contingent valuation method | វិធីសាស្រ្តវាយតម្លៃបម្រុង |
| DRM | disaster risk management | ការគ្រប់គ្រងគ្រោះភ័យនៃគ្រោះមហន្តរាយ |
| EAF | ecosystem approach to fisheries | វិធីសាស្រ្តនេសាទ ដោយប្រើប្រាស់ប្រព័ន្ធបរិស្ថាន |
| EEZ | exclusive economic zone | តំបន់សេដ្ឋកិច្ចផ្តាច់មុខ |
| ESCR | International Covenant on Economic, Social and Cultural Rights | អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ |
| FARMC | Fisheries and Aquatic Resources Management Council (Philippines) | ក្រុមប្រឹក្សាគ្រប់គ្រងធនធាននេសាទ និងវារីជាតិ (ប្រទេសហ្វីលីពីន) |
| GEF | Global Environment Facility | កម្មវិធីបរិស្ថានសកល |

| | | |
|---|---|---|
| HIPC | heavily indebted poor country | ប្រទេសក្រីក្រដែលជាប់បំណុលធ្ងន់ធ្ងរ |
| ICCAT | International Commission for the Conservation of Atlantic Tunas | គណៈកម្មការអន្តរជាតិអភិរក្សសត្វក្នុងមហាសមុទ្រអាត្លង់ទិច |
| ICT | information and communication technologies | បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ |
| ICZM | integrated coastal zone management | ការគ្រប់គ្រងតំបន់ឆ្នេរដែលមានលក្ខណៈសមាហរណកម្ម |
| IMF | International Monetary Fund | មូលនិធិរូបិយវត្ថុអន្តរជាតិ |
| ITQ | individual transferable quota | កូតាបុគ្គលដែលអាចផ្ទេរបាន |
| IUU | illegal, unreported and unregulated (fishing) | (ការនេសាទ) ដែលខុសច្បាប់ គ្មានការរាយការណ៍ និងគ្មានច្បាប់គ្រប់គ្រងត្រឹមត្រូវ |
| LGAF | Land Governance Assessment Framework | ក្របខ័ណ្ឌវាយតម្លៃលើអភិបាលកិច្ចដីធ្លី |
| LGU | Local Government Unit (Philippines) | អង្គភាពនៅថ្នាក់មូលដ្ឋានរបស់រដ្ឋាភិបាល (ប្រទេសហ្វីលីពីន) |
| LMMA | locally managed marine area | តំបន់សមុទ្រ ដែលគ្រប់គ្រងនៅមូលដ្ឋាន |
| M&E | monitoring and evaluation | ការពិនិត្យតាមដាន និងវាយតម្លៃ |
| MCS | monitoring, control and surveillance | ការពិនិត្យតាមដាន ត្រួតពិនិត្យ និងឃ្លាំមើល |
| MPA | marine protected area | តំបន់ការពារក្នុងដែនសមុទ្រ |
| MSP | marine spatial planning | ការរៀបចំផែនការលំហរសមុទ្រ |
| NGO | non-governmental organization | អង្គការមិនមែនរដ្ឋាភិបាល |
| NOAA | National Oceanic and Atmospheric Administration (United States) | រដ្ឋបាលសមុទ្រ និងបរិយាកាសជាតិ (សហរដ្ឋអាមេរិច) |
| OECD | Organisation for Economic Co-operation and Development | អង្គការសម្រាប់កិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច |
| PM&E | participatory monitoring and evaluation | ការពិនិត្យតាមដាន និងការវាយតម្លៃដោយមានការចូលរួម |

| | | |
|---|---|---|
| PRA | participatory rural appraisal | ការវាយតម្លៃជនបទដោយមានការចូលរួម |
| PRSP | poverty reduction strategy plan | ផែនការយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ |
| RFB | regional fishery body | ស្ថាប័នជលផលថ្នាក់តំបន់ |
| RFMO/A | regional fisheries management organization/arrangement | ស្ថាប័ន/ការរៀបចំការគ្រប់គ្រងការងារនេសាទថ្នាក់តំបន់ |
| RUM | random utility modelling | ការបង្កើតគំរូសម្រាប់ប្រើប្រាស់ដោយចៃដន្យ |
| SFLP | Sustainable Fisheries Livelihoods Programme | កម្មវិធីប្រកបរបរនេសាទសម្រាប់ចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព |
| SIA | social impact assessment | ការវាយតម្លៃផលប៉ះពាល់សង្គម |
| SIDS | Small Island Developing States | រដ្ឋកំពុងអភិវឌ្ឍ ដែលជាដែនកោះតូចៗ |
| SWOT | strengths, weaknesses, opportunities and threats | ចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងការគំរាមកំហែង |
| TCM | travel cost method | វិធីសាស្ត្រចំណាយសម្រាប់ការធ្វើដំណើរ |
| TURF | territorial use rights in fisheries | សិទ្ធិប្រើប្រាស់ដែនដី នៅក្នុងវិស័យនេសាទ |
| UNEP | United Nations Environment Programme | កម្មវិធីបរិស្ថានរបស់សហប្រជាជាតិ |
| VGGT | Voluntary Guidelines on the Responsible Governance of Tenure of Land, Fisheries and Forests in the Context of National Food Security | សេចក្តីណែនាំស្ម័គ្រចិត្តស្តីពីអភិបាលកិច្ច ប្រកបដោយការទទួលខុសត្រូវលើសិទ្ធិកាន់កាប់ដីធ្លី ធនធាននេសាទ និងធនធានព្រៃឈើ នៅក្នុងបរិបទសន្តិសុខស្បៀង |

## សេចក្តីផ្តើម

### សាវតារ

សេចក្តីណែនាំស្ម័គ្រចិត្តស្តីពីអភិបាលកិច្ច ប្រកបដោយការ ទទួលខុសត្រូវលើសិទ្ធិកាន់កាប់ដីធ្លី ធនធាននេសាទ និង ធនធានព្រៃឈើ នៅក្នុងបរិបទសន្តិសុខស្បៀង (ដែលហៅកាត់ថា VGGT) បានទទួលការគាំទ្រជាផ្លូវការពីគណៈកម្មាធិការ សន្តិសុខស្បៀងពិភពលោក (CFS) កាលពីថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១២។ ការគាំទ្រនេះជាសក្ខីភាពបង្ហាញពីការបញ្ចប់ ដោយជោគជ័យនូវដំណើរការពិគ្រោះយោបល់ និងចរចា ដែលចំណាយពេលវេលាអស់ជាច្រើន ហើយឥឡូវនេះ មាន ក្របខ័ណ្ឌ ដែលបានទទួលការឯកភាពជាអន្តរជាតិមួយ ដោយមានដាក់បញ្ចូលគោលការណ៍ និងស្តង់ដាដែលត្រូវបានគេ ទទួលយក អំពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើសិទ្ធិកាន់កាប់ដីធ្លី ធនធាននេសាទ និងធនធានព្រៃឈើ (សូម មើលប្រអប់ទី ១)។ VGGT នឹងត្រូវប្រើប្រាស់ដោយតួអង្គ និងអ្នកពាក់ព័ន្ធនានា ដូចជា អាជ្ញាធររបស់រដ្ឋាភិបាល វិស័យ ឯកជន សង្គមស៊ីវិល និងប្រជាពលរដ្ឋទូទៅ នៅពេលដែលពួកគេរៀបចំយុទ្ធសាស្ត្រ គោលនយោបាយ ច្បាប់ និងកម្មវិធីនានា ហើយសេចក្តីណែនាំនេះ គឺជាឧបករណ៍ដ៏សំខាន់មួយ សម្រាប់ធ្វើការវិនិច្ឆ័យថាតើសកម្មភាពដែលស្នើឡើង គឺជាការអនុវត្ត ដែលអាចទទួលយកបានដែរឬទេ។ ការអនុវត្ត VGGT នឹងចូលរួមចំណែកចំពោះការកាត់បន្ថយភាពក្រីក្រ សន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងកំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌ ដែលនាំឱ្យមានការលើកកម្ពស់និរន្តរភាពផ្នែកសេដ្ឋកិច្ច សង្គម និងបរិស្ថាន សម្រាប់ភពផែនដី និងមនុស្សជាតិ នាពេលអនាគត ស្របទៅតាមលទ្ធផលនៃសន្និសីទរបស់សហប្រជាជាតិស្តីពី ការអភិវឌ្ឍប្រកបដោយចីរភាព ដែលធ្វើឡើងនៅក្នុងទីក្រុង Rio de Janeiro នៅក្នុងឆ្នាំ ២០១២ (Rio+20)។

**ប្រអប់ទី ១ ៖ អ្វីទៅដែលហៅថាអភិបាលកិច្ចលើសិទ្ធិកាន់កាប់ និងហេតុអ្វីបានជាវាមានសារៈសំខាន់?**

សិទ្ធិកាន់កាប់ គឺជាមធ្យោបាយ ដើម្បីឱ្យមនុស្សមានលទ្ធភាពប្រើប្រាស់ដីធ្លី ធនធាននេសាទ ធនធានព្រៃឈើ និង ធនធានធម្មជាតិដទៃទៀត។ អភិបាលកិច្ចលើសិទ្ធិកាន់កាប់ មានផលប៉ះពាល់លើថាតើមនុស្សអាចទទួលបានសិទ្ធិ និងការពារ សិទ្ធិដែលមានរួចទៅហើយរបស់ពួកគេ ក្នុងការប្រើប្រាស់ និងគ្រប់គ្រងលើធនធានទាំងនេះដែរឬទេ និងថាតើពួកគេទទួល បានសិទ្ធិ និងការពារសិទ្ធិទាំងនេះដោយរបៀបណា។ បញ្ហាពាក់ព័ន្ធនឹងសិទ្ធិកាន់កាប់ជាច្រើន កើតឡើង ដោយសារតែ

អភិបាលកិច្ច មានកម្រិតខ្សោយ ហើយគុណភាពនៃអភិបាលកិច្ចមានផលប៉ះពាល់លើការខិតខំប្រឹងប្រែង ដើម្បីធ្វើការដោះស្រាយបញ្ហាទាំងនេះ។ សិទ្ធិកាន់កាប់ធនធានធម្មជាតិមិនគ្រប់គ្រាន់ និងមិនជាប់លាប់ ជារឿយៗ នាំឱ្យមានភាពក្រីក្រ និងគ្រោះអត់ឃ្លានធ្ងន់ធ្ងរ។ ការលុបបំបាត់គ្រោះអត់ឃ្លាន និងភាពក្រីក្រ ក៏ដូចជាការប្រើប្រាស់បរិស្ថានប្រកបដោយនិរន្តរភាព និងការបន្តផ្តល់សេវាប្រព័ន្ធ គឺអាស្រ័យលើថាតើប្រជាពលរដ្ឋ សហគមន៍ និងមនុស្សផ្សេងទៀត អាចទទួលបានដីធ្លី និងធនធានធម្មជាតិដទៃទៀត ដោយរបៀបណា។ ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋជាច្រើននាក់ ជាពិសេសប្រជាពលរដ្ឋក្រីក្ររស់នៅតាមតំបន់ជនបទ គឺផ្អែកទៅតាមលទ្ធភាពទទួលបានធនធាន និងគ្រប់គ្រងធនធានទាំងនេះឱ្យបានជាប់លាប់ ប្រកបដោយសមធម៌។ ធនធានទាំងនេះ រួមមាន ៖ ប្រភពអាហារ និងទីជម្រក មូលដ្ឋានសម្រាប់ការប្រតិបត្តិផ្នែកសង្គម វប្បធម៌ និងការគោរព ជំនឿសាសនា និងកត្តាចម្បងនៅក្នុងកំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌។

ប្រភព ៖ FAO (2012a)

នៅក្នុងវិស័យនេសាទ អភិបាលកិច្ចលើសិទ្ធិកាន់កាប់ ដែលគ្មានប្រសិទ្ធភាព គឺជាឧបសគ្គចម្បងមួយចំពោះការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព និងប្រសិទ្ធភាព ដូច្នេះនាំឱ្យមានផលប៉ះពាល់មកលើជីវភាពរស់នៅ និងសន្តិសុខ ស្បៀង និងអាហារូបត្ថម្ភ។ សហគមន៍នេសាទខ្នាតតូចជាច្រើន ទទួលរងគ្រោះ ដោយសារការទទួលបានធនធានដែលពួកគេពឹងអាស្រ័យលើ មានមិនជាប់លាប់។ ខណៈពេលដែលលទ្ធភាពទទួលបានធនធាននេសាទ គឺជាកត្តាគន្លឹះមួយ ជាការសំខាន់ណាស់ ដែលគេត្រូវយល់ផងដែរថា សហគមន៍នេសាទក៏ពឹងអាស្រ័យលើលទ្ធភាពទទួលបានធនធាន និងសេវាដទៃទៀតផងដែរ ដូចជា ដីធ្លី លំនៅដ្ឋាន ទីផ្សារ ធនធានហិរញ្ញវត្ថុ ព័ត៌មាន ប្រព័ន្ធច្បាប់ និងសេវាសង្គម (ឧ. អប់រំ ការថែទាំសុខភាព អនាម័យ ជាដើម)។ ធាតុពិត សិទ្ធិកាន់កាប់ដីធ្លី និងធនធាននេសាទ ចាំបាច់ត្រូវតែយកមកដាក់បញ្ចូលគ្នា។ សហគមន៍នេសាទខ្នាតតូច ត្រូវការសិទ្ធិប្រើប្រាស់ធនធាននេសាទ និងដីធ្លីនៅតាមតំបន់ឆ្នេរ តំបន់បឹង ឬតំបន់ជាប់ទឹកឱ្យបានជាប់លាប់ ដើម្បីធានា និងសម្រួលឱ្យពួកគេអាចប្រកបរបរនេសាទ ធ្វើសកម្មភាពបន្ថែម (ដូចជា កែច្នៃ និងរកទីផ្សារ) ក៏ដូចជា មានលំនៅដ្ឋាន និងទទួលបានការគាំទ្រដទៃទៀត សម្រាប់ជីវភាពរស់នៅរបស់ពួកគេ។

ធនធាននេសាទយ៉ាងច្រើនរបស់ពិភពលោក ទាំងក្នុងសមុទ្ទ ទាំងទឹកសាប កំពុងស្ថិតក្នុងស្ថានអន្តរាយ។ ការនេសាទហួសកម្រិត និងអប្រសិទ្ធភាពសេដ្ឋកិច្ច ដោយសារតែការប្រើប្រាស់ធនធាននេសាទលើសចំណុះ គឺជាអ្វីដែលកើតឡើងក្នុង

វិស័យនេសាទរបស់ប្រទេសជាច្រើន ក្នុងពិភពលោក។ នេះមានន័យថា វិស័យនេសាទមិនបានចូលរួមចំណែកចំពោះការអភិវឌ្ឍ ដែលធានាបាននូវនិរន្តរភាពផ្នែកសេដ្ឋកិច្ច សង្គម និងបរិស្ថាន តាមបែបផែន ដែលវិស័យនេះអាចធ្វើបានឡើយ។ ស្ថានភាពនេះកាន់តែធ្លាក់ចុះដុនដាបទៅទៀត ដោយសារតែភាពមិនប្រាកដប្រជា ពាក់ព័ន្ធនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍដទៃទៀត ដោយសារតែបម្រែបម្រួលក្នុងសកលលោក។ ការលើកកម្ពស់អភិបាលកិច្ចលើសិទ្ធិកាន់កាប់ ដោយធ្វើការពិចារណាលើបញ្ហាទាំងនេះ និងមូលហេតុរបស់វា គឺជាការងារ ដែលត្រូវធ្វើជាបន្ទាន់។

## គោលបំណង និងវិសាលភាពនៃមគ្គុទេសក៍នេះ

មគ្គុទេសក៍នេះត្រូវបានរៀបចំឡើង ដើម្បីជួយដល់ការអនុវត្ត VGGT ពាក់ព័ន្ធនឹងវិស័យនេសាទសមុទ្ទ និងទឹកសាប។ មគ្គុទេសក៍នេះពន្យល់ពីលក្ខណៈរបស់វិស័យនេសាទ និងផ្តល់នូវការណែនាំបច្ចេកទេស។ មគ្គុទេសក៍នេះមានគោលបំណងចូលរួមចំណែកសម្រេចគោលដៅរបស់ VGGT ពាក់ព័ន្ធនឹងការលើកកម្ពស់អភិបាលកិច្ចលើសិទ្ធិកាន់កាប់ធនធាន ក្នុងវិស័យនេសាទ។ មានការផ្តល់ការយកចិត្តទុកដាក់ពិសេសលើការងារនេសាទទ្រង់ទ្រាយតូច ដោយសារតែសារៈសំខាន់ជាពិសេសរបស់វិស័យនេះ ចំពោះសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ការលុបបំបាត់ភាពក្រីក្រ ការអភិវឌ្ឍប្រកបដោយសមធម៌ និងការប្រើប្រាស់ធនធានប្រកបដោយនិរន្តរភាព (សូមមើលប្រអប់ទី ២)។ មានសហគមន៍នេសាទតូចៗជាច្រើន ដែលងាយរងគ្រោះ និងបាត់បង់ឱកាស ដូច្នេះសហគមន៍ទាំងនេះ តំណាងឱ្យមនុស្ស ដែលក្រុមគោលដៅស្នូលរបស់ VGGT។

មគ្គុទេសក៍នេះ ផ្តោតគោលដៅលើមន្ត្រីក្នុងរដ្ឋាភិបាល និងអង្គការស្ថាប័នផ្សេងទៀត ដែលធ្វើការងារពាក់ព័ន្ធនឹងបញ្ហាអភិបាលកិច្ចលើសិទ្ធិកាន់កាប់ធនធាន នៅក្នុងវិស័យនេសាទ និងតាមតំបន់ ដែលមានសហគមន៍នេសាទតាំងនៅ ឬដែលពួកគេប្រកបរបរចិញ្ចឹមជីវិតរបស់ពួកគេ។ ដូច្នេះ ក្រុមគោលដៅរួមមានបុគ្គលិកពាក់ព័ន្ធ ដែលធ្វើការងារនៅតាមស្ថាប័នជលផល និងស្ថាប័នរដ្ឋាភិបាល និងស្ថាប័នថ្នាក់តំបន់នានា ក៏ដូចជាស្ថាប័នក្នុងវិស័យឯកជន និងសង្គមស៊ីវិលផងដែរ។ ផ្នែកទី ១ របស់មគ្គុទេសក៍នេះ ផ្តល់នូវការពន្យល់ ពាក់ព័ន្ធជាមួយនឹងទស្សនទានសំខាន់ៗ ដើម្បីស្វែងយល់ពីសិទ្ធិកាន់កាប់ នៅក្នុងវិស័យនេសាទ។ ផ្នែកនេះមានភាពពាក់ព័ន្ធជាពិសេស ចំពោះអ្នកដែលមិនដឹងពីវិស័យនេសាទ។ ផ្នែកទី ២ ពិភាក្សាពីអភិក្រមសម្រាប់អនុវត្តសិទ្ធិកាន់កាប់ នៅក្នុងវិស័យនេសាទ ហើយផ្តោតលើអ្នកដែលមានភារកិច្ចអនុវត្ត VGGT នៅក្នុងវិស័យនេសាទ និងសម្រាប់ជាប្រយោជន៍ដល់សហគមន៍នេសាទតូចតូច។

អភិបាលកិច្ច នៅក្នុងវិស័យនេសាទ ពាក់ព័ន្ធជាមួយនឹងសិទ្ធិទទួលបានធនធាននេសាទ (លទ្ធភាពធ្វើការនេសាទ) គឺជាប្រធានបទ ដែលមានការស្រាវជ្រាវកន្លងមក និងមានការណែនាំច្រើនមកហើយ។ ក្នុងពេលខិតខំបង្ហាញជារួមឱ្យបានសុក្រិតអំពីបញ្ហានេះ មគ្គុទេសក៍នេះផ្តោតការយកចិត្តទុកដាក់លើក្តីបារម្ភ ពាក់ព័ន្ធជាមួយនឹងសិទ្ធិកាន់កាប់ នៅក្នុងបរិបទនៃការប្រកបរបរចិញ្ចឹមជីវិតរបស់ក្រុមងាយរងគ្រោះ និងក្រុមជួបប្រទះការលំបាក។ ព័ត៌មានលំអិតបន្ថែម និងឯកសារស្រាវជ្រាវឯកទេសនានា ដែលអ្នកអានត្រូវមើលរួមជាមួយនឹងឯកសារនេះ ក៏មានបង្ហាញជូនផងដែរ។

គួរកត់សម្គាល់ថា ពាក្យថា ធនធាននេសាទ នៅក្នុងឯកសារនេះ រួមមាន សត្វ ឬរុក្ខជាតិវារីជាតិដទៃទៀត ដែលត្រូវបានគេនេសាទ ឬប្រមូលផល។ ប៉ុន្តែ ខណៈពេលដែលមានការទទួលស្គាល់ថា ជារឿយៗ វារីវប្បកម្ម និង នេសាទ មានទំនាក់ទំនងយ៉ាងសំខាន់ជាមួយគ្នា មគ្គុទេសក៍នេះផ្តោតតែលើវិស័យនេសាទត្រីធម្មជាតិតែប៉ុណ្ណោះ។

**ប្រអប់ទី ២ ៖ នេសាទក្នុងទ្រង់ទ្រាយតូច**

ការប្រកបរបរនេសាទក្នុងទ្រង់ទ្រាយតូច បង្កើតប្រាក់ចំណូល ផ្តល់អាហារសម្រាប់ទីផ្សារនៅមូលដ្ឋាន នៅថ្នាក់ជាតិ និងអន្តរជាតិ និងជាការរួមចំណែកយ៉ាងសំខាន់ចំពោះអាហារូបត្ថម្ភ។ របរទាំងនេះផ្តល់ការងារដល់ប្រជានេសាទ ដែលចាប់ត្រីធម្មជាតិ និងកម្មករនេសាទជាង ៩០ ភាគរយ នៅក្នុងពិភពលោក ដែលមានប្រមាណពាក់កណ្តាលជាស្ត្រី។ បន្ថែមពីលើប្រជានេសាទ និងកម្មករនេសាទធ្វើការពេញម៉ោង និងក្រៅម៉ោង ការនេសាទតាមរដូវ និងម្តងម្កាល និងសកម្មភាពពាក់ព័ន្ធជារឿយៗ ផ្តល់នូវចំណូលបន្ថែមលើសកម្មភាពប្រកបរបរចិញ្ចឹមជីវិតដទៃទៀត នៅពេលជួបប្រទះការលំបាក ឬជាសកម្មភាពបន្ថែមជាប្រចាំ។ ការនេសាទទ្រង់ទ្រាយតូច ត្រូវបានគេប៉ាន់ប្រមាណថារួមចំណែកផ្តល់ផលចាប់ត្រីសកលជិតពាក់កណ្តាល ហើយនៅពេលពិចារណាលើផលចាប់ សម្រាប់ការបរិភោគដោយផ្ទាល់របស់មនុស្ស ការរួមចំណែករបស់វិស័យនេះកើនឡើង រហូតដល់ពីរភាគបី។ នេសាទទឹកសាប មានសារៈសំខាន់ជាពិសេស នៅក្នុងន័យនេះ ដោយសារផលិតកម្មអាហារពីត្រី ដែលប្រមូលបានពីការនេសាទក្នុងទ្រង់ទ្រាយតូច គឺជាសកម្មភាព ដែលគ្របដណ្តប់លើអនុវិស័យនេះ។

*ប្រភព ៖* FAO (2012b); World Bank, FAO and World Fish Center (2012)

## ផ្នែកទី ១ ៖ លក្ខណៈរបស់អភិបាលកិច្ចលើសិទ្ធិកាន់កាប់ធនធានប្រកបដោយការទទួលខុសត្រូវ នៅក្នុងវិស័យនេសាទ

*ផ្នែកទី ១ របស់ឯកសារនេះ មានបំណងបង្កើនការយល់ដឹងពីការអនុវត្តសិទ្ធិកាន់កាប់ប្រកបដោយការទទួលខុសត្រូវចំពោះវិស័យនេសាទ ដោយផ្តោតការយកចិត្តទុកដាក់លើសហគមន៍នេសាទ។ ផ្នែកនេះមានគោលបំណងផ្តល់នូវព័ត៌មានដល់អ្នកដែលមិនដឹងពីវិស័យនេសាទ និងពីរបៀបពិចារណាលើសិទ្ធិកាន់កាប់ នៅក្នុងបរិបទនេះ។ សំណួរពាក់ព័ន្ធជាមួយនឹងថាតើមានសិទ្ធិកាន់កាប់អ្វីខ្លះ និងហេតុអ្វីបានជាសិទ្ធិកាន់កាប់ទាំងនោះមានសារៈសំខាន់ចំពោះសហគមន៍នេសាទខ្នាតតូច ក៏ដូចជាអត្ថន័យរបស់សិទ្ធិនានានៅក្នុងវិស័យនេសាទ ត្រូវបានលើកយកមកពិភាក្សា។ សិទ្ធិកាន់កាប់ធនធាន មានទម្រង់ជាច្រើនហើយទិដ្ឋភាពទូទៅអំពីសិទ្ធិ និងប្រព័ន្ធផ្សេងៗដែលមាន ត្រូវបានលើកយកមកបង្ហាញ។ មានការបង្ហាញផងដែរអំពីគោល-នយោបាយ និងក្របខ័ណ្ឌច្បាប់អន្តរជាតិពាក់ព័ន្ធ និងមានការគូសបញ្ជាក់ពីភាពចាំបាច់ ដើម្បីយល់ពីប្រព័ន្ធកាន់កាប់ធនធានតាមទម្លាប់ និងមិនផ្លូវការ។ លើសពីនេះ ទស្សនទានស្មុគស្មាញអំពីសិទ្ធិកាន់កាប់ធនធាន ក៏ត្រូវបានលើកយកមកពិភាក្សាផងដែរ រួមជាមួយនឹងបញ្ហានានា ដែលពាក់ព័ន្ធជាមួយនឹងការប្រែប្រួលជាសកល ដូចជា ការប្រែប្រួលអាកាសធាតុ ជាដើម។*

### តើសិទ្ធិកាន់កាប់ និងអភិបាលកិច្ចលើសិទ្ធិកាន់កាប់ មានន័យយ៉ាងដូចម្តេច នៅក្នុងបរិបទនៃវិស័យនេសាទ?

**ពាក់ព័ន្ធជាមួយនឹងនិយមន័យសិទ្ធិកាន់កាប់ VGGT** ពន្យល់ថា ៖

*ប្រព័ន្ធសិទ្ធិកាន់កាប់ ធ្វើការកំណត់ថាតើអ្នកអាចប្រើប្រាស់ធនធានអ្វីបាន សម្រាប់រយៈពេលយូរប៉ុណ្ណា និងក្រោមលក្ខខណ្ឌអ្វីខ្លះ។ ប្រព័ន្ធនេះអាចមានមូលដ្ឋានលើគោលនយោបាយ និងច្បាប់ជាលាយលក្ខណ៍អក្សរ ក៏ដូចជាលើទំនៀមទម្លាប់ និងការអនុវត្ត ដែលមិនមានសរសេរជាលាយលក្ខណ៍អក្សរ។*

**(អារម្ភកថា)**

សិទ្ធិកាន់កាប់ នៅក្នុងវិស័យនេសាទ - ដូចគ្នានឹងវិស័យធនធានធម្មជាតិដទៃទៀតដែរ - សំដៅលើបែបផែននៃការកំណត់ និងការចរចា អំពីទំនាក់ទំនងរវាងមនុស្ស និងមនុស្ស នៅក្នុងបរិបទនៃការប្រើប្រាស់ធនធាននេសាទ និងធនធាន ដែលពាក់ព័ន្ធ ដូចជា សិទ្ធិកាន់កាប់កំណត់ពីមនុស្ស ដែលជាអ្នកប្រើប្រាស់ និងអ្នកដែលមានសិទ្ធិស្របច្បាប់លើធនធានអ្វីមួយ និងអ្នកដែលមិនមានសិទ្ធិស្របច្បាប់។ បន្ទាប់មក អភិបាលកិច្ចលើសិទ្ធិកាន់កាប់ពាក់ព័ន្ធជាមួយនឹងរបៀបធ្វើការបែងចែក គ្រប់គ្រង (កំណត់ឱ្យស្របច្បាប់ ផ្ទេរ ។ល) និងគ្រប់គ្រងលើសិទ្ធិកាន់កាប់ (សូមមើលប្រអប់ទី ៣)

ខណៈពេលដែលសិទ្ធិកាន់កាប់ផ្លូវការ ជាទូទៅ នៅតែជាទស្សនទានដែលមានការវិវឌ្ឍបន្តបន្ទាប់ នៅក្នុងវិស័យនេសាទ ប្រព័ន្ធសិទ្ធិកាន់កាប់តាមទំនៀមទម្លាប់ ក្នុងវិស័យនេសាទ មានប្រវត្តិយូរលង់ណាស់មកហើយ (Cordell, 1989)។ សិទ្ធិទាំងនេះ ច្រើនតែជាទម្រង់សិទ្ធិ (ដើម្បីធ្វើការនេសាទ) នៅក្នុងតំបន់ណាមួយ - ឧ. សិទ្ធិទទួលបាន ឬប្រើប្រាស់ដែនដី (សូមមើលផ្នែក តើសិទ្ធិកាន់កាប់ផ្លូវការ នៅក្នុងវិស័យនេសាទ មានច្រើនប្រភេទអ្វីខ្លះ? ខាងក្រោម) - ហើយជារឿយៗ មានស្របគ្នាជាមួយនឹងសិទ្ធិកាន់កាប់ដីធ្លីដែរ។ នៅតាមទីកន្លែងជាច្រើន ឧទាហរណ៍ នៅតាមរដ្ឋកោះតូចៗក្នុងតំបន់អូសេអានីជាដើម ធនធានធម្មជាតិ និងបរិវេណ ដែលរដ្ឋទាំងនេះកាន់កាប់ កន្លងមក មិនត្រូវបានគេបែងចែកជាដី និងទឹកពីរផ្សេងគ្នានោះទេ (Aswani, 2005)។ ផ្ទុយទៅវិញ ធម្មជាតិ ដែលរាប់បញ្ចូលមនុស្ស និងសង្គមផងដែរនោះ ត្រូវបានគេមើលឃើញរួមគ្នា ដោយសហគមន៍មានលំហធនធាន សម្រាប់មុខងារច្រើនយ៉ាង ជាមូលដ្ឋានសម្រាប់ការប្រកបរបរចិញ្ចឹមជីវិតរបស់ពួកគេ (Ruddle, 1988)។ ដូច្នេះ សិទ្ធិកាន់កាប់ក្នុងវិស័យនេសាទ មិនអាចយកមកពិចារណាដាច់តែឯងនោះទេ ប៉ុន្តែចាំបាច់ត្រូវតែពិចារណាដោយផ្សារភ្ជាប់ជាមួយនឹងបរិបទដីធ្លី និងមុខរបរចិញ្ចឹមជីវិតទូលំទូលាយ (FAO, 2011a)។

**ប្រអប់ទី ៣ ៖ អ្វីទៅដែលហៅថាអភិបាលកិច្ច?**

អភិបាលកិច្ច អាចត្រូវបានគេចាត់ទុកថាជាការរៀបចំ ជាស្ថាប័ន និងជាអ្វីផ្សេងទៀត ទាំងផ្លូវការ ទាំងក្រៅផ្លូវការ ដែលកំណត់ពីរបៀបប្រើប្រាស់ធនធាន ឬបរិយាកាសអ្វីមួយ, របៀបធ្វើការវាយតម្លៃ និងវិភាគបញ្ហា និងឱកាស ឥរិយាបថដែលគេចាត់ទុកថាអាចទទួលយកបាន ឬហាមឃាត់ និងវិធាន និងការដាក់ទោសទណ្ឌ ដែលត្រូវអនុវត្ត ដើម្បីមានឥទ្ធិពលលើនិន្នាការនៃការប្រើប្រាស់ធនធាន និងបរិយាកាស។

*ប្រភព ៖* Juda (1999)

ប៉ុន្តែ អភិបាលកិច្ច ក៏អាចមានអត្ថន័យជារួមច្រើនជាងនេះផងដែរ ៖

អភិបាលកិច្ច គឺជាទំនាក់ទំនងសាធារណ: និងឯកជនទាំងមូល ដែលធ្វើឡើង ដើម្បីដោះស្រាយបញ្ហាសង្គម និង បង្កើតនូវឱកាសក្នុងសង្គម។ អភិបាលកិច្ច រួមមាន ការរៀបចំ និងការបង្កើតគោលការណ៍ណែនាំដល់ទំនាក់ទំនងទាំងនេះ និង យកចិត្តទុកដាក់ចំពោះស្ថាប័ន ដែលនាំឱ្យមានទំនាក់ទំនងទាំងនេះ។

*ប្រភព* ៖ Kooiman *et al.* (2005)

ប៉ុន្តែ ការរៀបចំសិទ្ធិកាន់កាប់ជាផ្លូវការ នៅក្នុងវិស័យនេសាទ ច្រើនតែផ្តោតលើលទ្ធភាពប្រកបរបរនេសាទ និងការប្រើប្រាស់ធនធាននេសាទ។ នៅក្នុងបរិបទនេះ ពាក្យថា "សិទ្ធិ" (ដូចជានៅក្នុងការគ្រប់គ្រងផ្អែកតាមសិទ្ធិ ដែលត្រូវបានលើកយកមកពិភាក្សាខាងក្រោម) ប្រហែលជាពាក្យ ដែលគេនិយមប្រើប្រាស់ច្រើនជាង "សិទ្ធិកាន់កាប់។[2] តែទោះជាយ៉ាងណា ពាក្យថា សិទ្ធិកាន់កាប់ គឺជាពាក្យដែលមានប្រយោជន៍ជាង ដោយសារតែវាបង្ហាញពីប្រព័ន្ធសិទ្ធិដែលមានលក្ខណៈទូលំទូលាយ ទាំងផ្លូវការ ទាំងមិនផ្លូវការ ហើយមានដាក់បញ្ចូលនូវទស្សនទានសិទ្ធិក្នុងសង្គម ដែលបុគ្គល ក្រុមមនុស្ស ឬសហគមន៍អាចមានចំពោះធនធាននេសាទ។ ពាក្យថា សិទ្ធិកាន់កាប់ គ្របដណ្តប់លើទស្សនទានសិទ្ធិក្នុងការប្រើប្រាស់ និងគ្រប់គ្រង ប៉ុន្តែ ខុសពីកម្មសិទ្ធិ និងមានលក្ខណៈទូលំទូលាយជាងការគ្រប់គ្រងធនធាននេសាទ (សូមមើលប្រអប់ទី ៤)។ ដូច្នេះ សិទ្ធិកាន់កាប់ ក៏មានដាក់បញ្ចូលនូវសិទ្ធិតាមប្រពៃណី និងទំនៀមទម្លាប់ ដែលមិនត្រូវបានគេផ្តល់ទទួលស្គាល់ស្របច្បាប់ផងដែរ។

[2] ពាក្យថា "ទ្រព្យសម្បត្តិ" ក៏ត្រូវបានប្រើប្រាស់ផងដែរ ដូចជា "ទ្រព្យសម្បត្តិរួម" និង "ទ្រព្យសម្បត្តិឯកជន" ជាដើម (សូមមើលផ្នែកតើគេអាចគ្រប់គ្រងធនធាននេសាទ ក្នុងនាមជាទ្រព្យសម្បត្តិរួម ប្រកបដោយនិរន្តរភាព ដោយរបៀបណា? និងតើសិទ្ធិកាន់កាប់ធនធាននេសាទជាផ្លូវការមានច្រើនប្រភេទអ្វីខ្លះ? ខាងក្រោម)។

## ហេតុអ្វីបានជាចាំបាច់ត្រូវមានអភិបាលកិច្ចលើសិទ្ធិកាន់កាប់ប្រកបដោយការទទួលខុសត្រូវ នៅក្នុងវិស័យនេសាទ?

**VGGT ផ្តោតសំខាន់លើសារៈសំខាន់នៃអភិបាលកិច្ចលើសិទ្ធិកាន់កាប់ និង ៖**

រដ្ឋគួរខិតខំធានាឱ្យមានអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើសិទ្ធិកាន់កាប់ ដោយហេតុថាដីធ្លី ធនធាននេសាទ និងព្រៃឈើ មានសារៈសំខាន់យ៉ាងខ្លាំងចំពោះការសម្រេចឱ្យបាននូវសិទ្ធិមនុស្ស សន្តិសុខស្បៀង ការលុបបំបាត់ភាពក្រីក្រ ការប្រកបរបរចិញ្ចឹមជីវិតប្រកបដោយចីរភាព ស្ថិរភាពសង្គម សន្តិសុខលំនៅដ្ឋាន ការអភិវឌ្ឍជនបទ និងកំណើនសង្គម និងសេដ្ឋកិច្ច។

**(៤.១ នៅក្នុង *សិទ្ធិ និងការទទួលខុសត្រូវ ពាក់ព័ន្ធនឹងសិទ្ធិកាន់កាប់*)**

អភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើសិទ្ធិកាន់កាប់ ធានាឱ្យមានការទទួលស្គាល់ កំណត់ បែងចែក និងគ្រប់គ្រងលើសិទ្ធិកាន់កាប់ ប្រកបដោយយុត្តិធម៌ និងសមធម៌ ដោយមានការគោរពសិទ្ធិមនុស្ស និងឆ្លុះបញ្ចាំងពីគោលដៅសង្គម និងភាពចាំបាច់ ដើម្បីផ្តល់ការគាំទ្រដល់សក្តានុពលនៃវិស័យនេសាទខ្នាតតូច ក្នុងការចូលរួមចំណែកចំពោះសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ការកាត់បន្ថយភាពក្រីក្រ ការអភិវឌ្ឍប្រកបដោយសមធម៌ និងការប្រើប្រាស់ធនធានប្រកបដោយនិរន្តរភាព។ ការទទួលស្គាល់សិទ្ធិដែលមានស្រាប់ ឬការបែងចែកសិទ្ធិ និងការទទួលខុសត្រូវលើធនធាននេសាទ និងធនធានធម្មជាតិដទៃទៀត ទៅដល់អ្នកដែលមានសិទ្ធិស្របច្បាប់ អាចសម្រេចនូវមុខងារសំខាន់ៗចំនួនពីរ។ ទីមួយ អ្នកប្រើប្រាស់ត្រូវការអាចប្រើប្រាស់ធនធាន ដែលពួកគេពឹងអាស្រ័យលើ សម្រាប់ការប្រកបមុខរបរចិញ្ចឹមជីវិតរបស់ពួកគេ ឱ្យបានជាប់លាប់ - ដោយធៀបជាមួយនឹងអ្នកប្រើប្រាស់ជាសក្តានុពលដទៃទៀត[3]។ ទីពីរ ការទទួលស្គាល់ និងការបែងចែកសិទ្ធិទទួលបានធនធាននេសាទ គឺជាឧបករណ៍មួយ សម្រាប់ធ្វើការគ្រប់គ្រងធនធាននេសាទ ដើម្បីលើកកម្ពស់ការប្រើប្រាស់ធនធានដែលធានាបាន នូវនិរន្តរភាពសង្គម សេដ្ឋកិច្ច និងបរិស្ថាន។

[3] សិទ្ធិកាន់កាប់ជាប់លាប់ សម្រាប់មនុស្សមួយចំនួន ចៀសមិនរួចពីការផាត់ចេញមនុស្សដទៃទៀត។ សារៈសំខាន់នៃការមានគោលបំណងច្បាស់លាស់ គួបផ្សំជាមួយ នឹងសិទ្ធិមនុស្ស និងគោលដៅសង្គមជារួម និងភាពស៊ីសង្វាក់ផ្នែកនយោបាយ ត្រូវបានលើកយកមកពិភាក្សាបន្ថែមទៀត នៅក្នុងផ្នែក កំណត់ពីគោលបំណង នៅក្នុងផ្នែកទី ២។

## សន្តិសុខជីវភាពរស់នៅ និងសុខុមាលភាពសង្គម

ការមានលទ្ធភាពប្រើប្រាស់ធនធាននានា គឺជាបុរេលក្ខខណ្ឌមួយ សម្រាប់ការមានជីវភាពរស់នៅបានជាប់លាប់ និងមានការអភិវឌ្ឍ។ ការមិនមានលទ្ធភាពពឹងអាស្រ័យលើធនធានជាមូលដ្ឋានមួយចំនួន នាំឱ្យមានភាពងាយរងគ្រោះ។ លើសពីនេះ មនុស្សច្រើនតែវិនិយោគលើអនាគតរបស់ពួកគេ នៅពេលដែលពួកគេមានទំនុកចិត្តថា ពួកគេនឹងបន្តអាចប្រើប្រាស់ធនធាន ដែលពួកគេត្រូវការ សម្រាប់ជីវភាពរស់នៅរបស់ពួកគេ។ ប្រជានេសាទ និងកម្មករនេសាទ ត្រូវការដំបូងគេបំផុតនូវលទ្ធភាពទទួលបានធនធាននេសាទ ដើម្បីបន្តអនុវត្តយុទ្ធសាស្ត្រចិញ្ចឹមជីវិតរបស់ពួកគេ ប៉ុន្តែដូចលើកឡើងខាងលើដែរ សហគមន៍នេសាទក៏ត្រូវការអាចប្រើប្រាស់ធនធានដទៃទៀត ដូចជា ដីធ្លី ជាដើម ដើម្បីអាចទទួលបានទឹកប្រើប្រាស់ ជាក់ស្តែង កន្លែងទុកដាក់ទូក និងឧបករណ៍របស់ពួកគេ លំនៅដ្ឋាន ។ល។ អ្នកកែច្នៃ និងឈ្មួញត្រី ក៏ត្រូវការដីធ្លីផងដែរ ដើម្បីអាចចុះទៅដល់ទឹក សម្រាប់រៀបចំអាជីវកម្មរបស់ពួកគេ។ លើសពីនេះ នៅតាមសហគមន៍នេសាទខ្នាតតូចជាច្រើន ប្រជាពលរដ្ឋ ប្រកបរបរចិញ្ចឹមជីវិតចម្រុះមុខ ហើយគ្រួសារនានាអាចបំពេញសកម្មភាពសេដ្ឋកិច្ចផ្សេងទៀត (ដូចជា ការដាំដុះ ឬទេសចរណ៍) ស្របជាមួយនឹងសកម្មភាពនេសាទ ដែលតម្រូវឱ្យពួកគេមានលទ្ធភាពទទួលបានធនធានពាក់ព័ន្ធ សម្រាប់សកម្មភាពទាំងនេះ។ ស្របទៅតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ បុគ្គលទាំងអស់មានសិទ្ធិទទួលបាន "ជីវភាពរស់នៅសមស្រប ដូចជា អាហារហូបចុកបានគ្រប់គ្រាន់"[4] និងមានសិទ្ធិទទួលបាន "លក្ខខណ្ឌការងារប្រកបដោយយុត្តិធម៌ និងផ្តល់នូវលក្ខណៈ អំណោយផល ដែលធានាបាននូវ ... ជីវភាពរស់នៅសមរម្យសម្រាប់ពួកគេ និងសម្រាប់គ្រួសាររបស់ពួកគេ"[5] ដូច្នេះសិទ្ធិទទួលបានធនធាន និងសិទ្ធិមនុស្ស មានទំនាក់ទំនងរឹងមាំជាមួយគ្នា (សូមមើលខាងក្រោម)។ លើសពីនេះ សហគមន៍នេសាទខ្នាតតូច សហគមន៍ជនជាតិដើមភាគតិច និងសហគមន៍ផ្សេងទៀត ជារឿយៗ ចាត់ទុកសកម្មភាពនេសាទ (និងសកម្មភាពពាក់ព័ន្ធនានា) លើសពីប្រភពចំណូលទៅទៀត។ វាគឺជាបែបផែននៃជីវិត ហើយការធានានូវសិទ្ធិប្រកបរបរចិញ្ចឹមជីវិតតាមបែបប្រពៃណីរបស់ពួកគេ គឺជាបញ្ហាយុត្តិធម៌សង្គម (Jentoft, 2011)។

ពាក់ព័ន្ធជាមួយនឹងការមានលទ្ធភាពទទួលបានដីធ្លីប្រើប្រាស់បានជាប់លាប់ នៅតាមប្រទេសជាច្រើន ដីនៅតាមតំបន់ឆ្នេរ មិនអាចយកមកធ្វើជាកម្មសិទ្ធិឯកជននោះឡើយ។ នៅតាមដែនកោះនៅសមុទ្រការីបៀន និងសមុទ្រឥណ្ឌាមួយចំនួន ដី

[4] មាត្រា ១១.១ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌។

[5] មាត្រា ៧ (ii) កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌។

ជាប់ឆ្នេរ គឺជាកម្មសិទ្ធិផ្តាច់មុខរបស់រដ្ឋាភិបាល ហើយអាចជួលបាន តែមិនអាចលក់ទៅឱ្យបុគ្គលឯកជនបានឡើយ។ ប៉ុន្តែ នៅតាមដែនកោះជាច្រើន នៅសមុទ្រប៉ាស៊ីហ្វិច និងសមុទ្រឥណ្ឌា ដូចជា ប្រទេសម៉ាល់ឌីវ ជាដើម មាននិន្នាការនៃការកាន់កាន់ កម្មសិទ្ធិតាមបែបប្រពៃណី ដោយសហគមន៍ ភូមិ និងក្រុមញាតិផៅ គឺជាម្ចាស់លើដីតាមតំបន់ឆ្នេរ។ ប៉ុន្តែ ឆ្នេរខ្សាច់ នៅតាម រដ្ឋកោះតូចៗ នៅការីបៀន សមុទ្រឥណ្ឌា និងតំបន់ប៉ាស៊ីហ្វិច ច្រើនតែត្រូវបានចាត់ទុកថាជាទ្រព្យសម្បត្តិសាធារណៈ សម្រាប់ ប្រើប្រាស់ និងកម្សាន្តដោយមនុស្សគ្រប់គ្នា។ នៅក្នុងករណីដែលការអភិវឌ្ឍតំបន់ឆ្នេរ ដូចជា វិស័យទេសចរណ៍ ជាដើម មាន ការរំខានដល់ទស្សនទាននេះ វិវាទអាចកើតមានឡើង (Cambers, Muehlig-Hofmann and Troost, 2003)។ នៅក្នុង បរិបទនេះ សហគមន៍នេសាទ ស្ថិតនៅក្នុងស្ថានភាពពិសេសមួយ ពាក់ព័ន្ធជាមួយនឹងសិទ្ធិកាន់កាប់ និងលទ្ធភាពប្រើប្រាស់ តំបន់ឆ្នេរ។ ប្រសិនបើវិស័យ និងសកម្មភាពសេដ្ឋកិច្ចផ្សេងទៀត ដែលទទួលបានការគាំទ្រខ្លាំងផ្នែកនយោបាយ ធ្វើការទាម ទារតំបន់នេះ នោះសហគមន៍ទាំងនេះអាចទទួលរងការគំរាមកំហែងជាការបណ្តេញចេញ ប្រសិនបើពួកគេមិនមានសិទ្ធិកាន់ កាប់ដីធ្លីជាផ្លូវការ ដែលពួកគេកាន់កាប់ និងតំបន់នេសាទរបស់ពួកគេនោះទេ។ ដូច្នេះ សហគមន៍នេសាទត្រូវការសិទ្ធិរួមគ្នា លើដីធ្លីផង និងធនធាននេសាទផង។

## ការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាពសេដ្ឋកិច្ច និងអាចធានាបាននូវនិរន្តរភាពនៃប្រព័ន្ធជីវសាស្ត្រ

ការប្រើប្រាស់ហួសកម្រនិងការកេងកេងចំណេញហួសហេតុ គឺជាតថភាពគួរឱ្យសោកសង្រេងនៃវិស័យនេសាទ ជាច្រើន នៅក្នុងពិភពលោក ដែលការគ្រប់គ្រងនេសាទតាមបែបធម្មតា មិនបានទទួលជោគជ័យ ឬធ្វើឡើងមិនបានគ្រប់គ្រាន់ (សូមមើលផ្នែកខាងក្រោម តើអ្នកណាដែលមានសិទ្ធិទទួលបានធនធាននេសាទ និងថាតើមានការទទួលខុសត្រូវពាក់ព័ន្ធ អ្វីខ្លះ?)។ នេះនាំឱ្យមានការចុះថមថយនូវអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ច ដែលគេហៅថាថ្លៃជួល ដែលអាចបង្កើតឡើងដោយ វិស័យនេសាទ។ ថ្លៃជួលនោះ ឬជាការបាត់បង់ថ្លៃជួល ត្រូវបានគេធ្វើការប៉ាន់ប្រមាណ នៅកម្រិតសកល ដោយរបាយការណ៍ រួមគ្នា រវាងធនាគារពិភពលោក និងអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិដែលមានចំណងជើងថា *The Sunken Billions* (World Bank, 2009)។ ការសិក្សានេះលើកឡើងថា ដោយសារតែអប្រសិទ្ធភាពរបស់វិស័យនេសាទ ធនធាន នេសាទរបស់ពិភពលោកលោក កំពុងធ្វើឱ្យសេដ្ឋកិច្ចពិភពលោកមានការខាតបង់ ៥០ ពាន់លានដុល្លារ ក្នុងមួយឆ្នាំលើថ្លៃជួល ធនធានធនធាន ដែលកន្លងផុតទៅ។ មូលហេតុដែលនាំឱ្យវិស័យនេសាទមិនអាចសម្រេចនូវលទ្ធផលសេដ្ឋកិច្ចល្អប្រសើរ បែបនេះគឺដោយសារតែមានទូក ឧបករណ៍នេសាទ និងអ្នកនេសាទ (សមត្ថភាពនេសាទ) ច្រើនពេក បើធៀបជាមួយនឹងចំនួន

ត្រី ដែលអាចចាប់បាន ប្រកបដោយនិរន្តភាពតាមរយៈការផ្តល់ឱ្យអ្នកប្រើប្រាស់ចូលពាក់ព័ន្ធជាមួយនឹងអនាគតរបស់ធនធាននេះធនធាននេះ គេរំពឹងថា ពួកគេនឹងមានឥរិយាបថប្រកបដោយការទទួលខុសត្រូវជាងមុន ហើយការលើកទឹកចិត្តនៅពីក្រោយ "ការប្រជែងដណ្តើមត្រីគ្នា" នឹងលែងមានទៀត។ ដើម្បីឱ្យអភិក្រមនេះដំណើរការទៅបាន សិទ្ធិ ដែលផ្តល់ទៅឱ្យអ្នកប្រើប្រាស់ម្នាក់ ឬអ្នកប្រើប្រាស់មួយក្រុម ចាំបាច់ត្រូវតែធានាឱ្យបាន - ប្រសិនបើហានិភ័យមានកម្រិតខ្ពស់ ដែលនាំឱ្យមានការដកហូតសិទ្ធិនេះ នោះការលើកទឹកចិត្តឱ្យមានការគ្រប់គ្រងរបរនេសាទប្រកបដោយនិរន្តរភាពនឹងលែងមានទៀត។ VGGT លើកឡើងថា (ផ្នែក ៤.៣) ".. ពុំមានសិទ្ធិកាន់កាប់ណា រួមទាំងកម្មសិទ្ធិឯកជនផង គឺជាសិទ្ធិដាច់ណាត់នោះឡើយ។ គ្រប់សិទ្ធិកាន់កាប់ទាំងអស់ មានកម្រិតត្រឹមសិទ្ធិរបស់អ្នកដទៃ និងត្រឹមវិធានការ ដែលអនុវត្តដោយរដ្ឋ ជាចាំបាច់ ដើម្បីគោលបំណងសាធារណៈ" ស្របពេលដែលនេះ គឺជាគោលការណ៍ជាចាំបាច់នៃសិទ្ធិកាន់កាប់ធនធានធម្មជាតិជាទូទៅ គួរមានការកត់សម្គាល់ថា សិទ្ធិកាន់កាប់ក្នុងរយៈពេលវែង គឺជាសមាសភាគដ៏សំខាន់មួយនៃការគ្រប់គ្រងធនធាននេសាទផ្អែកតាមសិទ្ធិ ប្រកបដោយជោគជ័យ។[6] តែទោះជាយ៉ាងណាក៏ដោយ គួរមានការចង្អុលបង្ហាញថា ប្រព័ន្ធគ្រប់គ្រងធនធាននេសាទផ្អែកតាមសិទ្ធិ មិនអាចដោះស្រាយបញ្ហានេសាទហួសកម្រិត និងនាំឱ្យមានការគ្រប់គ្រងបានល្អដោយស្វ័យប្រវត្តិនោះទេ។ ប្រភេទរបបសិទ្ធិសមស្រប ចាំបាច់រទូវតែមួយ ហើយលក្ខខណ្ឌដទៃទៀត ត្រូវតែយកមកអនុវត្ត ឧ. ភាពចាំបាច់ ដើម្បីមានយន្តការពង្រឹងការអនុវត្ត និងព័ត៌មាន (បែបវិទ្យាសាស្ត្រ) ជាដើម (WHAT, 2000)។

ទិដ្ឋភាពចំនួនពីរយ៉ាង - ការមានមុខរបរចិញ្ចឹមជីវិតជាប់លាប់ និងការប្រើប្រាស់ធនធានប្រកបដោយនិរន្តរភាព និងប្រសិទ្ធភាព ជាការពិត គឺមានទំនាក់ទំនងជាមួយគ្នា។ ការងារនេសាទ ដែលមានលក្ខណៈល្អប្រសើរផ្នែកសេដ្ឋកិច្ច គឺជាបុរេលក្ខខណ្ឌ សម្រាប់សម្រេចនូវគោលដៅ និងអត្ថប្រយោជន៍ផ្សេងៗ ដូចជា ការប្រកបរបរចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព សន្តិសុខស្បៀង និងការធ្វើឱ្យមានស្តុកត្រីប្រកបដោយផលិតភនិងតំបន់នេសាទ (World Bank, 2009)។ វិស័យនេសាទខ្នាតតូច អាចបំពេញតួនាទីយ៉ាងសំខាន់ នៅក្នុងការអភិវឌ្ឍ និងកំណើនសេដ្ឋកិច្ច ប្រសិនបើទទួលបានការលើកទឹកចិត្តសមស្រប និងបរិយាកាសដែលអំណោយផល។ ការអនុវត្តសិទ្ធិប្រើប្រាស់ និងគ្រប់គ្រង នៅតាមសហគមន៍នេសាទខ្នាតតូចទំនងជាផ្តល់នូវប្រយោជន៍ផ្នែកសេដ្ឋកិច្ច សង្គម និងបរិស្ថាន (UNEP *et al.,* 2012)។

[6] សូមមើលទំព័រទី ១៦ និងការពិភាក្សានៅក្នុងជំពូកការបែងចែកសិទ្ធិ ក្នុងផ្នែកទី ២។

## តើអ្នកណាដែលមានសិទ្ធិទទួលបានធនធាននេសាទ និងថាតើមានភារៈទទួលខុសត្រូវពាក់ព័ន្ធអ្វីខ្លះ?

> **VGGT លើកឡើងថា ៖**
>
> *រដ្ឋមានអំណាចក្នុងការបែងចែកសិទ្ធិកាន់កាប់ ក្នុងទម្រង់ផ្សេងៗពីគ្នា ចាប់ពីការប្រើប្រាស់មានកំណត់ រហូតដល់កម្មសិទ្ធិពេញលេញ។ គោលនយោបាយទាំងឡាយគួរទទួលស្គាល់ពីសិទ្ធិកាន់កាប់ និងអ្នកមានសិទ្ធិផ្សេងៗគ្នា។*
>
> **(៨.៨ នៅក្នុង *ដីសាធារណៈ ធនធាននេសាទ និងធនធានព្រៃឈើ*)**
>
> *រដ្ឋគួរផ្តល់នូវការទទួលស្គាល់ និងការការពារសមស្របដល់សិទ្ធិកាន់កាប់ស្របច្បាប់របស់ជនជាតិដើមភាគតិច និងសហគមន៍ដទៃទៀត ដែលប្រើប្រាស់ប្រព័ន្ធកាន់កាប់បែបទំនៀមទម្លាប់ ស្របទៅតាមកាតព្វកិច្ចដែលមានស្រាប់ ក្រោមច្បាប់ជាតិ និងអន្តរជាតិ និងទៅតាមការប្តេជ្ញាចិត្ត ដែលមានលក្ខណៈស្ម័គ្រចិត្ត នៅក្រោមលិខិតុបករណ៍ថ្នាក់តំបន់ និងអន្តរជាតិជាធរមាន។*
>
> **(៩.៤ នៅក្នុង *ជនជាតិដើមភាគតិច និងសហគមន៍ដទៃទៀត ដែលប្រើប្រាស់ប្រព័ន្ធកាន់កាប់បែបទំនៀមទម្លាប់*)**

ដោយសារតែលក្ខណៈរបស់ធនធាននេសាទ - ការរស់នៅក្នុងទឹក ដែលគេមានការលំបាក ដើម្បីមើលឃើញ និងកម្រអាចរក្សាទុកបាននៅក្នុងព្រំដែន ដែលបានកំណត់។ ដូច្នេះ “កម្មសិទ្ធិ” លើធនធាននេសាទ ច្រើនតែមានលក្ខណៈផ្សេងគ្នាពីកម្មសិទ្ធិដីធ្លី ជាពិសេស នៅពេលធ្វើការកំណត់ថាជាកម្មសិទ្ធិឯកជន ឬកម្មសិទ្ធិបុគ្គល។ តាមពិតទៅ ខណៈពេលដែលត្រីក្នុងបឹង ក្នុងបរិវេណដីរបស់អ្នកណាម្នាក់ អាចចាត់ទុកថាជាកម្មសិទ្ធិឯកជន នៅក្នុងវិស័យសមុទ្ទ “កម្មសិទ្ធិបុគ្គលនៅក្នុងវិស័យនេសាទ កម្រនឹងមានណាស់” (p.4, Scott, 2000)។ នៅតាមប្រទេសនៅអឺរ៉ុបភាគច្រើន កម្មសិទ្ធិលើត្រី មុនពេលចាប់ គឺមិនអាចគេដឹងបានឡើយ ដោយកន្លងមក ត្រីធម្មជាតិ ត្រូវបានគេចាត់ទុកថាជាសម្បត្តិដែលគ្មានម្ចាស់ (MRAG *et al.*, 2009)។ ប៉ុន្តែ នៅតាមទីកន្លែងជាច្រើន នៅក្នុងពិភពលោក ធនធាននេសាទត្រូវបានគេចាត់ទុកថាជាកម្មសិទ្ធិសមូហភាពរបស់សហគមន៍ ដែលប្រើប្រាស់ធនធានទាំងនេះ ហើយទស្សនទានអំពីទ្រព្យសម្បត្តិរួម មានសារៈសំខាន់ចំពោះសហគមន៍នេសាទខ្នាតតូចរបស់ជនជាតិដើមភាគតិចជាច្រើន (សូមមើលបន្ថែមខាងក្រោម និងការពិភាក្សា នៅក្នុងផ្នែកខាងក្រោម តើគេអាចគ្រប់គ្រងធនធាននេសាទក្នុងនាមជាសម្បត្តិរួម ប្រកបដោយនិរន្តរភាព ដោយរបៀបណា?)។

នៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខតាមសមុទ្ទ របស់បណ្តាប្រទេសនានា បណ្តារដ្ឋទាំងឡាយមានយុត្តាធិការលើធនធានរស់ ដូច្នេះរដ្ឋាភិបាលមានការទទួលខុសត្រូវលើការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋទាំងនេះ។ គេអាចប្រើប្រាស់វិធានការផ្សេងៗ ដើម្បីគ្រប់គ្រងលើការងារនេសាទ (ដូចជា ការផ្តល់អាជ្ញាប័ណ្ណ កូតាផលចាប់ បទបញ្ជាលើឧបករណ៍នេសាទ) ហើយរដ្ឋាភិបាលក៏អាចធ្វើប្រតិភូកម្មសិទ្ធិ និងការទទួលខុសត្រូវទៅឱ្យបុគ្គល ឬសហគមន៍ផងដែរ។ ធនធាននេសាទ មានចរិតជាធនធានរួម ពោលគឺ "ធនធាន ដែល (i) ការផាត់ចេញអ្នកទទួលផល តាមរយៈមធ្យោបាយរូបវ័ន្ត និងមធ្យោបាយស្ថាប័ន នាំឱ្យមានការខាតបង់ជាពិសេស ហើយ (ii) ការកេងប្រវ័ញ្ចរបស់អ្នកប្រើប្រាស់ម្នាក់ នាំឱ្យមានការថយចុះធនធាន សម្រាប់អ្នកដទៃទៀត" (p. 278, Ostrom *et al.,* 1999)។ ភាពចាំបាច់នៃការគ្រប់គ្រងធនធាននេសាទ មានមូលដ្ឋានផ្អែកលើទស្សនទាននៃស្ថុកត្រី ដែលជាធនធានរួម ហើយដែល "អ្នកនេសាទម្នាក់ៗមិនអាចគ្រប់គ្រងសកម្មភាពរបស់អ្នកនេសាទដទៃទៀត នៅក្នុងការទាញប្រយោជន៍ពីធនធានរួមនេះឡើយ។ ការខិតខំរបស់បុគ្គលម្នាក់ៗ នៅក្នុងការប្រើប្រាស់ធនធាននេះ តែសមល្មម នឹងនាំឱ្យប្រយោជន៍នេះអាចហូរទៅកាន់អ្នកប្រើប្រាស់ដទៃទៀត ហើយជាលទ្ធផល មានមូលហេតុគ្រប់យ៉ាង ដែលនាំឱ្យមានការប្រើប្រាស់លើសកម្រិត ជាជាងអភិរក្សធនធាននេះ" (FAO, 2005-2013a)។ ការងារនេសាទ ដែលមិនមានច្បាប់ទម្លាប់ត្រឹមត្រូវ ពាក់ព័ន្ធនឹងលទ្ធភាពប្រើប្រាស់ តែងត្រូវបានគេហៅថានេសាទ "ដោយបើកឱ្យប្រើចំហ" ពោលគឺផ្តល់លទ្ធភាពឱ្យអ្នកក៏ដោយ ដែលចង់នេសាទ ដូច្នេះទំនងជានាំឱ្យមានអប្រសិទ្ធភាពសេដ្ឋកិច្ច ដោយសារការប្រើប្រាស់លើស និងការទាញប្រយោជន៍ពីធនធាននេះលើសកម្រិត (សូមមើលប្រអប់ទី ៤)។

**ប្រអប់ទី ៤ ៖ អ្វីទៅជាការគ្រប់គ្រងធនធាននេសាទ?**

ការគ្រប់គ្រងធនធាននេសាទ មានគោលបំណងសម្រេចឱ្យបាននូវការប្រើប្រាស់ធនធាននេសាទប្រកបដោយនិរន្តរ-ភាព តាមរយៈការទាញប្រយោជន៍ឱ្យអស់ពីលទ្ធភាពសម្រាប់សង្គម ហើយក្នុងពេលជាមួយគ្នាផ្តល់ការពារដល់ជីវចម្រុះ។ ពាក្យថា "ការគ្រប់គ្រងនេសាទទំនើប" ច្រើនតែគេប្រើប្រាស់ សម្រាប់ការគ្រប់គ្រងធនធាននេសាទ ដែលធ្វើឡើងដោយរដ្ឋតាមរយៈវិធានការបញ្ជា និងត្រួតពិនិត្យពីថ្នាក់កណ្តាលទៅ។ នេះគឺជាប្រព័ន្ធ ដែលជារឿយៗ ជំនួសឱ្យប្រព័ន្ធនៅថ្នាក់មូលដ្ឋានបែបទំនៀមទម្លាប់ និងប្រពៃណី ខណៈពេលដែលរដ្ឋ ដែលមានរដ្ឋបាលបែបមជ្ឈការ ត្រូវបានបង្កើតឡើង ហើយតំបន់សេដ្ឋកិច្ចផ្តាច់មុខ ត្រូវបានពង្រីកបន្ថែម នៅក្នុងទសវត្សរ៍ ១៩៧០។ ដោយសារតែប្រព័ន្ធទាំងនេះមិនមែនចេះតែមានប្រសិទ្ធភាពគ្រប់ពេលទាំងអស់ គេបានចាប់ផ្តើមធ្វើការតស៊ូមតិ ដើម្បីឱ្យមានការគ្រប់គ្រងតាមបែបចូលរួម ដែលមានការធ្វើ

វិមជ្ឈការ និងប្រគល់មុខងាររបស់រដ្ឋក្នុងកម្រិតផ្សេងៗគ្នា និងការដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រង ដោយយកសិទ្ធិធ្វើជាមូលដ្ឋាន។

វិសាលភាពនៃការគ្រប់គ្រងធនធាននេសាទ ក៏ត្រូវបានពង្រីកបន្ថែមផងដែរ នៅក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះ ដើម្បីធ្វើការពិចារណាឱ្យបានកាន់តែទូលំទូលាយ និងច្បាស់លាស់បន្ថែមទៀតលើប្រព័ន្ធអេកូឡូហ្ស៊ី។ អភិក្រមនេសាទ ដោយផ្អែកមូលដ្ឋានលើប្រព័ន្ធអេកូឡូហ្ស៊ី "ខិតខំធ្វើឱ្យមានតុល្យភាពរវាងគោលបំណងសង្គមផ្សេងៗគ្នា ដោយធ្វើការពិចារណាលើចំណេះដឹង និងភាពមិនប្រាកដប្រជាអំពីសមាសភាគមានជីវិត សមាសភាគគ្មានជីវិត និងសមាសភាគមនុស្ស របស់ប្រព័ន្ធអេកូឡូហ្ស៊ី និងអន្តរកម្មរបស់ពួកគេ និងដោយធ្វើការពិចារណាលើអភិក្រមនេសាទ ដែលមានលក្ខណៈសមាហរណកម្ម នៅក្នុងព្រំដែនប្រកបដោយអត្ថន័យផ្អែកអេកូឡូហ្ស៊ី" (p.14, FAO, 2003)១ គោលការណ៍របស់អភិក្រមនេះ មិនមែនជាអ្វី ដែលថ្មីនោះទេ ប៉ុន្តែមានមូលដ្ឋានរឹងមាំលើលិខិតុបករណ៍គោលនយោបាយ និងកិច្ចព្រមព្រៀងអន្តរជាតិជាច្រើនអំពីការ អភិវឌ្ឍប្រកបដោយនិរន្តរភាព។ រដ្ឋាភិបាល និងអង្គការស្ថាប័នជាច្រើន កំពុងបោះជំហានទៅអនុវត្តអភិក្រមគ្រប់គ្រងការងារនេសាទ និងគ្រប់គ្រងធនធានធម្មជាតិ ផ្អែកទៅតាមប្រព័ន្ធអេកូឡូហ្ស៊ី។

[១]សូមមើលផងដែរ FAO. 2009. *Fisheries management. 2. The ecosystem approach to fisheries. 2.2 The human dimensions of the ecosystem approach to fisheries.* FAO Technical Guidelines for Responsible Fisheries No. 4, Suppl. 2, Add. 2. Rome. 88 pp.

*ប្រភព ៖* FAO (1997, 2003, 2005-2013a)

កន្លងមក សិទ្ធិប្រើប្រាស់ និងការទទួលខុសត្រូវលើការគ្រប់គ្រងធនធាននេសាទសមុទ្ទ និងទឹកសាប នៅក្នុងន័យជាក់ស្តែង ច្រើនតែត្រូវបានសន្មត ដោយសហគមន៍នេសាទនៅមូលដ្ឋាន។ ដូចដែលពន្យល់ខាងលើ សិទ្ធិ និងប្រព័ន្ធគ្រប់គ្រងទាំងនេះ ជារឿយៗ មាននៅតាមកន្លែង។ ប៉ុន្តែ ដោយសារតែប្រព័ន្ធគ្រប់គ្រងនេសាទ ដែលមានលក្ខណៈមជ្ឈការ ការអភិវឌ្ឍបច្ចេកវិទ្យា និងការផ្លាស់ប្តូរប្រជាសាស្ត្រ ការអនុវត្តតាមទំនៀមទម្លាប់សម្រាប់ធ្វើការបែងចែក និងចែករំលែកអត្ថប្រយោជន៍នៃធនធានសម្រាប់ការប្រកបរបរនេសាទក្នុងទ្រង់ទ្រាយតូច ជារឿយៗ លែងមានទៀត។ ពេលខ្លះ ការទាមទារធនធានបែបប្រពៃណី និងទំនៀមទម្លាប់ នៅតែមាន ប៉ុន្តែការទាមទារទាំងនេះមិនមែនត្រូវបានគេទទួលស្គាល់តាម ផ្លូវច្បាប់ជានិច្ចកាលនោះទេ ហើយការទទួលខុសត្រូវលើការគ្រប់គ្រងអាចមានភាពមិនច្បាស់លាស់ និង/ឬពុំមាន ប្រសិទ្ធភាព។

ភាពចម្រុះផ្នែកច្បាប់ (legal pluralism) គឺជាពាក្យ ដែលគេប្រើប្រាស់ ដើម្បីរៀបរាប់ពីស្ថានភាព ដែលគំនិត គោលការណ៍ និងប្រព័ន្ធច្បាប់ផ្សេងៗជាច្រើន ត្រូវបានអនុវត្តក្នុងពេលជាមួយគ្នា ហើយនេះគឺជាអ្វីដែលមាននៅក្នុងវិស័យ នេសាទ (Jentoft *et al,* 2009)។

នៅក្នុងឆ្នាំ ១៩៦៨ Hardin (1968) បានបង្ហាញពីទស្សនទានមួយឈ្មោះថា "សោកនាដកម្មរបស់ធនធានរួម (tragedy of the commons)" ដោយលើកឡើងថា ប្រសិនបើធនធានរួមមិនត្រូវបានគេធ្វើឯកជនភាវូបនីយកម្ម ហើយមានភ្ជាប់ជាមួយនូវសិទ្ធិកាន់កាប់អចលទ្រព្យខ្លះនោះទេ អ្នកប្រើប្រាស់ធនធានរួមនឹងធ្លាក់ចូលទៅក្នុងដំណើរការនៃការប្រើ ប្រាស់លើសកម្រិត ដែលនាំឱ្យមានការបំផ្លិចបំផ្លាញធនធាននេះជាមិនខាន។ ការបោះជំហានកាលពីពេលថ្មីៗនេះទៅរកការគ្រប់គ្រងការងារនេសាទ ដោយយកសិទ្ធិធ្វើជាមូលដ្ឋាន គឺផ្អែកទៅតាមទស្សនទានដែលថា ការងារនេសាទនឹងបង្កើតនូវប្រយោជន៍កាន់តែច្រើន ប្រសិនបើអ្នកប្រើប្រាស់មានសិទ្ធិកាន់តែខ្លាំងលើធនធានទាំងនេះ ស្របទៅតាមសិទ្ធិកាន់កាប់អចលទ្រព្យដូចជា ដីធ្លី ជាដើម។ ដូច្នេះ ការគ្រប់គ្រងការងារនេសាទ ដែលយកសិទ្ធិធ្វើជាមូលដ្ឋាន គឺជាទស្សនទានមួយ ដែលផ្តោតការយកចិត្តទុកដាក់លើបុព្វសិទ្ធិ និងសិទ្ធិ និងការទទួលខុសត្រូវ នៅក្នុងទម្រង់សិទ្ធិកាន់កាប់អចលទ្រព្យរួម ឬឯកជនរបស់បុគ្គលម្នាក់ (អ្នកនេសាទ) នាវានេសាទ សហគមន៍ ឬក្រុមហ៊ុន ដែលធ្វើប្រកបរបរនេសាទ។ ជារឿយៗ សិទ្ធិទាំងនេះត្រូវបានគេហៅថាសិទ្ធិប្រើប្រាស់ ហើយមាននៅក្នុងទម្រង់ផ្សេងៗជាច្រើន ដែលក្នុងនោះរួមមានប្រយោជន៍ជាច្រើន ដែលសំដៅលើបុព្វសិទ្ធិផង និងការទទួលខុសត្រូវផង (សូមមើលផ្នែកតើសិទ្ធិកាន់កាប់ជាផ្លូវការ នៅក្នុងវិស័យនេសាទ មានប្រភេទផ្សេងៗពីគ្នាអ្វីខ្លះ?)។

ជាទូទៅ មានកត្តាចំនួន ៤ ត្រូវបានគេប្រើប្រាស់ ដើម្បីរៀបរាប់ពីលក្ខណៈនៃសិទ្ធិកាន់កាប់ប្រភេទផ្សេងៗគ្នា នៅក្នុងវិស័យនេសាទ។ កត្តាទាំងនេះអនុវត្តចំពោះសិទ្ធិកាន់កាប់គ្រប់ប្រភេទទាំងអស់ ទាំងសិទ្ធិកាន់កាប់អចលទ្រព្យរួម និងឯកជន។ នៅពេលដែលកត្តាទាំងនេះមានកាន់តែធំ នោះសិទ្ធិមានតែខ្លាំង (Scott, 2000)៖

- **សន្តិសុខ** សំដៅលើលទ្ធភាពរបស់អ្នកមានសិទ្ធិ នៅក្នុងការប្រកាន់សិទ្ធិនេះ និងមិនឱ្យបុគ្គលផ្សេងទៀត ស្ថាប័ន ឬរដ្ឋាភិបាលជំទាស់ ឬដកហូតសិទ្ធិនេះបាន។

- **ភាពយូរអង្វែង** សំដៅលើរយៈពេលដែលទទួលបានសិទ្ធិនេះ និងអាចមានចាប់ពីគ្មានសោះ ឬមួយរដូវ ឬមួយឆ្នាំ ដល់មិនកំណត់។

- **ភាពអាចផ្ទេរបាន** សំដៅលើលទ្ធភាពរបស់អ្នកមានសិទ្ធិ នៅក្នុងការប្រគល់បន្ត (ផ្ទេរ ឬលក់) នូវសិទ្ធិរបស់ខ្លួន ទៅឱ្យអ្នកដទៃ។

- **ភាពផ្តាច់មុខ** សំដៅលើកម្រិតដែលអ្នកមានសិទ្ធិ ត្រូវបានគេអនុញ្ញាតឱ្យប្រើប្រាស់ និងគ្រប់គ្រងសិទ្ធិរបស់ខ្លួន - ដូចជា ចំណែកនៃបរិមាណត្រី ដោយមិនមានការរំខានពីបទដ្ឋានគតិយុត្តិសម្រាប់គ្រប់គ្រងលើការងារនេសាទ (ពាក់ព័ន្ធជាមួយនឹងវិធីសាស្ត្រប្រមូលផល រដូវ ។ល)។

នៅពេលរៀបចំ និងអនុវត្តប្រព័ន្ធសិទ្ធិកាន់កាប់ នៅក្នុងវិស័យនេសាទ មានការសម្រេចចិត្តជាច្រើន ដែលត្រូវធ្វើឡើងពាក់ព័ន្ធជាមួយនឹងកត្តាទាំងនេះ។ ចំណុចនេះត្រូវបានលើកយកមកធ្វើការពិភាក្សាបន្ថែម នៅក្នុងផ្នែកទី ២ (សូមមើលជំពូកការបែងចែកសិទ្ធិ )។ សិទ្ធិក្នុងប្រភេទផ្សេងៗគ្នា ត្រូវបានលើកយកមកពិភាក្សាខាងក្រោម អមជាមួយនឹងឧទាហរណ៍ផង (សូមមើលតារាងទី ១)។

## តើគេអាចគ្រប់គ្រងធនធាននេសាទប្រកបដោយនិរន្តរភាព ក្នុងនាមជាទ្រព្យសម្បត្តិរួម បានដែរឬទេ?

**VGGT ទទួលស្គាល់ពីសារៈសំខាន់របស់ធនធាន ដែលត្រូវបានគេប្រើប្រាស់រួមគ្នា និងលើកឡើងថា ៖**

*ដោយកត់សម្គាល់ឃើញថា មានដីធ្លី ធនធាននេសាទ និងធនធានព្រៃឈើ ជាកម្មសិទ្ធិសាធារណៈ ដែលត្រូវបានគេប្រើប្រាស់ និងគ្រប់គ្រងរួមគ្នា (នៅក្នុងបរិបទជាតិតែមួយ ដែលគេហៅថាធនធានរួម) នៅក្នុងករណីដែលអាចអនុវត្តបាន រដ្ឋគួរទទួលស្គាល់ និងការពារដីធ្លី ធនធាននេសាទ និងធនធានព្រៃឈើ ដែលជាកម្មសិទ្ធិសាធារណៈទាំងនេះ និងប្រព័ន្ធ ពាក់ព័ន្ធសម្រាប់ប្រើប្រាស់ និងគ្រប់គ្រងធនធានទាំងនេះជាសមូហភាព រាប់បញ្ចូលទាំងដំណើរការ ដែលរដ្ឋប្រើប្រាស់ ដើម្បី ធ្វើការបែងចែកធនធានទាំងនេះផងដែរ។*

**(៨.៣ នៅក្នុង *ដីធ្លី ធនធាននេសាទ និងធនធានព្រៃឈើសាធារណៈ*)**

ជាការសំខាន់ណាស់ ដែលគេត្រូវយល់ថា របបគ្រប់គ្រងការងារនេសាទ ដែលយកសិទ្ធិធ្វើជាមូលដ្ឋាន មិនចាំបាច់មានន័យថាជាការធ្វើឯកជនភាវូបនីយកម្មលើធនធាននានា តាមរយៈសិទ្ធិកាន់កាប់របស់បុគ្គលម្នាក់ៗនោះទេ ប៉ុន្តែគេត្រូវយល់ថា របបនេះក៏មានដាក់បញ្ចូលនូវជម្រើសផ្សេងៗទៀត សម្រាប់ទ្រព្យសម្បត្តិរួម និងការរៀបចំតាមសហគមន៍ផងដែរ[7]។ មានភស្តុតាងបង្ហាញថា គេអាចប្រើប្រាស់ធនធានរួមប្រកបដោយនិរន្តរភាពបាន ឧ. ដោយឱ្យសហគមន៍មូលដ្ឋានធ្វើការគ្រប់គ្រង ដោយខ្លួនឯង ជាដើម។ គួរមានការបំពេញទៅតាមលក្ខខណ្ឌមួយចំនួន ដូចជា អ្នកប្រើប្រាស់ចាំបាច់ត្រូវដឹងថា អត្ថប្រយោជន៍រួម មានកម្រិតខ្ពស់ជាងការខាតបង់នានា ហើយពួកគេគួរតែមានស្វ័យភាពខ្លះ ដើម្បីដាក់ចេញនូវវិធានសម្រាប់ប្រើប្រាស់ និងប្រមូលផលរបស់ខ្លួន។ លទ្ធភាពរបស់អ្នកប្រើប្រាស់ នៅក្នុងការចងក្រងខ្លួនឯង គឺអាស្រ័យលើស្ថានភាពសង្គម ហើយអ្នកប្រើប្រាស់ចាំបាច់ត្រូវតែ "ដឹងដូចៗគ្នាអំពីរបៀបដែលប្រព័ន្ធធនធាននេះដំណើរការ និងរបៀបដែលសកម្មភាពរបស់ពួកគេ មានផលប៉ះពាល់មកលើគ្នាទៅវិញទៅមក និងមកលើធនធាននេះ" (p. 281, Ostrom *et al.*, 1999)។ តាមពិតទៅ ធនធាន នៅតាមតំបន់ឆ្នេរភាគច្រើន ទំនងជាមានប្រព័ន្ធគ្រប់គ្រង (បែបសម្ហូហភាព) ក្នុងទម្រង់មួយចំនួនភ្ជាប់ជាមួយ អាចជាការរៀបចំបែបទំនៀមទម្លាប់ ដែលសហគមន៍នេសាទក្នុងមូលដ្ឋាននៅតែយកមកអនុវត្តក្នុងកម្រិតមួយ ឬប្រព័ន្ធ ដែលត្រូវបានជំនួសដោយការគ្រប់គ្រងនៅថ្នាក់កណ្តាល។

ខណៈពេលដែលនេសាទ "បើកឱ្យប្រើប្រាស់ដោយសេរី" នាំឱ្យមានហានិភ័យនាំឱ្យមានការកេងចំណេញលើធនធាន និងអប្រសិទ្ធភាពសេដ្ឋកិច្ច តួនាទីនៃការមានលទ្ធភាពប្រកបរបរនេសាទ សម្រាប់បង្ការភាពក្រីក្រ ចាំបាច់ត្រូវតែយកមកធ្វើការពិចារណា នៅពេលដែលគេអនុវត្ត ឬកែលំអរបបសិទ្ធិកាន់កាប់ធនធាននេសាទនោះ (Jentoft and Eide, 2011)។ "ការមានលទ្ធភាពចូលទៅកន្លែងនេសាទ ដោយងាយស្រួល និងដោយសេរីសមល្មម ផ្តល់លទ្ធភាពឱ្យប្រជាពលរដ្ឋក្រីក្រ អាចពឹងអាស្រ័យកាន់តែច្រើនលើធនធាននេសាទតាមកន្លែងតូចៗ ដើម្បីទទួលបាននូវទំនិញ និងសេវា ដែលពួកគេត្រូវការ ដើម្បីទ្រទ្រង់ជីវភាពរស់នៅរបស់ពួកគេឱ្យមាននិរន្តរភាព ឬដើម្បីទទួលបានការងារដោយមានប្រាក់ឈ្នួលធ្វើ។ នេសាទទឹកសាបមានសារៈសំខាន់ជាពិសេស នៅក្នុងបរិបទនេះ។ ទិដ្ឋភាពសំណាញ់សុវត្ថិភាពនៃការងារនេសាទ កាន់តែមានសារៈសំខាន់ និងភាពពាក់ព័ន្ធចំពោះគ្រួសារក្រីក្រ និងបាត់បង់ឱកាស ជាពិសេស អ្នកដែលមានលទ្ធភាពតិចតួចក្នុងការទទួលបានដីធ្លី និងធនធានដទៃទៀត" (p. 409, Kurien and Willmann, 2009) ។ វាផ្តល់នូវឱកាសសម្រាប់បំពេញបន្ថែមលើសកម្មភាព

---

[7] ពេលខ្លះ ការគ្រប់គ្រងការងារនេសាទ ដោយយកសិទ្ធិធ្វើជាមូលដ្ឋាន ត្រូវបានគេបកស្រាយថាជាការធ្វើឯកជនភាវូបនីយកម្ម តាមរយៈការបែងចែកសិទ្ធិបុគ្គល។ នៅទីនេះ អភិក្រមនេះមានដាក់បញ្ចូលផងដែរនូវសិទ្ធិចំពោះទ្រព្យសម្បត្តិរួមរបស់អ្នកប្រើប្រាស់មួយក្រុម ឬសហគមន៍ណាមួយ។

ដទៃទៀត នៅក្នុងពេលដែលមានការរំខាននានា (អត់មានការងារធ្វើ គ្រោះមហន្តរាយធម្មជាតិ ។ល)។ ការប្រកបរបរនេសាទខ្នាតតូច ក៏មានសារៈសំខាន់ផងដែរ សម្រាប់ការកាត់បន្ថយភាពក្រីក្រ ដោយសារតែលទ្ធភាពរបស់របរទាំងនេះក្នុងការស្រូបយកកម្លាំងពលកម្មដែលលើស (Béné, 2011)។ ប្រសិនបើ និងនៅពេលគេពិចារណាបម្លែងធនធាននេសាទរួម ទៅជាសិទ្ធិកាន់កាប់ក្នុងទម្រង់ដទៃទៀត គេចាំបាច់ត្រូវពិចារណាលើប្រភេទមុខងារទាំងនេះ។

នៅក្នុងសេចក្តីថ្លែងទីក្រុងបាងកក [8] *ដែលរៀបចំដោយអង្គការសង្គមស៊ីវិល ដែលធ្វើការងារពាក់ព័ន្ធនឹងនេសាទខ្នាតតូច សម្រាប់សន្និសីទសកលស្តីពីនេសាទខ្នាតតូច ការធ្វើឯកជនភាវូបនីយកម្មធនធាននេសាទ និងទឹក និងដី ដែលសហគមន៍នេសាទពឹងអាស្រ័យលើ សម្រាប់ការប្រកបរបរចិញ្ចឹមជីវិតរបស់ពួកគេ ត្រូវបានគេជំទាស់ប្រឆាំងខ្លាំងក្លា* (SAMUDRA, 2008)។ មានការផ្តល់សារៈសំខាន់ដល់ការការពារលទ្ធភាពទទួលបានធនធាននេសាទបែបទំនៀមទម្លាប់ និងប្រពៃណីសម្រាប់សហគមន៍នេសាទតូចតាច។ រដ្ឋត្រូវបានជម្រុញឱ្យ "ផ្តល់នូវការធានាចំពោះសិទ្ធិទទួលបានធនធានរបស់សហគមន៍នេសាទជនជាតិដើមភាគតិចតូចតាច និងចំពោះដែនដី ដីធ្លី និងទឹក ដែលសហគមន៍ទាំងនេះពឹងអាស្រ័យលើកន្លងមកសម្រាប់ជីវិត និងជីវភាពរស់នៅរបស់ពួកគេ" និង "ការពារលទ្ធភាពរបស់ស្ត្រី ដែលជាសមាជិករបស់សហគមន៍នេសាទ ក្នុងការទទួលបានធនធាននេសាទ។ សេចក្តីថ្លែងទាំងនេះបង្ហាញពីភាពចាំបាច់ ដើម្បីជំនួសរបប "នេសាទដោយចំហ" ជាមួយនឹងប្រព័ន្ធ ដែលធានាបាននូវការទទួលបានធនធានបានជាប់លាប់របស់ក្រុមមួយចំនួន (អ្នកនេសាទតូចតាច) ដូចជា តាមរយៈសិទ្ធិកាន់កាប់ទ្រព្យសម្បត្តិតាមសហគមន៍ ឬទ្រព្យសម្បត្តិរួមជាដើម (FAO, 2009a)។ [9]

---

[8] អត្ថបទអាចរកបានក្នុង ៖
www.foodsovereignty.org/Portals/0/documenti%20sito/Core%20issues/Fisheries/bangkokstatement.pdf

[9] សម្រាប់ការពិភាក្សាអំពីរបៀបធ្វើការសម្រេចចិត្តអំពីប្រភេទប្រព័ន្ធសិទ្ធិកាន់កាប់ ដែលគួរអនុវត្តក្នុងស្ថានភាពផ្សេងៗពីគ្នា សូមមើលជំពូក ការបែងចែកសិទ្ធិនៅក្នុងផ្នែកទី ២។

**ហេតុអ្វីបានជាគេគួរប្រើប្រាស់អភិក្រមសិទ្ធិមនុស្ស នៅក្នុងអភិបាលកិច្ច និងការអភិវឌ្ឍសកម្មភាពនេសាទខ្នាតតូច?**

**VGGT លើកឡើងពីសិទ្ធិមនុស្ស និងគូសបញ្ជាក់ពីសារៈសំខាន់នៃអភិបាលកិច្ចលើសិទ្ធិកាន់កាប់ ឱ្យស្របទៅតាមកាតព្វកិច្ចរបស់រដ្ឋ ក្រោមច្បាប់អន្តរជាតិ និងលើកឡើងថា ៖**

*ដោយសារតែគ្រប់សិទ្ធិមនុស្សទាំងអស់ មានលក្ខណៈជាសកល មិនអាចបំបែកបាន ពឹងអាស្រ័យលើគ្នា និងមានទំនាក់ទំនងជាមួយគ្នាទៅវិញទៅមក អភិបាលកិច្ចលើសិទ្ធិកាន់កាប់ដីធ្លី ធនធាននេសាទ និងធនធានព្រៃឈើ មិនគួរផ្តោតតែលើសិទ្ធិ ដែលមានទំនាក់ទំនងដោយផ្ទាល់ ជាមួយនឹងលទ្ធភាពទទួលបាន និងប្រើប្រាស់ដីធ្លី ធនធាននេសាទ និងធនធានព្រៃឈើនោះទេ ប៉ុន្តែថែមទាំងគ្រប់សិទ្ធិស៊ីវិល នយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌ផងដែរ។ នៅក្នុងការបំពេញការងារនេះ រដ្ឋគួរគោរព និងការពារសិទ្ធិស៊ីវិល និងសិទ្ធិនយោបាយរបស់អ្នកការពារសិទ្ធិមនុស្ស ដូចជា សិទ្ធិមនុស្សរបស់កសិករ ជនជាតិដើមភាគតិច អ្នកនេសាទ អ្នកចិញ្ចឹមសត្វ និងកម្មករតាមតំបន់ជនបទ ហើយគួរសង្កេតមើលកាតព្វកិច្ចសិទ្ធិមនុស្សរបស់ពួកគេ នៅពេលធ្វើការងារជាមួយនឹងបុគ្គល និងសមាគម ដែលធ្វើសកម្មភាព ដើម្បីការពារដីធ្លី ធនធាននេសាទ និងធនធានព្រៃឈើ។*

**(៤.៨ នៅក្នុង *សិទ្ធិ និងការទទួលខុសត្រូវ ពាក់ព័ន្ធនឹងសិទ្ធិកាន់កាប់*)**

ដូចដែលបានលើកឡើងខាងលើ ការប្រើប្រាស់ពាក្យថា "សិទ្ធិ នៅក្នុងបរិបទនេសាទ ច្រើនតែសំដៅលើការគ្រប់គ្រងការងារនេសាទ (សិទ្ធិនេសាទ) ដែលយកសិទ្ធិធ្វើជាមូលដ្ឋាន។ ប៉ុន្តែ ការពិភាក្សាកាលពីពេលថ្មីៗនេះ បានដាក់បញ្ចូលនូវទស្សនវិស័យសិទ្ធិមនុស្ស និងសិទ្ធិទទួលបានមុខរបរចិញ្ចឹមជីវិតឱ្យបានជាប់លាប់ និងប្រកបដោយយុត្តិធម៌ រាប់បញ្ចូលទាំងសិទ្ធិសង្គម និងសេដ្ឋកិច្ច និងសិទ្ធិទទួលបានធនធានពាក់ព័ន្ធ (ដូចជា ដីធ្លី ជាដើម) ជាពិសេស នៅក្នុងបរិបទនេសាទខ្នាតតូច។ ការភ្ជាប់ទំនាក់ទំនងរវាងសិទ្ធិនេសាទ និងសិទ្ធិមនុស្ស ឆ្លុះបញ្ចាំងពីការបោះជំហានទៅរកអភិក្រមមួយ ដែលស្របជាមួយនឹងតថភាពនៃការប្រកបរបរចិញ្ចឹមជីវិតផ្សេងៗគ្នារបស់សហគមន៍នេសាទខ្នាតតូច និងភាពស្មុគស្មាញនៃភាពក្រីក្រ។ ការប្រើប្រាស់អភិក្រម ដែលមានមូលដ្ឋានទូលាយ ចំពោះការបែងចែកសិទ្ធិ នៅក្នុងបរិបទនេសាទ និងសហគមន៍នេសាទ មានន័យថាជាការផ្តល់ឱ្យអ្នកនេសាទនូវសិទ្ធិប្រកបរបរចិញ្ចឹមជីវិតឱ្យបានគ្រប់គ្រាន់ និងទទួលបាននូវអត្ថប្រយោជន៍ប្រកបដោយសមធម៌។ សិទ្ធិកាន់កាប់ធនធានដែលល្អ (ប្រកបដោយភាពយុត្តិធម៌ និងជាប់លាប់) គួរធ្វើឱ្យមានតុល្យភាពរវាងគោលដៅ

សង្គម វប្បធម៌ សេដ្ឋកិច្ច និងបរិស្ថាន ជួយកាត់បន្ថយវិវាទនានា បង្កើនសន្តិសុខស្បៀង និងលើកកម្ពស់ជីវភាពរស់នៅរបស់អ្នកនេសាទ និងសហគមន៍នេសាទតូចតាច និងសម្រួលឱ្យមានការការពារប្រព័ន្ធអេកូឡូហ្ស៊ីនៅមូលដ្ឋាន។ ការធ្វើឱ្យមានតុល្យភាពបែបនេះមិនមែនជាការងាយស្រួលនោះទេ ប៉ុន្តែ តាមរយៈការផ្លាស់ប្តូរទស្សនវិស័យឱ្យទៅជាផ្តោតលើប្រជាពលរដ្ឋពោលគឺលើជីវភាពរស់នៅរបស់សហគមន៍នេសាទ ជាជាងលើធនធាននេសាទ នោះរបៀបដែលគេយល់ និងកំណត់ពីសិទ្ធិកាន់កាប់ នឹងមានការប្រែប្រួល។ នេះតម្រូវឱ្យមានការយល់ដឹងឱ្យបានល្អអំពីបញ្ហានានាចំពោះមុខ និងអាទិភាពរបស់សហគមន៍នេសាទ។ ឧទាហរណ៍ ភាពចាំបាច់ ដើម្បីឱ្យមានការទទួលបានធនធាននេសាទឱ្យបានជាប់លាប់ និងការទទួលខុសត្រូវលើការគ្រប់គ្រងធនធានទាំងនេះ អាចមិនត្រូវបានគេចាត់ទុកថាជាអាទិភាពទីមួយឡើយ។ ដោយសារតែភាពក្រីក្រ និងភាពងាយរងគ្រោះ បញ្ហាបន្ទាន់ដទៃទៀត ដូចជា ផ្នែកសុខភាព ការអប់រំ ។ល។ អាចត្រូវបានចាត់ទុកថាមានសារៈសំខាន់ជាង។ សហគមន៍នេសាទតូចតាច អាចខ្វះសមត្ថភាព និងការលើកទឹកចិត្ត ដើម្បីចូលរួម នៅក្នុងការគ្រប់គ្រងធនធាននេសាទ ហើយគេចាំបាច់ត្រូវដោះស្រាយទិដ្ឋភាពផ្សេងទៀតរបស់ភាពក្រីក្រជាមុនសិន ឬទន្ទឹមគ្នានឹងពេលដែលមានការដោះស្រាយបញ្ហាពាក់ព័ន្ធនឹងសិទ្ធិកាន់កាប់ (Allison *et al.,* 2012; FAO, 2009a)។

**ក្នុងចំណោមគោលការណ៍អនុវត្តនានា VGGT លើកឡើងពី ៖**

***ការមិនរើសអើង*** *៖ ពុំគួរមានអ្នកណាម្នាក់គួរទទួលរងការរើសអើង ក្នុងច្បាប់ និងគោលនយោបាយ ក៏ដូចជានៅក្នុងការអនុវត្តជាក់ស្តែងនោះទេ។*

***សមធម៌ និងយុត្តិធម៌*** *៖ ទទួលស្គាល់ថា សមភាពរវាងបុគ្គល និងបុគ្គល អាចទាមទារឱ្យមានការទទួលស្គាល់ភាពខុស ប្លែកគ្នារវាងបុគ្គល និងបុគ្គល និងការអនុវត្តនូវវិធានការជាវិជ្ជមាន ដូចជា ការផ្តល់នូវភាពអង់អាច ជាដើម ដើម្បីលើកកម្ពស់ សិទ្ធិកាន់កាប់ និងលទ្ធភាពទទួលបានដីធ្លី ធនធាននេសាទ និងធនធានព្រៃឈើប្រកបដោយសមធម៌ សម្រាប់ទាំងអស់គ្នា ដូចជា ស្ត្រី និងបុរស យុវជន និងជនដែលងាយរងគ្រោះ និងជនដែលបាត់បង់ឱកាសកន្លងមក នៅក្នុងបរិបទជាតិ។*

***សមភាពយេនឌ័រ*** *៖ ធានានូវសិទ្ធិស្មើភាពគ្នាសម្រាប់ស្ត្រី និងបុរស ក្នុងការទទួលបានគ្រប់សិទ្ធិមនុស្សទាំងអស់ ហើយក្នុងពេលជាមួយគ្នាទទួលស្គាល់ភាពខុសប្លែកគ្នារវាងស្ត្រី និងបុរស និងចាត់វិធានការជាក់លាក់ ក្នុងគោលបំណងពន្លឿន*

*សមភាព នៅក្នុងការអនុវត្តជាក់ស្តែង នៅពេលដែលចាំបាច់។ រដ្ឋគួរធានាថា ស្ត្រី និងក្មេងស្រី មានសិទ្ធិកាន់កាប់ និងលទ្ធភាពទទួលបានដីធ្លី ធនធាននេសាទ និងធនធានព្រៃឈើស្មើភាពគ្នា ដោយមិនគិតពីស្ថានភាពស៊ីវិល និងស្ថានភាពគ្រួសាររបស់ពួកគេ។*

**(៣ខ នៅក្នុង *គោលការណ៍ណែនាំនៃអភិបាលកិច្ចលើសិទ្ធិកាន់កាប់ប្រកបដោយការទទួលខុសត្រូវ* )**

មូលដ្ឋានស្នូលនៃសិទ្ធិមនុស្ស គឺការមិនរើសអើង ហើយសមភាព និងយុត្តិធម៌ ក៏ដូចជាសមភាពយេនឌ័រ គឺស្ថិតនៅក្នុងចំណោមគោលការណ៍នានា ដែល VGGT យកមកធ្វើជាមូលដ្ឋាន។[10] ការពិចារណាលើយេនឌ័រ នៅក្នុងវិស័យនេសាទមានសារៈសំខាន់យ៉ាងខ្លាំង ហើយខណៈពេលដែលទស្សនទានយេនឌ័រ បើតាមនិយមន័យ ផ្តោតលើបុរសផង និងស្ត្រីផង ក្មេងប្រុសផង និងក្មេងស្រីផង និងលើតួនាទី និងទំនាក់ទំនងរវាងពួកគេ ដែលត្រូវបានកំណត់ឡើងនៅក្នុងសង្គម វប្បធម៌ និងសេដ្ឋកិច្ច ជារឿយៗ ស្ត្រីជួបប្រទះនឹងការលំបាកជាងបុរស។ ដូច្នេះ កិច្ចខិតខំប្រឹងប្រែងឱ្យមានសមភាពយេនឌ័រ មានន័យថាជាការគាំទ្រ និងការផ្តល់ភាពអង់អាចដល់ស្ត្រី ហើយនៅក្នុងពេលជាមួយគ្នា បំពេញការងារជាមួយបុរសផង និងស្ត្រីផង (សូមមើលប្រអប់ទី ៥)។ នៅពេលពិភាក្សាអំពីសិទ្ធិកាន់កាប់ គេត្រូវតែមានការប្រុងប្រយ័ត្ន ដោយត្រូវធានាយ៉ាងណាឱ្យការរៀបចំនានាផ្តល់ប្រយោជន៍ដល់បុរសផង និងស្ត្រីផង។[11]

**ប្រអប់ទី ៥ ៖ បុរស និងស្ត្រី នៅក្នុងវិស័យនេសាទ**

ជារឿយៗ វិស័យនេសាទត្រូវបានគេចាត់ទុកថាជាវិស័យ ដែលគ្របដណ្តប់ដោយបុរស ដោយហេតុថាអ្នកនេសាទភាគច្រើន ពោលគឺជាអ្នកចុះទូកទៅនេសាទ គឺជាបុរស។ ប៉ុន្តែ ស្ត្រីក៏បំពេញតួនាទីសំខាន់ស្មើគ្នាផងដែរ ហើយគេប៉ាន់ប្រមាណថា ពាក់កណ្តាលនៃអ្នកដែលធ្វើការងារនេសាទក្នុងពិភពលោកទាំងអស់ គឺជាស្ត្រី។ ជាទូទៅ ស្ត្រី គឺជាមនុស្សសំខាន់នៅក្នុងការចាត់ចែងត្រី និងផលិតផលវារីជាតិដទៃទៀត ក្រោយប្រមូលផលហើយ ចាប់ពីពេលប្រមូលដាក់លើគោក រហូត

[10] សូមមើលជំពូក គោលការណ៍ទូទៅ នៅក្នុងផ្នែកទី ២។

[11] សូមមើលផងដែរនូវឯកសារ ដែលមានចំណងជើងថា ការអភិបាលដីធ្លី សម្រាប់ស្ត្រី និងបុរស - មគ្គុទេសក៍បច្ចេកទេស ដើម្បីគាំទ្រដល់ការសម្រេចឱ្យបាននូវអភិបាលកិច្ចលើសិទ្ធិកាន់កាប់ដីធ្លី ប្រកបដោយការទទួលខុសត្រូវ និងសមភាពយេនឌ័រ (FAO, 2013a)។ មគ្គុទេសក៍សម្រាប់អនុវត្តនេះក៏ត្រូវបានរៀបចំផងដែរ ដើម្បីគាំទ្រដល់សេចក្តីណែនាំនេះ ប៉ុន្តែមិនមានលើកឡើងពីយេនឌ័រ នៅក្នុងវិស័យនេសាទនោះទេ។

ដល់ពេលប្រគល់ទៅឱ្យអតិថិជន។ ស្ត្រី ក៏ចូលរួមបំពេញការងារជាសហគ្រិន និងជាអ្នកទិញត្រីផងដែរ។ វាមិនមែនជារឿងខុសធម្មតា នោះទេ ដែលពួកគេត្រូវការលុយជាមុន ដើម្បីរ៉ាប់រងលើការចុះនេសាទរបស់ពួកគេ ឬផ្តល់កម្ចីដល់អ្នកនេសាទជាមុន ជាថ្នូរនឹងការធានាការផ្គត់ផ្គង់ត្រី នៅពេលដែលគេយកត្រីមកគោក។ នៅតាមប្រទេសមួយចំនួន វាជារឿងធម្មតាដែលស្ត្រីទៅនេសាទ ឬប្រមូលអាហារសមុទ្ទ ដូចជា គ្រុំ និងខ្យង ជាដើម នៅតាមតំបន់ឆ្នេរ ឬទឹកសាប។

*ប្រភព ៖* FAO (2010)

## តើសិទ្ធិកាន់កាប់ផ្លូវការ នៅក្នុងវិស័យនេសាទ មានប្រភេទផ្សេងៗគ្នាអ្វីខ្លះ?

**ជាគោលការណ៍ដ៏សំខាន់មួយ VGGT លើកឡើងថា ៖**

*រដ្ឋគួរទទួលស្គាល់ និងផ្តល់ការគោរពដល់អ្នកដែលមានសិទ្ធិកាន់កាប់ស្របច្បាប់ទាំងអស់ ក៏ដូចជាដល់សិទ្ធិរបស់ពួកគេ។ រដ្ឋគួរចាត់វិធានការសមស្រប ដើម្បីកំណត់ កត់ត្រា និងគោរពអ្នកដែលមានសិទ្ធិកាន់កាប់ស្របច្បាប់ និងសិទ្ធិរបស់ពួកគេមិនថាសិទ្ធិទាំងនេះត្រូវបានកត់ត្រាជាផ្លូវការឬអត់នោះទេ ក្នុងការទប់មិនឱ្យមានការប៉ះពាល់ដល់សិទ្ធិកាន់កាប់របស់អ្នកដទៃទៀត និងក្នុងការបំពេញភារកិច្ចនានា ដែលពាក់ព័ន្ធជាមួយនឹងសិទ្ធិកាន់កាប់។*

**(៣ក នៅក្នុង *គោលការណ៍ណែនាំស្តីពីអភិបាលកិច្ចលើសិទ្ធិកាន់កាប់ ប្រកបដោយការទទួលខុសត្រូវ*)**

សិទ្ធិកាន់កាប់ នៅក្នុងវិស័យនេសាទ មានទម្រង់ច្រើនយ៉ាងផ្សេងៗគ្នា នៅក្នុងបរិបទនៃការគ្រប់គ្រងធនធាននេសាទដោយយកសិទ្ធិមកធ្វើជាមូលដ្ឋាន។ នេះគឺជាទស្សនទាន ដែលមានលក្ខណ:ស្មុគស្មាញគួរសម ហើយពុំមានលក្ខខណ្ឌ ដែលទទួលបានការយល់ព្រមជាសកលនោះឡើយ។ ការកំណត់ និងនិយមន័យ ដែលប្រើប្រាស់ មានលក្ខណ:ខុសគ្នាពីប្រទេសមួយទៅប្រទេសមួយទៀត ពីទីតាំងមួយទៅទីតាំងមួយទៀត និងពីស្ថាប័នមួយទៅស្ថាប័នមួយទៀត។ នៅក្នុងឯកសារនេះ ពាក្យថា "សិទ្ធិប្រើប្រាស់" ត្រូវបានគេប្រើប្រាស់ជាអាទិភាព នៅពេលមានការលើកឡើងពីសិទ្ធិផ្លូវការ ក្នុងការទទួលបានធនធាននេសាទ ពោលគឺនៅពេលកំណត់ថាតើអ្នកណាខ្លះ ដែលពាក់ព័ន្ធនឹងការងារនេសាទ និងពាក់ព័ន្ធដោយរបៀបណា។ នៅពេល

ដែលសិទ្ធិក៏មានរាប់បញ្ចូលផងដែរនូវការទទួលខុសត្រូវក្នុងការគ្រប់គ្រង ដូចជា សិទ្ធិ ឬកាតព្វកិច្ច ដើម្បីចូលជាសមាជិករបស់គណៈកម្មាធិការគ្រប់គ្រងធនធាននេសាទ ពេលខ្លះ ពាក្យថា "សិទ្ធិគ្រប់គ្រង" ក៏ត្រូវបានប្រើប្រាស់ផងដែរ។[12]

សិទ្ធិកាន់កាប់ធនធាននេសាទ ជាធម្មតា ត្រូវបានគេចាត់ទុកជាផ្នែកមួយនៃក្របខ័ណ្ឌអភិបាលកិច្ច និងគ្រប់គ្រងធនធាននេសាទ ដែលមានលក្ខណៈទូលំទូលាយ។ ការរៀបចំសិទ្ធិកាន់កាប់មួយចំនួន មានលក្ខណៈដូចគ្នានឹងវិធានការ ដែលត្រូវបានអនុវត្ត នៅក្នុងការគ្រប់គ្រងធនធាននេសាទទំនើប (សូមមើលប្រអប់ទី ៤) ផងដែរ ដូចជា សិទ្ធិទទួលបានធនធាននេសាទ (អាជ្ញាប័ណ្ណ) ឬសិទ្ធិដកហូត ឬប្រមូលផល (កូតា) ជាដើម។ ការរៀបចំទាំងនេះ មានលក្ខណៈស្រដៀងគ្នានឹងការត្រួតពិនិត្យលើធាតុចូល (កិច្ចប្រឹងប្រែង) និងធាតុចេញនៃការគ្រប់គ្រងធនធាននេសាទដែរ ប៉ុន្តែត្រូវបានគេចាត់ទុកថាជា សិទ្ធិ ឬបុព្វសិទ្ធិ ដែលផ្តល់ទៅឱ្យអ្នកនេសាទ ជាជាងជាការដាក់កំហិត និងការដាក់ជាបទបញ្ញានានា បើតាមទស្សនវិស័យនៃការគ្រប់គ្រងធនធាននេសាទ ដែលយកសិទ្ធិមកធ្វើជាមូលដ្ឋាន។

មានរបបគ្រប់គ្រង តាមតំបន់ផ្សេងៗគ្នាជាច្រើន ដែលសំដៅលើទីតាំងនេសាទ ដូចជា សិទ្ធិប្រើប្រាស់ដែននេសាទ (TURFs) ជាដើម។ សិទ្ធិប្រើប្រាស់ដែននេសាទ ផ្តល់សិទ្ធិទៅឱ្យបុគ្គល ឬក្រុម ឱ្យធ្វើការនេសាទ នៅក្នុងទីតាំងណាមួយ ដែលជាធម្មតា ផ្អែកទៅតាមសិទ្ធិបែបទំនៀមទម្លាប់ (សូមមើលខាងក្រោម)។

តំបន់ការពារក្នុងដែនសមុទ្ទ (MPAs) ជាទូទៅ ត្រូវបានគេលើកកម្ពស់ ចេញពីទស្សនវិស័យនៃការអភិរក្សជីវចម្រុះ ប៉ុន្តែអាស្រ័យទៅតាមនិយមន័យជាក់ស្តែងនៃទស្សនទាននេះ នៅក្នុងស្ថានភាពជាក់លាក់ណាមួយ តំបន់ទាំងនេះក៏ត្រូវបានគេចាត់ទុកថាជាវិធានការសម្រាប់គ្រប់គ្រងធនធាននេសាទផងដែរ។ ការហាមឃាត់ក្នុងទម្រង់ផ្សេងៗគ្នាមិនឱ្យមានការប្រើប្រាស់ឧបករណ៍នេសាទ នៅកន្លែងណាមួយ ក្នុងពេលណាមួយ ត្រូវបានគេចាត់ទុកថាជាឧបករណ៍គ្រប់គ្រងធនធាននេសាទ ដែលគេនិយមអនុវត្តបំពេញ។ ប៉ុន្តែ តំបន់ការពារក្នុងដែនសមុទ្ទ ច្រើនតែបង្កើតឡើងជាអង្គភាពគ្រប់គ្រងឯករាជ្យ ដែលពេលខ្លះ រំលោភលើសិទ្ធិកាន់កាប់ធនធានដែលមានស្រាប់ ដោយក្នុងពេលជាមួយគ្នា គេគួរតែយកវិធានការទាំងនេះមកពិចារណាក្នុងក្របខ័ណ្ឌគ្រប់គ្រង ដែលមានលក្ខណៈទូលំទូលាយជាងវិញ។ វិធានការទាំងនេះមានចាប់ពី តំបន់ "ហាមឃាត់

---

[12] ពាក្យបច្ចេកទេស ដែលគេនិយមប្រើប្រាស់ នៅក្នុងសិទ្ធិកាន់កាប់ទ្រព្យសម្បត្តិ (ទ្រព្យសម្បត្តិរួម និងទ្រព្យសម្បត្តិឯកជន) សិទ្ធិទទួលបាន និងសិទ្ធិនេសាទ។ សម្រាប់ការបញ្ជាក់បន្ថែម សូមមើលអត្ថបទជាច្រើន នៅក្នុង Shotton (2000)។ ផ្នែកនេះយកចេញពីឯកសារនេះ និងយកចេញពី MRAG *et al.,* (2009); FAO (2005-2013b) និង Charles (2011)។

មិនឱ្យមានការនេសាទ” រហូតដល់តំបន់ “ប្រើប្រាស់ច្រើនយ៉ាង” ដោយមានផែនការត្រឹមត្រូវ ហើយវិធានការទាំងនេះកាន់តែផ្តោតលើគោលបំណងអភិរក្សជីវចម្រុះផង និងគ្រប់គ្រងធនធាននេសាទផង។[13]

ការកំណត់តំបន់ គឺជាអភិក្រមឧបករណ៍គ្រប់គ្រងតាមតំបន់មួយប្រភេទ។ ពេលខ្លះ ប្រទេសនានាផ្តល់អាទិភាពឱ្យចូលទៅក្នុងតំបន់ សម្រាប់ការនេសាទខ្នាតតូច ជាទូទៅ នៅតាមតំបន់ជិតឆ្នេរ ដូចជា តាមរយៈការហាមឃាត់មិនឱ្យមាននាវាធំៗ មកនេសាទនៅជិតឆ្នេរ។ ប៉ុន្តែ ពេលខ្លះ របបទាំងនេះមិនត្រូវបានគេអនុវត្តឱ្យបានខ្លាំងក្លានោះឡើយ ហើយទំនងជាមិនអាចដោះស្រាយនូវបញ្ហាគ្មានលទ្ធភាពកំហិតការចូលទៅក្នុងតំបន់ទាំងនេះ ដើម្បីធ្វើការនេសាទឡើយ។ ក៏អាចមានផងដែរនូវការប្រើប្រាស់តំបន់ជាប់ឆ្នេរនេះ សម្រាប់គោលបំណងមិនមែននេសាទ ហើយចាំបាច់ត្រូវមានការផ្តោតការយកចិត្តទុកដាក់ឱ្យបានកាន់តែច្រើនលើប្រព័ន្ធរៀបចំទីកន្លែងឱ្យបានកាន់តែទូលំទូលាយ ដោយមានដាក់បញ្ចូល និងសម្របសម្រួលផែនការ និងសកម្មភាពនានារបស់វិស័យផ្សេងៗគ្នាជាមួយគ្នា (សូមមើលប្រអប់ទី ៦)។

**ប្រអប់ទី ៦ ៖ អ្វីទៅជាការរៀបចំផែនការទីតាំង ដែលមានលក្ខណៈសមាហរណកម្ម?**

ការគ្រប់គ្រង ដែលមានលក្ខណៈសមាហរណកម្ម (មិនថាលើសមុទ្ទ តំបន់ឆ្នេរ ទីជម្រាល ។ល។ នោះទេ) គឺជាអភិក្រម ឬយន្តការមួយ ដើម្បីគ្រប់គ្រងការប្រើប្រាស់ (ប្រជែងគ្នាលើ) តំបន់ចាត់តាំងណាមួយ។ ការប្រើប្រាស់ទាំងនេះ រួមមានវិស័យផ្សេងៗគ្នា ដូចជា នេសាទ វារីវប្បកម្ម ព្រៃឈើ ប្រេង និងឧស្ម័ន រ៉ែ កសិកម្ម នាវា និងទេសចរណ៍។ ការគ្រប់គ្រងបែបនេះ រួមមាន ការគ្រប់គ្រងអ្នកពាក់ព័ន្ធជាច្រើន (ឧ. សហគមន៍ និងឧស្សាហកម្មមូលដ្ឋាន ជាដើម) និងអន្តរកម្មរវាងមនុស្ស និងមនុស្ស និងសមាសភាគដទៃទៀតរបស់ប្រព័ន្ធអេកូឡូហ្ស៊ី និងរវាងកម្រិតផ្សេងៗរបស់រដ្ឋាភិបាល។ ភាពចាំបាច់ដើម្បីឱ្យមានការអនុវត្តអភិក្រមអន្តរវិស័យ ដែលមានលក្ខណៈសមាហរណកម្ម កាន់តែទទួលបានការទទួលស្គាល់ខ្លាំងឡើងៗ និងការយកចិត្តទុកដាក់យ៉ាងច្រើនលើអភិក្រមនេសាទ ដោយគិតគូរពីប្រព័ន្ធអេកូឡូហ្ស៊ី គឺជាផ្នែកមួយនៃអភិក្រមនេះ (សូមមើលប្រអប់ទី ៤)។

ក្របខ័ណ្ឌរៀបចំផែនការ និងគ្រប់គ្រងទីតាំង ពាក់ព័ន្ធជាមួយនឹងវិស័យនេសាទ មានច្រើនប្រភេទ និងមាន

[13] មានពាក្យបច្ចេកទេសផ្សេងៗជាច្រើន ដែលគេប្រើប្រាស់សម្រាប់ការរៀបចំប្រភេទតំបន់ការពារក្នុងសមុទ្ទ ដូចជា បម្រុង ដែនជម្រកសមុទ្ទ សួនសមុទ្ទ ទីជម្រករបស់ធនធាននេសាទ តំបន់សមុទ្ទដែលគ្រប់គ្រងនៅមូលដ្ឋាន ហើយពុំមាននិយមន័យរបស់ទស្សនទាននេះដែលត្រូវបានគេឯកភាពក្នុងសកលលោកទាំងមូលឡើយ។ សូមមើល FAO (2011b) សម្រាប់ព័ត៌មានបន្ថែមអំពី MPAs និងធនធាននេសាទ។

សក្តានុពល ដាក់បញ្ចូលតម្រូវការចំនួនពីរសម្រាប់ធនធាននេសាទផង និងដីធ្លីសម្រាប់សហគមន៍នេសាទផង ពោលគឺការរៀបចំផែនការទីតាំងក្នុងដែនសមុទ្រ (MSP) ផង និងការគ្រប់គ្រងតំបន់ឆ្នេរតាមបែបសមាហរណកម្ម (ICZM) ផង។ ក្រមសីលធម៌សម្រាប់ការនេសាទប្រកបដោយការទទួលខុសត្រូវ FAO (1995) លើកឡើងជាពិសេសអំពីភាពចាំបាច់ ដើម្បី "ធ្វើការពិចារណាលើធនធាននេសាទ នៅក្នុងការប្រើប្រាស់តំបន់ឆ្នេរ ដើម្បីប្រយោជន៍ចម្រុះ និងត្រូវដាក់បញ្ចូលធនធាននេសាទ ទៅក្នុងការគ្រប់គ្រង ការរៀបចំផែនការ និងការអភិវឌ្ឍតំបន់ឆ្នេរ" (ប្រការ ១០.៩)។

*ប្រភព ៖* FAO (1995, 2011b)

ប្រព័ន្ធគ្រប់គ្រងតាមសហគមន៍ ផ្តល់សិទ្ធិគ្រប់គ្រង ទៅឱ្យសហគមន៍ ឬក្រុមសហគមន៍។ នៅពេលដែលសហគមន៍ និងរដ្ឋាភិបាល ចែករំលែកការទទួលខុសត្រូវក្នុងការគ្រប់គ្រង មានការលើកឡើងពីការរៀបចំការគ្រប់គ្រងរួមគ្នា។ ការរៀបចំការគ្រប់គ្រងរួមគ្នា ក៏អាចមានការចូលរួមពីដៃគូដទៃទៀតផងដែរ ដូចជា អង្គការមិនមែនរដ្ឋាភិបាល ស្ថាប័នស្រាវជ្រាវ និងអ្នកដឹកនាំបែបប្រពៃណី (សូមមើលឧទាហរណ៍ នៅក្នុងប្រអប់ទី ៧)។ ការគ្រប់គ្រងរួមគ្នា ត្រូវបានគេចាត់ទុកថាជាការអនុវត្តល្អបំផុត ដែលគេផ្តល់អនុសាសន៍ថាគួរធ្វើតាម សម្រាប់ការគ្រប់គ្រងធនធាននេសាទខ្នាតតូច។ ជារឿយៗ ការរៀបចំការគ្រប់គ្រងរួមគ្នា ត្រូវបានដាក់បញ្ចូលជាមួយនឹងការធ្វើប្រតិភូកម្មការទទួលខុសត្រូវក្នុងការគ្រប់គ្រង ពីរដ្ឋាភិបាលនៅថ្នាក់កណ្តាល ទៅរដ្ឋាភិបាលនៅថ្នាក់មូលដ្ឋាន បន្ថែមពីលើការប្រគល់ការទទួលខុសត្រូវក្នុងការគ្រប់គ្រងទៅឱ្យអ្នកប្រើប្រាស់ធនធាន។ នៅក្នុងវិស័យនេសាទ និងពាក់ព័ន្ធជាមួយនឹងការទទួលខុសត្រូវក្នុងការគ្រប់គ្រងតំបន់ឆ្នេរ និងតំបន់ជាប់ឆ្នេរ ប្រទេសជាច្រើនបានប្រគល់ការទទួលខុសត្រូវកាន់តែច្រើន ទៅឱ្យរដ្ឋាភិបាលនៅថ្នាក់មូលដ្ឋាន (ឧ. ប្រទេសហ្វីលីពីន និងប្រទេសឥណ្ឌូនេស៊ី ជាដើម) (Pomeroy and Rivera-Guieb, 2006; Pomeroy, 2001)។

**ប្រអប់ទី ៧ ៖ រចនាសម្ព័ន្ធគ្រប់គ្រងរួមគ្នា នៅក្នុងប្រទេស Burkina Faso**

គម្រោងសាកល្បងមួយ ក្រោមកម្មវិធីរបរនេសាទចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព (SFLP) បានគាំទ្រដល់ការដាក់ឱ្យអនុវត្តនូវការរៀបចំគ្រប់គ្រងរួមគ្នាលើទំនប់ធំៗ (បឹងសិប្បនិម្មិត) នៅក្នុងប្រទេស Burkina Faso ហើយគណៈកម្មាធិការគ្រប់គ្រងចំនួន ២ ត្រូវបានបង្កើតឡើង - មួយសម្រាប់បឹង Bagré និងមួយទៀតសម្រាប់បឹង Kompienga។ គណៈកម្មា-ធិការទាំងនេះ មានការចូលរួមពីរដ្ឋបាលមូលដ្ឋាន រដ្ឋបាលបច្ចេកទេសវិមជ្ឈការ កុងស៊ុល អង្គការមិនមែនរដ្ឋាភិបាល

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ តំណាងអ្នកគ្រប់គ្រងបែបប្រពៃណី និងតំណាងសមាគមអ្នកជំនាញផ្នែកសង្គម។ គណៈកម្មាធិការទាំងនេះបានទទួលបានងារស្របច្បាប់ ដើម្បីផ្តល់ការអនុម័ត និងបញ្ជាក់សុពលភាពលើផែនការគ្រប់គ្រងរួមគ្នា ក៏ដូចជាវិធាន នីតិវិធីនានា។ គណៈកម្មការឯកទេស ត្រូវបានបង្កើតឡើង ដើម្បីដោះស្រាយបញ្ហាគ្រប់គ្រងជាក់លាក់ ដូចជា ការឃ្លាំមើលជំរុំនេសាទ ការបង្កើតនូវមូលនិធិគ្រប់គ្រងធនធាននេសាទនៅមូលដ្ឋាន ការបណ្តុះបណ្តាលសមាជិកគណៈកម្មាធិការ និងការការពារជម្រកត្រី តាមរយៈការកំណត់តំបន់សម្រាប់ត្រីកូន។

លើសពីនេះ នៅក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រងរួមគ្នាលើគម្រោងសាកល្បងនេះ គណៈកម្មាធិការថ្មីមួយត្រូវបានបង្កើតឡើង នៅក្នុងភូមិ Kompiengbiga/Tounga ដែលជាភូមិនេសាទធំជាងគេរបស់បឹង Kompienga ក្នុងគោលបំណងដោះស្រាយវិវាទនានា ដែលកើតឡើងរវាងសហគមន៍ជនចំណាកស្រុកធំជាងគេ និងប្រជាជនដែលរស់នៅក្នុងតំបន់នេះ។ គណៈកម្មាធិការនេះ មានសមាសភាពជាប្រធានក្រុមសហគមន៍ និងក្រុមជនជាតិផ្សេងៗទាំងអស់ ហើយគណៈកម្មាធិការនេះ មានភារកិច្ចដោះស្រាយបញ្ហានានា ដូចជា ចោរកម្ម សត្វវង្វេងផ្លូវក្នុងភូមិ ជម្លោះរវាងអ្នកភូមិ ភាពតានតឹងក្នុងគ្រួសារ ការ អនុវត្តវិធានការគ្រប់គ្រងធនធាននេសាទ ការសងកម្ចីរវាងអ្នកភូមិ និងអ្នកភូមិ និងការចូលរួមនៅក្នុងសេវាសហគមន៍។ ជាមួយនឹងការបង្កើតគណៈកម្មាធិការនេះ ចំនួនទំនាស់ធ្ងន់ធ្ងរមានការថយចុះ ហើយគណៈកម្មាធិការនេះក៏បានបង្កើតនូវភាពបើកចំហថ្មីមួយរវាងក្រុមជនចំណាកស្រុក និងក្រុមប្រជាជនមូលដ្ឋានផងដែរ។ ជាទូទៅ គ្រប់គណៈកម្មាធិការទាំង ៣ នេះ សុទ្ធតែបានបំពេញតួនាទីយ៉ាងសំខាន់ នៅក្នុងការបង្កើនការយល់ដឹងដល់អាជ្ញាធរជាតិអំពីភាពចាំបាច់ ដើម្បីធ្វើការពិចារណាលើប្រយោជន៍របស់សហគមន៍នេសាទ នៅក្នុងការគ្រប់គ្រងធនធាននេសាទ។

*ប្រភព* ៖ Njock, Allison and Konan (2008); Konan (2007)

តារាងទី ១ បង្ហាញឧទាហរណ៍អំពីប្រភេទសិទ្ធិផ្សេងៗគ្នា ដោយមានការរៀបរាប់សង្ខេបពីដំណើរការរបស់សិទ្ធិនេះ និងលក្ខណៈរបស់វា។

**តារាងទី ១ ៖ ប្រភេទប្រព័ន្ធគ្រប់គ្រង ដោយយកសិទ្ធិធ្វើជាមូលដ្ឋាន - ឧទាហរណ៍ដែលមាននៅតាមប្រទេស OECD**

| **ប្រភេទសិទ្ធិ** | **លក្ខណៈសំខាន់ៗ** |
|---|---|
| សិទ្ធិប្រើប្រាស់ដែនដី | ការបែងចែកតំបន់ណាមួយ នៅក្នុងដែនសមុទ្រ ទៅឱ្យអ្នកប្រើប្រាស់ណាមួយ ជាធម្មតា គឺជាក្រុមមួយ ដែល |

| | |
|---|---|
| នៅក្នុងវិស័យនេសាទ | ត្រូវធ្វើការនេសាទ ដោយបែងចែកសិទ្ធិដល់អ្នកប្រើប្រាស់ នៅក្នុងក្រុមនេះ។ ជាធម្មតា មានរយៈពេលយូរ និង មានលទ្ធភាពផ្ទេរផ្លូវការ និងក្រៅផ្លូវការក្នុងកម្រិតខ្ពស់ នៅក្នុងក្រុម។ |
| កូតាផលចាប់តាមសហគមន៍ | កូតាផលចាប់ ត្រូវបានផ្តល់ដល់សហគមន៍នេសាទ ដែលសម្រេចចិត្តបែងចែកសិទ្ធិ ក្នុងសហគមន៍ ដោយសហការគ្នា។ ជារឿយៗ កូតាត្រូវបានគេប្រើប្រាស់ នៅក្នុងការធ្វើឱ្យសិទ្ធិប្រើប្រាស់បែបប្រពៃណី នៅក្នុងការងារនេសាទខ្នាតតូច មានលក្ខណៈផ្លូវការ។ កូតាទាំងនេះផ្តល់នូវភាពផ្តាច់មុខ ភាពបែងចែក និងភាពបត់បែន ក្នុងកម្រិតមួយខ្ពស់។ |
| ការកំហិតរបស់ផលចាប់ របស់នាវា | ការដាក់កំហិតលើបរិមាណផលចាប់ ដែលនាវានីមួយៗអាចប្រមូលបាន សម្រាប់រយៈពេលណាមួយ (សប្តាហ៍ ខែ ឬឆ្នាំ) ឬសម្រាប់មួយជើង។ មធ្យោបាយទាំងនេះ ត្រូវបានកំណត់ថាជាមធ្យោបាយ ដែលមានកម្រិតទាប ឬមធ្យម សម្រាប់លក្ខណៈសិទ្ធិភាគច្រើន។ មធ្យោបាយទាំងនេះផ្តល់នូវភាពផ្តាច់មុខមានកម្រិត ហើយអាច នាំឱ្យមានការថយចុះនូវការប្រណាំងប្រជែង ដើម្បីបានត្រី ហើយក្នុងពេលជាមួយគ្នា ផ្តល់នូវភាពបត់បែន និង គុណភាពកម្មសិទ្ធិ ក្នុងកម្រិតមួយចំនួន។ |
| កូតាមិនអាចផ្ទេរបាន របស់បុគ្គលម្នាក់ៗ | ផ្តល់សិទ្ធិចាប់ត្រីក្នុងបរិមាណមួយ សម្រាប់ប្រភេទត្រីអ្វីមួយ ឬជាធម្មតា ជាភាគរយនៃផលចាប់សរុបដែលអាចអនុញ្ញាតឱ្យបាន (TAC)។ ភាពផ្តាច់មុខ និងភាពបត់បែនក្នុងកម្រិតខ្ពស់ ផ្តល់លទ្ធភាពឱ្យអ្នកមានសិទ្ធិប្រើប្រាស់សិទ្ធិរបស់ពួកគេ ដោយអស់ចំណាយតិចបំផុត ដើម្បីធានាបាននូវបរិមាណត្រី ដែលផ្តល់ឱ្យ។ ការប្រជែងគ្នា ដើម្បីចាប់ត្រី ដែលស្ថិតក្រោម ដែលមានលក្ខណៈប្រជែងគ្នា TAC ត្រូវបានលុបបំបាត់ចោល ប៉ុន្តែកង្វះភាពអាចផ្ទេរបាន ដាក់កំហិតលើប្រសិទ្ធភាពនៃការប្រមូលផល។ |
| កូតាដែលអាចផ្ទេរបាន របស់បុគ្គលម្នាក់ៗ | ផ្តល់សិទ្ធិចាប់ត្រី គិតជាភាគរយនៃ TAC ដែលគេអាចផ្ទេរទៅឱ្យអ្នកដទៃបាន។ មធ្យោបាយមួយនេះដាក់ពិន្ទុខ្ពស់ដល់គ្រប់លក្ខណៈវិនិច្ឆ័យទាំងអស់។ លក្ខណៈរបស់ប្រព័ន្ធនេះផ្តល់លទ្ធភាពឱ្យគេអាចផ្តល់ការលើកទឹកចិត្ត ក្នុងរយៈពេលវែងសមស្រប សម្រាប់ការសម្រេចចិត្តវិនិយោគ និងការប្រើប្រាស់សមត្ថភាពនេសាទក្នុងរយៈពេលខ្លីឱ្យអស់ពីលទ្ធភាព។ |
| អាជ្ញាធរប័ណ្ណមានកម្រិត ដែលមិនអាចផ្ទេរបាន | អាជ្ញាប័ណ្ណទាំងនេះអាចភ្ជាប់ជាមួយនឹងនាវាមួយ ម្ចាស់របស់នាវា ឬទាំងពីរ ហើយត្រូវតែមានការកំណត់ចំនួន និងអនុវត្តបានតែប្រភេទត្រីអ្វីមួយ ឬទៅតាមទីផ្សារ។ តាមរយៈការដាក់កំហិតលើការនេសាទប្រភេទត្រីអ្វី មួយ មធ្យោបាយនេះជួយកាត់បន្ថយការប្រជែងគ្នា ដើម្បីបានត្រី និងបង្ការការថមថយនូវការជួល។ ប៉ុន្តែកង្វះលទ្ធភាពក្នុងការផ្ទេរ និងការបែងចែក ដាក់កំហិតលើការប្រើប្រាស់សមត្ថភាពនេសាទឱ្យអស់ពីលទ្ធភាព។ |

| | |
|---|---|
| អាជ្ញាធរប័ណ្ណមានកម្រិត ដែលអាចផ្ទេរបាន | តាមរយៈការធ្វើឱ្យអាជ្ញាប័ណ្ណមានកម្រិតអាចផ្ទេរបាន អ្នកនេសាទទទួលបានការលើកទឹកចិត្តច្រើនជាងមុនក្នុងការកែសម្រួលសមត្ថភាព និងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ក្នុងរយៈពេលខ្លី រហូតដល់រយៈពេលវែង ជាការឆ្លើយតបចំពោះស្ថានភាពធម្មជាតិ និងសេដ្ឋកិច្ច។ ជាទូទៅ អាជ្ញាប័ណ្ណទាំងនេះត្រូវបានផ្តល់សម្រាប់រយៈពេលដ៏វែង ប៉ុន្តែមិនអាចធ្វើការបំបែកតូចៗបានឡើយ។ |
| កូតានៃកិច្ចខិតខំប្រឹងប្រែងរបស់បុគ្គលម្នាក់ៗ ដែលមិនអាចផ្ទេរបាន | សិទ្ធិនានាត្រូវបានភ្ជាប់ជាមួយនឹងបរិមាណឯកតានៃកិច្ចខិតខំប្រឹងប្រែង ដែលអ្នកនេសាទម្នាក់អាចមាន នៅក្នុងរយៈពេលមួយ។ សិទ្ធិទាំងនេះច្រើនតែត្រូវបានគេប្រើប្រាស់ នៅក្នុងការនេសាទពពួកសត្វនៅនឹងមួយកន្លែង ហើយត្រូវបានគេចាត់ប្រភេទថាមានភាពផ្តាច់មុខ រយៈពេល និងគុណភាពកម្មសិទ្ធិកម្រិតមធ្យម ឬកម្រិតខ្ពស់។ |
| កូតានៃកិច្ចខិតខំប្រឹងប្រែងរបស់បុគ្គលម្នាក់ៗ ដែលអាចផ្ទេរបាន | ភាពអាចផ្ទេរបាន ធ្វើឱ្យការកែសម្រួលក្នុងរយៈពេលខ្លី និងរយៈពេលវែង កាន់តែងាយស្រួលជាងមុន និងផ្តល់លទ្ធភាពឱ្យមានការប្រើប្រាស់សមត្ថភាពនេសាទ កាន់តែល្អប្រសើរជាងមុន។ |

*ប្រភព ៖ ដកស្រង់ចេញពី* pp. 13-14, MRAG *et al.* (20090.

## តើមានសិទ្ធិកាន់កាប់បែបទំនៀមទម្លាប់ និងក្រៅផ្លូវការអ្វីខ្លះ?

**VGGT លើកឡើងថា ៖**

*តួអង្គរដ្ឋ និងតួអង្គមិនមែនរដ្ឋ គួរទទួលស្គាល់ថា ដីធ្លី ធនធាននេសាទ និងធនធានព្រៃឈើ មានគុណតម្លៃផ្នែកសង្គម វប្បធម៌ ជំនឿអារក្ខ សេដ្ឋកិច្ច បរិស្ថាន និងនយោបាយ ចំពោះជនជាតិដើមភាគតិច និងសហគមន៍ដទៃទៀត ដែលប្រើប្រាស់ប្រព័ន្ធសិទ្ធិកាន់កាប់បែបទំនៀមទម្លាប់។*

**(៩.១ នៅក្នុង ជនជាតិដើមភាគតិច និងសហគមន៍ដទៃទៀតដែលប្រើប្រាស់ ប្រព័ន្ធសិទ្ធិកាន់កាប់បែបទំនៀមទម្លាប់)**

*ជនជាតិដើមភាគតិច និងសហគមន៍ដទៃទៀត ដែលប្រើប្រាស់ប្រព័ន្ធសិទ្ធិកាន់កាប់បែបទំនៀមទម្លាប់ ដែលធ្វើការគ្រប់គ្រងដោយខ្លួនឯងលើដីធ្លី ធនធាននេសាទ និងធនធានព្រៃឈើ គួរលើកកម្ពស់ និងផ្តល់សិទ្ធិប្រកបដោយសមធម៌ សន្តិសុខ*

*និងនិរន្តរភាព លើធនធានទាំងនេះ ដោយផ្តោតការយកចិត្តទុកដាក់ពិសេស លើការផ្តល់លទ្ធភាពដល់ស្ត្រីប្រកបដោយសមធម៌។*

**(៩.២ នៅក្នុង *ជនជាតិដើមភាគតិច និងសហគមន៍ដទៃទៀតដែលប្រើប្រាស់ ប្រព័ន្ធសិទ្ធិកាន់កាប់បែបទំនៀមទម្លាប់*)**

*នៅក្នុងករណីដែលជនជាតិដើមភាគតិច និងសហគមន៍ដទៃទៀត ដែលប្រើប្រាស់ប្រព័ន្ធសិទ្ធិកាន់កាប់បែបទំនៀមទម្លាប់ មានសិទ្ធិកាន់កាប់ស្របច្បាប់លើដីដែលបន្សល់ពីជីដូនជីតារបស់ពួកគេមក ហើយដែលពួកគេកំពុងរស់នៅលើសព្វថ្ងៃនេះ រដ្ឋគួរទទួលស្គាល់ និងការពារសិទ្ធិទាំងនេះ។ ជនជាតិដើមភាគតិច និងសហគមន៍ដទៃទៀត ដែលប្រើប្រាស់ប្រព័ន្ធសិទ្ធិកាន់កាប់បែបទំនៀមទម្លាប់ មិនគួរត្រូវបានគេបណ្តេញចេញដោយបង្ខំពីដី ដែលបន្សល់ពីជីដូនជីតារបស់ពួកគេឡើយ។*

**(៩.៥ នៅក្នុង *ជនជាតិដើមភាគតិច និងសហគមន៍ដទៃទៀតដែលប្រើប្រាស់ ប្រព័ន្ធសិទ្ធិកាន់កាប់បែបទំនៀមទម្លាប់*)**

សិទ្ធិកាន់កាប់ធនធាននេសាទ អាចទទួលបានការទទួលស្គាល់ផ្លូវការ និងស្របច្បាប់ ដូចគ្នានឹងសិទ្ធិ ដែលរៀបរាប់ខាងលើ នៅក្នុងបរិបទនៃការគ្រប់គ្រងធនធាននេសាទ ដោយយកសិទ្ធិធ្វើជាមូលដ្ឋាន ឬការទទួលស្គាល់ក្រៅផ្លូវការ និងបែបទំនៀមទម្លាប់ (ឬបែបប្រពៃណី)។ សិទ្ធិកាន់កាប់បែបទំនៀមទម្លាប់របស់សហគមន៍មួយ រួមមាន សិទ្ធិសមូហភាពរបស់សមាជិកសហគមន៍ក្នុងការប្រើប្រាស់ធនធានធម្មជាតិរួម និងសិទ្ធិឯកជនរបស់សមាជិកសហគមន៍ ក្នុងការទទួលបានចំណែកដីធ្លី ឬធនធានធម្មជាតិជាក់លាក់។ សិទ្ធិកាន់កាប់ក្រៅផ្លូវការ គឺជាសិទ្ធិកាន់កាប់ ដែលខ្វះការការពារផ្លូវការពីរដ្ឋ។ ជារឿយៗ សិទ្ធិទាំងនេះកើតមានព្រមគ្នា ដូចជា ការលេចឡើងនូវសិទ្ធិកាន់កាប់ក្រៅផ្លូវការ នៅតាមតំបន់នានា ដែលកើតឡើងដោយសារតែការធ្វើចំណាកស្រុក (ប្រអប់ទី ៨)។ សិទ្ធទាំងនេះអាចនៅតែស្របច្បាប់ ដោយសារតែសិទ្ធិទាំងនេះត្រូវបានលើកឡើង ដោយច្បាប់ និងអនុសញ្ញាអន្តរជាតិ ឬលិខិតុបករណ៍ច្បាប់ដទៃទៀត បើទោះបីជាមិនមានចែងច្បាស់ នៅក្នុងច្បាប់ជាតិស្តីពីសិទ្ធិកាន់កាប់ក៏ដោយ។

**ប្រអប់ទី ៨ ៖ អ្នកនេសាទ និងកម្មករនេសាទចំណាកស្រុក និងសិទ្ធិក្រៅផ្លូវការ**

នៅក្នុងប្រវត្តិសាស្ត្រកន្លងមក ចំណាកស្រុក គឺជាយុទ្ធសាស្ត្រប្រកបរបរចិញ្ចឹមជីវិតធម្មតា របស់សហគមន៍នេសាទនៅអាហ្វ្រិច ក៏ដូចជានៅតាមតំបន់ដទៃទៀត។ នៅតំបន់អាហ្វ្រិចភាគខាងលិច និងភាគកណ្តាល ប្រទេសនៅតាមតំបន់ឆ្នេរ

អនុញ្ញាតឱ្យសហគមន៍នេសាទចំណាកស្រុកពីប្រទេសជិតខាងចូលមក ដោយពុំមានការកំហិត ហើយការបើកចំហឱ្យមានការនេសាទបែបនេះ នាំឱ្យមានការកើនឡើងនូវចំនួនជនចំណាកស្រុក ដែលចូលមកនេសាទក្នុងតំបន់ទាំងនេះ។ ចំណាកស្រុកបានបង្កើតឱ្យមាននូវសិទ្ធិកាន់កាប់តំបន់នេសាទក្រៅផ្លូវការ។ ជារឿយៗ សិទ្ធិទាំងនេះ គឺជាផ្នែកមួយនៃប្រព័ន្ធគ្រប់គ្រងបែបទំនៀមទម្លាប់។ នៅប្រទេសបេនីន កាម៉េរូន និងហ្គាបុន ការសិក្សាមួយដែលធ្វើឡើងដោយកម្មវិធីប្រកបរបរនេសាទចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព (SFLP) បានរកឃើញនូវភស្តុតាងបង្ហាញថា ជនចំណាកស្រុក ដែលទើបមកដល់ថ្មី នឹងត្រូវគេណែនាំឱ្យស្គាល់ប្រធាន ឬមេភូមិ សម្រាប់បង់ប្រាក់ស្នួយសារ។ ប្រសិនបើជនចំណាកស្រុកមិនគោរពតាមនីតិវិធីនេះទេ នោះវិវាទនឹងកើតមានឡើងជាមិនខាន។

ជារឿយៗ ជនចំណាកស្រុកមានបញ្ហាច្រើន ក្នុងការទទួលបានសិទ្ធិកាន់កាប់ដីធ្លី សម្រាប់ប្រកបរបរកសិកម្ម ដែលការកាន់កាប់ដីធ្លីនេះ គឺជាផ្នែកធម្មតាមួយរបស់យុទ្ធសាស្ត្រប្រកបរបរចិញ្ចឹមជីវិត ដែលមានភាពស្មុគស្មាញរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេសាទ។ លើសពីនេះ ជនចំណាកស្រុកទាំងនេះ ក៏ដូចជាសហគមន៍នេសាទក្នុងមូលដ្ឋាន ដែលពុំមានសិទ្ធិកាន់កាប់ដែលមានការទទួលស្គាល់ជាផ្លូវការ - អាចមានអារម្មណ៍ថាខ្លួនទទួលបានការគំរាមកំហែង ដោយសារតែគំនិតផ្ដួចផ្ដើមអភិវឌ្ឍន៍តំបន់ឆ្នេរ និងប្រឈមនឹងការបណ្ដេញចោល។

*ប្រភព ៖* Njock and Westlund (2010)

ជាទូទៅ សិទ្ធិក្រៅផ្លូវការ និងបែបទំនៀមទម្លាប់ បំពេញតួនាទីសំខាន់បំផុត ជាពិសេស នៅក្នុងវិស័យនេសាទខ្នាតតូច និងនៅតាមប្រទេសកំពុងអភិវឌ្ឍ។ លើសពីនេះ ប្រព័ន្ធសិទ្ធិកាន់កាប់ជាច្រើន មានមូលដ្ឋានលើសិទ្ធិ ដែលកាលពីដំបូង មានលក្ខណៈជាទំនៀមទម្លាប់។ នៅតាមប្រទេសមួយចំនួន សិទ្ធិកាន់កាប់បែបទំនៀមទម្លាប់ ទទួលបានការទទួលស្គាល់ផ្លូវការស្របច្បាប់ ស្មើនឹងសិទ្ធិកាន់កាប់ ដែលតម្រូវដោយច្បាប់ដទៃទៀតដែរ។ នៅប្រទេសដទៃទៀត សិទ្ធិទាំងនេះខ្វះការទទួលស្គាល់តាមផ្លូវច្បាប់។ នេះមានន័យថា មានករណីដែល ដែលមានសិទ្ធិបែបទំនៀមទម្លាប់ស្របច្បាប់ ប៉ុន្តែសិទ្ធិទាំងនេះមិនត្រូវបានគេទទួលស្គាល់ជាផ្លូវការ អ្នកមានសិទ្ធិទាំងនេះមិនអាចការពារសិទ្ធិទាំងនេះដោយងាយស្រួលបាន នៅក្នុងករណីដែលមានការប្រកួតប្រជែងពីអ្នកប្រើប្រាស់ធនធានដទៃទៀត។ គម្រោងពង្រីកតំបន់ទេសចរណ៍ កំពង់ផែ ឬហេដ្ឋារចនាសម្ព័ន្ធកំពង់ផែ និងភាពរីកចម្រើនផ្នែកឧស្សាហកម្ម នាំឱ្យមានការទាមទារពីក្រុម និងអ្នកប្រើប្រាស់ធនធានដទៃទៀតលើដីធ្លី នៅ

តំបន់ឆ្នេរ ដែលកន្លងមកជារបស់សហគមន៍នេសាទ។ ការបណ្តេញសហគមន៍តំបន់ឆ្នេរចេញដោយបង្ខំ សម្រាប់គោលបំណងនៃការអភិវឌ្ឍទាំងនេះ កំពុងមានការកើនឡើង (Monslave Suárez, Marques Osorio and Langford, 2009)។ ក៏មានឧទាហរណ៍ផងដែរ ដែលបង្ហាញពីការរៀបចំសិទ្ធិកាន់កាប់ផ្លូវការ ដែលត្រូវបានបង្កើតឡើង ដោយមិនមានការគោរពសិទ្ធិ ទំនៀមទម្លាប់ និងប្រពៃណី ដែលមានរួចទៅហើយ ហើយទង្វើបែបនេះបាននាំឱ្យមានការកើនឡើងនូវជម្លោះ និងការលំបាក សម្រាប់សហគមន៍ នៅតាមតំបន់ឆ្នេរ។ ឧទាហរណ៍មួយ គឺកំណែទម្រង់ច្បាប់ក្រោយរបបអាផាថេត នៅអាហ្វ្រិចខាងត្បូង ដែលខកខានមិនបានបំពេញសិទ្ធិបែបទំនៀមទម្លាប់របស់សហគមន៍ ដែលប្រកបរបរនេសាទជាប្រពៃណីកន្លងមក (សូមមើលប្រអប់ទី ៩)។

**ប្រអប់ទី ៩ ៖ ការបំពេញសិទ្ធិបែបទំនៀមទម្លាប់ នៅអាហ្វ្រិចខាងត្បូង**

នៅអាហ្វ្រិចខាងត្បូង មានប្រព័ន្ធសិទ្ធិកាន់កាប់បែបទំនៀមទម្លាប់ នៅតាមសហគមន៍ ជាច្រើនប្រភេទ រាប់សតវត្សរ៍មកហើយ។ ប្រព័ន្ធទាំងនេះមានលក្ខណៈផ្សេងគ្នាពីតំបន់មួយ ទៅតំបន់មួយទៀត ទៅតាមការការវិវឌ្ឍនៃប្រវត្តិសាស្រ្ត និងរបៀបរបបដែលប្រព័ន្ធច្បាប់បែបទំនៀមទម្លាប់របស់តំបន់ទាំងនេះ មានទំនាក់ទំនងជាមួយនឹងអភិបាលកិច្ចរបស់អាណានិគម និងរបបអាផាថេត។ ក្រោយពីការបោះឆ្នោតជ្រើសរើសរដ្ឋាភិបាលប្រជាធិបតេយ្យ នៅក្នុងឆ្នាំ ១៩៩៤ មក មានសេចក្តីសង្ឃឹមថា កំណែទម្រង់ច្បាប់របស់រដ្ឋថ្មីនេះ នឹងនាំឱ្យមានការគ្រប់គ្រងធនធានសមុទ្រ កាន់តែសមស្របសម្រាប់សហគមន៍នេសាទតូចតូច។ រដ្ឋធម្មនុញ្ញថ្មីរបស់អាហ្វ្រិចខាងត្បូង ទទួលស្គាល់ច្បាប់បែបទំនៀមទម្លាប់កន្លងមក ដោយសារតែច្បាប់ទាំងនេះមានសង្គតភាពជាមួយនឹងសេចក្តីព្រាងច្បាប់អំពីសិទ្ធិ។

ប៉ុន្តែ ច្បាប់ស្តីពីធនធានសមុទ្ទ ដែលត្រូវបានដាក់ឱ្យអនុវត្ត នៅក្នុងឆ្នាំ ១៩៩៨ ខកខានមិនបានទទួលស្គាល់វិស័យសិប្បកម្មខ្នាតតូច និងប្រព័ន្ធ និងសិទ្ធិនេសាទបែបទំនៀមទម្លាប់ឡើយ។ ផ្ទុយទៅវិញ ប្រព័ន្ធផ្តល់ការអនុញ្ញាតមួយ ត្រូវបានដាក់ឱ្យអនុវត្តសម្រាប់វិស័យចិញ្ចឹមជីវិត ដែលទើបទទួលបានការទទួលស្គាល់ថ្មីមួយ ដែលផ្តោតជាចម្បងលើប្រភេទសត្វនៅមួយកន្លែងដែលមានតម្លៃទាប។ នៅតំបន់ឆ្នេរភាគខាងលិច និងភាគខាងជើង ដែលជាទីតាំងរបស់ក្រុមហ៊ុនឧស្សាហកម្មធំៗ រដ្ឋបានផ្តល់សិទ្ធិពាណិជ្ជកម្ម រយៈពេល ៤ ឆ្នាំ ដល់បុគ្គលមួយចំនួន និងសមាគមដែលបានចុះបញ្ជិកា ប្រកបរបរតូចតាច តាមតំបន់ឆ្នេរ។ សិទ្ធិទាំងនេះត្រូវបានគេហៅថា “ពាណិជ្ជកម្មមានកម្រិត” និងរួមមានការបែងចែកសិទ្ធិតិចតួចបំផុត ដែលគេមិនគិតថាចំណេញសម្រាប់សហគ្រាសខ្នាតតូច។ ដំណើរការដាក់ពាក្យសុំសិទ្ធិទាំងនេះ មានលក្ខណៈស្មុគស្មាញខ្លាំង និងមានការ

រើសអើងចំពោះអ្នកនេសាទ ដែលចេះអក្សរតិចតួច។ លើសពីនេះ ដំណើរការធ្វើការផ្ទៀងផ្ទាត់ មិនត្រូវបានអ្នកនេសាទចាត់ទុកថាមានភាពសមស្របនោះឡើយ ហើយដំណើរការតវ៉ាទៀតសោត មានលក្ខណៈស្មុគស្មាញ និងត្រូវចំណាយអស់ច្រើន។ ដូច្នេះ អ្នកនេសាទតូចតាចជាច្រើន ដែលប្រកបរបរនេះជាប្រពៃណី ត្រូវបានផាត់ចេញមិនឱ្យទទួលបានធនធាន ឬប្រើប្រាស់តំបន់ ដែលពួកគេចាត់ទុកថាជាតំបន់នេសាទតាមប្រពៃណីរបស់ពួកគេ។ នៅក្នុងឆ្នាំ ២០០៦ ក្រសួងកិច្ចការបរិស្ថាន និងទេសចរណ៍ បានផ្តល់នូវសិទ្ធិពាណិជ្ជកម្មជាលក្ខណៈបុគ្គល ដោយមិនបានគិតគូរពីបរិបទសហគមន៍ នៅក្នុងការសម្រេចចិត្តរបស់ខ្លួនឡើយ។ ជាការឆ្លើយតបចំពោះការខកខានរបស់គោលនយោបាយថ្មីនេះ ក្នុងការបំពេញសិទ្ធិរបស់ពួកគេ អ្នកនេសាទមកពីតំបន់ Cape ភាគខាងលិច និងភាគខាងជើង បានចាប់ផ្តើមធ្វើសកម្មភាពតស៊ូមតិជាច្រើន ដើម្បីបង្កើនការយល់ដឹងអំពីការលំបាករបស់ពួកគេ និងជម្រុញឱ្យមានគោលនយោបាយ ដែលកាន់តែមានសមធម៌ជាងមុន។ ចុងក្រោយ នៅក្នុងឆ្នាំ ២០១២ គោលនយោបាយស្តីពីការធ្វើនេសាទក្នុងទ្រង់ទ្រាយតូចថ្មីមួយ ត្រូវបានអនុម័ត ដោយបានផ្តល់ការទទួលស្គាល់ជាផ្លូវការដល់សហគមន៍នេសាទជាលក្ខណៈសិប្បកម្ម។ គោលនយោបាយនេះមានគោលបំណង "ផ្តល់នូវដំណោះស្រាយ និងការទទួលស្គាល់សិទ្ធិរបស់សហគមន៍អ្នកនេសាទខ្នាតតូច នៅអាហ្វ្រិចខាងត្បូង ដើម្បីបំពេញទៅតាមការសន្យាផ្តល់សមភាពពេញលេញ ដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ" (DAFF, 2012)។ គោលនយោបាយនេះទទួលស្គាល់សិទ្ធិបែបទំនៀមទម្លាប់ និងផ្តល់លទ្ធភាពឱ្យមានការទទួលបានសិទ្ធិនេសាទជាសមូហភាព (និងលែងប្រើប្រាស់ប្រព័ន្ធកូតាបុគ្គល ដែលផាត់មនុស្សភាគច្រើនចេញ) និងលើកកម្ពស់ការគ្រប់គ្រងធនធានសមុទ្ររួមគ្នា។ គោលនយោបាយនេះក៏ជាមូលដ្ឋានសម្រាប់ធ្វើការកំណត់ព្រំប្រទល់តំបន់នេសាទផ្តាច់មុខសម្រាប់អ្នកនេសាទតូចតាចផងដែរ ដែលស្ថិតនៅខាងក្រៅព្រំប្រទល់សម្រាប់ក្រុមហ៊ុននេសាទជាលក្ខណៈពាណិជ្ជកម្មធំ។

*ប្រភព ៖* DAFF (2012); Masifundise (2012); Sunde *et al.* (forthcoming).

## តើមានអ្វីខ្លះកើតមានឡើង ចំពោះធនធាននេសាទរួម និងធនធាននេសាទ នៅក្នុងដែនទឹកអន្តរជាតិ?

**ពាក់ព័ន្ធជាមួយនឹងការប្តេជ្ញាចិត្តនៅថ្នាក់តំបន់ និងអន្តរជាតិ VGGT បញ្ជាក់ថា ៖**

*រដ្ឋគួរធានាថា រាល់សកម្មភាពទាំងអស់ ពាក់ព័ន្ធជាមួយនឹងការទទួលស្គាល់តាមផ្លូវច្បាប់ និងការបែងចែកសិទ្ធិកាន់*

*កាប់ និងភារកិច្ចនានា ធ្វើឡើងស្របជាមួយនឹងកាតព្វកិច្ច ដែលមានស្រាប់របស់ពួកគេ នៅក្រោមច្បាប់ជាតិ និងអន្តរជាតិ និងស្របទៅតាមការប្តេជ្ញាចិត្តស្ម័គ្រចិត្ត ក្រោមលិខិតុបករណ៍ថ្នាក់តំបន់ និងអន្តរជាតិ ដែលមានជាធរមាន។*

**(៧.២ នៅក្នុង *ការការពារ* )**

នៅក្នុងទឹកអន្តរជាតិ ពោលគឺ នៅតាមតំបន់ហួសពីយុត្តាធិការជាតិ (ABNJ) សិទ្ធិចំពោះធនធាន និងការទទួលខុសត្រូវលើការគ្រប់គ្រង ច្រើនតែមិនមានភាពច្បាស់លាស់។ ដែនទឹកទាំងនេះ ស្ថិតនៅមិនឆ្ងាយប៉ុន្មានពីតំបន់ឆ្នេរ ហើយជាទូទៅត្រូវបានប្រើប្រាស់ ដោយក្រុមហ៊ុននេសាទធំៗ ដែលពេលខ្លះប្រើប្រាស់នាវាមកពីកន្លែងឆ្ងាយ។ នៅតាមតំបន់ជាច្រើនប្រទេស ដែលចាប់អារម្មណ៍ចំពោះការនេសាទក្នុងតំបន់នេះ បានប្រមូលផ្តុំគ្នាបង្កើតជាអង្គភាពនេសាទថ្នាក់តំបន់ (RFB) ឬស្ថាប័ន/ការរៀបចំគ្រប់គ្រងនេសាទថ្នាក់តំបន់ (RFMO/A)។[14] ការអភិវឌ្ឍបែបនេះបានទទួលការគាំទ្រយ៉ាងច្រើន តាមរយៈកិច្ចព្រមព្រៀងសហប្រជាជាតិស្តីពីការអនុវត្តបញ្ញត្តិរបស់អនុសញ្ញាសហប្រជាជាតិស្តីពីច្បាប់សមុទ្ទ ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៨២ ពាក់ព័ន្ធនឹងការអភិរក្ស និងការគ្រប់គ្រងពូជត្រីដែលផ្លាស់ទីពីតំបន់មួយទៅតំបន់មួយទៀត និងពូជត្រីដែល ផ្លាស់ទីក្នុងកម្រិតខ្ពស់ (កិច្ចព្រមព្រៀងស្តីពីពូជត្រីរបស់សហប្រជាជាតិ ឆ្នាំ ១៩៩៥)។ អង្គភាពនេសាទថ្នាក់តំបន់ មានអណត្តិគ្រប់គ្រងរបស់ខ្លួនផ្សេងៗគ្នា ប៉ុន្តែជាទូទៅ នៅមានភាពចាំបាច់ ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការថ្នាក់តំបន់ និងអន្តរជាតិ ប្រសិនបើគេចង់ឱ្យមានការប្រើប្រាស់ធនធានប្រកបដោយនិរន្តរភាព។

មានដែនទឹក និងធនធាន ដែលចែករំលែកដោយប្រទេសចាប់ពី ២ ឡើងទៅ។ វាមិនមែនជារឿងខុសធម្មតានោះទេ ដែលមានពពួកត្រីធ្វើដំណើរឆ្លងដែនពីតំបន់ EEZs មួយទៅ តំបន់ EEZs មួយទៀត និងនៅក្នុងដែនទឹកអន្តរជាតិ។ ពូជត្រីមួយចំនួន ផ្លាស់ទីក្នុងកម្រិតខ្ពស់ ហើយជាទូទៅ ត្រីមិនគោរពព្រំដែននោះទេ។ នៅក្នុងករណីមួយចំនួន ស្ថាប័ន/ការរៀបចំគ្រប់គ្រងនេសាទថ្នាក់តំបន់ (RFMO/A) ក៏ត្រូវបានបង្កើតឡើង នៅក្នុងស្ថានភាពទាំងនេះផងដែរ (ដូចជា គណៈកម្មការនេសាទបាល់ទិចអន្តរជាតិ ជាដើម)។ លើសពីនេះកិច្ចសហប្រតិបត្តិការក្នុងទម្រង់ផ្សេងទៀត សម្រាប់គោលបំណងគ្រប់គ្រងក៏មានផងដែរ ដូចជា កិច្ចពិគ្រោះយោបល់ជាទៀងទាត់រវាងប្រទេស និងប្រទេស, កម្មវិធីរួម ដែលផ្តោតលើផ្នែកជាក់លាក់នៃការគ្រប់គ្រងធនធាននេសាទ (ឧ. ការអង្កេតឃ្លាំមើល) ឬកិច្ចព្រមព្រៀងសហប្រតិបត្តិការទូទៅ ជាដើម។ បឹង និងអាងទន្លេ

---

[14] សូមមើល www.fao.org/fishery/rfb/search/en

ធំៗមួយចំនួន នៅអាហ្វ្រិច ស្ថិតក្រោមការទទួលខុសត្រូវរបស់គណៈកម្មការអាងទន្លេ (ដូចជា គណៈកម្មការអាងបឹង Chad គណៈកម្មការអាងបឹង Victoria និងគណៈកម្មការអន្លង់ទន្លេនីហ្សេ ជាដើម)។ ជាធម្មតា គណៈកម្មការទាំងនេះមានអណត្តិការងារទូលំទូលាយលើសពីការងារនេសាទទៅទៀត ហើយនៅតាមទីតាំងមួយចំនួន ក៏មានជារចនាសម្ព័ន្ធស្ថាប័នផងដែរ ជាពិសេស សម្រាប់កិច្ចសហប្រតិបត្តិការក្នុងវិស័យនេសាទ (ឧ. អង្គការគ្រប់គ្រងការងារនេសាទក្នុងបឹង Victoria ជាដើម)។ ការគ្រប់គ្រងធនធានឆ្លងដែន នៅតាមដែនទឹកក្នុងតំបន់ឆ្នេរ និងទឹកសាប គឺជាការងារ ដែលពាក់ព័ន្ធផ្ទាល់ជាមួយនឹងការងារនេសាទក្នុងទ្រង់ទ្រាយតូច ជាពិសេស ដោយសារតែការធ្វើចំណាកស្រុក គឺជាយុទ្ធសាស្ត្រចិញ្ចឹមជីវិតពេញនិយមរបស់សហគមន៍នេសាទជាច្រើន។

គំនិតផ្តួចផ្តើមដទៃទៀត ដែលមានគោលបំណងលើកកម្ពស់កិច្ចសហប្រតិបត្តិការឆ្លងដែន និងប្រើប្រាស់អភិក្រមថ្នាក់តំបន់ សម្រាប់គ្រប់គ្រងធនធានធម្មជាតិ រួមមាន គំនិតផ្តួចផ្តើមប្រព័ន្ធអេកូឡូហ្ស៊ីសមុទ្រក្នុងទ្រង់ទ្រាយធំ[15] ដែលដឹកនាំដោយរដ្ឋបាលសមុទ្រ និងបរិយាកាសជាតិ (NOAA) របស់សហរដ្ឋអាមេរិច និងគម្រោងគាំទ្រនានា ដែលទទួលបានថវិកាពីកម្មវិធីបរិស្ថានសកល (GEF) និងកម្មវិធីសមុទ្ទតំបន់របស់កម្មវិធីបរិស្ថានសហប្រជាជាតិ (UNEP)។ អភិក្រមអន្តរវិស័យមួយទៀត គឺ “អភិក្រមតំបន់ទេសភាព” ដែលអនុវត្តដោយអង្គការ WWF ដូចជា នៅក្នុងអាងទន្លេកុងហ្គោ ជាដើម។[16]

## តើមានក្របខ័ណ្ឌច្បាប់ និងគោលនយោបាយអន្តរជាតិ ពាក់ព័ន្ធជាមួយនឹងអភិបាលកិច្ចលើសិទ្ធិកាន់កាប់ធនធាននេសាទ ដែរឬទេ?

**VGGT លើកឡើងពីក្របខ័ណ្ឌច្បាប់ដទៃទៀត និងលើកឡើងថា ៖**

*VGGT គួរបកស្រាយ និងអនុវត្តឱ្យស្របតាមកាតព្វកិច្ច ដែលមានស្រាប់ នៅក្រោមច្បាប់ជាតិ និងអន្តរជាតិ និងស្របតាមការសន្យាស្ម័គ្រចិត្ត ក្រោមលិខិតុបករណ៍ថ្នាក់តំបន់ និងអន្តរជាតិ ដែលមានជាធរមាន។ សេចក្តីណែនាំទាំងនេះបំពេញបន្ថែម និងផ្តល់ការគាំទ្រដល់គំនិតផ្តួចផ្តើមនៅថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិនានា ដែលផ្តោតលើសិទ្ធិមនុស្ស*

15 សូមមើល www.lme.noaa.gov

16 wwf.panda.org/what_we_do/where_we_work/congo_basin_forests/wwf_solutions

*និងផ្តល់នូវសិទ្ធិកាន់កាប់ដីធ្លី ធនធាននេសាទ និងធនធានព្រៃឈើជាប់លាប់ជាងមុន និងជល់គំនិតផ្តួចផ្តើម ដើម្បីលើកកម្ពស់អភិបាលកិច្ច។ ពុំមានចំណុចណាមួយ នៅក្នុង VGGT ទាំងនេះ គួរយកទៅបកស្រាយថាដាក់កំហិត ឬធ្វើឱ្យប៉ះពាល់ដល់កាតព្វកិច្ចផ្លូវច្បាប់ ដែលរដ្ឋត្រូវបំពេញ ក្រោមច្បាប់អន្តរជាតិនោះទេ។*

**(២.២ នៅក្នុង *លក្ខណៈ និងវិសាលភាព*)**

បន្ថែមពីលើ VGGT រដ្ឋនានាបានប្តេជ្ញាចិត្តធានាឱ្យមានការអភិវឌ្ឍប្រកបដោយសមធម៌ និងនិរន្តរភាព ផ្តល់នូវមុខរបរចិញ្ចឹមជីវិតជាប់លាប់ ធានានូវការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយការទទួលខុសត្រូវ និងការពារបរិស្ថាន - ក៏ដូចជាការគោរព ការពារ និងសម្រេចឱ្យបាននូវសិទ្ធិមនុស្ស តាមរយៈលិខិតុបករណ៍ និងកិច្ចព្រមព្រៀងអន្តរជាតិជាច្រើន (សូមមើលប្រអប់ ១០)។ លិខិតុបករណ៍ទាំងនេះមានភាពពាក់ព័ន្ធក្នុងកម្រិតខ្ពស់ នៅក្នុងបរិបទអភិបាលកិច្ចលើសិទ្ធិកាន់កាប់នៅក្នុងវិស័យនេសាទ។

**ប្រអប់ទី ១០ ៖ លិខិតុបករណ៍អន្តរជាតិមួយចំនួន**

- សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស
- សេចក្តីណែនាំស្ម័គ្រចិត្តស្តីពីការសម្រេចឱ្យបានជាបន្តបន្ទាប់នូវសិទ្ធិទទួលបានស្បៀងគ្រប់គ្រាន់ នៅក្នុងបរិបទសន្តិសុខស្បៀងរបស់ជាតិ (សេចក្តីណែនាំអំពីសិទ្ធិទទួលបានស្បៀង)
- កតិកាសញ្ញាអន្តរជាតិអំពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ (កតិកាសញ្ញា ESCR)
- សេចក្តីប្រកាសរបស់សហប្រជាជាតិស្តីពីសិទ្ធិរបស់ជនជាតិដើមភាគតិច (សេចក្តីប្រកាសស្តីពីជនជាតិដើមភាគតិច)
- អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងចំពោះស្ត្រី (CEDAW)
- អនុសញ្ញាស្តីពីសិទ្ធិកុមារ
- កិច្ចប្រជុំកំពូលរបស់ពិភពលោកអំពីការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងផែនការសកម្មភាពទីក្រុង Johannesburg
- អនុសញ្ញាស្តីពីជីវចម្រុះ (CBD)
- ឯកសារលទ្ធផល ដែលអនុម័តនៅក្នុងកិច្ចប្រជុំ RIO+២០ ៖ អនាគតដែលយើងចង់បាន

ពាក់ព័ន្ធជាមួយនឹងសកម្មភាពនេសាទ មានលិខិតុបករណ៍អន្តរជាតិជាច្រើន រាប់បញ្ចូលទាំង កិច្ចព្រមព្រៀងចង កាតព្វកិច្ច ដែលធ្វើនិយ័តកម្មលើការគ្រប់គ្រងធនធានសោទ ដូចជា អនុសញ្ញាសហប្រជាជាតិស្តីពីច្បាប់សមុទ្រ ឆ្នាំ ១៩៨២ និងកិច្ចព្រមព្រៀងរបស់សហប្រជាជាតិស្តីពីពូជត្រី ឆ្នាំ ១៩៩៥ ជាដើម។ ក្រមសីលធម៌របស់ FAO ស្តីពីការធ្វើនេសាទប្រកប ដោយការទទួលខុសត្រូវ (ក្រមសីលធម៌) គឺជាលិខិតុបករណ៍នេសាទស្ម័គ្រចិត្តជាមូលដ្ឋានមួយ ដែលជម្រុញលើកកម្ពស់ការ ធ្វើនេសាទប្រកបដោយនិរន្តរភាព។ ផែនការសកម្មភាពអន្តរជាតិ ត្រូវបានរៀបចំឡើង ក្រោមក្រមសីលធម៌នេះ ដូចជា ក្រមសីលធម៌ សម្រាប់ការនេសាទខុសច្បាប់ ពុំមានការរាយការណ៍ និងពុំមានច្បាប់ទម្លាប់គ្រប់គ្រងត្រឹមត្រូវ និងការគ្រប់ គ្រងសមត្ថភាពនេសាទ។ ក្រមសីលធម៌នេះក៏ទទួលបានការគាំទ្រពីសេចក្តីណែនាំបច្ចេកទេសជាច្រើន ដែលផ្តល់ការណែនាំ អំពីការអនុវត្តសម្រាប់បញ្ហាសំខាន់ៗផងដែរ។

ការកាន់កាប់ តាមរយៈសិទ្ធិប្រើប្រាស់ សម្រាប់អ្នកនេសាទតូចតាច ត្រូវបានលើកឡើងនៅក្នុងក្រមសីលធម៌នេះ ៖ “នៅពេលរៀបចំវិធានការគ្រប់គ្រង គេគួរពិចារណាលើសិទ្ធិទាំងឡាយ ដែលផ្តល់លទ្ធភាពផ្តាច់មុខ ឬជាអាទិភាព ដល់ការ ប្រកបរបរនេសាទតូចតាច។ ឧទាហរណ៍ ការកំណត់តំបន់ អាចផ្តល់អាទិភាព និងការពារដល់ការទទួលបានធនធានរបស់ អ្នកនេសាទតូចតាច ដែលពួកគេភាគច្រើន ជាប្រជាជនក្រីក្របំផុត” (មាត្រា ៦.១៨)។ លើសពីនេះ ក្រមសីលធម៌នេះលើក ឡើងថា មិនត្រឹមតែសម្រាប់វិស័យនេសាទប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងពាក់ព័ន្ធជាមួយនឹងធនធានតាមតំបន់ឆ្នេរជាទូទៅផង ដែល “រដ្ឋគួរបង្កើតនូវក្របខ័ណ្ឌស្ថាប័ន និងច្បាប់សមស្រប ដើម្បីកំណត់ពីការប្រើប្រាស់ធនធានតំបន់ឆ្នេរដែលអាចមាន និង គ្រប់គ្រងលើធនធានទាំងនេះ ដោយពិចារណាពីសិទ្ធិរបស់សហគមន៍នេសាទ តាមតំបន់ឆ្នេរ” (មាត្រា ១០.១.៣)។

ក្រមសីលធម៌នេះក៏លើកឡើងផងដែរពីភាពចាំបាច់ ដើម្បីឱ្យរដ្ឋធានាយ៉ាងណាឱ្យមានក្របខ័ណ្ឌគោលនយោបាយ ច្បាប់ និងស្ថាប័នសមស្រប ដើម្បីសម្រេចឱ្យបាននូវការ “ការប្រើប្រាស់ធនធានប្រកបដោយនិរន្តរភាព និងសមាហរណកម្ម ដោយធ្វើការពិចារណាលើភាពផុយស្រួយនៃប្រព័ន្ធអេកូឡូហ្ស៊ីតំបន់ឆ្នេរ និងភាពកម្រិតនៃធនធានធម្មជាតិ ក៏ដូចជាលើ តម្រូវការរបស់សហគមន៍តំបន់ឆ្នេរ” (មាត្រា ១០.១.១)។ ចំណុចនេះត្រូវបានលើកឡើង នៅក្នុងបរិបទនៃការគ្រប់គ្រង តំបន់ឆ្នេរ ហើយកាន់តែមានការទទួលស្គាល់ខ្លាំងឡើងលើភាពចាំបាច់ ដើម្បីប្រើប្រាស់អភិក្រមក្តោបរួម សម្រាប់ការគ្រប់គ្រង និងអភិវឌ្ឍធនធាននេសាទ។ ដូចដែលពន្យល់ នៅក្នុងប្រអប់ទី ៤ EFA ផ្តោតសំខាន់លើការគ្រប់គ្រងធនធាននេសាទ ប៉ុន្តែក៏

បានពង្រីកទស្សនវិស័យឱ្យមានលក្ខណៈទូលាយ ក្តោបរួម មានលក្ខណៈសមាហរណកម្ម និងចូលរួម ផ្អែកទៅតាមទស្សនវិជ្ជា និងគុណតម្លៃ ដែលលើកឡើងក្នុងក្រមសីលធម៌នេះ។

ពាក់ព័ន្ធជាមួយនឹងការងារនេសាទខ្នាតតូច សារៈសំខាន់នៃវបរនេសាទទាំងនេះចំពោះសន្តិសុខស្បៀង និង អាហារូបត្ថម្ភ ការលុបបំបាត់ភាពក្រីក្រ ការអភិវឌ្ឍប្រកបដោយសមធម៌ និងការប្រើប្រាស់ប្រើប្រាស់ធនធានប្រកបដោយនិរន្តរភាព កាន់តែទទួលបានការទទួលស្គាល់ច្រើនជាងមុន។ នៅក្នុងកិច្ចប្រជុំលើកទី ២៩ របស់គណៈកម្មាធិការនេសាទរបស់ FAO (COFI) នៅក្នុងឆ្នាំ ២០១១ មានការផ្តល់ជាអនុសាសន៍ថា គួរមានការបង្កើតនូវលិខិតុបករណ៍អន្តរជាតិថ្មីមួយ សម្រាប់ធានានិរន្តរភាពការងារនេសាទខ្នាតតូច ដើម្បីបំពេញបន្ថែមលើក្រមសីលធម៌នេះ។ លិខិតុបករណ៍នេះនឹងមានទម្រង់ជាសេចក្តីណែនាំអន្តរជាតិ ហើយបច្ចុប្បន្ននេះ (២០១២) កំពុងត្រូវបានបង្កើតឡើង។[17]

## តើគេអាចកំណត់តម្លៃរបស់សិទ្ធិកាន់កាប់ ដោយរបៀបណា?

**ពាក់ព័ន្ធជាមួយនឹងតម្លៃ និងការកំណត់ពីតម្លៃរបស់សិទ្ធិកាន់កាប់ VGGT លើកឡើងថា ៖**

*រដ្ឋគួរធានាថា ប្រព័ន្ធសមស្របនានាត្រូវបានប្រើប្រាស់ សម្រាប់កំណត់ពីតម្លៃរបស់សិទ្ធិកាន់កាប់ដោយយុត្តិធម៌ និងទាន់ពេលវេលា សម្រាប់គោលបំណងជាក់លាក់ ដូចជា សម្រាប់ដំណើរការទីផ្សារ ការធានាសម្រាប់កម្ចី ប្រតិបត្តិការសិទ្ធិកាន់កាប់ ដោយសារការវិនិយោគ អស្សាមិករណ៍ និងការយកពន្ធ។ ប្រព័ន្ធទាំងនេះគួរជម្រុញលើកកម្ពស់គោលដៅនៃការអភិវឌ្ឍ ប្រកបដោយនិរន្តរភាព និងគោលដៅទូលំទូលាយផ្នែកសង្គម សេដ្ឋកិច្ច និងបរិស្ថាន។ រដ្ឋគួរសម្រួលដល់ប្រតិបត្តិការទីផ្សារឱ្យមានប្រសិទ្ធភាព និងតម្លាភាព ដើម្បីជម្រុញឱ្យមានការចូលរួម នៅក្រោមលក្ខខណ្ឌ និងឱកាសស្មើគ្នា សម្រាប់ការផ្ទេរសិទ្ធិកាន់កាប់ ដែលផ្តល់ប្រយោជន៍ដល់គ្នាទៅវិញទៅមក ដែលកាត់បន្ថយនូវវិវាទ និងអស្ថិរភាព លើកកម្ពស់ការប្រើប្រាស់ដីធ្លី ធនធាននេសាទ និងធនធានព្រៃឈើប្រកបដោយនិរន្តរភាព និងការអភិរក្សបរិស្ថាន, លើកកម្ពស់ការប្រើប្រាស់ធនធានហិរញ្ញវត្ថុ ធនធានធម្មជាតិ... *

ពាក់ព័ន្ធជាមួយនឹងដីធ្លី ធនធាននេសាទ និងធនធានព្រៃឈើ ឱ្យបានសមស្រប និងប្រកបដោយសមធម៌ ស្របទៅតាមសន្និសញ្ញាដែលមានជាធរមាន, ពង្រីកឱកាសសេដ្ឋកិច្ច និងបង្កើនការចូលរួមរបស់ប្រជាពលរដ្ឋក្រីក្រ។

[17] សូមមើលប្រអប់ទី ២ FAO, 2005, និង www.fao.org/fishery/ssf/guidelines/en.

(១៨.១ នៅក្នុង *ការកំណត់ពីតម្លៃ*)

សិទ្ធិកាន់កាប់មានតម្លៃរបស់វា។ ទីមួយ មានតម្លៃដែលពាក់ព័ន្ធជាមួយនឹងសិទ្ធិផ្ទាល់តែម្តង ជាពិសេស នៅពេលដែលសិទ្ធិកាន់កាប់ ទទួលបានការទទួលស្គាល់ផ្លូវការ និងស្របច្បាប់ ដោយសារតែសន្តិសុខ និងការគ្រប់គ្រង ដែលសិទ្ធិនេះ នាំមកឱ្យអ្នកមានសិទ្ធិ។ ទីពីរ មានតម្លៃ ពាក់ព័ន្ធជាមួយនឹងធនធានសំខាន់ៗ ដូចជា ធនធាននេសាទ និងទីជម្រក និងប្រព័ន្ធ អេកូឡូហ្ស៊ីដែលពាក់ព័ន្ធ ឬតម្លៃដីធ្លី ប្រសិនបើធនធាននេះសំដៅលើដី (តំបន់ឆ្នេរ) កន្លែងណាមួយនោះ។ ពាក់ព័ន្ធជាមួយនឹង ធនធាននេសាទ គេអាចមើលឃើញតម្លៃនេះ ចេញពីទស្សនវិស័យផ្សេងៗគ្នា និងមានភាពពាក់ព័ន្ធ ជាមួយនឹង ៖

- តម្លៃរបស់ពូជត្រីនាពេលបច្ចុប្បន្ន និងនាពេលអនាគត ដែលសិទ្ធិនេះផ្តល់នូវសិទ្ធប្រើប្រាស់ (និងគ្រប់គ្រង) ឱ្យ
- តម្លៃសេដ្ឋកិច្ច សង្គម និងវប្បធម៌របស់សកម្មភាពនេសាទ និងសកម្មភាពពាក់ព័ន្ធ
- តម្លៃរបស់សេវាប្រព័ន្ធអេកូឡូហ្ស៊ីដទៃទៀត

ប្រសិនបើគេចង់កំណត់ពីតម្លៃគិតជារូបិយវត្ថុ គេអាចនិយាយបាហាថា ធនធាននេសាទ ឬពូជត្រី មានតម្លៃ ពាក់ព័ន្ធជាមួយនឹងតម្លៃបច្ចុប្បន្ន និងតម្លៃអនាគតរបស់ត្រី នៅពេលដែលគេយកត្រីមកគោក ដកចំណាយយកត្រីមកគោកចេញ។

ដោយសារតែធនធាននេសាទ គឺជាធនធានកកើតឡើងវិញ ប្រសិនបើមានការប្រើប្រាស់ប្រកបដោយនិរន្តរភាព និន្នាការនៃការទាញប្រយោជន៍ពីធនធាននេះ នាពេលបច្ចុប្បន្ន មានឥទ្ធិពលលើប្រយោជន៍ និងតម្លៃរបស់វានាពេលអនាគត។ ដូច្នេះ ធនធាននេសាទ ដែលត្រូវបានប្រើប្រាស់យ៉ាងល្អ បើគិតតាមន័យជីវសាស្ត្រផង និងន័យសេដ្ឋកិច្ចផង នឹងផ្តល់នូវតម្លៃយ៉ាងខ្ពស់ ទាំងពេលបច្ចុប្បន្ន និងពេលអនាគត។

គុណតម្លៃផ្នែកសេដ្ឋកិច្ច សង្គម និងវប្បធម៌ របស់សិទ្ធិកាន់កាប់ មានទំនាក់ទំនងជាមួយនឹងសកម្មភាពនេសាទ (និងសកម្មភាពកែច្នៃ ជួញដូរ និងសកម្មភាពបន្ទាប់បន្សំដទៃទៀត) ក្នុងទម្រង់ជាប្រយោជន៍នានា ដូចជា ការងារ និងការផ្តល់នូវប្រាក់ចំណូល ជាដើម។ តម្លៃនេះអាចមានការប្រែប្រួល ទៅតាមសារៈសំខាន់ ដែលប្រជាជននៅមូលដ្ឋានផ្តល់ដល់សកម្មភាពនេសាទ ដូចជា ថាតើមានឱកាសប្រកបរបរចិញ្ចឹមជីវិតដទៃទៀត សម្រាប់ពួកគេដែរឬទេ។ ជារឿយៗ ការប្រកបរបរនេសាទខ្នាតតូច បំពេញនូវមុខងារស្រូបយកកម្លាំងពលកម្ម និងផ្តល់នូវសំណាញ់សុវត្ថិភាពដ៏សំខាន់ ហើយភាពងាយស្រួល

ក្នុងការនេសាទ អាចមានសារៈសំខាន់ សម្រាប់ឱ្យគ្រួសារក្រីក្រអាចទ្រទ្រង់ជីវភាពរស់នៅរបស់ពួកគេ។[18] លើសពីនេះ សម្រាប់អ្នកនេសាទ និងកម្មករនេសាទតូចតាចជាច្រើននាក់ ការងារនេសាទ គឺជាបែបផែននៃជីវិតរបស់ពួកគេ និងមានតម្លៃផ្នែកសង្គម និងវប្បធម៌យ៉ាងសំខាន់ (Béné, 2011; Béné, Macfadyen and Allison, 2007)។

ធនធាននេសាទ គឺជាផ្នែកមួយនៃប្រព័ន្ធអេកូឡូហ្ស៊ី ហើយធនធានទាំងនេះមានតម្លៃរបស់វា ដោយសារតែធនធានទាំងនេះផ្តល់នូវសេវាប្រព័ន្ធអេកូឡូហ្ស៊ី។ តម្លៃរបស់ប្រព័ន្ធអេកូឡូហ្ស៊ី គឺជារង្វាស់ ដើម្បីឱ្យដឹងថាតើសេវាប្រព័ន្ធអេកូឡូហ្ស៊ីមានសារៈសំខាន់កម្រិតណាចំពោះប្រជាពលរដ្ឋ រួមទាំង សហគមន៍តំបន់ឆ្នេរ និងសមាជិកដទៃទៀតក្នុងសង្គមទូទៅផង។ គេអាចបែងចែកប្រភេទសេវាទាំងនេះជាសេវាដែលមានតម្លៃសម្រាប់ការប្រើប្រាស់ ដោយផ្ទាល់ និងដោយប្រយោល និងតម្លៃមិនមែនសម្រាប់ការប្រើប្រាស់។ តម្លៃសម្រាប់ការប្រើប្រាស់ មានមូលដ្ឋានផ្អែកលើការប្រើប្រាស់បរិស្ថានជាក់ស្តែង ឬជម្រើស ក្នុងការប្រើប្រាស់ ខណៈពេលដែលតម្លៃមិនមែនសម្រាប់ការប្រើប្រាស់ គឺជាតម្លៃ ដែលមិនជាប់ពាក់ព័ន្ធជាមួយនឹងការប្រើប្រាស់ប្រព័ន្ធអេកូឡូហ្ស៊ី ឬសេវារបស់ប្រព័ន្ធនេះជាក់ស្តែង។ ដូច្នេះ ការប្រើប្រាស់ដោយផ្ទាល់ រួមមាន ដូចជា អាហារ (ត្រី) សកម្មភាពកម្សាន្ត និងការសម្រាក។ តម្លៃមិនមែនសម្រាប់ការប្រើប្រាស់ ឆ្លុះបញ្ចាំងពីគុណតម្លៃរបស់មុខងារគាំទ្រ និងនិយ័តកម្ម ដូចជា តាមរយៈការរក្សាគុណភាពទឹក និងប្រពៃណីរបស់សហគមន៍ ឬនៅពេលដែលមនុស្សរីករាយនឹងមើលកម្មវិធីទូរទស្សន៍អំពីតំបន់នេះ និងអំពីជីវិតសត្វព្រៃ ដែលទទួលបានតម្លៃនៃការប្រើប្រាស់ដោយផ្ទាល់។ តម្លៃទាំងនេះមាន អនុប្រភេទមួយចំនួន ដូចជា ៖

- តម្លៃជម្រើស គឺជាប្រភេទនៃតម្លៃប្រើប្រាស់ ផ្អែកទៅតាមគំនិតដែលថា មនុស្សចង់មានជម្រើសប្រើប្រាស់អ្វីមួយនាពេលអនាគត
- តម្លៃមរតក គឺជាតម្លៃ ពាក់ព័ន្ធនឹងការដឹងថា មនុស្សជំនាន់ក្រោយ នឹងមានជម្រើស ក្នុងការរីករាយនឹងអ្វីមួយ
- តម្លៃអត្ថិភាព (ភាពឋិតនៅ) សំដៅលើតម្លៃ ដែលមនុស្សម្នាក់ផ្តល់ដល់ការដឹងថាមានអ្វីមួយឋិតនៅ បើទោះបីជាពួកគេមិនប្រើវា ឬមានផែនការប្រើវាក៏ដោយ

តម្លៃ ដូចបានរៀបរាប់ខាងលើ ពាក់ព័ន្ធជាមួយនឹងធនធាននេសាទ ក៏ដូចជាការនេសាទ និងសកម្មភាពពាក់ព័ន្ធ - គឺជាតម្លៃរបស់សេវាប្រព័ន្ធអេកូឡូហ្ស៊ីពាក់ព័ន្ធ។ បន្ថែមពីលើនេះ មានតម្លៃអរូបីបន្ថែមទៀត ដែលគេពិបាកនឹងដឹង ប៉ុន្តែនៅ តែមាន

[18] សូមមើលផ្នែក (ខាងលើ) តើគេអាចគ្រប់គ្រងធនធាននេសាទក្នុងនាមជាទ្រព្យសម្បត្តិរួម ប្រកបដោយនិរន្តរភាព ដោយរបៀបណា?

សារៈសំខាន់ សម្រាប់ការយល់ដឹងពីតម្លៃពេញលេញរបស់ធនធាននេសាទ ក៏ដូចជាទីជម្រក និងប្រព័ន្ធអេកូឡូហ្ស៊ីពាក់ ព័ន្ធរបស់វា។[19] នៅក្នុងវប្បធម៌មួយចំនួន តម្លៃរបស់ពពួកសត្វមួយប្រភេទ ឬតំបន់ជាក់លាក់មួយ គឺពាក់ព័ន្ធជាមួយនឹងការ អនុវត្តរបស់ដូនតា និងការប្រតិបត្តិជំនឿលើអារក្ខរបស់សហគមន៍ ហើយមិនងាយសង្ខេបចេញជាទស្សនទានអំពីតម្លៃ នៅក្នុងប្រព័ន្ធគ្រប់គ្រងធនធាននេសាទតាមបែបទំនើបបាននោះទេ។

**ពាក់ព័ន្ធជាមួយនឹងប្រធានបទកំណត់ពីតម្លៃ VGGT លើកឡើងថា ៖**

*គោលនយោបាយ និងច្បាប់នានា ដែលពាក់ព័ន្ធជាមួយនឹងការកំណត់តម្លៃ គួរខិតខំធានាយ៉ាងណាឱ្យប្រព័ន្ធកំណត់តម្លៃនេះគិតគូរពិចារណាផងដែរអំពីតម្លៃមិនមែនទីផ្សារ ដូចជា តម្លៃផ្នែកសង្គម វប្បធម៌ សាសនា ជំនឿអារក្ខ និងបរិស្ថានជាដើម នៅក្នុងករណីដែលពាក់ព័ន្ធ។*

**(១៨.២ នៅក្នុង *ការកំណត់ពីតម្លៃ*)**

ស្របតាមហេតុផលខាងលើ ដែលលើកឡើងថា ធនធាននេសាទ ដែលត្រូវបានគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព មានគុណតម្លៃខ្ពស់ជាងធនធាននេសាទ ដែលគ្រប់គ្រងមិនបានល្អ និងប្រើប្រាស់លើសកម្រិត វាបង្ហាញយ៉ាងច្បាស់ថា តម្លៃរបស់សិទ្ធិកាន់កាប់ដែលពាក់ព័ន្ធ អាចមានការប្រែប្រួល ទៅតាមពេលវេលា។ តាមរយៈការវិនិយោគលើអភិបាលកិច្ចល្អ ដែលជម្រុញលើកកម្ពស់ការនេសាទប្រកបដោយការទទួលខុសត្រូវ និងលើកកម្ពស់ស្ថានភាពរបស់ធនធាន គាំទ្រដល់តម្លៃផ្នែកសេដ្ឋកិច្ច សង្គម និងវប្បធម៌ និងការពារសេវាប្រព័ន្ធអេកូឡូហ្ស៊ីសំខាន់ៗ គេអាចបង្កើនតម្លៃរបស់សិទ្ធិកាន់កាប់បាន។ ការវិនិយោគមិនចំប្រភេទ អាចនាំឱ្យបញ្ហាកាន់តែពិបាកដោះស្រាយ។ ការបង្កើនសមត្ថភាពនេសាទ តាមរយៈការបន្ថែមនាវា និងប្រើប្រាស់បច្ចេកវិទ្យាកាន់តែល្អជាងមុន ដែលផ្តល់លទ្ធភាពផនាវាអាចធ្វើការនេសាទកាន់តែមានប្រសិទ្ធភាពជាងមុន អាចជម្រុញឱ្យកាន់តែមានការទាញប្រយោជន៍លើសកម្រិតពីធនធាននេះ ដែលនាំឱ្យមានការថមថយនូវតម្លៃនាពេលអនាគត។

ជាការសំខាន់ណាស់ ដែលគេត្រូវយល់ពីសមាសភាគផ្សេងៗនៃតម្លៃរបស់សិទ្ធិកាន់កាប់ និងរបៀបដែលអត្ថប្រយោជន៍ (និងចំណាយ) ពាក់ព័ន្ធនានា ត្រូវបានគេបែងចែក ពោលគឺថាតើអ្នកដែលចំណេញ និងអ្នកណាដែលខាត នៅ

[19] សម្រាប់ការពិភាក្សាលំអិតបន្ថែមទៀតអំពីសេវាប្រព័ន្ធអេកូឡូហ្ស៊ី សូមមើល De Young, Charles and Hjort (2008)

ពេលដែលគេធ្វើការបែងចែក ឬផ្ទេរសិទ្ធិនានា។ ការយល់ដឹងឱ្យបានល្អប្រសើរអំពីតម្លៃ ក៏ចាំបាច់ត្រូវតែមានផងដែរ ដើម្បីផ្តល់ព័ត៌មានដល់ការសម្រេចចិត្តកម្រិតគោលនយោបាយ នៅក្នុងវិស័យនេសាទ។ នៅក្នុងផ្នែកទី ២ បញ្ហាពាក់ព័ន្ធជាមួយនឹងការកំណត់ពីតម្លៃ ត្រូវបានលើកយកមកធ្វើការពិភាក្សាបន្តទៀត (សូមមើលផ្នែក ប៉ាន់ប្រមាណពីតម្លៃរបស់សិទ្ធិកាន់កាប់)។

## តើមានបញ្ហាថ្មីៗអ្វីខ្លះ ដែលចាំបាច់ត្រូវយកមកធ្វើការពិចារណា នាពេលអនាគត?

**ពាក់ព័ន្ធជាមួយនឹងការប្រែប្រួលអាកាសធាតុ និងគ្រោះភ័យនៃគ្រោះមហន្តរាយ VGGT លើកឡើងថា ៖**

*រដ្ឋគួរធានាយ៉ាងណាឱ្យសិទ្ធិកាន់កាប់ដីធ្លី ធនធាននេសាទ និងធនធានព្រៃឈើស្របច្បាប់ របស់បុគ្គល សហគមន៍ ឬមនុស្សគ្រប់រូប ដែលទំនងជាទទួលរងផលប៉ះពាល់ ជាពិសេស កសិករ អ្នកផលិតស្បៀងក្នុងទ្រង់ទ្រាយតូច និងជនដែលងាយរងគ្រោះ និងបាត់បង់ឱកាស ទទួលបានការគោរព និងការការពារដោយច្បាប់ គោលនយោបាយ យុទ្ធសាស្ត្រ និងសកម្មភាពនានា ក្នុងគោលបំណងបង្ការ និងឆ្លើយតបចំពោះផលប៉ះពាល់របស់ការប្រែប្រួលអាកាសធាតុ ស្របទៅតាមកាតព្វកិច្ចរបស់ពួកគេ ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងក្របខ័ណ្ឌអំពីការប្រែប្រួលអាកាសធាតុ ដែលពាក់ព័ន្ធ។*

**(២៣.១ នៅក្នុង *គ្រោះមហន្តរាយធម្មជាតិ* )**

គ្រប់ភាគីទាំងអស់ គួរធានាយ៉ាងណាឱ្យមានការពិភាក្សាអំពីសិទ្ធិកាន់កាប់ដីធ្លី ធនធាននេសាទ និងធនធានព្រៃឈើ នៅពេលបង្ការ និងត្រៀមទប់ទល់ជាមួយនឹងគ្រោះមហន្តរាយធម្មជាតិ និងនៅក្នុងការឆ្លើយតបរបស់ខ្លួន ចំពោះគ្រោះមហន្តរាយធម្មជាតិ។ ក្របខ័ណ្ឌនិយ័តកម្ម សម្រាប់សិទ្ធិកាន់កាប់ ដូចជា ការរៀបចំផែនការទីតាំង ជាដើម គួររៀបចំឡើង ដើម្បីបញ្ចៀស ឬកាត់បន្ថយឱ្យបានជាអតិបរមានូវផលប៉ះពាល់ ដែលអាចកើតឡើង ដោយសារគ្រោះមហន្តរាយធម្មជាតិ។

**(២៤.១ នៅក្នុង *គ្រោះមហន្តរាយធម្មជាតិ* )**

នៅក្នុងពិភពលោក ពោរពេញដោយការផ្លាស់ប្តូរនៅថ្ងៃនេះ មាននិន្នាការជាច្រើន ពាក់ព័ន្ធជាមួយនឹងការផ្លាស់ប្តូរជាសកល។ និន្នាការទាំងនេះ រួមមានដូចជា សកលភាវូបនីយកម្មនៃការធ្វើពាណិជ្ជកម្ម ជាដើម។ ត្រី និងផលិតផលត្រី គឺស្ថិតនៅ ក្នុងចំណោមផលិតផលអាហារ ដែលត្រូវបានគេជួញដូរច្រើនជាងគេ នៅក្នុងពិភពលោក ហើយពាណិជ្ជកម្មត្រីមាន

ការកើនឡើង នៅក្នុងរយៈពេលថ្មីៗនេះ។ ស្របពេលនឹងមានការកើនឡើងនូវចំនួនប្រជាជនក្នុងសកលលោក តម្រូវការអាហារក៏មានការកើនឡើងផងដែរ ហើយការឡើងចុះនូវតម្លៃស្បៀងអាហារ គឺជាក្តីបារម្ភមួយ។ បច្ចេកវិទ្យាព័ត៌មានក៏មានការវិវឌ្ឍ និងមានការប្រើប្រាស់យ៉ាងឆាប់រហ័ស ហើយរបៀបរបបរស់នៅ និងប្រព័ន្ធរបស់មនុស្សក៏មានការប្រែប្រួល រួមជាមួយនឹងការវិវឌ្ឍផ្នែកប្រជាសាស្ត្រផងដែរ (Perry and Ommer, 2010)។ គួរកត់សម្គាល់ថា សហគមន៍នេសាទខ្នាតតូចច្រើនតែប្រឈមនឹងផលប៉ះពាល់នៃការឡើងចុះធនធាន មេរោគអេដស៍/ជំងឺអេដស៍ ការឡើងចុះនៃទីផ្សារ ទំនាស់ ការបាត់បង់ឱកាសនយោបាយ និងអភិបាលកិច្ចនៅមានកម្រិតខ្សោយ ក៏ដូចជាសិទ្ធិប្រើប្រាស់មិនជាប់លាប់ (Cochrane *et al.,* 2009; Allison, Beveridge and van Brakel, 2009)។

ការផ្លាស់ប្តូរនានា ដែលទំនងជាមានសារៈសំខាន់ ប៉ុន្តែពិបាកនឹងដឹងជាមុន មានភាពពាក់ព័ន្ធជាមួយនឹងការប្រែប្រួលអាកាសធាតុ។ ការគំរាមកំហែង បង្កឡើងដោយសារការប្រែប្រួលអាកាសធាតុ ចំពោះសង្គមមនុស្ស និងចំពោះប្រព័ន្ធអេកូ-ឡូហ្ស៊ីធម្មជាតិ ត្រូវបានគេទទួលស្គាល់ថាជាក្តីបារម្ភដ៏សំខាន់ ចំពោះការអភិវឌ្ឍប្រកបដោយនិរន្តរភាពនាពេលអនាគត។ ការផ្លាស់ប្តូរជាច្រើន ដែលពាក់ព័ន្ធនឹងអាកាសធាតុ ទំនងជាកើតមានឡើង នៅក្នុងប្រព័ន្ធសមុទ្រ នៅក្នុងឆ្នាំខាងមុខនេះ ដូចជាការកើនឡើងនូវសីតុណ្ហភាព ការកើនឡើងនូវកម្ពស់ទឹកសមុទ្រ ការកើនឡើងនូវជាតិអាស៊ីដ ការប្រែប្រួលរបបទឹកភ្លៀង និងការកើនឡើងនូវភាពញឹកញាប់នៃគ្រោះអាកាសធាតុធ្ងន់ធ្ងរ (Perry and Ommer, 2010; Cochrane and Garcia, 2009)។ ការផ្លាស់ប្តូរទាំងនេះនឹងមានផលប៉ះពាល់មកលើប្រព័ន្ធអេកូឡូហ្ស៊ីវារីជាតិ ផលិតភាពរបស់ប្រព័ន្ធនេះ មកលើធនធាននេសាទ និងមកលើមនុស្ស ដែលពឹងអាស្រ័យលើធនធាននេសាទ។

ការសម្របទៅតាមការផ្លាស់ប្តូរជាសកល មានការប្រែប្រួលខុសៗគ្នាពីសកម្មភាពនេសាទមួយ ទៅសកម្មភាពនេសាទមួយទៀត។ សកម្មភាពនេសាទ ដែលទទយលរងផលប៉ះពាល់ជាងគេ គឺសកម្មភាពនេសាទ នៅតាមទន្លេ និងបឹងតូចៗ ក្នុងតំបន់ដែលមានការប្រែប្រួលសីតុណ្ហភាព និងរបបទឹកភ្លៀងខ្លាំង និងសកម្មភាពនេសាទពពួកវារីជាតិ ដែលធ្វើដំណើរឆ្ងាយៗ ដើម្បីពងកូន។ សកម្មភាពនេសាទ ដែលរងផលប៉ះពាល់បន្ទាប់ គឺសកម្មភាពនេសាទ នៅតាមតំបន់សេដ្ឋកិច្ចផ្តាច់មុខ សកម្មភាពនេសាទតាមទន្លេ និងបឹងធំៗ សកម្មភាពនេសាទ នៅតាមតំបន់ទន្លេដែលលយចូលទៅក្នុងសមុទ្រ (ជាពិសេស នៅកន្លែង ដែលមានសត្វដែលមិនផ្លាស់ទីទៅកន្លែងផ្សេង ឬមិនពងនៅកន្លែងផ្សេង) និងសកម្មភាពនេសាទ នៅតាមសមុទ្រ ដែលមានកម្រិតខ្ពស់ៗ (FAO, 2005-2013c)។ គួរមានកត់សម្គាល់ថា ប្រព័ន្ធអេកូឡូហ្ស៊ីនេសាទទឹកសាប ទទួល

រងផលប៉ះពាល់ ដោយសារការប្រែប្រួលរបបទឹកភ្លៀង និងទឹកភ្លៀងដែលហូរ អាចដោយសារឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ (Cochrane *et al.,* 2009)។ រដ្ឋកំពុងអភិវឌ្ឍ តាមដែនកោះតូចៗ (SIDS) នឹងទទួលរងផលប៉ះពាល់ជាពិសេសជាពិសេស ពាក់ព័ន្ធជាមួយនឹងផ្កាថ្មតែម្តង។

សហគមន៍នេសាទខ្នាតតូចជាច្រើន មានភាពងាយរងគ្រោះជាពិសេស ដោយសារតែការប្រែប្រួលអាកាសធាតុ ក៏ដូចជា ដោយសារគ្រោះមហន្តរាយធម្មជាតិ។ ជារឿយៗ សហគមន៍នេសាទខ្នាតតូច មានទីតាំង នៅតាមតំបន់ ដែលងាយទទួលរងគ្រោះមហន្តរាយធម្មជាតិ។ កន្លែងដែលដី និងទឹកជួបគ្នា គឺជាកន្លែងដែលមានបរិស្ថានរស់រវើកជាងគេ។ កំណើននៃភាពធ្ងន់ធ្ងរនៃផលប៉ះពាល់របស់គ្រោះមហន្តរាយធម្មជាតិ ដែលកើតឡើងដោយសារការប្រែប្រួលអាកាសធាតុ កាន់តែធ្ងន់ធ្ងរបន្ថែមទៀត ដោយសារតែការប្រែប្រួលប្រជាសាស្ត្រ។ គោលនយោបាយ និងអន្តរាគមន៍គ្រប់គ្រងគ្រោះភ័យនៃគ្រោះមហន្តរាយ (DRM) និងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ (CCA) ដែលឆ្លើយតបចំពោះតម្រូវការជាក់លាក់របស់ការនេសាទក្នុងទ្រង់ទ្រាយតូច ហើយដែលទទួលស្គាល់ថា ចាំបាច់ត្រូវតែមានការពិចារណាពិសេសសម្រាប់សហគមន៍នេសាទដែលរស់នៅតាមដែនកោះតូចៗ ចាំបាច់ត្រូវតែជាផ្នែកសំខាន់មួយនៃគោលនយោបាយ និងកម្មវិធីសកម្មភាព សម្រាប់អភិបាលកិច្ច និងការអភិវឌ្ឍក្នុងទ្រង់ទ្រាយតូច ដោយពាក់ព័ន្ធជាមួយនឹងសិទ្ធិកាន់កាប់ផងដែរ។ នៅពេលដែលមិនមានសិទ្ធិទទួលបានធនធាន ដែលពួកគេពឹងអាស្រ័យលើឱ្យបានជាប់លាប់ ជាពិសេស ដីធ្លី និងទឹកតែម្តង ជារឿយៗ ផលប៉ះពាល់ដោយសារការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយធម្មជាតិ តែងមានការកើនឡើង (សូមមើលប្រអប់ទី ១១)។

**ប្រអប់ទី ១១ ៖ ភាពពាក់ព័ន្ធនៃគោលនយោបាយស្តីពីតំបន់បម្រុង ក្រោយគ្រោះមហន្តរាយស៊ូណាមិ ឆ្នាំ ២០០៤**

សហគមន៍នេសាទ នៅតាមឆ្នេរសមុទ្រអានដាម៉ាន់ ប្រទេសថៃ ដែលមិនមានប័ណ្ណកម្មសិទ្ធិដីធ្លី ប្រឈមនឹងការលំបាកក្នុងការទាមទារដីធ្លីរបស់ពួកគេមកវិញ ក្រោយគ្រោះមហន្តរាយស៊ូណាមិ កាលពីខែ ធ្នូ ឆ្នាំ ២០០។ ដោយសារតែពួកគេមិនមានសិទ្ធិកាន់កាប់ដីធ្លីរបស់ពួកគេជាផ្លូវការ ពួកគេត្រូវបានគេចាត់ទុកថាជាអ្នករស់នៅក្នុងសំណង់អាណាធិបតេយ្យលើដីរបស់រដ្ឋ។ មុនពេលដែលគ្រោះមហន្តរាយស៊ូណាមិកើតមានឡើង កន្លែងរស់នៅរបស់ពួកគេភាគច្រើន ទទួលរងសម្ពាធដោយសារតែឧស្សាហកម្មទេសចរណ៍ ចង់ធ្វើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធតំបន់ឆ្នេរ។ ក្រោយពេលគ្រោះមហន្តរាយស៊ូណាមិកើតឡើង កសិដ្ឋានចិញ្ចឹមបង្គារមើលឃើញឱកាស នៅក្នុងសហគមន៍ ដែលត្រូវបានរលកយក្សបោកបក់បំផ្លាញអស់

ទាំងនេះ។ ដោយសារតែមានការយកចិត្តទុកដាក់ចំពោះស្ថានភាពនេះ តាមរយៈប្រព័ន្ធផ្សព្វផ្សាយនានា និងដោយមានជំនួយពីក្រុមនានា ដែលផ្តល់ការគាំទ្រដល់សហគមន៍នេសាទ ការដណ្តើមដីធ្លីមានការថមថយ។ ប៉ុន្តែ វិវាទដីធ្លីទាំងនេះក៏ធ្វើឱ្យមានភាពយឺតយ៉ាវ ដល់ការស្តារឡើងវិញ និងពន្យារពេលការសាងសង់ផ្ទះឡើងវិញផងដែរ។

*ប្រភព* ៖ Fernando and Punchihewa (2001); ACHR (2006)

## ផ្នែកទី ២ ៖ ការអនុវត្តសិទ្ធិកាន់កាប់ប្រកបដោយការទទួលខុសត្រូវ នៅក្នុងវិស័យនេសាទ

ផ្នែកទី ២ របស់មគ្គុទេសក៍នេះ ផ្តោតជាសំខាន់លើរបៀបអនុវត្តសិទ្ធិកាន់កាប់ប្រកបដោយការទទួលខុសត្រូវ នៅក្នុងវិស័យនេសាទ។ ក្រោយពីបង្ហាញពីប្រធានបទនេះ តាមរយៈការរៀបរាប់ពីបរិបទ និងសមាសភាគសំខាន់ៗនៃការអនុវត្តសិទ្ធិកាន់កាប់ប្រកបដោយការទទួលខុសត្រូវ ផ្នែកនេះធ្វើការពិភាក្សាអំពីកត្តានានា ដែលត្រូវយកមកធ្វើការពិចារណា និងការអនុវត្តល្អៗ នៅពេលធ្វើការបែងចែក ផ្ទេរ និងចាត់ចែងសិទ្ធិកាន់កាប់ ក្នុងវិស័យនេសាទ។ សន្ទានុក្រមមាននៅក្នុងឧបសម្ព័ន្ធទី ១ ហើយឧបសម្ព័ន្ធទី ២ បង្ហាញពីអភិក្រម និងវិធីសាស្ត្រផ្សេងៗ ដែលអាចយកមកអនុវត្ត និងមានបង្ហាញនៅក្នុងព័ត៌មានបន្ថែមអំពីឧបករណ៍។

### បរិបទនៃការអនុវត្ត

**VGGT លើកឡើងថា ៖**

*ស្របទៅតាមលក្ខណៈស្ម័គ្រចិត្តរបស់ VGGT ទាំងនេះ រដ្ឋមានការទទួលខុសត្រូវលើការអនុវត្ត ការពិនិត្យតាមដាន និងការវាយតម្លៃលើមគ្គុទេសក៍ទាំងនេះ។*

**(២៦.១ នៅក្នុង *ការលើកកម្ពស់ ការអនុវត្ត ការពិនិត្យតាមដាន និងការវាយតម្លៃ*)**

*រាល់ភាគីទាំងអស់ រាប់បញ្ចូលទាំងអង្គការសង្គមស៊ីវិល និងវិស័យឯកជនផង ត្រូវបានលើកទឹកចិត្តឱ្យប្រើប្រាស់កិច្ចប្រឹងប្រែងរួមសហការគ្នា ដើម្បីលើកកម្ពស់ និងអនុវត្ត VGGT ទាំងនេះ ស្របទៅតាមអាទិភាព និងបរិបទជាតិ។ រាល់ភាគីទាំងអស់ ត្រូវបានលើកទឹកចិត្តឱ្យធ្វើការផ្សព្វផ្សាយព័ត៌មានអំពីអភិបាលកិច្ចលើសិទ្ធិកាន់កាប់ ប្រកបដោយការទទួលខុសត្រូវ ដើម្បីធ្វើឱ្យការអនុវត្តមានភាពល្អប្រសើរជាងមុន។*

**(២៦.៥ នៅក្នុង *ការលើកកម្ពស់ ការអនុវត្ត ការពិនិត្យតាមដាន និងការវាយតម្លៃ*)**

មានប្រព័ន្ធសិទ្ធិកាន់កាប់ច្រើនយ៉ាងផ្សេងៗគ្នា នៅក្នុងវិស័យនេសាទ ពាក់ព័ន្ធជាមួយនឹងការប្រកបរបរចិញ្ចឹមជីវិតរបស់សហគមន៍នេសាទខ្នាតតូច។ យូរៗទៅ ប្រព័ន្ធប្រើប្រាស់ធនធានធម្មជាតិ តាមបែបប្រពៃណី និងទំនៀមទម្លាប់ ទាំងធនធាននេសាទ ទាំងដីធ្លី មានការវិវឌ្ឍ ទៅតាមកាលៈទេសៈក្នុងមូលដ្ឋាន។ នៅពេលធ្វើឱ្យប្រព័ន្ធក្រៅផ្លូវការដែលកំពុងមានក្លាយជាប្រព័ន្ធស្របច្បាប់ ឬនៅពេលដាក់ឱ្យអនុវត្តនូវការរៀបចំថ្មីៗ មានលទ្ធភាពជាច្រើន ពាក់ព័ន្ធនឹងរបៀបគួរកំណត់ពីសិទ្ធិ និងការទទួលខុសត្រូវ និងរបៀបចាត់ចែងប្រព័ន្ធសិទ្ធិកាន់កាប់។ តាមពិតទៅ ពុំមានដំណោះស្រាយថេរ ឬការកំណត់ពីនីតិវិធី សម្រាប់អនុវត្តការងារអភិបាលកិច្ចលើសិទ្ធិកាន់កាប់ នៅក្នុងវិស័យនេសាទនោះឡើយ ប៉ុន្តែដំណើរការសម្រាប់អនុវត្តការងារអភិបាលកិច្ចបែបនេះ គឺមានសារៈសំខាន់យ៉ាងខ្លាំង។ កាលៈទេសមានការប្រែប្រួលយ៉ាងច្រើនពីប្រទេសមួយ ទីតាំងមួយ វិស័យនេសាទមួយ ឬសហគមន៍នេសាទមួយ ជាមួយនឹងមួយទៀត ហើយជាការសំខាន់ណាស់ ដែលគេត្រូវធ្វើការពិចារណាលើស្ថានភាពនៅមូលដ្ឋាន តាមរយៈអភិក្រមរួមដែលមានការចូលរួម សម្រាប់ធ្វើការបែងចែក ផ្ទេរ និងចាត់ចែងសិទ្ធិកាន់កាប់។ ដូច្នេះ ការណែនាំ ដែលអាចផ្តល់ឱ្យបាន សំខាន់លើកឡើងពីដំណើរការ និងគោលការណ៍ឱ្យយកមកធ្វើការពិចារណា ជាជាងលើកឡើងពីដំណោះស្រាយ ឬវិធីសាស្រ្ត ដែលមានលក្ខណៈរឹងត្អឹង។

VGGT (ដែលមគ្គុទេសក៍ផ្តល់ការគាំទ្រ) ផ្តល់នូវក្របខ័ណ្ឌអន្តរជាតិមួយ សម្រាប់អនុវត្តសិទ្ធិកាន់កាប់ប្រកបដោយការទទួលខុសត្រូវ ដែលគួរអនុវត្ត នៅគ្រប់កម្រិតផ្សេងៗទាំងអស់ ទាំងនៅថ្នាក់ជាតិ និងនៅថ្នាក់មូលដ្ឋាន។ ចាំបាច់ត្រូវតែមានភាពស៊ីសង្វាក់គ្នារវាងការរៀបចំសិទ្ធិកាន់កាប់ប្រភេទផ្សេងៗគ្នា ដែលមានសារៈសំខាន់សម្រាប់សហគមន៍នេសាទ ក្នុងនោះមានសិទ្ធិប្រើប្រាស់ធនធាននេសាទផង និងសិទ្ធិកាន់កាប់ដីធ្លីក្នុងតំបន់ឆ្នេរផង។ ក្រសួង ឬស្ថាប័នរដ្ឋាភិបាល ដែលទទួលខុសត្រូវលើអភិបាលកិច្ច និងការគ្រប់គ្រងធនធាននេសាទ គួរលើកកម្ពស់ការបញ្ជ្រាបគោលការណ៍របស់ VGGT នៅក្នុងគ្រប់គោលនយោបាយ យុទ្ធសាស្រ្ត និងផែនការនេសាទពាក់ព័ន្ធទាំងអស់។ VGGT ក៏គួរអនុវត្ត ដោយក្រសួង និងស្ថាប័នដទៃទៀត ដែលធ្វើការងារពាក់ព័ន្ធជាមួយនឹងសិទ្ធិកាន់កាប់ ដែលមានផលប៉ះពាល់លើសហគមន៍នេសាទខ្នាតតូច នៅតាមតំបន់ឆ្នេរ និងតំបន់ទឹកសាបផងដែរ។ គួរមានការផ្តោតការយកចិត្តទុកដាក់ជាពិសេសលើរដ្ឋបាលការពារដែនសមុទ្ទ ដែលជារឿយៗ ស្ថិតក្រោមការទទួលខុសត្រូវផ្នែករដ្ឋបាលមួយផ្សេង ខុសពីស្ថាប័នជលផល។ ក្នុងពេលជាមួយគ្នា ចាំបាច់ត្រូវមានការសម្របសម្រួល និងសហការជាមួយនឹងអាជ្ញាធររដ្ឋាភិបាល ដែលធ្វើការងារពាក់ព័ន្ធជាមួយនឹងសិទ្ធិកាន់កាប់ដីធ្លី និងការរៀបចំផែនការតំបន់ឆ្នេរ ដើម្បីធានាយ៉ាងណាឱ្យសហគមន៍នេសាទ មានសិទ្ធិពេញលេញ សម្រាប់ផ្តល់នូវការគាំទ្រដល់ជីវភាពរស់នៅ របស់ពួកគេ។

មានគន្លងផ្លូវផ្សេងៗ សម្រាប់លើកកម្ពស់អភិបាលកិច្ចលើសិទ្ធិកាន់កាប់ ហើយចំណុចចាប់ផ្តើម សម្រាប់កំណែទម្រង់ ចាំបាច់ មិនមែនដូចគ្នាជានិច្ចកាលនោះទេ។ ឱកាសអាចលេចឡើង ជាចំណុចផ្តើម សម្រាប់ដាក់ឱ្យអនុវត្តនូវអភិបាលកិច្ចលើសិទ្ធិកាន់កាប់ប្រកបដោយភាពទទួលខុសត្រូវជាងមុន ដូចជា ៖

- ភាពចាំបាច់ជាទូទៅ ដើម្បីធ្វើកំណែទម្រង់គោលនយោបាយជារួម ឬធ្វើការកែប្រែក្របខ័ណ្ឌច្បាប់ នៅថ្នាក់ជាតិ ពាក់ព័ន្ធជាមួយនឹងអភិបាលកិច្ច និងការគ្រប់គ្រងធនធាននេសាទ។ ចំណុចនេះអាចជម្រុញឱ្យមាន តាមរយៈការផ្លាស់ប្តូរនៅក្នុងគោលនយោបាយ ឬស្ថាប័នពាក់ព័ន្ធនានា ដូចជា ពាក់ព័ន្ធជាមួយនឹងវិមជ្ឈការ ជាដើម។
- ភាពចាំបាច់ ដើម្បីដោះស្រាយបញ្ហានេសាទលើសកម្រិត ដែលបង្កការគំរាមកំហែងមកលើប្រសិទ្ធភាពសេដ្ឋកិច្ច និងនិរន្តរភាពផ្នែកជីវសាស្ត្ររបស់ធនធាន នៅក្នុងវិស័យនេសាទជាក់លាក់។
- ភាពចាំបាច់ ដើម្បីដោះស្រាយវិវាទរវាងក្រុមអ្នកពាក់ព័ន្ធ ឬអ្នកប្រើប្រាស់ធនធានផ្សេងៗគ្នា។

នៅក្នុងស្ថានភាពផ្សេងទៀត ចាំបាច់ត្រូវមានគំនិតផ្តួចផ្តើមជាក់លាក់ ដើម្បីបង្កលក្ខណៈឱ្យមានការពិនិត្យឡើងវិញលើប្រព័ន្ធអភិបាលកិច្ច ដែលមានស្រាប់ និងធ្វើការកែលំអការរៀបចំសិទ្ធិកាន់កាប់។ គំនិតផ្តួចផ្តើមទាំងនេះអាចមានប្រភពចេញពីស្ថាប័នណាមួយក្នុងជួររដ្ឋាភិបាល (ដែលធ្វើការងារពាក់ព័ន្ធជាមួយនឹងធនធាននេសាទ ឬពាក់ព័ន្ធជាមួយនឹងសិទ្ធិកាន់កាប់ នៅក្នុងវិស័យដទៃទៀត) ឬចេញពីខាងក្រៅរដ្ឋាភិបាល ដូចជា ចេញពីសង្គមស៊ីវិល ឬដៃគូអភិវឌ្ឍន៍ ដែលលើកកម្ពស់គោលការណ៍អភិបាលកិច្ចលើសិទ្ធិកាន់កាប់ប្រកបដោយការទទួលខុសត្រូវ តាមរយៈកម្មវិធី និងគម្រោងរបស់ខ្លួន។

ការអនុវត្តសិទ្ធិកាន់កាប់ប្រកបដោយការទទួលខុសត្រូវ គឺជាការប្តេជ្ញាចិត្តរយៈពេលវែង ដែលតម្រូវឱ្យមានភាពជាដៃគូ និងការសហការ និងទុកលទ្ធភាពឱ្យមានពេលវេលាគ្រប់គ្រាន់ ដើម្បីឱ្យមានការចូលរួម និងការចាប់អារម្មណ៍របស់ក្រុមអ្នកពាក់ព័ន្ធ។ មគ្គុទេសក៍នេះផ្តល់នូវដំបូន្មានអំពីសមាសភាគផ្សេងៗរបស់ដំណើរការ ដែលទំនងជាចាំបាច់ត្រូវមាននៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ដោយផ្តោតការយកចិត្តទុកដាក់លើទិដ្ឋភាព និងអភិក្រមសំខាន់។ រូបភាពទី ១ បង្ហាញដោយសង្ខេបអំពីបរិបទ និងដំណើរការនានា ដែលគេចាត់ទុកថាមានសារៈសំខាន់ សម្រាប់អនុវត្តសិទ្ធិកាន់កាប់ប្រកបដោយការទទួលខុសត្រូវ ស្របទៅតាម VGGT។ ផ្នែកខាងក្រោមនេះ ពិភាក្សាពីសមាសភាគផ្សេងៗទាំងនេះ និងមានបង្ហាញពីប្រអប់ ដែលផ្តល់

ការណែនាំជាក់លាក់អំពីបញ្ហាមួយចំនួន។ ឧបសម្ព័ន្ធទី ២ ផ្តល់ព័ត៌មានបន្ថែមអំពីគោលវិធី និងឧបករណ៍នានា ដែលត្រូវបានស្នើឡើងទាំងនេះ។[20]

**រូបភាពទី ១ ៖ បរិបទ និងដំណើរការនៃការអនុវត្តសិទ្ធិកាន់កាប់ប្រកបដោយការទទួលខុសត្រូវ**




## គោលការណ៍ទូទៅ

**VGGT ពន្យល់ថា នៅក្នុងបរិបទនៃអភិបាលកិច្ចលើសិទ្ធិកាន់កាប់ រដ្ឋមានកាតព្វកិច្ច ក្រោមលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិជាធរមាន។ អភិបាលកិច្ចលើសិទ្ធិកាន់កាប់ នៅក្នុងវិស័យនេសាទ គួរគ្របដណ្តប់ដោយគោលការណ៍ទូទៅ ដែលជាមូលដ្ឋាននៃអភិបាលកិច្ចល្អ ដូចជា ៖**

*សេចក្តីថ្លៃថ្នូររបស់មនុស្ស ការមិនរើសអើង សមធម៌និងយុត្តិធម៌ សមភាពយេនឌ័រ អភិក្រមក្តោបរួមប្រកបដោយនិរន្តរភាព ការពិគ្រោះយោបល់ និងការចូលរួម នីតិរដ្ឋ តម្លាភាព គណនេយ្យភាព និងការកែលំអជាប្រចាំ។*

[20] ឧបករណ៍ជាច្រើន ដែលបង្ហាញនៅក្នុងឧបសម្ព័ន្ធទី ២ គឺយកចេញពីប្រអប់ឧបករណ៍ EFA ដែលអាចរកបាន តាមរយៈ ៖ www.fao.org/fishery/eaf-net/topic/166272/en.

(៣៩ នៅក្នុង *គោលការណ៍ណែនាំអំពីអភិបាលកិច្ចលើសិទ្ធិកាន់កាប់ប្រកបដោយការទទួលខុសត្រូវ*)

នៅពេលអនុវត្តប្រព័ន្ធសិទ្ធិកាន់កាប់ រដ្ឋាភិបាលចាំបាច់ត្រូវតែផ្តល់នូវការការពារ ដើម្បីធានាឱ្យមានការអនុវត្តតាមគោលការណ៍អភិបាលកិច្ចល្អ។ សមធម៌ គឺជាកត្តាដ៏សំខាន់មួយ នៅក្នុងអភិបាលកិច្ចលើសិទ្ធិកាន់កាប់ប្រកបដោយការទទួលខុសត្រូវ ដែលទំនងជានឹងត្រូវឆ្លុះបញ្ចាំងក្នុងគោលដៅសង្គមជារួមផងដែរ (សូមមើលខាងក្រោម)។ ពេលខ្លះ ចាំបាច់ត្រូវមានការប្រតិបត្តិដោយអនុគ្រោះ ដើម្បីឱ្យមានការសម្រេចនូវលទ្ធផលប្រកបដោយសមធម៌ សម្រាប់មនុស្សគ្រប់រូប ទាំងបុរសទាំងស្ត្រី រាប់បញ្ចូលទាំងជនងាយរងគ្រោះ និងជនបាត់បង់ឱកាសផងដែរ។ សមភាពអន្តរជំនាន់ ក៏ចាំបាច់ត្រូវយកមកធ្វើការពិចារណាផងដែរ ហើយត្រូវមានផ្តោតការយកចិត្តទុកដាក់លើយុវជន។ សមភាពយេនឌ័រ អាចត្រូវបានគេចាត់ទុកថាជាផ្នែកមួយនៃគោលការណ៍រួមអំពីសមធម៌ យុត្តិធម៌ និងការមិនរើសអើង។ ដើម្បីសម្រេចឱ្យបាននូវសមភាពយេនឌ័រ ការបញ្ជ្រាបយេនឌ័រ ក្នុងគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការ នៅគ្រប់កម្រិតទាំងអស់ ចាំបាច់ត្រូវតែមួយ ដូចគ្នានឹងអន្តរាគមន៍គោលដៅផងដែរ។ នៅក្នុងបរិបទនៃការអនុវត្តសិទ្ធិកាន់កាប់ប្រកបដោយការទទួលខុសត្រូវ ជាការសំខាន់ណាស់ ដែលត្រូវមានការវិភាគយេនឌ័រ អមជាមួយនឹងគ្រប់ដំណើរការវាយតម្លៃ និងរៀបចំផែនការទាំងអស់។

ចាំបាច់ត្រូវមានអភិក្រមក្តោបរួម ប្រកបដោយនិរន្តរភាព សម្រាប់ធ្វើការពិចារណាលើភាពស្មុគស្មាញនៃការប្រកបរបរចិញ្ចឹមជីវិតរបស់សហគមន៍នេសាទ ក្នុងគោលបំណងលើកកម្ពស់អភិបាលកិច្ចលើសិទ្ធិកាន់កាប់ នៅក្នុងវិស័យនេសាទ។ គោលការណ៍ជាមូលដ្ឋាន នៅក្នុងវិស័យនេសាទខ្នាតតូច គឺថា គេគួរធ្វើការពិចារណាលើការគ្រប់គ្រងធនធានធម្មជាតិ និងប្រព័ន្ធអេកូឡូហ្ស៊ី រួមគ្នាជាមួយនឹងការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច ដូច្នេះគេចាំបាច់ត្រូវតែធ្វើការវាយតម្លៃ បែងចែក និងចាត់ចែងការរៀបចំសិទ្ធិកាន់កាប់ នៅក្នុងបរិបទនេះ។ និរន្តរភាព គឺជាទស្សនទានដ៏សំខាន់មួយ ដែលមានសុពលភាព សម្រាប់ទិដ្ឋភាពអេកូឡូហ្ស៊ីជីវសាស្ត្រផង និងទិដ្ឋភាពមនុស្សផង ដែលគេហៅថាសសរស្តម្ភទាំង ៣ នៃនិរន្តរភាពផ្នែកសង្គម សេដ្ឋកិច្ច និងបរិស្ថាន នៅក្នុងកិច្ចប្រជុំ Rio+២។ សកម្មភាពនានា គួរតម្រង់ទិស ដោយអភិក្រមដែលមានបម្រុងប្រយ័តជាមុន និងការគ្រប់គ្រងហានិភ័យ ដើម្បីបង្ការមិនឱ្យមានលទ្ធផល ដែលគេមិនចង់បាន ដូចជា មិនត្រឹមតែទាញប្រយោជន៍ហួសកម្រិតពីធនធាននេសាទ និងផលប៉ះពាល់ជាអវិជ្ជមានមកលើបរិស្ថានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផលវិបាកផ្នែកសង្គម និងសេដ្ឋកិច្ច ដែលមិនអាចទទួលយកបានផងដែរ។

| ការណែនាំទី ១ ៖ ការលើកកម្ពស់សមភាពយេនឌ័រ |
| --- |
| គួរមានការផ្តោតការយកចិត្តទុកដាក់លើស្ត្រី។ ដោយសារតែការនិយមយេនឌ័រ សម្រាប់ការងារនេសាទ ហើយជារឿយៗ ស្ត្រីតែងមានការលំបាក ពាក់ព័ន្ធជាមួយនឹងការធ្វើសេចក្តីសម្រេចចិត្ត ជារឿយៗ ស្ត្រីត្រូវបានគេភ្លេចមិនឱ្យចូលរួម ក្នុងដំណើរការគ្រប់គ្រងធនធាននេសាទ ដូច្នេះ នាំឱ្យពួកគេមានហានិភ័យ ពាក់ព័ន្ធជាមួយនឹងសិទ្ធិកាន់កាប់ផងដែរ។ ជារឿយៗ ស្ត្រីបំពេញការងារ នៅក្នុងវិស័យក្រោយប្រមូលផល ហើយជាអ្នកទទួលខុសត្រូវលើការកែច្នៃ និងជួញដូរត្រី (សូមមើលប្រអប់ទី ៥ នៅក្នុងផ្នែកទី ១)។ គួរមានបម្រុងប្រយ័ត្ន ដើម្បីកុំឱ្យមានការផាត់ស្ត្រីចេញ នៅពេលគេរៀបចំសិទ្ធិកាន់កាប់ឱ្យក្លាយជាសិទ្ធិផ្លូវការ។ ស្ត្រីគួរចូលរួម នៅក្នុងដំណើរការពិគ្រោះយោបល់អំពីសិទ្ធិកាន់កាប់ ក៏ដូចនៅក្នុងការគ្រប់គ្រងធនធាននេសាទ។ ដោយសារតែតួនាទីរបស់ពួកគេក្នុងការធានាសុខុមាលភាពរបស់គ្រួសារ ពួកគេអាចមានតម្រូវការផ្សេងពីបុរស ពាក់ព័ន្ធជាមួយនឹងសិទ្ធិ និងការរៀបចំសិទ្ធិកាន់កាប់។ គួរមានការទទួលស្គាល់លើសារៈសំខាន់របស់វិស័យក្រោយប្រមូលផល។ អ្នកដែលធ្វើការងារពាក់ព័ន្ធនឹងការស្វែងរកទីផ្សារ សម្រាប់ផលិតផលនេសាទ មានការយល់ដឹងពីកត្តាជម្រុញឱ្យមានការប្រើប្រាស់ធនធាននេះ ដូចជា តម្រូវការ ជាដើម។ កម្មករ ដែលធ្វើការងារក្រោយប្រមូលផល ក៏ត្រូវការអាចប្រើប្រាស់មធ្យោបាយផលិតកម្ម (ដូចជា ដីធ្លី ទឹក ត្រី ។ល) ឱ្យបានជាប់លាប់ផងដែរ ហើយពួកគេគឺជាផ្នែកដ៏សំខាន់មួយរបស់ប្រព័ន្ធនេសាទ។ |
| អភិក្រម/ឧបករណ៍ ដែលស្នើឡើង ៖<br>• ការវិភាគយេនឌ័រក្នុងសហគមន៍ (សូមមើលឧបសម្ព័ន្ធទី ២)<br>• ការវិភាគលើសង្វាក់ផ្គត់ផ្គង់ |

ការពិគ្រោះយោបល់ និងការចូលរួម គួរតែជាមូលដ្ឋាន សម្រាប់ការធ្វើសេចក្តីសម្រេចចិត្ត និងការតាក់តែងគោល-នយោបាយ ពាក់ព័ន្ធជាមួយនឹងសិទ្ធិកាន់កាប់ នៅក្នុងវិស័យនេសាទ។ ការសម្រេចចិត្ត នៅកម្រិតវិមជ្ឈការទាបបំផុត (គោលការណ៍សាប់ស៊ីឌែរិធី (Subsidiarity)) គួរត្រូវបានលើកទឹកចិត្តឱ្យមាន តាមបែបផែនមួយ ដែលធានាបាននូវតម្លាភាព គណនេយ្យភាព និងសមធម៌។ អ្នកនេសាទ និងកម្មករនេសាទតូចតាច គួរមានតំណាង នៅក្នុងស្ថាប័នវិជ្ជាជីវៈនៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ និងស្ថាប័នវិជ្ជាជីវៈតាមវិស័យ (ឧ. ក្រុមប្រឹក្សាគ្រប់គ្រងធនធាននេសាទ និងក្រុមប្រឹក្សាគ្រប់គ្រងតំបន់ឆ្នេរ ជាដើម)។ លើសពីនេះ ទំនាក់ទំនងតាមខ្សែបណ្តោយ នៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្ត ចាប់ពីថ្នាក់

មូលដ្ឋាន រហូតដល់ថ្នាក់ខេត្ត ជាតិ តំបន់ និងអន្តរជាតិ ដោយមានតំណាងសមស្របពីភាគីពាក់ព័ន្ធ នៅតាមកម្រិតនីមួយៗគួរត្រូវបានបង្កើតឡើង ដើម្បីធានាយ៉ាងណាឱ្យមានការឆ្លុះបញ្ចាំងសមស្របពីក្តីបារម្ភរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន នៅក្នុងគោលនយោបាយ និងកម្មវិធីសកម្មភាពនៅកម្រិតទូលំទូលាយ។ ប្រអប់ទី ១២ រៀបរាប់ពីវិមជ្ឈការ និងរចនាសម្ព័ន្ធអភិបាលកិច្ចនៅមូលដ្ឋាន ក្នុងវិស័យនេសាទ នៅក្នុងប្រទេសហ្វីលីពីន។ ដើម្បីឱ្យការចូលរួម និងវិមជ្ឈការធ្វើទៅប្រកបដោយប្រសិទ្ធភាព ចាំបាច់ត្រូវតែមានសមត្ថភាព នៅកម្រិតមូលដ្ឋាន និងកម្រិតសហគមន៍។ ភាពចាំបាច់ សម្រាប់ការពង្រឹងសមត្ថភាព ត្រូវបានលើកមកពិភាក្សាខាងក្រោម (សូមមើលផ្នែក សមត្ថភាព និងរចនាសម្ព័ន្ធស្ថាប័ន)។

**ប្រអប់ទី ១២ ៖ ការរៀបចំអភិបាលកិច្ច និងការគ្រប់គ្រងវិស័យនេសាទនៅមូលដ្ឋាន ក្នុងប្រទេសហ្វីលីពីន**

នៅក្នុងឆ្នាំ ១៩៩១ រដ្ឋាភិបាលហ្វីលីពីន បានទទួលស្គាល់ពីភាពចាំបាច់ នៅក្នុងការបង្កើនការចូលរួម ក្នុងការគ្រប់គ្រង និងធ្វើវិមជ្ឈការការគ្រប់គ្រងការប្រើប្រាស់ធនធាន ទៅឱ្យរដ្ឋាភិបាលនៅថ្នាក់មូលដ្ឋាន តាមរយៈកំណែទម្រង់គោលនយោបាយ និងស្ថាប័ន។ សមត្ថកិច្ច ត្រូវបានប្រគល់ទៅឱ្យអង្គភាពរដ្ឋាភិបាលនៅថ្នាក់មូលដ្ឋាន ជាពិសេស ក្រុង។ អង្គភាពរដ្ឋាភិបាលនៅថ្នាក់មូលដ្ឋាន និងសហគមន៍មូលដ្ឋាន បានទទួលនូវបុព្វសិទ្ធិ និង/ឬសិទ្ធិអាទិភាពមួយចំនួន។ ក្រុងមានអំណាចផ្តាច់មុខ ក្នុងការផ្តល់បុព្វសិទ្ធិនេសាទ នៅក្នុងដែនទឹករបស់ក្រុង រហូតដល់ចម្ងាយ ១៥ គីឡូម៉ែត្រពីច្រាំង និងក្នុងការកំណត់ពីថ្លៃជួល និងថ្លៃសេវានានា។ នៅក្នុងឆ្នាំ ១៩៩៨ ក្រមនេសាទរបស់ប្រទេសហ្វីលីពីន ត្រូវបានចុះហត្ថលេខាឱ្យក្លាយជាច្បាប់ ហើយមានការគាំទ្រឱ្យមានការបង្កើតក្រុមប្រឹក្សាគ្រប់គ្រងធនធាននេសាទ និងវារីជាតិ (FARMCs) នៅថ្នាក់ជាតិ ក្រុង និងបារ៉ាំងហ្គាយ (ភូមិ)។ សមាជិកសហគមន៍ ដែលបានចងក្រងគ្នាជាក្រុម បានទទួលឱកាសចូលរួមជាផ្លូវការ នៅក្នុងកិច្ចខិតខំប្រឹងប្រែងគ្រប់គ្រង តាមរយៈ FARMCs។ FARMCs មានភារកិច្ចអនុវត្តមុខងារផ្តល់ប្រឹក្សាដល់ការគ្រប់គ្រងជាច្រើន ដោយសហការយ៉ាងជិតស្និទជាមួយនឹងអង្គភាពរដ្ឋាភិបាលនៅថ្នាក់មូលដ្ឋាន។ មុខងារទាំងនេះ រួមមាន ជួយរៀបចំផែនការអភិវឌ្ឍន៍វិស័យនេសាទរបស់ក្រុង ផ្តល់អនុសាសន៍ដល់ការអនុម័តលើបទបញ្ញាពាក់ព័ន្ធនឹងការនេសាទ ជួយនៅក្នុងការពង្រឹងការអនុវត្ត និងការផ្តល់ប្រឹក្សាដល់អង្គភាពរដ្ឋាភិបាលនៅថ្នាក់មូលដ្ឋាន អំពីការងារនេសាទ។ FARMCs ត្រូវបានបង្កើតឡើងដោយអង្គការ និងសហករណ៍របស់អ្នកនេសាទ រួមជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាល ក្រោមជំនួយពីអង្គភាពរដ្ឋាភិបាលនៅថ្នាក់មូលដ្ឋាន។

*ប្រភព* ៖ Pomeroy (2001)

## ការកំណត់គោលបំណង

ពាក់ព័ន្ធជាមួយនឹងគោលបំណងរួម ដែលគួរជាមគ្គុទេសក៍បង្ហាញពីអភិបាលកិច្ចលើសិទ្ធិកាន់កាប់ VGGT លើកឡើងថា ៖

*រដ្ឋគួររៀបចំ និងផ្សព្វផ្សាយគោលនយោបាយនានាអំពីការបែងចែកសិទ្ធិកាន់កាប់ ទៅឱ្យអ្នកដទៃទៀត និងអំពីការធ្វើប្រតិភូកម្មការទទួលខុសត្រូវលើអភិបាលកិច្ចលើសិទ្ធិកាន់កាប់ នៅក្នុងករណីដែលសមស្រប។ គោលនយោបាយសម្រាប់បែងចែកសិទ្ធិកាន់កាប់ គួរមានសង្គតភាពជាមួយនឹងគោលបំណងផ្នែកសង្គម សេដ្ឋកិច្ច និងបរិស្ថាន ដែលមានកម្រិតទូលាយជាង។ សហគមន៍មូលដ្ឋាន ដែលបានប្រើប្រាស់ដីធ្លី ធនធាននេសាទ និងធនធានព្រៃឈើ ជាប្រពៃណីកន្លងមក គួរទទួលបានការគិតគូរត្រឹមត្រូវ នៅពេលដែលមានការបែងចែកសិទ្ធិកាន់កាប់សារជាថ្មី។ គោលនយោបាយនានា គួរធ្វើការពិចារណាលើសិទ្ធិកាន់កាប់របស់អ្នកដទៃ ហើយអ្នកដែលអាចទទួលរងផលប៉ះពាល់ គួរចូលរួមនៅក្នុងដំណើរការពិគ្រោះយោបល់ ដំណើរការចូលរួម និងដំណើរការធ្វើសេចក្ដីសម្រេចចិត្ត។ គោលនយោបាយទាំងនេះគួរធានាថា ការបែងចែកសិទ្ធិកាន់កាប់ មិនបង្កការគំរាមកំហែងដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ តាមរយៈការដកហូតសិទ្ធិស្របច្បាប់របស់ពួកគេ ក្នុងការទទួលបានធនធានទាំងនេះឡើយ។*

**(៨.៧ នៅក្នុង *ដី ធនធាននេសាទ និងធនធានព្រៃឈើសាធារណៈ* )**

នៅពេលដាក់ឱ្យអនុវត្តនូវប្រព័ន្ធសិទ្ធិកាន់កាប់ថ្មី ឬធ្វើការផ្លាស់ប្ដូរប្រព័ន្ធដែលកំពុងមាន គេគួរកំណត់ពីគោលបំណងឱ្យបានច្បាស់លាស់។ ជាការសំខាន់ណាស់ ដែលគោលបំណងទាំងនេះ ត្រូវមានភាពស៊ីសង្វាក់គ្នា ជាមួយនឹងគោលបំណងរួមផ្នែកសង្គមផ្សេងទៀត ក៏ដូចជាគោលបំណង និងគោលនយោបាយបរិស្ថាន ក្នុងវិស័យនេសាទ និងវិស័យដទៃទៀត។ ក្នុងពេលជាមួយគ្នា អាចមានភាពចាំបាច់ ដើម្បីបង្កើនការយល់ដឹងអំពី VGGT និងលិខិតុបករណ៍ដទៃទៀត ទាំងនៅកម្រិតនយោបាយខ្ពស់ៗ និងក្នុងចំណោមអ្នកអនុវត្តការងារជាក់ស្ដែង ដើម្បីធានាយ៉ាងណាឱ្យគោលការណ៍សំខាន់ៗក្នុងលិខិតុបករណ៍ទាំងនេះ ត្រូវបានឆ្លុះបញ្ចាំង នៅក្នុងក្របខ័ណ្ឌគោលនយោបាយរួម។ បណ្ដាប្រទេសកំពុងអភិវឌ្ឍជាច្រើនមាន

ផែនការយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ (PRSPs)[21] ឬលិខិតុបករណ៍គោលនយោបាយស្រដៀងគ្នានេះដែរ។ ផែនការទាំងនេះ មិនមែនជានិច្ចកាល សុទ្ធតែបានពិចារណាច្បាស់លាស់អំពីវិស័យនេសាទនោះទេ ហើយចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែង ដើម្បីដាក់ឱ្យអនុវត្តនូវទស្សនវិស័យតាមវិស័យផង និងគោលការណ៍អភិបាលកិច្ចល្អលើសិទ្ធិកាន់កាប់ផង។

| **ការណែនាំទី ២ ៖ ការបង្កើនការយល់ដឹង** |
| --- |
| ការបង្កើនការយល់ដឹង គឺអំពីការផ្សព្វផ្សាយព័ត៌មាន និងការបង្កើតនូវចំណេះដឹង។ នេះគឺជាអ្វីដែលចាំបាច់ត្រូវធ្វើ ដើម្បីឱ្យអ្នកពាក់ព័ន្ធអាចចូលរួម នៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្ត និងសម្របសម្រួលឱ្យគោលនយោបាយមានភាពស៊ីសង្វាក់គ្នា។ នៅពេលដែលឧបករណ៍ថ្មី ដូចជា VGGT នេះជាដើម ត្រូវបានដាក់ឱ្យប្រើប្រាស់ ចាំបាច់ត្រូវតែមានការខិតខំប្រឹងប្រែងជាពិសេស ដើម្បីផ្តល់លទ្ធភាពឱ្យអ្នកពាក់ព័ន្ធនានា ដឹងពីឧបករណ៍នេះ និងដឹងពីរបៀបគួរយកឧបករណ៍នេះទៅអនុវត្ត។ នេះរួមមានការធានាឱ្យគេដឹងពីគោលបំណងរបស់ VGGT និងរបៀបដែលគេចង់សម្រេចឱ្យបាននូវសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ការលុបបំបាត់ភាពក្រីក្រ ការអភិវឌ្ឍប្រកបដោយសមធម៌ និងការប្រើប្រាស់ធនធានប្រកបដោយនិរន្តរភាព។ សារៈសំខាន់របស់គោលការណ៍ទូទៅ និងតួនាទីរបស់យុត្តិធម៌សង្គម ក៏ចាំបាច់ត្រូវធ្វើការផ្សព្វផ្សាយផងដែរ។<br><br>ការបង្កើនការយល់ដឹង អាចមានទម្រង់ច្រើនយ៉ាងផ្សេងៗគ្នា ហើយរួមមានការចែកចាយសម្ភារបោះពុម្ព និងការរៀបចំសិក្ខាសាលា និងការបណ្តុះបណ្តាល។ ចាំបាច់ត្រូវមានការប្រើប្រាស់អភិក្រមផ្សេងៗគ្នា សម្រាប់ក្រុមអ្នកពាក់ព័ន្ធផ្សេងគ្នា ហើយអភិក្រមទាំងនេះចាំបាច់ត្រូវអនុវត្តជាជំហានផ្សេងៗគ្នា។ ការបង្កើនការយល់ដឹងត្រូវការនូវព័ត៌មាន និងការប្រើប្រាស់ឧបករណ៍ឱ្យបានសមស្របសម្រាប់ក្រុមគោលដៅជាក់លាក់។ |
| អភិក្រម/ឧបករណ៍ ដែលស្នើឡើង ៖<br>• សិក្ខាសាលាសម្រាប់អ្នកពាក់ព័ន្ធ (សូមមើលឧបសម្ព័ន្ធទី ២)<br>• យុទ្ធសាស្ត្រប្រាស្រ័យទាក់ទង និងសម្ភារសម្រាប់ការប្រាស្រ័យទាក់ទង<br>• វគ្គបណ្តុះបណ្តាល |

[21] PRSP គឺជាឧបករណ៍រៀបចំផែនការមួយ ដែលត្រូវបានដាក់ឱ្យអនុវត្តដោយមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) និងធនាគារពិភពលោក នៅក្នុងឆ្នាំ ១៩៩៩ និងមាន គោលបំណងជួយផ្តល់ការណែនាំដល់គោលនយោបាយនានា ជាពិសេស នៅក្នុងប្រទេសក្រីក្រ ដែលជាប់បំណុលធ្ងន់ធ្ងរ (HIPCs)។

ការរៀបចំសិទ្ធិកាន់កាប់ធនធាននេសាទ ត្រូវស្ថិតក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រងធនធាននេសាទទូលំទូលាយ។ នៅក្នុងវិស័យនេសាទ គេតែងតែកំណត់ដោយចង្អៀតចង្អល់ថា ការនេសាទហួសកម្រិត គឺជាបញ្ហា ហើយការប្រមូលផលប្រកបដោយនិរន្តរភាព គឺជាគោលបំណង ដែលត្រូវសម្រេច។ ជាមួយនឹងអភិក្រមនេសាទ ដែលគិតគូរពីប្រព័ន្ធអេកូឡូហ្ស៊ី មានការផ្តោតការយកចិត្តទុកដាក់បន្ថែមលើទំនាក់ទំនងអន្តរវិស័យ និងទស្សនវិស័យរួម។ ក្របខ័ណ្ឌច្បាប់របស់ជាតិ ក៏អាចទាមទារឱ្យវិស័យនេសាទ មានគណនេយ្យភាពចំពោះច្បាប់ ដែលអនុវត្តចំពោះគ្រប់វិស័យឧស្សាហកម្មទាំងអស់ផងដែរ ហើយជាធម្មតា វិស័យនេះស្ថិតនៅក្រោមច្បាប់បរិស្ថាន ដែលការពារគុណភាពបរិស្ថាន ជីវចម្រុះ និងសត្វដែលជិតផុតពូជ។ គោលនយោបាយ និងគោលបំណងរបស់រដ្ឋាភិបាល ក៏អាចមានផងដែរ ដូចជា ការខិតខំឱ្យមានប្រសិទ្ធភាព ឬការងារពេញលេញក្នុងឧស្សាហកម្ម ជាដើម។ សម្រាប់សិទ្ធិកាន់កាប់ប្រកបដោយការទទួលខុសត្រូវ នៅក្នុងបរិបទនៃការប្រកបរបរនេសាទតូចតាចសម្រាប់ចិញ្ចឹមជីវិត គោលបំណងនៅកម្រិតវិស័យ ក៏ចាំបាច់ត្រូវតែដាក់បញ្ចូលនូវមហិច្ឆតាសង្គម និងសេដ្ឋកិច្ចផងដែរ ដូចជា ដើម្បីលើកកម្ពស់ឱ្យមានការបែងចែកប្រយោជន៍នានាប្រកបដោយសមធម៌ និងធានានូវសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ ដោយសារតែសហគមន៍នេសាទ ត្រូវការអាចទទួលបានធនធាននេសាទ និងដីធ្លីឱ្យបានជាប់លាប់ សហគមន៍ទាំងនេះទំនងជា នឹងទទួលរងផលប៉ះពាល់ ដោយសារប្រព័ន្ធសិទ្ធិកាន់កាប់ នៅតាមវិស័យផ្សេង។ ជាការសំខាន់ណាស់ ដែលត្រូវមានភាពស៊ីសង្វាក់គ្នារវាងវិស័យផ្សេងៗទាំងនេះ ពោលគឺវិស័យនេសាទ និងវិស័យប្រើប្រាស់ដីធ្លី តែម្តង។ ការប្រើប្រាស់ប្រព័ន្ធរៀបចំផែនការ និងគ្រប់គ្រងទីតាំង ដែលមានលក្ខណៈសមាហរណកម្ម នៅតំបន់ឆ្នេរ ដូចជា ការរៀបចំផែនការលំហសមុទ្ទ (MSP) និងការគ្រប់គ្រងតំបន់ឆ្នេរ ដែលមានលក្ខណៈសមាហរណកម្ម (ICZM) អាចផ្តល់នូវប្រយោជន៍ពាក់ព័ន្ធជាមួយនឹងចំណុចនេះ (សូមមើលផ្នែកតើមានសិទ្ធិកាន់កាប់ផ្លូវការប្រភេទផ្សេងៗអ្វីខ្លះ នៅក្នុងវិស័យនេសាទ? នៅក្នុងផ្នែកទី ១ ខាងលើ)។

| ការណែនាំទី ៣ ៖ ការកំណត់ពីគោលបំណង |
|---|
| នៅពេលដែលអនុវត្តប្រព័ន្ធសិទ្ធិកាន់កាប់ថ្មី ឬធ្វើការកែប្រែប្រព័ន្ធដែលកំពុងមាន នៅក្នុងវិស័យនេសាទ (ឧ. កំណត់ពីសិទ្ធិប្រើប្រាស់ នៅក្នុងការរៀបចំការគ្រប់គ្រងរួមគ្នា ជាដើម) កិច្ចពិគ្រោះយោបល់បឋម ជាមួយនឹងអ្នកពាក់ព័ន្ធ គួរកំណត់ពីប្រយោជន៍ និងគោលបំណងរបស់ក្រុមផ្សេងៗ (សូមមើលផ្នែកអ្នកពាក់ព័ន្ធ និងសិទ្ធិកាន់កាប់ដែលមានស្រាប់ ខាងក្រោម)។ ចំណុចទាំងនេះគួរត្រូវបានចែករំលែក ហើយគួរមានរៀបចំចេញជាចក្ខុវិស័យរួមមួយ ដែលដាក់ចេញនូវគោលដៅគោលនយោបាយរបស់សិទ្ធិកាន់កាប់ និងប្រព័ន្ធគ្រប់គ្រងធនធាននេសាទ។ នេះអាចជាដំណើរការដ៏ពិបាកមួយ ដែលទាមទារ |

ឱ្យមានការចរចាគ្នា ការសម្រុះសម្រួល និងការគ្រប់គ្រងវិវាទ (សូមមើលផ្នែកយន្តការដោះស្រាយវិវាទ ខាងក្រោម)។ នៅក្នុងក្របខ័ណ្ឌនេះ ចាំបាច់ត្រូវតែមានគោលបំណងនៅកម្រិតនៃការគ្រប់គ្រង។ គោលបំណងទាំងនេះត្រូវសរសេរឱ្យបានជាក់លាក់បន្តិច ហើយច្រើនតែមាននៅពីរកម្រិត ៖ គោលបំណងនៅកម្រិតគ្រប់គ្រងរួម និងគោលបំណងនៅកម្រិតប្រតិបត្តិការ។ គោលបំណរួម លើកឡើងពីលទ្ធផលរបស់សិទ្ធិកាន់កាប់ និងប្រព័ន្ធគ្រប់គ្រងធនធាននេសាទ ដែលគេចង់សម្រេចឱ្យបាន។ គោលបំណងនៅកម្រិតប្រតិបត្តិការ មានភាពជាក់លាក់ជាង និងមានអត្ថន័យដោយផ្ទាល់ ជាក់ស្តែង សម្រាប់សិទ្ធិកាន់កាប់ និងការគ្រប់គ្រងធនធាននេសាទ។ គោលបំណងទាំងនេះគួរអាចវាស់វែងបាន និងអាចកែប្រែបាន ទៅតាមដំណើរការពិនិត្យតាមដាន និងវាយតម្លៃ (សូមមើលជំពូកខាងក្រោមការពិនិត្យតាមដាន និងការវាយតម្លៃ និងភាពអនុលោម)។

អភិក្រម/ឧបករណ៍ ដែលស្នើឡើង ៖

- សិក្ខាសាលាសម្រាប់អ្នកពាក់ព័ន្ធ (សូមមើល ***ឧបសម្ព័ន្ធទី ២***)
- ការសម្របសម្រួល (សូមមើល ***ឧបសម្ព័ន្ធទី ២***)
- ការរៀបចំចក្ខុវិស័យ (សូមមើល ***ឧបសម្ព័ន្ធទី ២***)

*ការកំណត់គោលបំណង ក៏ជាផ្នែកមួយដ៏សំខាន់របស់ដំណើរការ EAF ផងដែរ ហើយការណែនាំបន្ថែមមាននៅក្នុងសេចក្តីណែនាំបច្ចេកទេសរបស់ FAO អំពី EAF (សូមមើល FAO, 2003 and 2009b)។*

## ការបង្កើនចំណេះដឹង

### អ្នកពាក់ព័ន្ធ និងសិទ្ធិកាន់កាប់ដែលមានស្រាប់

**VGGT ការពារសិទ្ធិកាន់កាប់បែបទំនៀមទម្លាប់ដែលមានស្រាប់យ៉ាងខ្លាំងក្លា ហើយលើកឡើងថា ៖**

*នៅក្នុងករណីដែលរដ្ឋទាំងឡាយមានបំណងផ្តល់ការទទួលស្គាល់ ឬបែងចែកសិទ្ធិកាន់កាប់ ដំបូង រដ្ឋទាំងនេះគួរធ្វើការកំណត់ពីសិទ្ធិកាន់កាប់ដែលមានស្រាប់ និងអ្នកដែលមានសិទ្ធិទាំងនេះទាំងអស់សិន មិនថាមានការកត់ត្រាត្រឹមត្រូវ ឬអត់*

*នោះទេ។ ជនជាតិដើមភាគតិច និងសហគមន៍ដទៃទៀត ដែលប្រើប្រាស់ប្រព័ន្ធសិទ្ធិកាន់កាប់បែបទំនៀមទម្លាប់ អ្នកប្រកបរបរតូចតាច និងអ្នកផ្សេងទៀត ដែលអាចទទួលរងផលប៉ះពាល់ គួរចូលរួម នៅក្នុងដំណើរការពិគ្រោះយោបល់នេះ ស្របទៅតាមកថាខណ្ឌ ៣ខ.៦ និង៩.។ រដ្ឋគួរផ្តល់លទ្ធភាពឱ្យមានការទទួលបានយុត្តិធម៌ ស្របទៅតាមកថាខណ្ឌ ៤.៩ ប្រសិនបើប្រជាជនជឿថា សិទ្ធិកាន់កាប់របស់ពួកគេ មិនត្រូវបានគេទទួលស្គាល់។*

**(៧.៣ នៅក្នុង *ការការពារ* )**

នៅពេលរៀបចំផែនការ និងអនុវត្តប្រព័ន្ធសិទ្ធិកាន់កាប់ថ្មី ឬប្រព័ន្ធសិទ្ធិកាន់កាប់ដែលត្រូវបានកែប្រែ សកម្មភាពសំខាន់ដំបូងគេ ដែលត្រូវធ្វើ គឺការវិភាគអ្នកពាក់ព័ន្ធ។ ការវិភាគអ្នកពាក់ព័ន្ធ គួរធ្វើឡើងរួមគ្នា ជាមួយនឹងការពិនិត្យឡើងវិញលើប្រព័ន្ធសិទ្ធិកាន់កាប់ ដែលមានស្រាប់។ ចាំបាច់ត្រូវតែមានការគោរពសិទ្ធិប្រើប្រាស់បែបទំនៀមទម្លាប់ និងប្រពៃណីស្របច្បាប់សិន មុននឹងធ្វើការបែងចែកសិទ្ធិនានា។ ការវិភាគអ្នកពាក់ព័ន្ធ ក៏ជាឧបករណ៍វិភាគដ៏សំខាន់មួយ សម្រាប់ជម្រុញលើកកម្ពស់តម្លាភាពផងដែរ។

គួរមានការផ្តោតការយកចិត្តទុកដាក់ជាពិសេសលើជនជាតិដើមភាគតិច ហើយគួរមានការគោរពតាមលិខិតុបករណ៍ជាតិ និងអន្តរជាតិពាក់ព័ន្ធនានា។ លិខិតុបករណ៍ទាំងនេះផ្តល់នូវការណែនាំអំពីថាតើសិទ្ធិកាន់កាប់ណាខ្លះ ដែលគួរចាត់ទុកថាជាសិទ្ធិស្របច្បាប់។ មាត្រា ២៦ នៃសេចក្តីប្រកាសស្តីពីជនជាតិដើមភាគតិច លើកឡើងថា "ជនជាតិដើមភាគតិចមានសិទ្ធិទទួលបានដីធ្លី ដែនដី និងធនធាន ដែលពួកគេមានកម្មសិទ្ធិបែបប្រពៃណីកន្លងមក កាន់កាប់ ឬប្រើប្រាស់ ឬទទួលបាន។ នៅក្នុងវិស័យនេសាទ សិទ្ធិទទួលបានធនធានជាប្រពៃណី (ដូចជា ដីធ្លី និងធនធាននេសាទ ជាដើម) ច្រើនតែមានលើសពីក្រុមជនជាតិដើមភាគតិចទៅទៀត និងអនុវត្តចំពោះសហគមន៍នេសាទតូចតាចផងដែរ។ ក្រុមនេះលើកឡើងពីសារៈសំខាន់នៃការរៀបចំបែបប្រពៃណី និងជម្រុញឱ្យរដ្ឋធ្វើការពិចារណាលើសិទ្ធិទាំងនេះ ក្នុងការគ្រប់គ្រងធនធាននេសាទរបស់ខ្លួន ៖ "ដោយទទួលស្គាល់ពីការរួមចំណែកយ៉ាងសំខាន់របស់ការងារនេសាទតូចតាច និងជាលក្ខណៈសិប្បកម្ម ចំពោះការងារ ចំណូល និងសន្តិសុខស្បៀង រដ្ឋគួរផ្តល់ការការពារឱ្យបានសមស្របដល់សិទ្ធិរបស់អ្នកនេសាទ និងកម្មករនេសាទ ជាពិសេស អ្នកដែលប្រកបរបរនេសាទតូចតាច សម្រាប់ចិញ្ចឹមជីវិត ក្នុងលក្ខណៈសិប្បកម្ម ក្នុងការទទួលបានជីវភាពរស់នៅ ដោយយុត្តិធម៌ និង

ជាប់លាប់ ក៏ដូចជាអាទិភាពរបស់ពួកគេ ក្នុងការដែននេសាទ និងធនធាននេសាទ ក្នុងដែនទឹក ដែលពួកគេធ្លាប់តែទទួលបាន កន្លងមក ក្នុងយុត្តាធិការថ្នាក់ជាតិរបស់ពួកគេ ក្នុងករណីសមស្រប” (មាត្រា ៦.១៨)។

ស្ថានភាពរបស់អ្នកនេសាទ និងកម្មករនេសាទ ដែលជាជនចំណាកស្រុក គឺជាស្ថានភាពដែលមានលក្ខណៈពិសេស ពាក់ព័ន្ធជាមួយសិទ្ធិ ទាំងសិទ្ធិកាន់កាប់នៅក្នុងបរិបទនៃការទទួលបានធនធាននេសាទ និងធនធានដទៃទៀត (ដូចជា ដីធ្លី ជាដើម) ផង ទាំងសេវា ដែលចាំបាច់ សម្រាប់ធានាភាពជាប់លាប់នៃជីវភាពរស់នៅផង។ សិទ្ធិរបស់ពួកគេ ច្រើនតែមាន លក្ខណៈមិនផ្លូវការ ដូច្នេះសិទ្ធិទាំងនេះមិនទាន់ត្រូវបានគេធ្វើឱ្យស្របច្បាប់ឡើយ ហើយពេលខ្លះ មិនត្រូវបានគ្របដណ្តប់ ដោយការរៀបចំបែបទំនៀមទម្លាប់ក្នុងមូលដ្ឋានឡើយ។ នៅក្នុងការវិភាគលើអ្នកពាក់ព័ន្ធ ជាការសំខាន់ណាស់ ដែលត្រូវ ធានាយ៉ាងណាឱ្យមានការចូលរួមពីអ្នកនេសាទ និងកម្មករនេសាទ និងមានការយល់ដឹងដឹងពីប្រយោជន៍ ក្តីបារម្ភ និងសិទ្ធិ ក្រៅផ្លូវការរបស់ពួកគេ។

| **ការណែនាំទី ៤ ៖ ការវិភាគអ្នកពាក់ព័ន្ធ** |
|---|
| អ្នកពាក់ព័ន្ធ គឺជាអ្នកដែលមានប្រយោជន៍លើធនធាននេសាទ ដែលជាកម្មវត្ថុរបស់ប្រព័ន្ធសិទ្ធិកាន់កាប់ថ្មី ឬដែលត្រូវ បានកែប្រែ។ ការវិភាគអ្នកពាក់ព័ន្ធ ជួយកំណត់ក្នុងលក្ខណៈជាប្រព័ន្ធអំពីអ្នកពាក់ព័ន្ធ អំណាចរបស់ពួកគេ វិវាទដែលអាច កើតមានឡើង ការលើកទឹកចិត្ត និងទំនាក់ទំនងដទៃទៀត។ នៅក្នុងបរិបទនៃសិទ្ធិកាន់កាប់ ការវិភាគអ្នកពាក់ព័ន្ធក៏គួរមានដាក់ បញ្ចូលនូវសិទ្ធិកាន់កាប់បច្ចុប្បន្នរបស់ពួកគេផងដែរ (បើមាន) និងលក្ខណៈរបស់សិទ្ធិទាំងនេះ។ ក៏ចាំបាច់ត្រូវមានការស៊ើប អង្កេតលើវិធាន និងទំនាក់ទំនងនានាផងដែរ ដោយមានជំនួយពីការវិភាគស្ថាប័ន និងបណ្តាញនានា។ អ្វីដែលមានសារៈសំខាន់ ជាពិសេស គឺត្រូវកំណត់រកក្រុមអ្នកពាក់ព័ន្ធខ្សោយៗ ដូចជា ស្ត្រី ក្រុមជនជាតិដើមភាគតិច និងក្រុមដែលងាយរងគ្រោះដទៃ ទៀត ជាដើម។ |
| អភិក្រម/ឧបករណ៍ ដែលស្នើឱ្យយកមកប្រើប្រាស់ ៖<br>ការវិភាគអ្នកពាក់ព័ន្ធ (សូមមើល ***ឧបសម្ព័ន្ធទី ២***) - រួមមានការកំណត់ពីសិទ្ធិកាន់កាប់ដែលមានស្រាប់<br>ការវិភាគស្ថាប័ន និងបណ្តាញ |

**VGGT បង្ហាញពីសារៈសំខាន់នៃការប្រើប្រាស់អភិក្រមសកម្ម ដើម្បីសម្រេចនូវសមភាពយេនឌ័រ ៖**

*រដ្ឋគួរពិចារណាអនុម័តនូវក្របខ័ណ្ឌគោលនយោបាយ ច្បាប់ និងស្ថាប័នរបស់ខ្លួន ដើម្បីផ្តល់ការទទួលស្គាល់ដល់ប្រព័ន្ធសិទ្ធិកាន់កាប់របស់ជនជាតិដើមភាគតិច និងសហគមន៍ដទៃទៀត ដែលមានប្រព័ន្ធសិទ្ធិកាន់កាប់បែបទំនៀមទម្លាប់។ នៅក្នុងករណីដែលកំណែទម្រង់រដ្ឋធម្មនុញ្ញ ឬកំណែទម្រង់ច្បាប់ ពង្រឹងសិទ្ធិរបស់ស្ត្រី ហើយធ្វើឱ្យសិទ្ធិទាំងនេះមានភាពប្រទាំងប្រទើសជាមួយនឹងទំនៀមទម្លាប់ គ្រប់ភាគីទាំងអស់គួរសហការគ្នា ដើម្បីសម្រាប់ទៅតាមការផ្លាស់ប្តូរ នៅក្នុងប្រព័ន្ធសិទ្ធិកាន់កាប់បែបទំនៀមទម្លាប់ទាំងនេះ។*

**(៣ក នៅក្នុង *គោលការណ៍ណែនាំអំពីអភិបាលកិច្ចលើសិទ្ធិកាន់កាប់ប្រកបដោយការទទួលខុសត្រូវ*)**

គេចាំបាច់ត្រូវយល់ពីសិទ្ធិកាន់កាប់ដែលមានស្រាប់ មិនត្រឹមតែ ដើម្បីធានាឱ្យមានភាពយុត្តិធម៌ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដោយសារតែសិទ្ធិទាំងនេះ គឺជាមូលដ្ឋានដ៏មានប្រយោជន៍ និងប្រកបដោយអានុភាព សម្រាប់ប្រព័ន្ធថ្មី ឬប្រព័ន្ធដែលត្រូវបានកែសម្រួលផងដែរ។ ការរៀបចំប្រព័ន្ធសិទ្ធិកាន់កាប់ថ្មី អាចផ្តួចផ្តើមឱ្យមាន ដោយសារតែការរៀបចំបច្ចុប្បន្ននេះលែងមានដំណើរការទៀត។ ប៉ុន្តែ ជារឿយៗ ប្រព័ន្ធបែបទំនៀមទម្លាប់ មានការវិវឌ្ឍក្នុងរយៈពេលមួយដ៏យូរ ដោយមានការពិចារណាលើកាលៈទេសៈនៅមូលដ្ឋាន ដោយនាំឱ្យគេអាចបង្កើតនូវស្ថាប័នរស់រវើក និងមានភាពបត់បែន ដែលអាចដាក់ឱ្យអនុវត្តបាន (Aswani, 2005; សូមមើលប្រអប់ទី ១២)។ ប៉ុន្តែ ត្រូវតែមានការយកចិត្តទុកដាក់ ដើម្បីធានាយ៉ាងណាកុំឱ្យប្រព័ន្ធសិទ្ធិកាន់កាប់ថ្មីនេះបង្កឱ្យមានបញ្ហាវិសមភាពដដែលៗ ដូចនៅក្នុងប្រព័ន្ធកន្លងមក ឧទាហរណ៍ នៅក្នុងបរិបទបែបទំនៀមទម្លាប់កន្លងមក ស្ត្រីតែងតែមានតួនាទី ដែលចាញ់ប្រៀបគេ។ ក៏មានផងដែរនូវហានិភ័យដែលថា ស្ថានភាពច្បាប់ចម្រុះ - ពោលគឺ "មាន យន្តការច្បាប់ផ្សេងៗពីគ្នា ត្រូវបានគេយកមកអនុវត្តចំពោះស្ថានភាពដូចគ្នា" (Bavinck, 2005) - អាចនាំឱ្យមានវិវាទ និងការបែកបាក់គ្នា ដោយសារតែក្រុមផ្សេងៗគ្នាខិតខំទាញប្រយោជន៍ពីធនធានទាំងនេះ ទៅតាមប្រព័ន្ធដែលសមស្របចំពោះប្រយោជន៍របស់ពួកគេជាង (Bavinck, 2005)។

**ប្រអប់ទី ១៣ ៖ ការដាក់បញ្ចូលសិទ្ធិបែបប្រពៃណី**

នៅ Gouyave ក្នុងប្រទេស Grenada វិវាទ និងវិធានជាប្រពៃណីទប់ទល់នឹងការការច្រោះដីមាត់ឆ្នេរ បានជម្រុញឱ្យមានការរៀបចំនូវសិទ្ធិកាន់កាប់ និងច្បាប់ស្តីពីសិទ្ធិថ្មីមួយ។ តែទោះជាយ៉ាងណាក៏ដោយ សិទ្ធិជាប្រពៃណីទាំងឡាយ នៅតែជាសមាសភាគរឹងមាំមួយរបស់ប្រព័ន្ធថ្មីនេះ ហើយច្បាប់មិនបានជំនួសឱ្យគ្រប់សិទ្ធិ និងវិធានក្រៅផ្លូវការទាំងអស់ឡើយ។ កត្តាសំខាន់មួយ ដើម្បីឱ្យប្រព័ន្ធនេះទទួលបានជោគជ័យ គឺកម្រិត ដែលច្បាប់នេះផ្តល់លទ្ធភាពឱ្យមានការបកស្រាយ នៅថ្នាក់មូលដ្ឋាន និងការរៀបចំវិធានសម្រាប់ដីមាត់ឆ្នេរបន្តធ្វើឡើង តាមរយៈស្ថាប័នក្រៅផ្លូវការដែលមានស្រាប់។ ស្ថាប័នទាំងនេះត្រូវបានបំពេញបន្ថែម ដោយប្រព័ន្ធយុត្តិធម៌ផ្លូវការ ប៉ុន្តែមិនបានជំនួសចេញនោះទេ។

*ប្រភព ៖* Finlay and McConney (2011)

នៅពេលពិនិត្យលើសិទ្ធិកាន់កាប់ដែលកំពុងមាន សិទ្ធិរបស់អ្នកប្រើប្រាស់ នៅក្នុងវិស័យដទៃទៀត ក៏ចាំបាច់ត្រូវតែយកមកធ្វើការពិចារណាផងដែរ។ ជារឿយៗ តែងមានការប្រជែងគ្នា ដើម្បីបានទឹកយកមកប្រើប្រាស់ ហើយការប្រជែងគ្នានេះកំពុងមានការកើនឡើង។ ជារឿយៗ សហគមន៍នេសាទតូចតាច ទទួលរងផលប៉ះពាល់ ដោយសារតែវិស័យផ្សេងទៀត ដែលគេផ្តល់អាទិភាពឱ្យនៅតាមតំបន់ឆ្នេរ - ដូចជា វិស័យទេសចរណ៍ ថាមពល អភិវឌ្ឍន៍ឧស្សាហកម្ម ជាដើម - ដែលនាំឱ្យមានការព្រងើយកន្តើយចំពោះសិទ្ធិបែបទំនៀមទម្លាប់ ប៉ុន្តែក៏អាចមានផងដែរនូវស្ថានភាព ដូចជា ស្ថានភាពដែលកសិករមានការទាមទារស្របច្បាប់លើធនធានទឹក សម្រាប់គោលបំណងស្រោចស្រព។ ក្នុងពេលថ្មីៗនេះ គេឃើញមានការកើនឡើងនូវចំនួនតំបន់ការពារក្នុងដែនសមុទ្ទ (MPAs) ដែលរៀបចំឡើង ស្របទៅតាមការប្តេជ្ញាចិត្តជាអន្តរជាតិផ្នែកជីវចម្រុះ។[22] ខណៈពេលដែលទស្សនទាន MPAs ដំបូងឡើយ មានទំនាក់ទំនងយ៉ាងជិតស្និទជាមួយនឹងការអភិរក្សជីវចម្រុះ ឥឡូវនេះ មានការយល់ដឹងកាន់តែប្រសើរជាងមុនអំពីភាពចាំបាច់ ដើម្បីអនុវត្ត MPAs នៅក្នុងក្របខ័ណ្ឌពហុវិស័យ ដែលមានការសម្រុះសម្រួលគ្នា។ ដំណើរការរៀបចំផែនការ និងអនុវត្ត MPAs មានសារៈសំខាន់ចំពោះជោគជ័យរបស់តំបន់ទាំងនេះ ហើយការ

[22] ឧទាហរណ៍ ផែនការអនុវត្តរបស់កិច្ចប្រជុំកំពូលពិភពលោកស្តីពីការអភិវឌ្ឍប្រកបដោយចីរភាព ទីក្រុង Johannesburg ប្រទេសអាហ្វ្រិចខាងត្បូង ឆ្នាំ ២០០២។

ចូលរួម និងការចាប់អារម្មណ៍របស់អ្នកនេសាទ សហគមន៍របស់ពួកគេ និងអ្នកពាក់ព័ន្ធដទៃទៀត ក៏ជាបុរេលក្ខខណ្ឌមួយផងដែរ (សូមមើលប្រអប់ទី ១៤)។

**ប្រអប់ទី ១៤ ៖ ករណីតំបន់ការពារក្នុងដែនសមុទ្ទ (MPAs)**

មានករណី ដែលការបង្កើត MPAs នាំឱ្យចុះខ្សោយដល់សិទ្ធិកាន់កាប់របស់សហគមន៍នេសាទ។ នៅក្នុងករណីទាំងនេះ ការអនុវត្ត MPA មានទំនាក់ទំនងជាមួយនឹងជាមួយនឹងវិវាទ ការបដិសេធមិនឱ្យមានការប្រកបរបរចិញ្ចឹមជីវិត និងធ្វើឱ្យប្រជាពលរដ្ឋក្នុងមូលដ្ឋានធ្លាក់ចូលក្នុងភាពក្រីក្រ ឬថែមទាំងប្រព្រឹត្តបទល្មើសទៀតផង ៖

- នៅ Guam ដែលស្ថិតនៅក្នុងសមុទ្ទប៉ាស៊ីហ្វិចភាគខាងលិច អ្នកនេសាទបាត់បង់សិទ្ធិលើដែននេសាទ ដោយសារតែមានការបង្កើត MPAs ចំនួន ៥ ក្នុងឆ្នាំ ១៩៩៧ នៅក្នុងតំបន់នេសាទ Chamorro នៅឆ្នេរភាគខាងលិច ដែលពួកគេធ្លាប់តែនេសាទជាប្រពៃណីកន្លងមក។ ការនេសាទប្រភេទត្រីជាច្រើន និងបច្ចេកទេសនេសាទភាគច្រើន ត្រូវបានហាមឃាត់ នៅក្នុង MPAs ទាំងនេះ។ នេះក៏មានផលវិបាកផ្នែកសុវត្ថិភាពផងដែរ ដោយសារតែអ្នកនេសាទត្រូវបានគេបង្ខំឱ្យទៅនេសាទនៅឆ្នេរខាងកើត ដែលសម្បូរខ្យល់បក់ខ្លាំង។ ការសិក្សាមួយបង្ហាញថា ចំនួនករណីស្លាប់ របស់អ្នកនេសាទ Chamorro ដោយសារលង់ទឹក កើនឡើងជិត ២ ដង ក្រោយពេលបង្កើតតំបន់ការពារក្នុងដែន សមុទ្ទទាំងនេះ។

- ឧទ្យានសមុទ្ទជាតិ Had Chao Mai នៅក្នុងប្រទេសថៃ ត្រូវបានបង្កើតឡើង ដោយពុំមានការពិគ្រោះយោបល់ជាមួយនឹងសហគមន៍មូលដ្ឋានឡើយ។ ព្រំដែនរបស់តំបន់ការពារក្នុងដែនសមុទ្ទនេះ និងវិធាននានាក៏ពុំមានភាពច្បាស់លាស់ ហើយជម្លោះរវាងសហគមន៍ និងអាជ្ញាធរគ្រប់គ្រង តែងតែកើតមានឡើង។ សហគមន៍ ដែលមានទីតាំងនៅក្នុងឧទ្យាននេះ ប្រឈមនឹងបញ្ហាបន្ថែមទៀត ដោយសារតែពួកគេជាច្រើននាក់មិនមានប័ណ្ណ ឬឯកសារកម្មសិទ្ធិដីធ្លី សូម្បីតែដីធ្លី ដែលចាំបាច់សម្រាប់សង់ជម្រក និងរបរកសិកម្មរបស់ពួកគេ។ ចុងក្រោយ ពួកគេទទួលរងការគំរាមកំហែង ជាមួយនឹងការបាត់បង់ទីលំនៅ។

ក៏មានករណីជាច្រើនផងដែរ ដែលសិទ្ធិកាន់កាប់ត្រូវបានពង្រឹង នៅក្នុងការអនុវត្តតំបន់ការពារក្នុងដែនសមុទ្ទ។ នៅ

ក្នុងគ្រប់ករណីទាំងអស់នេះ គេអាចមើលឃើញថា ការពង្រឹងសិទ្ធិកាន់កាប់ គឺជាកត្តាលើកទឹកចិត្តដ៏រឹងមាំមួយសម្រាប់សហគមន៍ ដែលទទួលយក MPAs ដោយផ្តល់លទ្ធភាពឱ្យពួកគេអាចផាត់អ្នកដទៃទៀត ដូចជា អ្នកនេសាទ ជាដើម ពីតំបន់ផ្សេងទៀត ឬក្រុមតាមវិស័យដទៃទៀត ដូចជា វិស័យទេសចរណ៍ និងវិស័យប្រេង ជាដើម។ ឧទាហរណ៍ ដែលគេដឹងច្រើនជាងគេមួយចំនួន រួមមាន តំបន់សមុទ្រដែលគ្រប់គ្រងក្នុងមូលដ្ឋាន (LMMAs) ដែលត្រូវបានបង្កើត នៅតាមបណ្តាប្រទេសក្នុងសមុទ្រប៉ាស៊ីហ្វិច និងប្រទេសមួយចំនួនតូចនៅអាស៊ី។ LMMA ច្រើនតែជាតំបន់ នៅជិតឆ្នេរ ដែលគ្រប់គ្រងដោយសហគមន៍មូលដ្ឋាន ឬសហការគ្រប់គ្រង ដោយសហគមន៍ដែលរស់នៅជិតតំបន់ទាំងនេះ រួមជាមួយនឹងអាជ្ញាធរមូលដ្ឋាន និង/ឬអង្គការដៃគូ ហើយត្រូវបានគេចាត់ថាជាកម្មសិទ្ធិ និង/ឬស្ថិតក្រោមការត្រួតពិនិត្យរបស់អ្នកនៅមូលដ្ឋាន។

ដូច្នេះ គេអាចកត់សម្គាល់ដឹងថា ការបញ្ជាក់ឱ្យបានច្បាស់លាស់អំពីការរៀបចំសិទ្ធិកាន់កាប់ ត្រូវតែជាសមាសភាគសំខាន់មួយ នៅក្នុងការរៀបចំផែនការ និងការអនុវត្ត MPA។ ជារួម ការអនុវត្ត MPA ត្រូវតែបោះជំហានទៅរកសមធម៌ និងការចូលរួម ដែលជាគោលដៅចុងក្រោយផង និងជាមធ្យោបាយ ដើម្បីឱ្យមានការអភិរក្ស និងការគ្រប់គ្រងប្រកបដោយនិរន្តរភាពផង។

*ប្រភព ៖* Sharma and Rajagopalan (2011), citing the Western Pcific Regional Fisheries Management Council (2010); Prasertcharoeunsuk and Shott (2010); Govan (2009). See also FAO (2011b) and www.lmmanetwork.org

## ការប៉ាន់ប្រមាណពីតម្លៃរបស់សិទ្ធិកាន់កាប់

**VGGT ទទួលស្គាល់ថា តម្លៃរបស់សិទ្ធិកាន់កាប់ មិនមែនឆ្លុះបញ្ចាំងក្នុងតម្លៃទីផ្សារ ជានិច្ចកាលនោះទេ ហើយផ្តល់អនុសាសន៍ថា ៖**

*.... រដ្ឋគួរចាត់វិធានការនានា ដើម្បីបង្ការមិនឱ្យមានផលប៉ះពាល់ ដែលគេមិនចង់បានមកលើសហគមន៍មូលដ្ឋានជនជាតិដើមភាគតិច និងក្រុមងាយរងគ្រោះ ដែលអាចកើតឡើង ដោយសារការបំប៉ោងដីធ្លី ការប្រមូលផ្តុំដីធ្លី និងការបំពេញសិទ្ធិកាន់កាប់បែបទំនៀមទម្លាប់។ រដ្ឋ និងភាគីដទៃទៀត គួរទទួលស្គាល់ថា តម្លៃនានា ដូចជា តម្លៃសង្គម វប្បធម៌ និង*

*បរិស្ថានជាដើម មិនមែនជានិច្ចកាល ត្រូវបានឆ្លុះបញ្ចាំង នៅក្នុងទីផ្សារ ដែលពុំមានច្បាប់ទម្លាប់គ្រប់គ្រងត្រឹមត្រូវនោះឡើយ។ រដ្ឋគួរការពារផលប្រយោជន៍ទូទៅរបស់សង្គម តាមរយៈគោលនយោបាយ និងច្បាប់ស្ដីពីសិទ្ធិកាន់កាប់ ដែលមានលក្ខណៈសមស្រប។*

**(១១.២ នៅក្នុង ទីផ្សារ )**

ដូចដែលបានកត់សម្គាល់ នៅក្នុងផ្នែកទី ១ តម្លៃរបស់សិទ្ធិកាន់កាប់ នៅក្នុងវិស័យនេសាទ អាចមើលឃើញក្នុងទស្សនៈវិស័យចំនួន ២ ៖ តម្លៃរបស់សិទ្ធិខ្លួនឯង ក្នុងនាមជាមូលដ្ឋាននៃសន្តិសុខ និងជីវភាពរស់នៅ និងយោងទៅតាមតម្លៃរបស់ធនធាននេសាទ និងសារៈសំខាន់ផ្នែកសេដ្ឋកិច្ច សង្គម និងវប្បធម៌របស់សកម្មភាពនេសាទ (និងរបស់សកម្មភាពពាក់ព័ន្ធដទៃទៀត) ក៏ដូចជាតម្លៃ ដែលមាននៅក្នុងសេវាប្រព័ន្ធអេកូឡូហ្ស៊ី។ ខណៈពេលដែលតម្លៃរបស់សិទ្ធិខ្លួនឯងមានសារៈ-សំខាន់ គេពិបាកនឹងកំណត់ចេញថាមានតម្លៃប៉ុន្មានគិតជារូបិយប័ណ្ណជាក់ស្ដែងណាស់ ហើយការពិភាក្សានៅទីនេះផ្ដោតសំខាន់លើតម្លៃរបស់ធនធាននេសាទ សកម្មភាពនេសាទ និងសេវាប្រព័ន្ធអេកូឡូហ្ស៊ី។ តម្លៃទាំងនេះមិនងាយនឹងកំណត់ឡើយ ប៉ុន្តែមានវិធីសាស្ត្រផ្សេងៗ ដែលគេអាចប្រើប្រាស់ សម្រាប់គោលបំណងនេះបាន។ អភិក្រមទាំងនេះ រួមមាន ការរៀបចំគំរូសេដ្ឋកិច្ចជីវសាស្ត្រ ការវាយតម្លៃសេដ្ឋកិច្ច និងការវាយតម្លៃផលប៉ះពាល់សង្គម (SIAs)។ សិទ្ធិកាន់កាប់ប្រភេទផ្សេងៗគ្នា លើធនធាននេសាទតែមួយ អាចមានតម្លៃផ្សេងៗគ្នា អាស្រ័យលើថាតើគេធ្វើការប៉ាន់ប្រមាណលើសមាសភាគផ្សេងៗរបស់តម្លៃដោយរបៀបណា ក្រោមសេណារីយ៉ូផ្សេងៗគ្នា។

| **ការណែនាំទី ៥ ៖ វិធីសាស្ត្រវាយតម្លៃ** |
|---|
| ការប្រើប្រាស់វិធីសាស្ត្រវាយតម្លៃផ្សេងៗគ្នា រួមជាមួយគ្នា ទំនងជាចាំបាច់ត្រូវតែធ្វើឡើង ដើម្បីបង្កើតនូវមូលដ្ឋានសម្រាប់ការធ្វើសេចក្ដីសម្រេចចិត្តផ្នែកនយោបាយ ដែលចាំបាច់ អំពីប្រព័ន្ធសិទ្ធិកាន់កាប់ ដែលត្រូវរៀបចំឡើង និងរបៀបធ្វើការបែងចែក និង/ឬផ្ទេរសិទ្ធិនានា។ ការវិភាគគ្រប់ជ្រុងជ្រោយលើជម្រើសផ្សេងៗ ដូចជា ការពិចារណាលើសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ការលុបបំបាត់ភាពក្រីក្រ ការអភិវឌ្ឍប្រកបដោយសមធម៌ និងការប្រើប្រាស់ធនធានប្រកបដោយនិរន្តរភាព គឺជាអ្វីដែលគួរធ្វើឡើង ដើម្បីធានាយ៉ាងណាឱ្យមានការដាក់ឱ្យអនុវត្តនូវប្រព័ន្ធសិទ្ធិកាន់កាប់ ដែលមានប្រសិទ្ធភាពបំផុត និង |

| |
|---|
| មានភាពស៊ីសង្វាក់គ្នា ជាមួយនឹងគោលបំណងសង្គមជារួម (សូមមើលផ្នែកកំណត់គោលបំណង ខាងលើ)។ |
| អភិក្រម/ឧបករណ៍ ដែលស្នើឡើង ៖<br>- ការបង្កើតនូវគំរូសេដ្ឋកិច្ចជីវសាស្ត្រ<br>- វិធីសាស្ត្រវាយតម្លៃសេដ្ឋកិច្ច (សូមមើលឧបសម្ព័ន្ធទី ២)<br>- SIA |

## ការវិនិយោគ

> **VGGT គាំទ្រដល់ការវិនិយោគប្រកបដោយការទទួលខុសត្រូវ និងធ្វើការប្រកាសថា ៖**
>
> *តួអង្គរដ្ឋ និងតួអង្គមិនមែនរដ្ឋ គួរទទួលស្គាល់ថា ការវិនិយោគសាធារណៈ និងឯកជនប្រកបដោយការទទួលខុសត្រូវ មានសារៈសំខាន់ចំពោះការលើកកម្ពស់សន្តិសុខស្បៀង។ អភិបាលកិច្ចលើសិទ្ធិកាន់កាប់ដីធ្លី ធនធាននេសាទ និងធនធានព្រៃឈើប្រកបដោយការទទួលខុសត្រូវ លើកទឹកចិត្តឱ្យអ្នកដែលមានសិទ្ធិកាន់កាប់ ធ្វើការវិនិយោគប្រកបដោយការទទួលខុសត្រូវលើធនធានទាំងនេះ សម្រាប់បង្កើនផលិតកម្មកសិកម្មប្រកបដោយនិរន្តរភាព និងបង្កើតចំណូលឱ្យបានកាន់តែច្រើនជាងមុន។ រដ្ឋគួរលើកកម្ពស់ និងគាំទ្រដល់ការវិនិយោគប្រកបដោយការទទួលខុសត្រូវលើដីធ្លី ធនធាននេសាទ និងធនធានព្រៃឈើ ដែលគាំទ្រដល់គោលបំណងសង្គម សេដ្ឋកិច្ច និងបរិស្ថានទូលំទូលាយ ក្រោមប្រព័ន្ធកសិកម្មផ្សេងៗគ្នា។ រដ្ឋគួរធានាយ៉ាងណាឱ្យគ្រប់សកម្មភាពទាំងអស់ មានសង្គតភាព ជាមួយនឹងកាតព្វកិច្ចដែលមានស្រាប់ ក្រោមច្បាប់ជាតិ និងអន្តរជាតិ និងជាមួយនឹងការប្តេជ្ញាចិត្តស្ម័គ្រចិត្ត ក្រោមលិខិតុបករណ៍ថ្នាក់តំបន់ និងអន្តរជាតិ ដែលមានជាធរមាន។*
>
> **(១២.១ នៅក្នុង *ការវិនិយោគ* )**

ប្រសិនបើអភិបាលកិច្ច នៅក្នុងវិស័យនេះ និងការគ្រប់គ្រងធនធាននេសាទ ត្រូវបានកែលំអឱ្យបានកាន់តែប្រសើរជាងមុន ដើម្បីឱ្យការទាញប្រយោជន៍ពីធនធាននេះកាន់តែមាននិរន្តរភាពផ្នែកជីវសាស្ត្រ និងសេដ្ឋកិច្ច នោះតម្លៃរបស់ធនធាន និងសិទ្ធិកាន់កាប់ពាក់ព័ន្ធ នឹងមានការកើនឡើង។ មានការខិតខំធ្វើការវាយតម្លៃលើបរិមាណនៃការវិនិយោគ ដែលចាំបាច់

ដើម្បីធានាយ៉ាងណាឱ្យធនធាននេសាទក្នុងពិភពលោក អាចចូលរួមចំណែកពេញលេញទៅតាមសក្តានុពលរបស់ខ្លួន ចំពោះសេដ្ឋកិច្ច របស់ពិភពលោក ហើយហាក់បីដូចជា គេត្រូវការវិនិយោគនូវធនធានយ៉ាងច្រើនលើពូជត្រី ដែលត្រូវបានគេទាញប្រយោជន៍ ហួសកម្រិតកន្លងមកនេះ។ ការខាតបង់ ត្រូវបានគេប៉ាន់ប្រមាណនៅក្នុងការសិក្សា *The Sunken Billions* (សូមមើលទំព័រទី ៦) ត្រូវបានពន្យល់តាមរយៈស្ថានភាពសេដ្ឋកិច្ចអន់ថយរបស់វិស័យនេសាទ ដោយសារតែអភិបាលកិច្ចមានកម្រិតខ្សោយ ហើយនេះគឺជាមូលហេតុផង និងជាលទ្ធផលផងនៃការនេសាទហួសពីកម្រិតជីវសាស្ត្រ និងអប្រសិទ្ធភាពសេដ្ឋកិច្ច។ ការសិក្សានេះគាំទ្រដល់ការពង្រឹងសិទ្ធិកាន់កាប់ នៅក្នុងវិស័យនេសាទ ក្នុងគោលបំណងបង្កើននូវប្រយោជន៍ ដែលទទួលបានពីវិស័យនេសាទ។ ប៉ុន្តែ ការសិក្សានេះក៏ទទួលស្គាល់ផងដែរពីបញ្ហាប្រឈមសំខាន់ៗផ្នែកនយោបាយ សង្គម និងច្បាប់ ដែលអាចកើតមានឡើង។ ដូចគ្នានឹងការវិនិយោគដែលមានលក្ខណៈវិជ្ជមានយ៉ាងណាក៏ដោយ គេត្រូវទទួលរងការខាតបង់ និងការលះបង់ ជាមុនសិន ជាមួយនឹងសេចក្តីសង្ឃឹមថាគេនឹងទទួលបានអត្ថប្រយោជន៍សេដ្ឋកិច្ច នាពេលអនាគត (Munro, 2010)។

**VGGT លើកកម្ពស់ការវិនិយោគ ដែលមានប្រយោជន៍សម្រាប់អ្នកផលិតខ្នាតតូច និងលើកឡើងថា ៖**

*ដោយសារតែអ្នកផលិតតូចតាច និងអង្គការរបស់ពួកគេ នៅតាមប្រទេសកំពុងអភិវឌ្ឍ គឺជាអ្នកធ្វើការវិនិយោគលើវិស័យកសិកម្មមួយភាគធំ ដែលចូលរួមចំណែកយ៉ាងសំខាន់ ចំពោះសន្តិសុខស្បៀង អាហារូបត្ថម្ភ ការលុបបំបាត់ភាពក្រីក្រ និងភាពធន់របស់បរិស្ថាន រដ្ឋគួរផ្តល់ការគាំទ្រដល់ការវិនិយោគរបស់អ្នកផលិតតូចតាចទាំងនេះ ក៏ដូចជាការវិនិយោគសាធារណៈ និងឯកជន ដែលគិតគូរពីអ្នកផលិតតូចតាចទាមងនេះ។*

**(១២.២ នៅក្នុង *ការវិនិយោគ* )**

ផ្នែកម្ខាងទៀតនៃការវិនិយោគ គឺត្រូវពិនិត្យលើត្រី បន្ទាប់ពីចាប់បាន។ ប្រសិនបើគេអាចបង្កើនតម្លៃរបស់ត្រី ក្រោយយកមកដល់គោក ប្រយោជន៍ជារួម ដែលទទួលបានពីវិស័យនេសាទ នឹងមានការកើនឡើង រួមជាមួយនឹងតម្លៃរបស់សិទ្ធិកាន់កាប់ ដែលអនុញ្ញាតឱ្យមានការចាប់ត្រីនេះដែរ។ ដូច្នេះ ការវិនិយោគក្នុងវិស័យក្រោយប្រមូលផល ដែលកាត់បន្ថយការខាតបង់ក្រោយពេលប្រមូលផល និងបង្កើតនូវតម្លៃបន្ថែម សម្រាប់អ្នកនេសាទតូចតាច និងកម្មករនេសាទ អាចជាការវិនិយោគ

ដែលមានសារៈសំខាន់ផងដែរ។ ការលើកកម្ពស់លទ្ធភាពទទួលបានទីផ្សារ សម្រាប់វិស័យនេសាទខ្នាតតូច គឺជាអភិក្រម ដែលមានលក្ខណៈស្រដៀងគ្នានេះដែរ។ ប៉ុន្តែ អាចមានការដោះដូរ និងការសម្រេចចិត្តនយោបាយ ដែលត្រូវធ្វើឡើង ពាក់ព័ន្ធជាមួយនឹងថាតើគេត្រូវដោះស្រាយបញ្ហាសន្តិសុខស្បៀងរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន និងលទ្ធភាពទទួលបានផលិតផលនេសាទក្នុងតម្លៃសមរម្យដោយរបៀបណា សម្រាប់ក្រុមប្រជាជនក្រីក្រ ប្រសិនបើ ឧទាហរណ៍ មានការលើកទឹកចិត្តឱ្យមានការនាំចេញពីប្រទេសកំពុងអភិវឌ្ឍ ទៅកាន់ទីផ្សារនាំចេញ ដែលផ្តល់ប្រាក់ចំណេញច្រើន ក្នុងប្រទេសអភិវឌ្ឍ។ ទាំងនេះគឺជាការសម្រេចចិត្តផ្នែកនយោបាយ ដែលត្រូវធ្វើឡើង និងគួរយោងទៅតាមគោលបំណងសង្គមជារួម។ គួរចងចាំថា តម្លៃរបស់សកម្មភាពនេសាទ និងសកម្មភាពពាក់ព័ន្ធនានា មិនមែនតំណាងតែដោយតម្លៃជួល ដែលសកម្មភាពនេះបង្កើតឡើងនោះទេ។ ជារឿយៗ គេមានការលំបាកក្នុងការប៉ាន់ប្រមាណពីតម្លៃសេដ្ឋកិច្ច សង្គម និងវប្បធម៌ ក៏ដូចជាតម្លៃរបស់ប្រព័ន្ធអេកូឡូហ្ស៊ីឱ្យបានច្បាស់លាស់ណាស់ ប៉ុន្តែតម្លៃទាំងនេះសុទ្ធតែមានសារៈសំខាន់។

បន្ថែមពីលើការធ្វើឱ្យការគ្រប់គ្រងវិស័យនេសាទ កាន់តែមានភាពប្រសើរជាងមុន ការវិនិយោគលើចំណុចផ្សេងទៀត ពាក់ព័ន្ធជាមួយនឹងអភិបាលកិច្ចលើសិទ្ធិកាន់កាប់ ក៏មានសារៈសំខាន់ផងដែរ។ ការវិនិយោគទាំងនេះ តម្រូវឱ្យមានអន្តរាគមន៍ជាច្រើន និងមានការប្រែប្រួល ទៅតាមស្ថានភាពជាក់លាក់។ នៅក្នុងវិស័យនេសាទខ្នាតតូច ការកសាងសមត្ថភាព និងការអភិវឌ្ឍស្ថាប័ន ដើម្បីបង្កើនការយល់ដឹងអំពីសិទ្ធិ និងការទទួលខុសត្រូវរបស់អ្នកមានសិទ្ធិ និងដើម្បីលើកកម្ពស់សមត្ថភាពរបស់ពួកគេ ក្នុងការគ្រប់គ្រងធនធានប្រកបដោយនិរន្តរភាព ទំនងជាអ្វីដែលត្រូវមានឱ្យបានទូលំទូលាយ។ ចំណុចមួយចំនួន ក្នុងចំណោមចំណុចទាំងនេះ ត្រូវបានលើកយកមកពិភាក្សាក្នុងជំពូកការចាត់ចែងសិទ្ធិកាន់កាប់ ខាងក្រោម។

## ការបែងចែកសិទ្ធិ

### ដំណើរការនៃការបែងចែក

**VGGT លើកកម្ពស់ឱ្យមានការបែងចែកសិទ្ធិកាន់កាប់ប្រកបដោយយុត្តិធម៌ និងសមធម៌ និងលើកឡើងថា ៖**

*នៅពេលដែលរដ្ឋទទួលស្គាល់ ឬបែងចែកសិទ្ធិកាន់កាប់ដីធ្លី ធនធាននេសាទ និងធនធានព្រៃឈើ រដ្ឋគួរកំណត់ ទៅ*

*តាមច្បាប់ជាតិ នូវការការពារ ដើម្បីបញ្ចៀសមិនឱ្យមានការរំលោភ ឬការលុបបំបាត់សិទ្ធិរបស់អ្នកដទៃទៀត ដូចជា សិទ្ធិកាន់កាប់ស្របច្បាប់ ដែលមិនបានទទួលការការពារដោយច្បាប់ នាពេលបច្ចុប្បន្ននេះ។ ជាពិសេស ការការពារទាំងនេះ គួរផ្តល់ការការពារដល់ស្ត្រី និងជនងាយរងគ្រោះ ដែលមានសិទ្ធិកាន់កាប់បន្ទាប់បន្សំ ដូចជា សិទ្ធិប្រមូលផ្តុំគ្នា ជាដើម។*

**(៧.១ នៅក្នុង *ការការពារ* )**

នៅពេលដែលរដ្ឋាភិបាល (ឬអាជ្ញាធររដ្ឋាភិបាល ដូចជា នាយកដ្ឋានជលផល ឬស្ថាប័នទទួលខុសត្រូវកំណត់ពីតំបន់ការពារក្នុងដែនសមុទ្ទ) សម្រេចចិត្តធ្វើការបែងចែកសិទ្ធិថ្មីៗ ឬធ្វើឱ្យសិទ្ធិក្រៅផ្លូវការ បែបទំនៀមទម្លាប់ ដែលកំពុងមានក្លាយជាសិទ្ធិផ្លូវការ - មានការសម្រេចចិត្ត និងការពិចារណាជាច្រើន ដែលត្រូវធ្វើឡើង។ ការសម្រេចចិត្ត និងការពិចារណាមួយចំនួន ត្រូវបានលើកយកមកពិភាក្សាខាងលើ ដូចជា ការសម្រេចចិត្ត និងការពិចារណា ពាក់ព័ន្ធជាមួយនឹងគោលការណ៍ និងការការពារ ការកំណត់ពីគោលបំណង និងការកំណត់ពីអ្នកពាក់ព័ន្ធ និងសិទ្ធិដែលមានស្រាប់ ជាដើម។ លើសពីនេះ ការរៀបចំប្រព័ន្ធសិទ្ធិកាន់កាប់ ចាំបាច់ត្រូវតែដាក់បញ្ចូលនូវការសម្រេចចិត្តអំពីប្រភេទសិទ្ធិ ដែលគួរមាន។ ប្រភេទសិទ្ធិផ្សេងៗដែលមាននៅក្នុងវិស័យនេសាទ ត្រូវបានលើកយកមកពិភាក្សាខាងលើ នៅក្នុងផ្នែកទី ១ (សូមមើលផ្នែកតើមានសិទ្ធិកាន់ កាប់ផ្លូវការប្រភេទផ្សេងៗអ្វីខ្លះ នៅក្នុងវិស័យនេសាទ?)។ គួរចងចាំថា ជាទូទៅ សិទ្ធិកាន់កាប់ធនធាននេសាទ ចាំបាច់ត្រូវតែបញ្ចូលគ្នា ជាមួយនឹងលទ្ធភាពទទួលបានធនធានសំខាន់ៗដទៃទៀត ដូចជា ដីធ្លី ជាដើម ដើម្បីផ្តល់នូវមុខរបរចិញ្ចឹមជីវិតឱ្យបានជាប់លាប់ នៅតាមសហគមន៍នេសាទខ្នាតតូច។ ទស្សនទានថ្មីមួយ អាចចាំបាច់ត្រូវមាន នៅក្នុងបរិបទនេះ ដូចជា សិទ្ធិប្រកបរបរចិញ្ចឹមជីវិត តាមសហគមន៍ ដែលឆ្លុះបញ្ចាំងពីតម្រូវការធនធាននេសាទផង និងដីធ្លីផង និងភ្ជាប់ទំនាក់ទំនងរវាងសិទ្ធិជាមួយនឹងតម្រូវការជាមូលដ្ឋាន សម្រាប់ជីវភាពរស់នៅ (FAO, 2012c)។ ប៉ុន្តែ ក្នុងស្ថានភាពជាក់ស្តែងបច្ចុប្បន្ននេះ ទំនងជាសហគមន៍ចាំបាច់ត្រូវទទួលបានសិទ្ធិដោយឡែកសម្រាប់ដីធ្លី និងសិទ្ធិសម្រាប់ធ្វើការនេសាទ បើទោះបីជាការសហការអន្តរវិស័យ និងភាពស៊ីសង្វាក់ផ្នែកគោលនយោបាយ គួរធានាយ៉ាងណាឱ្យសិទ្ធិទាំងពីរនេះអាចបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមកយ៉ាងណាក៏ដោយ (សូមមើលផ្នែកកំណត់គោលបំណង ខាងលើ)។

**VGGT លើកឡើងពីភាពចាំបាច់ ដើម្បីឱ្យមានការរៀបចំផែនការទីតាំង និងភាពស៊ីសង្វាក់គ្នាអន្តរវិស័យ និងលើក ឡើងថា ៖**

*រដ្ឋគួរធានាយ៉ាងណាឱ្យមានការរៀបចំផែនការទីតាំង ដោយមានច្បាប់គ្រប់គ្រងត្រឹមត្រូវ តាមបែបផែនមួយ ដែលទទួលស្គាល់ពីទំនាក់ទំនងរវាងគ្នាទៅវិញទៅមក រវាងដីធ្លី ធនធាននេសាទ និងធនធានព្រៃឈើ និងការប្រើប្រាស់ធនធានទាំងនេះ ក្នុងនោះរាប់បញ្ចូលទាំងទិដ្ឋភាពយេនឌ័រនៃការប្រើប្រាស់ធនធានទាំងនេះផងដែរ។*

**(២០.៣ នៅក្នុង *ការរៀបចំផែនការទីតាំង ដោយមានច្បាប់គ្រប់គ្រងត្រឹមត្រូវ*)**

ពាក់ព័ន្ធជាមួយនឹងធនធាននេសាទ និងការសម្រេចចិត្តអំពីប្រភេទសិទ្ធិនានា គេចាំបាច់ត្រូវធ្វើការកំណត់ថាតើសិទ្ធិណាខ្លះ ដែលគួរបែងចែកទៅឱ្យបុគ្គល ក្រុមបុគ្គល ឬសហគមន៍នានា។ នៅក្នុងវិស័យនេសាទដែលទើបបង្កើតឡើងថ្មីៗ ដែលមានលក្ខណៈជាទ្រង់ទ្រាយធំ ឬដែលធ្វើឡើង នៅតំបន់ណាមួយ សិទ្ធិរបស់បុគ្គល អាចជាសិទ្ធិសមស្រប។ សិទ្ធិទាំងនេះគួររៀបចំឡើង ដោយមានការដាក់កំហិតលើប្រយោជន៍ ដែលសហគមន៍អាចទទួលបាន។ នៅក្នុងស្ថានភាពមួយផ្សេងទៀត នៅក្នុងករណីដែលមានសិទ្ធិសហគមន៍បែបទំនៀមទម្លាប់ គេអាចពង្រឹងសិទ្ធិទាំងនេះបាន ដូច្នេះសិទ្ធិទាំងនេះ នៅតែមាននៅក្នុងសហគមន៍ ឬត្រូវបានបែងចែកទៅឱ្យអ្នកប្រើប្រាស់មួយក្រុមណាមួយ (ដូចជា សមាគមអ្នកនេសាទ ជាដើម)។ នៅក្នុងករណីភាគច្រើន សិទ្ធិជាសមូហភាពទាំងនេះ នឹងត្រូវបែងចែកបន្ថែមទៀត នៅក្នុងសហគមន៍ ឬក្នុងសមាគមរបស់អ្នកប្រើប្រាស់ (សូមមើលប្រអប់ទី ១៥)។ ចំណុចពាក់ព័ន្ធមួយ ដែលត្រូវលើកយកមកពិភាក្សា គឺនិយមន័យរបស់ពាក្យថា "សហគមន៍។ នៅក្នុងករណីជាច្រើន គេអាចកំណត់សហគមន៍បានយ៉ាងច្បាស់លាស់ ទៅតាមទីតាំងភូមិសាស្ត្រ។ នៅក្នុងស្ថានភាពដទៃទៀត សហគមន៍អាចជាក្រុមដែលមានប្រយោជន៍ដូចគ្នា ដូចជា អ្នកដែលប្រើប្រាស់ឧបករណ៍នេសាទដូចគ្នា ហើយសមាជិករបស់សហគមន៍អាចនៅរាយប៉ាយពីគ្នា (Shotton, 2000)។

**ប្រអប់ទី ១៥ ៖ ប្រព័ន្ធ "parcela" របស់អ្នកប្រមូលសារាយសមុទ្រនៅប្រទេសឈីលី**

ប្រព័ន្ធសិទ្ធិកាន់កាប់តាមបែបប្រពៃណី សម្រាប់ការប្រមូលប្រភេទសារាយសមុទ្រ ដែលមានឈ្មោះថា bull-kelp ត្រូវបានដាក់ឱ្យអនុវត្ត និងកែសម្រួល រាប់ជំនាន់មកហើយ នៅភាគកណ្តាលប្រទេសឈីលី។ ប្រព័ន្ធនេះ រួមមាន ការបែងចែកសិទ្ធិប្រើប្រាស់ តាមរបៀបវិលជុំ ទៅឱ្យសមាជិករបស់សមាគមអ្នកនេសាទ (និងគ្រួសាររបស់ពួកគេ) ដើម្បីធ្វើការប្រមូលសារ៉ាយសមុទ្រ ដែលមានឈ្មោះថា cochayuyo *(Durvilea antarctica)* នៅក្នុងតំបន់ឆ្នេរ ឬ "parcelas" (ដែលមានឆ្នេរ

ប្រវែងប្រហែល ជា ១០០-១៥០ ម៉ែត្រ)។ សារ៉ាយសមុទ្រនេះ ត្រូវបានយកចេញពីតំបន់ ដែលស្ថិតនៅចន្លោះរលកតូច និងធំ និងតំបន់ទឹករាក់ តាមរយៈការកាត់រុក្ខជាតិ នៅបាត់សមុទ្រ នៅក្នុងពេលដែលមានរលកទាបៗ និងបន្ទាប់មក ប្រមូលសារ៉ាយទាំងនេះមកកាន់ច្រាំងឆ្នេរ។ parcelas ត្រូវបានកំណត់ ផ្អែកទៅតាមផលិតកម្ម មិនមែនទៅតាមទំហំនោះទេ ហើយត្រូវបានកំណត់ដោយគូសតាមបន្ទាត់ ដែលគេស្រម៉ៃ ចេញពីដុំថ្មណាមួយ នៅតំបន់ចន្លោះដែលមានរលកធំ និងតូច ទៅដុំថ្មមួយទៀត។ តំបន់ទាំងនេះត្រូវបានបែងចែក ទៅឱ្យសមាជិកម្នាក់ៗ រៀងរាល់ ១-២ ឆ្នាំម្តង នៅដើមរដូវប្រមូលផល តាមរយៈការចាប់ឆ្នោត ដោយមានការគ្រប់គ្រង ដោយអ្នកដឹកនាំសមាគម។ អ្នកដែលកាន់កាប់ parcelas ត្រូវបានអនុញ្ញាតឱ្យធ្វើការប្រមូលសារ៉ាយទាំងនេះ អមជាមួយនឹងសមាជិកគ្រួសាររបស់ពួកគេ ឬផ្ទេរសិទ្ធិប្រមូលផលរបស់ខ្លួន ទៅឱ្យអ្នកដទៃទៀត ជាការផ្លោះប្តូរជាមួយនឹងការទូទាត់ជាប្រាក់ ឬមិនមែនជាប្រាក់ (ជារឿយៗ ធ្វើឡើងដោយសមាជិក ដែលមានវ័យចំណាស់ ឬពិការ)។ អ្នកកាន់កាប់ parcelas ធ្វើការសម្រេចចិត្តថាតើត្រូវគ្រប់គ្រង parcelas នេះយ៉ាងដូចម្តេច។ ការអនុវត្តធម្មតា គឺត្រូវសំអាតថ្ម ដកយកពពួក kelp ផ្សេងចេញ ដើម្បីឱ្យមានសារ៉ាយ cochayuyo ដុះកាន់តែច្រើនជាងមុន។

*ប្រភព ៖* Orensanz *et al.* (2011)

## ការណែនាំទី ៦ ៖ បញ្ជីត្រួតពិនិត្យ សម្រាប់ជ្រើសរើសរបបសិទ្ធិ

បញ្ជីត្រួតពិនិត្យ សម្រាប់ពិនិត្យលើភាពសមស្របរបស់ប្រព័ន្ធសិទ្ធិណាមួយ គួរដាក់បញ្ចូលនូវសំណួរដូចខាងក្រោម (ដកស្រង់ចេញពី p.11, Kurien, 1998, cited in WHAT, 2000) ៖

- តើរបបសិទ្ធិ មានភាពសមស្របជាមួយនឹង "លក្ខណៈធម្មជាតិដើម" របស់ធនធាន ដែលត្រូវគ្រប់គ្រង ដែរឬទេ?
- តើរបបសិទ្ធិនឹងធានាឱ្យមានតុល្យភាពរវាងផលិតភាពរបស់ធនធាន និងស្ថានភាពរបស់ធនធានដែលមានដែរឬទេ?
- តើរបបសិទ្ធិនេះមានភាពសមស្រប ជាមួយនឹងច្បាប់អន្តរជាតិ ដែលមានស្រាប់ ដែរឬទេ?
- តើវាជួយឱ្យមានតុល្យភាពរវាងវិវាទនានា ដែលទំនងជាកើតមានឡើងរវាងការប្រើប្រាស់ធនធាន សម្រាប់គោលបំណងសេដ្ឋកិច្ច និងសង្គមចម្រុះ ដែរឬទេ?

- តើរបបសិទ្ធិនេះនាំឱ្យមានចំណាយសមស្របបំផុតសម្រាប់ធ្វើការពិនិត្យតាមដាន ប្រមូលព័ត៌មាន និងអង្កេតឃ្លាំមើល (ចំណាយប្រតិបត្តិការ) នៃការគ្រប់គ្រងធនធាននេះដែរឬទេ?
- តើវាអាចជម្រុញលើកកម្ពស់អាទិភាពក្នុងសង្គម ដោយមិនចាំបាច់បំបាក់ទឹកចិត្តមិនឱ្យមាន "ភាពយុត្តិធម៌នៃសកម្មភាពរបស់បុគ្គលម្នាក់"?
- តើរបបនេះនឹងនាំឱ្យមានសមធម៌ និងការចូលរួមច្រើនជាងមុន ក្នុងចំណោមអ្នកប្រើប្រាស់ធនធាននានា ដែរឬទេ?

ការសម្រេចចិត្តអំពីអ្នកដែលគួរទទួលបានសិទ្ធិ ទំនងជាធ្វើឡើង ដោយផ្អែកទៅតាមការរួមផ្សំនៃកាលៈទេសៈបច្ចុប្បន្ន និងការចូលរួមកន្លងមក នៅក្នុងវិស័យនេសាទ។ យន្តការ ដែលគេអាចយកមកប្រើប្រាស់បាន រួមមាន អភិក្រមផ្អែកតាមទីផ្សារ ដែលសិទ្ធិកាន់កាប់ត្រូវបានគេដាក់ដេញថ្លៃ ឬលក់តាមរបៀបផ្សេងទៀត និងមានគណៈកម្មាធិការ ឬក្រុមប្រឹក្សាដែលទទួលបន្ទុកលើការបែងចែកសិទ្ធិ ចូលរួមនៅក្នុងដំណើរការនយោបាយមួយ ដែលធ្វើការពិចារណាលើសិទ្ធិបែបទំនៀមទម្លាប់ ប្រវត្តិនៃការចាប់ធនធាននេសាទ ជម្រើសសម្រាប់ជីវភាពរស់នៅ ភាពងាយរងគ្រោះ ការរក្សាសហគមន៍ជនបទ ។ល។ អភិក្រមផ្អែកលើទីផ្សារ ជាធម្មតា មានតម្លៃ ដែលគេនៅមានមន្ទិលសង្ស័យ សម្រាប់ការនេសាទក្នុងទ្រង់ទ្រាយតូច ដោយសារតែតម្លៃសង្គម ដែលជារឿយៗ គឺជាតម្លៃសំខាន់សម្រាប់ការនេសាទប្រភេទនេះ មិនត្រូវបានគេយកមកគិតបញ្ចូល។ អាចមានការសម្រេចចិត្តកម្រិតនយោបាយ ដើម្បីផ្ទេរការទទួលខុសត្រូវលើសិទ្ធិកាន់កាប់ធនធាននេសាទ នៅថ្នាក់មូលដ្ឋានវិញ ឧ. ផ្តល់នូវសិទ្ធិសមូហភាព ទៅឱ្យសហគមន៍ ទៅតាមទីតាំង និងការចូលរួមជាប្រពៃណីរបស់ពួកគេ នៅក្នុងការងារនេសាទ។ លើសពីនេះ នៅថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ ចាំបាច់ត្រូវមាននីតិវិធីបែងចែក។ ស្ថាប័នជលផលថ្នាក់តំបន់មួយចំនួន បានកំណត់នូវលក្ខណៈវិនិច្ឆ័យ សម្រាប់ធ្វើការជ្រើសរើសអ្នកចូលរួម ក្នុងសកម្មភាពនេសាទ ដែលស្ថិតក្រោមការទទួលខុសត្រូវរបស់ពួកគេ (សូមមើលឧទាហរណ៍ នៅក្នុងប្រអប់ទី ១៦)។

**ប្រអប់ទី ១៦ ៖ លក្ខណៈវិនិច្ឆ័យរបស់ ICCAT សម្រាប់ធ្វើការបែងចែកលទ្ធភាពនេសាទ**

គណៈកម្មការអន្តរជាតិទទួលបន្ទុកអភិរក្សសត្វក្នុងមហាសមុទ្រអាត្លង់ទិច (ICCAT) ប្រើប្រាស់នូវលក្ខណៈវិនិច្ឆ័យមួយចំនួនសម្រាប់ធ្វើការបែងចែកកូតា ទៅឱ្យភាគីម៉ៅការ និងសហប្រតិបត្តិការ នៅក្នុងតំបន់ដែលខ្លួនគ្រប់គ្រង។ លក្ខណៈ

វិនិច្ឆ័យទាំងនេះ រួមមាន ៖

- បរិមាណសត្វ ដែលចាប់បានកន្លងមក របស់អ្នកដែលកំពុងដាក់ពាក្យចូលរួម
- ប្រយោជន៍ និន្នាការនៃការនេសាទ និងរបៀបធ្វើការនេសាទ របស់ភាគីដែលកំពុងដាក់ពាក្យចូលរួម
- ប្រយោជន៍របស់អ្នកនេសាទតូចតាច ដែលប្រកបរបរនេសាទចិញ្ចឹមជីវិត ដោយប្រើប្រាស់ឧបករណ៍មិនមែនម៉ាស៊ីន
- តម្រូវការរបស់សហគមន៍ នៅតាមតំបន់ឆ្នេរ ដែលពឹងអាស្រ័យជាចម្បងលើការងារនេសាទ
- ការរួមចំណែកផ្នែកសង្គម-សេដ្ឋកិច្ច របស់ធនធាននេសាទ ក្រោមការគ្រប់គ្រងរបស់ ICCAT ដល់រដ្ឋកំពុងអភិវឌ្ឍ
- សារៈសំខាន់ផ្នែកសេដ្ឋកិច្ច និង/ឬសង្គមរបស់វិស័យនេសាទ របស់អ្នកដែលពាក្យសុំចូលរួម ដែលមាននាវានេសាទរបស់ខ្លួនធ្លាប់ចូលរួមនេសាទ នៅក្នុងតំបន់នេះ
- ឯកសារបង្ហាញពីភាពអនុលោម ឬកិច្ចសហប្រតិបត្តិការរបស់ដៃគូ ដែលដាក់ពាក្យចូលរួម ទៅតាមវិធានការអភិរក្ស និងគ្រប់គ្រងរបស់ ICCAT

*ប្រភព ៖* គេហទំព័ររបស់ ICCAT ( www.iccat.int )

សំណួរមួយចំនួន ដែលត្រូវឆ្លើយ នៅពេលរៀបចំប្រព័ន្ធសិទ្ធិកាន់កាប់ធនធាននេសាទ រួមមាន ថាតើសិទ្ធិ ដែលបែងចែកដោយរដ្ឋាភិបាល គួរតែជាសិទ្ធិអចិន្ត្រៃយ៍ ឬបណ្តោះអាសន្ន និងថាតើអ្នកមានសិទ្ធិ គួរត្រូវបានអនុញ្ញាតឱ្យផ្ទេរសិទ្ធិរបស់ខ្លួន ទៅឱ្យអ្នកប្រើប្រាស់ដទៃទៀត ដែរឬទេ។ ជម្រើសរវាងសិទ្ធិអចិន្ត្រៃយ៍ និងសិទ្ធិបណ្តោះអាសន្ន ពាក់ព័ន្ធសំខាន់ជុំវិញតុល្យភាពរវាងចំណុចពីរយ៉ាង ៖ ភាពបត់បែនក្នុងការគ្រប់គ្រង និងការលើកទឹកចិត្តឱ្យមានការប្រើប្រាស់ និងការអភិរក្សប្រកបដោយនិរន្តរភាព។ ការកំណត់រយៈពេលរបស់សិទ្ធិ ផ្តល់លទ្ធភាពឱ្យរដ្ឋាភិបាល អាចធ្វើការបែងចែកសិទ្ធិទាំងនេះឡើងវិញបាន ប្រសិនបើគោលបំណងសង្គម ឬកាលៈទេសៈផ្សេងទៀតមានការប្រែប្រួល (ប៉ុន្តែវានឹងធ្វើឱ្យសិទ្ធិកាន់កាប់មិនសូវជាប់លាប់ និងមិនសូវមានតម្លៃ)។ សិទ្ធិអចិន្ត្រៃយ៍ តម្រូវឱ្យមានការធ្វើសេចក្តីសម្រេចចិត្តជាមុនអំពីអ្នកដែលគួរជាអ្នកប្រើប្រាស់ និងអ្នកដែលគួរផាត់ចេញ។ ដោយឡែក សិទ្ធិអចិន្ត្រៃយ៍ ឬសិទ្ធិក្នុងរយៈពេលវែង ផ្តល់នូវសន្តិសុខច្រើនជាងមុនដល់អ្នកប្រើប្រាស់ធនធាននេសាទ ក៏ដូចជា “អាចរក្សាភាពគង់វង្សរបស់ធនធាននាពេលអនាគត និងជាការលើកទឹកចិត្តឱ្យមាន “ការ

រៀបចំផែនការសម្រាប់អនាគត” សម្រាប់ការប្រើប្រាស់ធនធាន ដោយសន្សំសំចៃ (p. 274, Charles, 2009)។ ពុំមានការផ្លោះប្តូរ ដែលល្អបំផុតរវាងចំណុចទាំងនេះនោះទេ ហើយការរៀបចំសិទ្ធិកាន់កាប់ ប្រហែលជាត្រូវមានលក្ខណៈបន្ថែមទៀត ដើម្បីក្តោបលើលទ្ធផលដែលគេចង់បាន ដូចជា ការភ្ជាប់លក្ខណៈវិនិច្ឆ័យរបស់ការងារអភិរក្ស ជាមួយនឹងជម្រើសបន្តសិទ្ធិរយៈពេលខ្លី (Shotton, 2000)។

ពាក់ព័ន្ធជាមួយនឹងលទ្ធភាពអាចផ្ទេរបាន ការអនុវត្តល្អ ក្នុងវិស័យនេសាទខ្នាតតូច អំពាវនាវឱ្យមានការយកចិត្តទុកដាក់លើកត្តាវប្បធម៌ក្នុងមូលដ្ឋាន និងកត្តាស្ថាប័ន ហើយអាចឱ្យមានការផ្ទេរដែលមានកម្រិតតែប៉ុណ្ណោះ។ ឧទាហរណ៍ លទ្ធភាពអាចផ្ទេរសិទ្ធិបានជាបណ្តោះអាសន្ន អាចអនុញ្ញាតឱ្យធ្វើបាន (ឧ. នៅក្នុងរដូវនេសាទ ជាដើម) ជាមធ្យោបាយសម្រាប់ផ្តល់នូវភាពបត់បែនរយៈពេលខ្លី ហើយក្នុងពេលជាមួយគ្នា អាចរក្សាបាននូវស្ថិតភាពក្នុងរយៈពេលវែង ក្នុងការបែងចែកសិទ្ធិ។ ការផ្ទេរជាអចិន្ត្រៃយ៍ ឬរយៈពេលវែង អាចចាត់ទុកថាជាទង្វើសមស្រប នៅក្នុងរង្វង់សហគមន៍ ឬគ្រួសារ ប៉ុន្តែមិនត្រូវធ្វើឡើង តាមរយៈការប្រើប្រាស់យន្តការទីផ្សារ (ដូចជា ទិញ និងលក់សិទ្ធិនោះទេ)។ យន្តការទីផ្សារ ច្រើនតែនាំឱ្យមាន ការប្រមូលផ្តុំការគ្រប់គ្រងលើសិទ្ធិ ដែលអាចនាំឱ្យមានការផ្លាស់ប្តូរសិទ្ធិ ចេញទៅខាងក្រៅសហគមន៍តូច។ នេះអាចមាន ផលប៉ះពាល់ជាអវិជ្ជមានមកលើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅតំបន់ជនបទ និងមកលើស្ថិរភាព និរន្តរភាព និងសមធម៌ នៅក្នុងសេដ្ឋកិច្ចរបស់សហគមន៍ និងតាមតំបន់ឆ្នេរ (Copes and Charles, 2004) (សូមមើលប្រអប់ទី ១៧)។ នៅក្នុងបរិបទមួយផ្សេងទៀតនៃការធ្វើនេសាទក្នុងទ្រង់ទ្រាយធំ សិទ្ធិកាន់កាប់ដែលអាចជួញដូរបាន (កូតាដែលអាចជួញដូរបានកូតា ដែលអាចផ្ទេរបានជាលក្ខណៈបុគ្គល [ITQs]។ល) អាចមានមានភាពសមស្រប នៅក្នុងបរិបទមួយចំនួន។ ប៉ុន្តែ វាមិនអាចសមស្របនៅក្នុងស្ថានភាពដទៃទៀត ហើយរដ្ឋគួរកំហិតលើភាពអាចផ្ទេរបានរបស់សិទ្ធិ (បុគ្គល) ទៅតាមការសមស្រប ក្នុងគោលបំណងធានាប្រយោជន៍ សម្រាប់សហគមន៍នេសាទតូចតាច។ ការផ្ទេរ និងការបែងចែកសិទ្ធិឡើងវិញ ត្រូវបានលើកយកមកធ្វើការពិភាក្សាខាងក្រោម នៅក្នុងផ្នែកការបែងចែកសិទ្ធិកាន់កាប់ឡើងវិញ និងការប្រកួតប្រជែងគ្នារបស់អ្នកប្រើប្រាស់។

**ប្រអប់ទី ១៧ ៖ លទ្ធភាពអាចផ្ទេរបាននូវសិទ្ធិនេសាទជាលក្ខណៈពាណិជ្ជកម្មរបស់ប្រជុំកោះ** Galapgos

អ្នកមុជទឹកជាលក្ខណៈពាណិជ្ជកម្ម នៅក្នុងដែនបម្រុងសមុទ្ទ Galapgos (ប្រទេសអេក្វាឌ័រ) ផ្តោតជាចម្បងលើបង្កងដែលមានបន្លាច្រើន (*Panulirus penicillatus* និង *P. gracilis*) ត្រសក់សមុទ្ទ (Isostichopus fuscus) និងធនធានតូចៗជា

ច្រើនផ្សេងទៀត។ ការប្រើប្រាស់ធនធាននេសាទ ត្រូវបានដាក់កំហិត ដោយឱសានវាទលើទំហំរបស់នាវា និងអ្នកនេសាទ ដែលចូលរួម ប៉ុន្តែគេនៅតែអាចផ្តល់អាជ្ញាប័ណ្ណថ្មីៗដល់កូនប្រុសស្រី របស់អ្នកនេសាទ ដែលមានស្រាប់ ដែលត្រូវតែជាប្រជាពលរដ្ឋរបស់ Galapgos។ អាជ្ញាប័ណ្ណផ្តល់លទ្ធភាពឱ្យមានការប្រមូលធនធាននានា នៅក្នុងតំបន់បម្រុង ដែលទទួលបានការអនុញ្ញាត។ លិខិតអនុញ្ញាតឱ្យធ្វើការនេសាទ ត្រូវបានចេញជាប្រចាំឆ្នាំ សម្រាប់ទូកនេសាទ ខណៈពេលដែលលទ្ធភាពចូលនេសាទរបស់អ្នកនេសាទ ត្រូវបានផ្តល់ឱ្យ តាមរយៈប័ណ្ណសម្គាល់ខ្លួនរបស់អ្នកនេសាទ ដែលមានសុពលភាពរយៈពេល ២ ឆ្នាំ។ ខណៈពេលដែលមានការកំណត់ពីចំនួនទូក គេអាចជំនួស “ទូក pangas” តូចៗ ដោយកាណូតធំ។ ដោយសារតែធនធាននេសាទមានការថយចុះ អ្នកនេសាទ ដែលបានចុះឈ្មោះ ត្រូវបានអនុញ្ញាតឱ្យធ្វើការផ្ទេរៈប្តូរលិខិតអនុញ្ញាតនេសាទរបស់ខ្លួន ជាមួយនឹងអាជ្ញាប័ណ្ណទេសចរណ៍ ដែលមានតម្លៃខ្ពស់ (ដែលគេមិនអាចនឹងរកបាន ប្រសិនបើមិនមានការផ្ទេរៈប្តូរបែបនេះ)។

*ប្រភព ៖* Orensanz *et al.* (2011)

**ការណែនាំទី ៧ ៖ វិធីសាស្ត្រ សម្រាប់ជ្រើសរើសអ្នកកាន់កាប់សិទ្ធិ**

ការសម្រេចចិត្តអំពីប្រភេទសិទ្ធិកាន់កាប់ ដែលគួរយកមកប្រើប្រាស់ នៅក្នុងសកម្មភាពនេសាទណាមួយ ឬនៅក្នុងស្ថានភាពជាក់លាក់ណាមួយនៅមូលដ្ឋាន ទទួលរងឥទ្ធិពល ដោយសារកត្តាច្រើនយ៉ាង។ ការសម្រេចចិត្តនេះគួរផ្តោតលើគោលបំណង ហើយត្រូវធ្វើការពិចារណាលើការការពារ ដូចដែលមានរៀបរាប់នៅក្នុង VGGT។ ដំណើរការពិគ្រោះយោបល់ និងការចូលរួម មានសារៈសំខាន់ សម្រាប់ធានាយ៉ាងណាឱ្យប្រព័ន្ធមួយទទួលបានការគោរពពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ និងមានប្រសិទ្ធភាព សម្រាប់ការអនុវត្ត។ លើសពីនេះ ចំណេះដឹងល្អអំពីការរៀបចំសិទ្ធិកាន់កាប់បែបទំនៀមទម្លាប់ នៅក្នុងករណីដែលមាន គឺជាធាតុចូលយ៉ាងសំខាន់ សម្រាប់ដំណើរការធ្វើសេចក្តីសម្រេចចិត្ត និងការរៀបចំប្រព័ន្ធសិទ្ធិកាន់កាប់។ នៅក្នុងករណីដែលមានសិទ្ធិកាន់កាប់ (បែបទំនៀមទម្លាប់) សិទ្ធិត្រូវបានបែងចែករួចទៅហើយដល់អ្នកប្រើប្រាស់នានា (និងមានការផាត់អ្នកដទៃចេញ) ដែលការបែងចែកសិទ្ធិនេះ ចាំបាច់ត្រូវតែជាមូលដ្ឋាន សម្រាប់ប្រព័ន្ធថ្មី ឬប្រព័ន្ធ ដែលត្រូវបានកែប្រែ។

យន្តការជាក់លាក់ សម្រាប់ធ្វើការបែងចែកសិទ្ធិថ្មីៗ រួមមាន អភិក្រមទីផ្សារ ដូចជា ការដេញថ្លៃ និងការលក់

ជាដើម។ ការដេញថ្លៃ អាចជាយន្តការសមស្របមួយ នៅក្នុងស្ថានភាព ដែលមានវិស័យនេសាទទ្រង់ទ្រាយធំ ដោយមានកត្តាសង្គម និងវប្បធម៌តិចតួច។ ការដេញថ្លៃសិទ្ធិកាន់កាប់ គឺជាវិធីមួយ សម្រាប់បង្កើនប្រសិទ្ធភាពសេដ្ឋកិច្ច ដល់កម្រិតអតិបរមា ប៉ុន្តែគេត្រូវតែមានបម្រុងប្រយ័ត្ន ដើម្បីធានាយ៉ាងណាឱ្យអ្នកនេសាទមួយចំនួន ឬក្រុមមនុស្សមួយចំនួន មិនត្រូវបានផាត់ចេញ ដោយសារតែមធ្យោបាយហិរញ្ញវត្ថុ ដែលត្រូវការសម្រាប់ដេញថ្លៃ។ គេអាចកត់សម្គាល់បានថា ការប្រើប្រាស់ការដេញថ្លៃ ជាវិធីសម្រាប់ធ្វើការបែងចែកសិទ្ធិ កម្រនឹងត្រូវបានគេយកមកប្រើប្រាស់នៅអឺរ៉ុបណាស់ ហើយលែងត្រូវបានគេប្រើនៅក្នុងបណ្តារដ្ឋ ដែលជាសមាជិករបស់អង្គការសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ (OECD) ទៀតហើយ។ អភិក្រមទីផ្សារដទៃទៀតក៏មានផងដែរ ដែលមានន័យថា សិទ្ធិទាំងឡាយត្រូវបានគេលក់ និងទិញ នៅក្នុងទីផ្សារ។ គុណវិបត្តិមួយនៃការប្រើប្រាស់យន្តការទាំងនេះគឺថា វានឹងធ្វើឱ្យរដ្ឋមានការលំបាក ក្នុងការផ្លាស់ប្តូរការបែងចែកសិទ្ធិនៅពេលក្រោយ ដូចជា នៅក្នុងករណីដែលមានការផ្លាស់ប្តូរគោលនយោបាយជាដើម។

នៅក្នុងស្ថានភាពជាច្រើន ដែលអភិក្រមទីផ្សារ មិនទំនងជាផ្តល់មកវិញនូវលទ្ធផលដែលគេចង់បាន គេចាំបាច់ត្រូវប្រើប្រាស់វិធីសាស្ត្រផ្សេងទៀត។ អង្គភាពពិសេសមួយ ដូចជា ក្រុមប្រឹក្សា ឬគណៈកម្មាធិការបែងចែកសិទ្ធិ ជាដើម អាចត្រូវបានរដ្ឋាភិបាលបង្កើតឡើង ដើម្បីកំណត់ពីរបៀបគួរបែងចែកសិទ្ធិ និងកំណត់ពីអ្នកដែលគួរទទួលបានសិទ្ធិ។ ប្រព័ន្ធនេះត្រូវបានប្រើប្រាស់ នៅតាមប្រទេសជាច្រើន ដូចជា កាណាដា ញូហ្សេលែន អាហ្វ្រិចខាងត្បូង និងសហរដ្ឋអាមេរិច ជាដើម។ លក្ខណៈវិនិច្ឆ័យមួយ ដែលអ្នកធ្វើសេចក្តីសម្រេចចិត្តអាចយកមកធ្វើការពិចារនា នៅក្នុងដំណើរការនេះ គឺប្រវត្តិនៃការចាប់ត្រី។ ប៉ុន្តែ មានបញ្ហា ដែលចាំបាច់ត្រូវដោះស្រាយ ដូចជា តើពេលវេលាណា ដែលគេកំពុងយកមកធ្វើការពិចារណា។ លើសពីនេះ នៅក្នុងវិស័យនេសាទមួយ ដែលត្រូវបានគេទាញប្រយោជន៍លើសកម្រិត វាអាចជារឿងអយុត្តិធម៌ នៅពេលដែលអ្នកដែលបានរួមចំណែកក្នុងការទាញប្រយោជន៍ហួសហេតុពីធនធាននេសាទ គួរទទួលបានសិទ្ធិឱ្យបន្តធ្វើការនេសាទនោះ។

លក្ខណៈវិនិច្ឆ័យ សម្រាប់ធ្វើការបែងចែកលទ្ធភាពនេសាទ ក៏ត្រូវបានស្ថាប័នជលផលថ្នាក់តំបន់ប្រើប្រាស់ ដើម្បីបែងចែកកូតាផងដែរ។

នៅក្នុងបរិបទនៃការធ្វើនេសាទខ្នាតតូច ក្នុងករណីដែលសិទ្ធិបែបទំនៀមទម្លាប់ក្នុងសហគមន៍ មានប្រវត្តិយូរលង់ណាស់មកហើយ អភិក្រមនេះប្រហែលជាចាំបាច់ត្រូវតែជាសិទ្ធិសមូហភាពផ្សេងទៅវិញ ដែលត្រូវបានបែងចែកទៅឱ្យសហគមន៍ នៅក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រងរួមគ្នា។ អភិក្រមនេះហាក់បីដូចជាមានប្រសិទ្ធភាព ជាពិសេស នៅក្នុងករណី

ដែលមានភាពស៊ីសង្វាក់គ្នាក្នុងសហគមន៍ដែលពាក់ព័ន្ធ មានបទពិសោធន៍ និងសមត្ថភាពសម្រាប់ធ្វើការគ្រប់គ្រងក្នុងមូលដ្ឋាន ទីតាំងភូមិសាស្ត្ររបស់សហគមន៍មានភាពច្បាស់លាស់ ហើយទំហំ និងវិសាលភាពជារួមមានកម្រិតសមល្មម (Charles, 2009; MRAG *et al.,* 2009; Shotton, 2000)។

អភិក្រម/ឧបករណ៍ ដែលត្រូវប្រើ ៖

- សិក្ខាសាលាជាមួយអ្នកពាក់ព័ន្ធ (សូមមើលឧបសម្ព័ន្ធទី ២)
- ការសម្របសម្រួល (សូមមើលឧបសម្ព័ន្ធទី ២)
- យន្តការបែងចែកជាក់លាក់ ៖ ការដេញថ្លៃ ទិន្នន័យអំពីប្រវត្តិចាប់ត្រីកន្លងមក គណៈកម្មការបែងចែក

សង្ខេបមកវិញ កាលៈទេសៈពិសេស លទ្ធផលនៃដំណើរការពិគ្រោះយោបល់ និងការសម្រេចចិត្តកម្រិតនយោបាយ អំពីប្រព័ន្ធសិទ្ធិកាន់កាប់ដែលគួរមាន គឺជាកត្តាកំណត់ពីរបៀបធ្វើការបែងចែកសិទ្ធិ ប្រភេទសិទ្ធិដែលគួរបែងចែក និងលក្ខណៈរបស់សិទ្ធិទាំងនេះ។ ដូច្នេះ ជាការសំខាន់ណាស់ ដែលត្រូវមានគោលដៅឱ្យបានច្បាស់លាស់ សម្រាប់ប្រព័ន្ធសិទ្ធិកាន់កាប់ (សូមមើលចំណុចខាងលើ) និងទទួលស្គាល់ថា ចាំបាច់ត្រូវមានដំណោះស្រាយផ្សេងៗគ្នា នៅក្នុងស្ថានភាពខុសៗគ្នា។ មានប្រភេទសិទ្ធិ និងប្រព័ន្ធសិទ្ធិកាន់កាប់ផ្សេងៗគ្នាជាច្រើន ហើយប្រព័ន្ធសិទ្ធិកាន់កាប់ក៏ប្រហែលជាចាំបាច់ត្រូវសម្របទៅតាមស្ថានភាពថ្មីៗ និងការផ្លាស់ប្តូរ ដែលកើតមានឡើង នៅក្នុងរយៈពេលមួយ។ ដំណើរការ ដែលប្រព័ន្ធនេះត្រូវបានបង្កើតឡើង មានសារៈសំខាន់យ៉ាងខ្លាំង ហើយការពិគ្រោះយោបល់ជាមួយនឹងអ្នកពាក់ព័ន្ធ និងអ្នកប្រើប្រាស់ធនធាននានា គឺជាគន្លឹះសំខាន់។ គោលការណ៍ចូលរួម និងតម្លាភាព របស់អភិបាលកិច្ចល្អ មានសារៈសំខាន់យ៉ាងខ្លាំង នៅក្នុងបរិបទនេះ។

## ការបែងចែកសិទ្ធិកាន់កាប់ឡើងវិញ និងការប្រកួតប្រជែងគ្នា ក្នុងចំណោមអ្នកប្រើប្រាស់

**VGGT ពិភាក្សាពីគោលការណ៍សម្រាប់ធ្វើការកែប្រែសិទ្ធិសារជាថ្មី និងអះអាងបញ្ជាក់ថា ៖**

*រដ្ឋគួរបង្កើតនូវយុទ្ធសាស្ត្រ សម្រាប់ធ្វើការកែសម្រួលអភិក្រមនានាឡើងវិញ ឱ្យសមស្របទៅតាមតម្រូវការនៅមូលដ្ឋាន។ យុទ្ធសាស្ត្រទាំងនេះ គួរធានាបាននូវនិរន្តរភាពផ្នែកសង្គម សេដ្ឋកិច្ច និងបរិស្ថាន និងឆ្លើយតបចំពោះយេនឌ័រ។*

*យុទ្ធសាស្ត្រនានា គួរកំណត់ពីគោលការណ៍ និងគោលបំណងរបស់អភិក្រមសម្រាប់ធ្វើការកែសម្រួលទាំងនេះ កំណត់ពីអ្នកទទួលផល ការអភិវឌ្ឍសមត្ថភាព និងចំណេះដឹង នៅក្នុងវិស័យសាធារណៈ វិស័យឯកជន សមាគមកសិករ និងអ្នកផលិតខ្នាតតូច សមាគមអ្នកនេសាទ និងសមាគមអ្នកប្រើប្រាស់ព្រៃឈើ និងអ្នកសិក្សាស្រាវជ្រាវនានា។ ច្បាប់គួរចែងឱ្យច្បាស់លាស់ពីនីតិវិធីដែលមានប្រសិទ្ធភាពផ្នែកចំណាយ សម្រាប់ធ្វើការរៀបចំសារជាថ្មីនូវប្លង់ដីធ្លី ឬកម្មសិទ្ធិ និងការប្រើប្រាស់ដីធ្លីទាំងនេះ។*

**(១៣.៥ នៅក្នុង *អភិក្រមសម្រាប់ប្រមូលផ្ដុំដីធ្លី និងអភិក្រមសម្រាប់ធ្វើការកែសម្រួលផ្សេងទៀត* )**

ដូចដែលបានពិភាក្សាខាងលើ សិទ្ធិកាន់កាប់ អាចជាសិទ្ធិបណ្ដោះអាសន្ន និង/ឬអាចផ្ទេរបាន។ នៅពេលដាក់បញ្ចូលលក្ខណៈបែបនេះ ទៅក្នុងប្រព័ន្ធសិទ្ធិកាន់កាប់ណាមួយ ដំណើរការសម្រាប់ផ្ទេរសិទ្ធិប្រកបដោយយុត្តិធម៌ និងសមធម៌ ចាំបាច់ត្រូវតែដាក់បញ្ចូល ទៅក្នុងប្រព័ន្ធនេះ។ អាចមានស្ថានភាព ដែលគេរកឃើញថា ប្រព័ន្ធសិទ្ធិកាន់កាប់ ដែលមានស្រាប់មិនមានយុត្តិធម៌ និងសមធម៌ និង/ឬមិនស្របទៅតាមគោលបំណងសង្គម និងបរិស្ថាន ហើយរដ្ឋាភិបាលចង់ធ្វើការកែសម្រួលប្រព័ន្ធនេះ ដើម្បីលើកកម្ពស់អភិបាលកិច្ចលើសិទ្ធិកាន់កាប់ធនធាននេសាទ។ កំណែទម្រង់បែបនេះអាចមានប្រយោជន៍ សម្រាប់សហគមន៍នេសាទ ដូចជា ការផ្ទេរសិទ្ធិប្រើប្រាស់នៅតាមតំបន់ជិតឆ្នេរ ដែលធ្លាប់បើកឱ្យនេសាទដោយសេរី ទៅជាការប្រើប្រាស់ផ្ដាច់មុខ សម្រាប់ការនេសាទតូចតាច ឬការបង្កើតនូវសិទ្ធិប្រើប្រាស់ដែនដី នៅក្នុងវិស័យនេសាទវិញ។

នៅក្នុងស្ថានភាពផ្សេងទៀត កំណែទម្រង់ ដោយនាំឱ្យមានការកែប្រែថ្មី អាចបង្កឱ្យមានការលំបាកដល់អ្នកនេសាទតូចតាច និងកម្មករនេសាទ។ កំណើននៃការប្រកួតប្រជែងរវាងវិស័យមួយ និងវិស័យមួយទៀត និងរវាងអាទិភាពមួយរបស់ជាតិ ជាមួយនឹងអាទិភាពផ្សេងទៀត អាចជាមូលហេតុ ដែលនាំឱ្យមានការបែងចែកសិទ្ធិសារជាថ្មីពីវិស័យមួយ ទៅវិស័យមួយទៀត។ វិស័យនេសាទខ្នាតតូច ជារឿយៗ ទទួលរងផលប៉ះពាល់ ដោយសារការប្រកួតប្រជែងពីការអភិវឌ្ឍនានា នៅតំបន់ឆ្នេរ ហើយគេអាចធ្វើសេចក្ដីសម្រេចចិត្តកម្រិតនយោបាយអំពីការប្រើប្រាស់តំបន់ឆ្នេរ ដូចជា សម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍ ដែលអាចផ្ដល់មកវិញនូវចំណូលជាប្រាក់កាសខ្ពស់ (ដោយមិនគិតពីតម្លៃ និងអត្ថប្រយោជន៍ផ្សេងទៀត)។ នៅក្នុងស្ថានភាពបែបនេះ សហគមន៍នេសាទតូចតាច ជារឿយៗ មានការលំបាក នៅក្នុងតវ៉ាប្រឆាំង ជាពិសេស ប្រសិនបើសិទ្ធិរបស់ពួកគេ គឺជាសិទ្ធិក្រៅផ្លូវការ ដោយហេតុថា ជារឿយៗ ពួកគេមានអំណាចនយោបាយតិចតួច និងមានលទ្ធភាពទទួល

បានជំនួយផ្លូវច្បាប់មិនគ្រប់គ្រាន់។ វាកាន់តែបង្កការលំបាកថែមទៀតសម្រាប់អ្នកនេសាទដែលជាជនចំណាកស្រុក និងសហគមន៍របស់ពួកគេ (សូមមើលប្រអប់ទី ៨ នៅក្នុងផ្នែកទី ១)។ ប្រសិនបើពួកគេបាត់បង់ដីធ្លីរបស់ពួកគេ សហគមន៍នេសាទអាច មានការលំបាក ក្នុងការអនុវត្តសិទ្ធិនេសាទរបស់ពួកគេ - សូម្បីតែនៅពេលដែលសិទ្ធិទាំងនេះ គឺជាសិទ្ធិប្រើប្រាស់ ដែលត្រូវបានទទួលស្គាល់ស្របច្បាប់ក៏ដោយ ដោយសារតែពួកគេពឹងអាស្រ័យលើតំបន់ឆ្នេរ ជាមូលដ្ឋានសម្រាប់ធ្វើសកម្មភាពរបស់ពួកគេ។ ដូច្នេះ ពាក់ព័ន្ធជាមួយនឹងការកែសម្រួលសិទ្ធិកាន់កាប់ដីធ្លី និងការបែងចែកសិទ្ធិសារជាថ្មីដល់សហគមន៍នេសាទតូចតាច គេគួរពិចារណាលើគោលការណ៍ ដូចតទៅ ៖

- ការផ្លាស់ប្តូរ ដោយស្ម័គ្រចិត្ត ពាក់ព័ន្ធជាមួយនឹងគោលការណ៍នៃការឯកភាពគ្នាជាមុន ដោយសេរី ផ្អែកទៅតាមព័ត៌មានត្រឹមត្រូវ គប្បីត្រូវខិតខំឱ្យមានជានិច្ច។
- អស្សាមិករណ៍គួរធ្វើឡើង តែនៅក្នុងករណីធ្ងន់ធ្ងរ មានហេតុផលសមស្រប និងជាជម្រើសចុងក្រោយប៉ុណ្ណោះ។ គួរមានការផ្តល់នូវសំណងឱ្យបានគ្រប់គ្រាន់ ដោយធ្វើការពិចារណាលើតម្លៃសង្គម វប្បធម៌ និងសេដ្ឋកិច្ច។

**VGGT ផ្តល់នូវអនុសាសន៍អំពីរបៀបដោះស្រាយបញ្ហាអស្សាមិករណ៍ ដែលចាំបាច់ត្រូវមាន និងធ្វើការប្រកាសថា ៖**

*រដ្ឋគួរធានាថា ការរៀបចំផែនការ និងដំណើរការអស្សាមិករណ៍ ធ្វើឡើងដោយតម្លាភាព និងដោយមានការចូលរួម។ អ្នកណាក៏ដោយ ដែលទំនងជាទទួលរងផលប៉ះពាល់ គួរត្រូវបានកំណត់ និងផ្តល់ព័ត៌មាន ក៏ដូចជាពិគ្រោះយោបល់ជាមួយឱ្យបានត្រឹមត្រូវ នៅគ្រប់ដំណាក់កាលទាំងអស់។ ការពិគ្រោះយោបល់ ស្របជាមួយនឹងគោលការណ៍នៅក្នុង VGGT ទាំងនេះ គួរផ្តល់ព័ត៌មាន ពាក់ព័ន្ធជាមួយនឹងអភិក្រមជាជម្រើសនានា ដើម្បីសម្រេចនូវគោលបំណងជាសាធារណៈ និងគួររៀបចំឡើងដើម្បីពិភាក្សាអំពីយុទ្ធសាស្ត្រនានា សម្រាប់កាត់បន្ថយជាអតិបរមានូវការរំខានចំពោះជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ រដ្ឋគួរមានការគិតពិចារណាឱ្យបានល្អិតល្អន់ នៅពេលដែលអស្សាមិករណ៍ ដែលស្នើឡើង មានការពាក់ព័ន្ធជាមួយនឹងផ្នែកនានា ដែលមានសារៈសំខាន់ពិសេសផ្នែកវប្បធម៌ សាសនា ឬបរិស្ថាន ឬនៅពេលដែលដីធ្លី ធនធាននេសាទ និងធនធានព្រៃឈើ ដែលពាក់ព័ន្ធ មានសារៈសំខាន់ជាពិសេស ចំពោះជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្រីក្រ ឬជនដែលងាយរងគ្រោះ។*

**(១៦.២ នៅក្នុង *អស្សាមិករណ៍ និងការផ្តល់សំណង*)**

*រដ្ឋគួរធានាឱ្យមានការវាយតម្លៃប្រកបដោយភាពយុត្តិធម៌ និងការផ្តល់សំណងជាបន្ទាន់ ទៅតាមច្បាប់ជាតិ។ ការ*

*ផ្តល់សំណងអាចមានទម្រង់ច្រើនយ៉ាង ដូចជា សាច់ប្រាក់ សិទ្ធិទទួលបានតំបន់ផ្សេងទៀត ឬរួមបញ្ចូលគ្នាទាំងពីរ។*

**(១៦.៣ នៅក្នុង *អស្សាមិករណ៍ និងការផ្តល់សំណង* )**

ចាំបាច់ត្រូវតែមានការទទួលស្គាល់ថា នៅក្នុងដំណើរការបែងចែក ឬដំណើរការបែងចែកសារជាថ្មីនូវសិទ្ធិកាន់កាប់ ទំនងជានឹងមានអ្នកឈ្នះ និងអ្នកចាញ់ ពោលគឺអ្នកដែលទទួលបានសិទ្ធិ ឬអ្នកដែលសិទ្ធិរបស់ខ្លួននឹងមានភាពជាប់លាប់ជាងមុន និងអ្នកដែលបាត់បង់សិទ្ធិ និងទទួលបានសិទ្ធិតិចជាងមុន។ នេះអាចជាករណី នៅពេលដែលបំណងដែលចង់សម្រេចគឺជាបំណងដែលល្អបំផុត។ សិទ្ធិកាន់កាប់ជាប់លាប់ មានន័យថា សិទ្ធិនេះអនុញ្ញាតឱ្យមានការផាត់អ្នកដទៃទៀតចេញ ហើយអ្នកប្រើប្រាស់ដទៃទៀតទាំងនេះ (ឬអ្នកប្រើប្រាស់សក្តានុពល) កាន់តែមានសិទ្ធិតិចជាងមុន។ នេះទំនងជារយៈពេលអន្តរកាលដែលពិបាកជាពិសេស។ ជារឿយៗ ចាំបាច់ត្រូវមានការលះបង់រយៈពេលខ្លី ដើម្បីនាំឱ្យមានការចំណេញនៅក្នុងរយៈពេលវែង (WHAT, 2000)។ លើសពីនេះ នៅក្នុងករណីដែលការធ្វើបែបនេះត្រូវបានគេចាត់ទុកថាមានភាពប្រសើរផ្នែកសង្គម និងសេដ្ឋកិច្ច វាអាចមានការលំបាកផ្នែកនយោបាយ។ ប្រសិនបើកំណែទម្រង់ ដែលនាំឱ្យមានការផាត់ចេញ ត្រូវបានចាត់ទុកថាមានភាពសមហេតុសមផល និងជាសកម្មភាពចាំបាច់ដែលត្រូវធ្វើ គេត្រូវមានការប្រុងប្រយ័ត្ន នៅពេលធ្វើការវាយតម្លៃថាតើអ្នកដែលបាត់បង់សិទ្ធិទាំងនេះ ជាអ្នកដែលមានសិទ្ធិស្របច្បាប់ដែរឬទេ របៀបដែលពួកគេទទួលរងផលប៉ះពាល់ តើពួកគេមានតម្រូវការអ្វីខ្លះ និងថាតើពួកគេគួរទទួលបានសំណងដែរឬទេ។ នៅក្នុងស្ថានភាពក្រីក្រ ការពិចារណាលើតម្រូវការជាបន្ទាន់ គឺជាការពិចារណា ដែលមានសារៈសំខាន់ជាពិសេស។

ក៏មានការទទួលស្គាល់ផងដែរថា មានស្ថានភាព ដែលធនធាននេសាទ ត្រូវបានគេទាញប្រយោជន៍លើសកម្រិតទាំងផ្នែកសេដ្ឋកិច្ច ទាំងផ្នែកជីវសាស្ត្រ និងមានភាពចាំបាច់ ដើម្បីកាត់បន្ថយសមភាព និងកិច្ចខិតខំប្រឹងប្រែងក្នុងការនេសាទ។ នេះ អាចមានភាពពាក់ព័ន្ធដោយផ្ទាល់ ជាមួយនឹងវិស័យ ដែលមានទ្រង់ទ្រាយតូចៗផង និងធំៗផង។ ពេលខ្លះ វាអាចមានការសម្រេចចិត្តកម្រិតនយោបាយ ដើម្បីធ្វើការបែងចែកសិទ្ធិសារជាថ្មី ពីវិស័យនេសាទក្នុងទ្រង់ទ្រាយធំ ទៅឱ្យវិស័យតូចៗ ដែលផលប៉ះពាល់ជារួមលើបរិស្ថាន មិនសូវជាមានលក្ខណៈអវិជ្ជមាន (បើទោះបីជានេះមិនមែនជាករណី ដែលតែងកើតមានឡើងយ៉ាងណាក៏ដោយ)។ ជាពិសេស នៅតាមសហគមន៍នេសាទតូចតាច អាចមានលទ្ធភាព ដើម្បីកាត់បន្ថយបរិមាណនៃការនេសាទទាំងមូល រួមទាំងការនេសាទរបស់អ្នកនេសាទផង តាមរយៈការកែសម្រួលសិទ្ធិ និងការកំហិតលើបរិមាណ ឬ

រយៈពេលនេសាទ ដែលផ្តល់លទ្ធភាពឱ្យមនុស្សគ្រប់គ្នាបន្តធ្វើការនេសាទ ប៉ុន្តែតិចជាងមុន។ នៅក្នុងស្ថានភាពដទៃទៀត ការធ្វើបែបនេះអាចជាការលំបាក ហើយចាំបាច់ត្រូវតែមានការស្វែងរកឱកាសប្រកបរបរចិញ្ចឹមជីវិតផ្សេងទៀត ជាការបំពេញបន្ថែម សម្រាប់អ្នកដែលមិនអាចបន្តធ្វើការនេសាទ ឬអនុវត្តសកម្មភាពពាក់ព័ន្ធនានា។ ដូច្នេះ ដើម្បីកាត់បន្ថយសម្ពាធនៃការនេសាទ ការជម្រុញឱ្យមានការបង្កើតបរិយាកាសអំណោយផលសម្រាប់សហគ្រិនភាព និងការគាំទ្រដល់ការបង្កើតឱកាសជាជម្រើសសម្រាប់រកចំណូល និងផ្តល់ការងារ គឺជាសកម្មភាពដែលមានសារៈសំខាន់។ ការគាំទ្រប្រភេទនេះ នឹងមានសារៈ-សំខាន់ ដើម្បីកាត់បន្ថយភាពងាយរងគ្រោះរបស់សហគមន៍នេសាទតូចតាចជាទូទៅ។

| **ការណែនាំទី ៨ ៖ ការធ្វើពិពិធកម្មមុខរបរចិញ្ចឹមជីវិត** |
| --- |
| ខណៈពេលដែលសហគមន៍នេសាទខ្នាតតូចជាច្រើន មានមុខរបរចិញ្ចឹមជីវិតចម្រុះ ហើយប្រជាពលរដ្ឋអាចបំពេញសកម្មភាពមិនមែននេសាទជាច្រើន ការស្វែងរកឱកាសផ្សេងទៀត សម្រាប់រកចំណូល មិនមែនជាកិច្ចការដែលងាយស្រួលរហូតនោះទេ។ ឧបសគ្គ ដែលរាំងស្ទះដល់ការកំណត់ និងការអនុវត្តជម្រើសល្អៗនានា អាចរួមមាន កង្វះធនធាន និងជំនាញ លទ្ធភាពទទួលបានទីផ្សារនៅមានកម្រិត និងទំនៀមទម្លាប់ និងឥរិយាបថក្នុងវប្បធម៌ និងសង្គម។ ការកំណត់សកម្មភាពជាសក្តានុពល ចាំបាច់ត្រូវតែធ្វើឡើងដោយសហគមន៍ និងបុគ្គលម្នាក់ៗដោយខ្លួនឯង ហើយគួរមានការផ្តល់នូវការគាំទ្រដល់ដំណើរការដែលមានការចូលរួម សម្រាប់ធ្វើការវិភាគពីចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងការគំរាមកំហែង (SWOT)។ នៅពេលដែលជម្រើស ដែលអាចមានត្រូវបានកំណត់ ទំនងជានឹងមានភាពចាំបាច់ សម្រាប់ផ្តល់ការគាំទ្របន្ថែមទៀត ពាក់ព័ន្ធជាមួយនឹងចំណុចនានា ដូចជា ការអភិវឌ្ឍជំនាញ និងលទ្ធភាពទទួលបានធនធាន (ឥណទាន) និងទីផ្សារ។ |
| អភិក្រម/ឧបករណ៍ ដែលត្រូវប្រើ ៖<br>- ការសម្របសម្រួល (សូមមើលឧបសម្ព័ន្ធទី ២)<br>- បច្ចេកទេសវាយតម្លៃជនបទដោយមានការចូលរួម (PRA) *(សូមមើលឧបសម្ព័ន្ធទី ២)*<br>- SWOT<br>- វគ្គបណ្តុះបណ្តាល និងការអភិវឌ្ឍជំនាញ |

## ការគ្រប់គ្រងលើសិទ្ធិកាន់កាប់

### សេវារដ្ឋបាល និងសេវាពាក់ព័ន្ធ ដែលផ្តល់ដោយរដ្ឋាភិបាល

**ពាក់ព័ន្ធជាមួយនឹងតួនាទីរបស់រដ្ឋ នៅក្នុងការគ្រប់គ្រងសិទ្ធិកាន់កាប់ VGGT លើកឡើងថា ៖**

*រដ្ឋគួរដាក់ការទទួលខុសត្រូវ នៅកម្រិតរបស់រដ្ឋាភិបាល ដែលអាចផ្តល់សេវាដល់ប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធ-ភាពបំផុត។ រដ្ឋគួរកំណត់ឱ្យបានច្បាស់លាស់ពីតួនាទី និងការទទួលខុសត្រូវរបស់ស្ថាប័ននានា ដែលធ្វើការងារពាក់ព័ន្ធជាមួយនឹងសិទ្ធិកាន់កាប់ធនធាននេសាទ និងធនធានព្រៃឈើ។ រដ្ឋគួរធានាឱ្យមានការសម្របសម្រួលរវាងស្ថាប័នអនុវត្តនានា ក៏ដូចជាជាមួយនឹងរដ្ឋាភិបាលនៅថ្នាក់មូលដ្ឋាន និងជនជាតិដើមភាគតិច ក៏ដូចជាជាមួយនឹងសហគមន៍ដទៃទៀត ដែលប្រើប្រាស់សិទ្ធិកាន់កាប់បែបទំនៀមទម្លាប់។*

**(៥.៦ នៅក្នុង *គោលនយោបាយ ក្របខ័ណ្ឌច្បាប់ និងក្របខ័ណ្ឌស្ថាប័ន ដែលពាក់ព័ន្ធជាមួយនឹងសិទ្ធិកាន់កាប់*)**

ពាក់ព័ន្ធជាមួយនឹងការគ្រប់គ្រងលើសិទ្ធិកាន់កាប់ តួនាទី និងការទទួលខុសត្រូវរបស់រដ្ឋ រួមមាន ការផ្តល់នូវសេវាប្រកបដោយសមត្ថភាព ទាន់ពេលវេលា ស្មើភាពគ្នា ងាយស្រួលទទួលបាន និងមិនមានការរើសអើង។ នៅក្នុងវិស័យនេសាទ សេវា ដែលរដ្ឋទំនងជាចាំបាច់ត្រូវផ្តល់ ពាក់ព័ន្ធជាមួយនឹងការគ្រប់គ្រងសិទ្ធិកាន់កាប់ជាផ្លូវការ រួមមាន ៖

- សេវាកសាងសមត្ថភាព និងអភិវឌ្ឍន៍ស្ថាប័ន ដើម្បីផ្តល់ការគាំទ្រដល់អ្នកមានសិទ្ធិ និងអ្នកប្រើប្រាស់ធនធាន ក្នុងការអនុវត្តសិទ្ធិរបស់ពួកគេ សម្រាប់ទៅតាមគោលការណ៍ស្តីពីការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងសមធម៌
- សេវាចុះបញ្ជីសិទ្ធិ និងកត់ត្រា ក៏ដូចជាប្រមូលព័ត៌មាន និងធ្វើការស្រាវជ្រាវ ដែលចាំបាច់ សម្រាប់អភិបាលកិច្ចលើសិទ្ធិកាន់កាប់ប្រកបដោយប្រសិទ្ធភាព
- សេវាដោះស្រាយវិវាទ និងសេវាច្បាប់នានា ដែលផ្តល់លទ្ធភាពឱ្យអ្នកមានសិទ្ធិ និងអ្នកប្រើប្រាស់ធនធាន អាចទទួលបានសេវាមជ្ឈត្តការ និង/ឬសេវាពីអាជ្ញាធរតុលាការ ទៅតាមការចាំបាច់

នៅពេលធ្វើការបែងចែក ឬផ្លាស់ប្តូរសិទ្ធិកាន់កាប់ ដូចជា ការធ្វើឱ្យសិទ្ធិបែបទំនៀមទម្លាប់ក្លាយជាសិទ្ធិស្របច្បាប់ តួនាទីរបស់រដ្ឋ និងសេវា ដែលរដ្ឋចាំបាច់ត្រូវផ្តល់ មានពាក់ព័ន្ធជាមួយនឹងទិដ្ឋភាពបន្ថែមទៀត ដែលអាចមានដូចជា ដំណើរការពិគ្រោះយោបល់ និងចរចា ដោយមានការចូលរួម និងការផ្តល់ការគាំទ្រដល់ការអភិវឌ្ឍស្ថាប័ន និងការបង្កើតនូវរចនាសម្ព័ន្ធស្ថាប័នសមស្រប។

ដូចដែលបានកត់សម្គាល់ខាងលើ ការគ្រប់គ្រង និងសិទ្ធិកាន់កាប់ធនធាននេសាទ (និងការគ្រប់គ្រង និងសេវានានា) ច្រើនតែស្ថិតក្រោមការទទួលខុសត្រូវរបស់នាយកដ្ឋាន ឬអាជ្ញាធរជលផល ប៉ុន្តែអាជ្ញាធរដទៃទៀតអាចពាក់ព័ន្ធផងដែរ (ដូចជា នៅក្នុងករណីការគ្រប់គ្រងតំបន់ការពារក្នុងដែនសមុទ្ទ ជាដើម)។ ប៉ុន្តែ ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការចម្រុះ ដែលមានទំនាក់ទំនងជាមួយគ្នាទៅវិញទៅមករបស់សហគមន៍នេសាទតូចតាច ដូចជា ការទទួលបានដីធ្លី និងធនធានដទៃទៀត ដែលចាំបាច់ សម្រាប់ការប្រកបរបរចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព គេចាំបាច់ត្រូវប្រើប្រាស់អភិក្រមក្តោបរួម ដោយយកសិទ្ធិធ្វើជាមូលដ្ឋាន សម្រាប់ធ្វើការងារអភិបាលកិច្ច និងអភិវឌ្ឍន៍ ពោលគឺត្រូវមានទំនាក់ទំនងអន្តរវិស័យ និងការសហការជាមួយនឹងស្ថាប័ន និង/ឬតួអង្គផ្សេងទៀតរបស់រដ្ឋាភិបាល ដើម្បីធានាយ៉ាងណាឱ្យមានស្ថាប័នទាំងនេះមានសមត្ថភាព ក្នុងការផ្តល់សេវាប្រកបដោយគុណភាព។ លើសពីនេះ ចំណេះដឹងអំពីស្ថានភាពមូលដ្ឋាន មានសារៈសំខាន់ សម្រាប់ផ្តល់សេវា ដែលសមស្របសម្រាប់កាលៈទេសៈជាក់លាក់ នៅតាមទីតាំងផ្សេងៗគ្នា ហើយការធ្វើវិមជ្ឈការការផ្តល់សេវាទៅឱ្យអាជ្ញាធរមូលដ្ឋាន ជាអ្នកទទួលខុសត្រូវ អាចផ្តល់ការគាំទ្រដល់ការសម្រេចនូវលទ្ធផលនានាឱ្យបានកាន់តែគ្រប់គ្រាន់ជាងមុន។

គួរមានការកត់សម្គាល់ថា ជារឿយៗ សហគមន៍នេសាទ ច្រើនមានទីតាំង នៅតំបន់ដាច់ស្រយាល។ ការធ្វើចំណាកស្រុក គឺជាយុទ្ធសាស្ត្រចិញ្ចឹមជីវិតជាទូទៅ ហើយអ្នកនេសាទ និងកម្មករនេសាទ ច្រើនតែចល័តជាងសហគមន៍ជនបទ។ គេចាំបាច់ត្រូវតែធ្វើការពិចារណាលើចំណុចទាំងនេះ នៅពេលផ្តល់សេវាតាមបែបផែនលើសពីមួយ ដោយធានាយ៉ាងណាឱ្យសេវា ទាំងនេះអាចបានដល់អ្នកនៅតាមតំបន់ដាច់ស្រយាល និងផ្តល់ទាន់ពេលវេលាដល់ប្រជាជន ដែលជាជនចំណាកស្រុក (Njock and Westlund, 2008)។ គួរមានការស្វែងយល់ពីបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ (ICT) ទំនើប សម្រាប់គោលបំណងនេះ។

ការគ្រប់គ្រងសិទ្ធិកាន់កាប់ ចាំបាច់ត្រូវតែមានថវិកាគាំទ្រ។ រដ្ឋអាចប្រមូលថ្លៃឈ្នួល ដែលបង្កើតដោយធនធាននេសាទ និងអាចប្រើប្រាស់ការយកពន្ធក្នុងទម្រង់ផ្សេងៗគ្នា ដើម្បីស្តារចំណូលនេះមកវិញ។ ការប្រមូលពន្ធ នៅក្នុងបរិបទនៃសិទ្ធិកាន់កាប់ ក្នុងវិស័យនេសាទ សំដៅលើប្រភេទពន្ធ និងថ្លៃសេវាដោយផ្ទាល់ និងដោយប្រយោល ក្នុងប្រភេទផ្សេងៗគ្នាជាច្រើន។ នៅពេលដែលរដ្ឋបែងចែកសិទ្ធិនេសាទ វាជារឿងធម្មតា ដែលអ្នកកាន់កាប់សិទ្ធិនេះត្រូវបង់ថ្លៃសេវា ដូចជា ថ្លៃអាជ្ញាប័ណ្ណ ឬថ្លៃចុះបញ្ជិកានាវា ជាដើម។ ការមានការបង់ពន្ធដទៃទៀតជាច្រើន ដែលអ្នកនេសាទ ក្រុមហ៊ុននេសាទ និងកម្មករនេសាទអាចបង់ផងដែរ (Béné, Macfadyen and Allison, 2007) ដូចជា ៖

- ពន្ធប្រាក់ចំណូល និងពន្ធការងារ ដូចជា ការរួមភាគទានចំពោះការធានារ៉ាប់រងរបស់ជាតិ
- ពន្ធលើចំណូលលក់ ឬប្រាក់ចំណូលរបស់ក្រុមហ៊ុន
- ពន្ធលើការងារសង្គម
- អាការលើផលិតផល ដែលប្រើប្រាស់ជាធាតុចូល សម្រាប់សកម្មភាពអាជីវកម្ម
- ពន្ធគយលើការនាំចូល និងការនាំចេញ
- ពន្ធតម្លៃបន្ថែម
- ថ្លៃសេវាយកត្រីមកគោក
- ពន្ធលើការលក់

កម្រិតនៃតម្លៃអាជ្ញាប័ណ្ណ - ពោលគឺតម្លៃរបស់សិទ្ធិកាន់កាប់ - គួរសំដៅលើតម្លៃរបស់សិទ្ធិនេះ (សូមមើលការពិភាក្សាខាងលើ)។ នៅក្នុងបរិបទនេះ មានការសម្រេចចិត្តកម្រិតនយោបាយ ដែលត្រូវធ្វើឡើង ហើយរដ្ឋអាចចង់ធ្វើការពិចារណាលើផលប៉ះពាល់នៃរចនាសម្ព័ន្ធថ្លៃសេវា និងផែនការប្រមូលពន្ធរបស់ខ្លួន។

## សមត្ថភាព និងរចនាសម្ព័ន្ធស្ថាប័ន

**VGGT លើកឡើងពីភាពចាំបាច់ ដើម្បីធានាយ៉ាងណាឱ្យមានសមត្ថភាព និងរចនាសម្ព័ន្ធស្ថាប័ន ដូចជា លើកឡើងថា ៖**

*ក្នុងកម្រិត ដែលអាចធ្វើបានទៅតាមធនធានដែលមាន រដ្ឋគួរធានាយ៉ាងណាឱ្យស្ថាប័នអនុវត្ត និងអាជ្ញាធរយុត្តិធម៌ មាននូវសមត្ថភាពធនធានមនុស្ស សមត្ថភាពរូបវន្ត សមត្ថភាពហិរញ្ញវត្ថុ និងសមត្ថភាពក្នុងទម្រង់ដទៃទៀត ដើម្បីអនុវត្ត គោលនយោបាយ និងច្បាប់ ឱ្យបានទាន់ពេលវេលា ប្រកបដោយប្រសិទ្ធភាព និងឆ្លើយតបចំពោះយេនឌ័រ។ បុគ្គលិកនៅគ្រប់កម្រិតទាំងអស់ គួរទទួលបានការបណ្តុះបណ្តាលបន្តបន្ទាប់ និងគួរត្រូវបានជ្រើសរើស តាមបែបផែនដែលអាចធានាបាននូវសមភាពយេនឌ័រ និងសមភាពសង្គម។*

**(៦.១ នៅក្នុងការផ្តល់សេវា )**

*... រដ្ឋ និងភាគីពាក់ព័ន្ធដទៃទៀត គួរផ្តល់ព័ត៌មានដល់បុគ្គល គ្រួសារ និងសហគមន៍ អំពីសិទ្ធិកាន់កាប់របស់ពួកគេ និងជួយអភិវឌ្ឍសមត្ថភាពរបស់ពួកគេខាងផ្នែកការពិគ្រោះយោបល់ និងការចូលរួម និងការផ្តល់នូវជំនួយវិជ្ជាជីវៈ ទៅតាមការចាំបាច់។*

**(១២.៩ នៅក្នុងការវិនិយោគ )**

អភិបាលកិច្ចលើសិទ្ធិកាន់កាប់ប្រកបដោយប្រសិទ្ធភាព សម្រាប់ការធ្វើនេសាទខ្នាតតូច ត្រូវការអមជាមួយនូវកិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍសមត្ថភាព នៅកម្រិតផ្សេងៗ។ ការអភិវឌ្ឍសមត្ថភាពនេះ ពាក់ព័ន្ធជាមួយនឹងការពង្រឹងជំនាញ និងសមត្ថភាពរបស់បុគ្គលម្នាក់ៗផង និងការធានាយ៉ាងណាឱ្យមានការដាក់ឱ្យអនុវត្តនូវរចនាសម្ព័ន្ធ និងដំណើរការស្ថាប័ន ដែលសមស្របផង។ ការអភិវឌ្ឍសមត្ថភាព គ្របដណ្តប់លើការផ្តល់ភាពអង់អាចដល់សហគមន៍នេសាទ និងសមាជិករបស់ពួកគេ ដើម្បីអាចបំពេញតួនាទីសកម្ម ក្នុងការប្រើប្រាស់សិទ្ធិរបស់ពួកគេ នៅក្នុងក្របខ័ណ្ឌនៃប្រព័ន្ធសិទ្ធិកាន់កាប់ និងបំពេញការទទួលខុសត្រូវរបស់ពួកគេ នៅក្នុងបរិបទនានា ដូចជា ការរៀបចំការគ្រប់គ្រងរួមគ្នា ជាដើម។ វាក៏មានន័យផងដែរថាជាការបង្កើតនូវក្របខ័ណ្ឌអំណោយផល ដូចជា គោលនយោបាយគាំទ្រ និងបញ្ញត្តិច្បាប់ ដែលចាំបាច់ សម្រាប់អនុវត្តប្រព័ន្ធសិទ្ធិ

កាន់កាប់ប្រកបដោយប្រសិទ្ធភាព និងសមធម៌ ដូចជា ការចូលរួមរបស់សហគមន៍នេសាទ នៅក្នុងការធ្វើសេចក្ដីសម្រេចចិត្ត អំពីការគ្រប់គ្រងធនធាននេសាទ ។ល។ ស្របទៅតាមសិទ្ធិរបស់ពួកគេ (Charles, 2011)។

វាជាការសំខាន់ ដែលត្រូវមានការផ្ដល់ភាពអង់អាចលើសពីគោលនយោបាយ និងច្បាប់ ដើម្បីដាក់បញ្ចូលនូវដំណើរការដោយមានការចូលរួម ដែលអនុវត្តនៅកម្រិតសហគមន៍។ គួរមានការទទួលស្គាល់ថា ជាធម្មតា គេបែងចែកសហគមន៍ "ទៅតាមទ្រព្យសម្បត្តិ និងអំណាច ដោយពេលខ្លះ អ្នកដែលមានធនធាននៅមូលដ្ឋាន និងអាជ្ញាធរមូលដ្ឋាន សមគំនិតគ្នា ដើម្បីផាត់ចេញអ្នកដែលមិនសូវមានអំណាច" (p. 32, FAO, 2005) ។ ដូច្នេះ គួរមានការស្វែងយល់ពី "របៀប របបនៃការដឹកនាំ "តាមបែបប្រពៃណី" ដែលអាជ្ញាធរមូលដ្ឋាន និងសង្គមស៊ីវិលអាចធ្វើការងារជាមួយគ្នាបាន ដើម្បីធានាយ៉ាងណាឱ្យមានការពិចារណាលើប្រយោជន៍របស់ក្រុមប្រជាពលរដ្ឋក្រីក្រ និងបាត់បង់ឱកាស នៅក្នុងការគ្រប់គ្រងធនធាននេសាទ តាមបែបវិមជ្ឈការ" (p. 32, FAO, 2005)។

លើសពីនេះ អភិបាលកិច្ចលើសិទ្ធិកាន់កាប់ប្រកបដោយប្រសិទ្ធភាព ត្រូវការនូវកិច្ចខិតខំប្រឹងប្រែង ដើម្បីគាំទ្រ និងកសាងសមត្ថភាពរបស់សមាគមអ្នកនេសាទ និងស្ថាប័ននានារបស់សហគមន៍។ ជារឿយៗ រដ្ឋាភិបាលក៏ត្រូវការជាចាំបាច់នូវការអភិវឌ្ឍសមត្ថភាពផងដែរ ដើម្បីឱ្យមន្ត្រីរដ្ឋាភិបាល និងការរៀបចំស្ថាប័ននានា អាចយល់ពីតម្រូវការ និងសិទ្ធិរបស់អ្នកនេសាទតូចតាច និងសហគមន៍របស់ពួកគេ។ នេះក៏ត្រូវបានអនុវត្តចំពោះរចនាសម្ព័ន្ធរបស់រដ្ឋាភិបាល នៅថ្នាក់មូលដ្ឋានផងដែរ ជាពិសេស នៅក្នុងករណីដែលដំណើរការវិមជ្ឈការបានផ្ដល់ឱ្យពួកគេនូវការទទួលខុសត្រូវច្រើនជាងមុន ពាក់ព័ន្ធជាមួយនឹង ការគ្រប់គ្រងធនធាននេសាទ និង (សិទ្ធិកាន់កាប់)។ ស្ថាប័ន និងនីតិវិធីសម្រាប់គ្រប់គ្រង ចាំបាច់ត្រូវតែធានាឱ្យមានភាពជា តំណាង និងការធ្វើសេចក្ដីសម្រេចចិត្តប្រកបដោយភាពយុត្តិធម៌។ ជារួម អភិបាលកិច្ចល្អ មានន័យថា ជាការផ្ដល់ការយកចិត្ត ទុកដាក់សមស្រប ដល់ការអភិវឌ្ឍសមត្ថភាព និងការអភិវឌ្ឍស្ថាប័ន នៅតាមអង្គការនានា ដែលតំណាង និងធ្វើការងារ តំណាងផលប្រយោជន៍របស់អ្នកប្រកបរបរនេសាទតូចតាច ដូចជា អ្នកដែលផ្ដល់ការគាំទ្របច្ចេកទេស ពាក់ព័ន្ធជាមួយនឹង បញ្ហាគ្រប់គ្រងធនធាននេសាទ អ្នកដែលធ្វើការងារផ្នែកសុខុមាលភាពសង្គម ឥណទាន/ការសន្សំប្រាក់ និងបញ្ហាទីផ្សារ និង អ្នកដែលចូលរួមនៅក្នុងការចរចានយោបាយ ឬការបញ្ចុះបញ្ចូលជាដើម (Charles, 2011)។

**VGGT ទទួលស្គាល់នូវសារៈសំខាន់របស់កិច្ចសហប្រតិបត្តិការថ្នាក់តំបន់ និងអន្តរជាតិ និងភាពចាំបាច់ ក្នុងការដោះស្រាយបញ្ហាឆ្លងដែន និងលើកឡើងថា ៖**

*ក្នុងករណីដែលសមស្រប រដ្ឋគួរធ្វើសុខុដុមនីយកម្មស្តង់ដាច្បាប់ ដែលពាក់ព័ន្ធជាមួយនឹងអភិបាលកិច្ចលើសិទ្ធិកាន់កាប់ ស្របទៅតាមកាតព្វកិច្ច ដែលមានស្រាប់ ក្រោមច្បាប់ជាតិ និងអន្តរជាតិ និងទៅតាមការប្តេជ្ញាចិត្តស្ម័គ្រចិត្ត ក្រោមលិខិតុបករណ៍ថ្នាក់តំបន់ និងអន្តរជាតិ ដែលមានជាធរមាន។ ក្នុងករណីសមស្រប គួរមានការសម្របសម្រួល ជាមួយនឹងស្ថាប័នថ្នាក់តំបន់ ដែលពាក់ព័ន្ធ និងភាគីដែលទទួលរងផលប៉ះពាល់។ រដ្ឋ ដោយមានការចូលរួមពីភាគីដែលទទួលរងផលប៉ះពាល់ ទៅតាមការសមស្រប គួរបង្កើត ឬពង្រឹងវិធានការអន្តរជាតិដែលមានស្រាប់ ដើម្បីគ្រប់គ្រងសិទ្ធិកាន់កាប់ ដែលឆ្លងព្រំដែនអន្តរជាតិ។ នៅក្នុងករណីសមស្រប រដ្ឋទាំងនេះគួរសម្របសម្រួលជាមួយនឹងអង្គភាពនៅថ្នាក់តំបន់ដែលពាក់ព័ន្ធ។ នេះគួរធ្វើឡើង ជាពិសេស ដើម្បីការពារមុខរបរចិញ្ចឹមជីវិត ស្របទៅតាមកថាខណ្ឌ ៤.៨ ក៏ដូចជាដើម្បីការពារសិទ្ធិរបស់អ្នកដែលទទួលរងផលប៉ះពាល់ទាំងអស់។*

**(២២.៣ នៅក្នុង *បញ្ហាឆ្លងដែន* )**

ការគ្រប់គ្រងសិទ្ធិកាន់កាប់ នៅតាមតំបន់ឆ្លងដែរ ដូចជា នៅពេលដែលធនធាននេសាទ ត្រូវបានប្រមូលដោយអ្នកនេសាទឆ្លងព្រំដែនអន្តរជាតិ បង្កឱ្យមានបញ្ហាពិសេស ដែលចាំបាច់ត្រូវដោះស្រាយ នៅថ្នាក់តំបន់ និងអន្តរជាតិ។ រដ្ឋត្រូវខិតខំធ្វើសុខុដុមនីយកម្មគោលនយោបាយ និងក្របខ័ណ្ឌច្បាប់នានា ដើម្បីបំពេញទៅតាមតម្រូវការរបស់សហគមន៍នេសាទ។ ភាពចាំបាច់ ដើម្បីឱ្យមានកិច្ចសហប្រតិបត្តិការថ្នាក់តំបន់ ពាក់ព័ន្ធជាមួយនឹងការគ្រប់គ្រងធនធាននេសាទ ក៏ត្រូវបានទទួលស្គាល់យ៉ាងល្អផងដែរ។ ដូចលើកឡើងខាងលើ ក្នុងផ្នែកទី ១ (សូមមើលផ្នែកតើអ្នកណា ដែលមានសិទ្ធិទទួលបានធនធាននេសាទ និងថាតើមានការទទួលខុសត្រូវពាក់ព័ន្ធអ្វីខ្លះ? ) កិច្ចសហប្រតិបត្តិការ ធ្វើឡើង តាមរយៈការបង្កើតស្ថាប័ននៅថ្នាក់ តំបន់ (ដូចជា RFBs និង RFMOs/As ជាដើម) និងតាមរយៈគំនិតផ្តួចផ្តើមពាក់ព័ន្ធនឹងធនធានសមុទ្ទ និងធនធានវារីជាតិថ្នាក់ តំបន់ ឬគំនិតផ្តួចផ្តើម ដែលមានមូលដ្ឋានលើប្រព័ន្ធអេកូឡូហ្ស៊ីដទៃទៀត។ ស្ថាប័នទាំងនេះចាំបាច់ត្រូវបំពេញតួនាទី ពាក់ព័ន្ធ ជាមួយនឹងការធានាសិទ្ធិកាន់កាប់ សម្រាប់ការប្រកបរបរនេសាទខ្នាតតូច និងសិទ្ធិកាន់កាប់របស់សហគមន៍នេសាទ។ រដ្ឋាភិបាលចាំបាច់ត្រូវផ្តល់ការគាំទ្រដល់កិច្ចសហប្រតិបត្តិការថ្នាក់តំបន់ ក្នុងក្របខ័ណ្ឌនេះ។

ការគ្រប់គ្រងធនធាននេសាទ និងសិទ្ធិកាន់កាប់ធនធាននេសាទ ច្រើនតែជាការទទួលខុសត្រូវរបស់នាយកដ្ឋានជលផល ឬស្ថាប័នគ្រប់គ្រង ដែលទទួលបានការចាត់តាំងដទៃទៀត (នៅថ្នាក់ជាតិ)។ ដូចដែលត្រូវបានលើកឡើងពីខាងដើម សហគមន៍នេសាទតូចតាច ត្រូវការសិទ្ធិទទួលបានធនធានដទៃទៀតបន្ថែមពីលើធនធាននេសាទឱ្យបានជាប់លាប់ ជាពិសេស ដីធ្លីតែម្តង ដើម្បីគាំទ្រដល់ការប្រកបរបរចិញ្ចឹមជីវិតរបស់ពួកគេ។ ការសម្របសម្រួលអន្តរវិស័យ ក្របខ័ណ្ឌរៀបចំផែនការទីតាំងដែលមានលក្ខណៈសមាហរណកម្ម (ដូចជា ICZM ជាដើម) និងភាពស៊ីសង្វាក់គ្នាផ្នែកគោលនយោបាយ ចាំបាច់ត្រូវតែមាន ដើម្បីបំពេញតម្រូវការនេះប្រកបដោយប្រសិទ្ធភាព។ ដើម្បីធ្វើបែបនេះបាន ទាមទារឱ្យមានរចនាសម្ព័ន្ធស្ថាប័ន និងនីតិវិធី ដែលផ្តល់លទ្ធភាពឱ្យមានកិច្ចសហប្រតិបត្តិការជាមួយគ្នា។ មានអភិក្រមជាច្រើន សម្រាប់រៀបចំស្ថាប័ន ហើយចាំបាច់ ត្រូវមានការស្វែងរកដំណោះស្រាយ សម្រាប់ករណីជាក់លាក់។ បទពិសោធន៍ ដែលទទួលបានពីការគ្រប់គ្រង ICZM, EAF និង MPA អាចផ្តល់ជាគំនិតមានប្រយោជន៍ជាច្រើន (សូមមើល FAO, 2011b, 2009b; de Young, Charles and Hjort, 2008)។

**ការណែនាំទី ៩ ៖ ការអភិវឌ្ឍសមត្ថភាព**

ការអភិវឌ្ឍសមត្ថភាព គឺជាទស្សនទានទូលំទូលាយមួយ ដែលជាគន្លឹះ សម្រាប់ផ្នែកនានា ដែលទទួលបានការគាំទ្រ និងត្រូវបានគេរំពឹងថាអាចចូលរួមចំណែកចំពោះសន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព។ ក្របខ័ណ្ឌរបស់ FAO បែងចែកសមត្ថភាពជា ២ ប្រភេទ ៖ សមត្ថភាពបច្ចេកទេស និងសមត្ថភាពមុខងារ។ សមត្ថភាពទាំងនេះ ចាំបាច់ត្រូវតែអភិវឌ្ឍឡើង នៅកម្រិត ៣ ផ្សេងៗគ្នា ដែលមានទំនាក់ទំនងជាមួយគ្នាទៅវិញទៅមក ៖ កម្រិតបុគ្គល កម្រិតស្ថាប័ន និងពាក់ព័ន្ធជាមួយនឹងបរិយាកាសអំណោយផល (សូមមើលផតថលអភិវឌ្ឍន៍សមត្ថភាពរបស់ FAO - FAO, 2013b) ៖

- សមត្ថភាពត្រូវបានអភិវឌ្ឍ នៅកម្រិតបុគ្គល នាំឱ្យមានការផ្លាស់ប្តូរជំនាញ ឥរិយាបថ និងអាកប្បកិរិយា ក្នុងចំណោមតួអង្គនានា នៅក្នុងវិស័យកសិកម្ម និងអភិវឌ្ឍន៍ជនបទ។ ការបណ្តុះបណ្តាល ការចែករំលែកចំណេះដឹង និងការបង្កើតបណ្តាញ គឺជាវិធីសាស្ត្រ សម្រាប់ពង្រឹងសមត្ថភាព នៅកម្រិតនេះ។
- ការពង្រឹងសមត្ថភាព នៅកម្រិតស្ថាប័ន រួមមាន ការចាត់វិធានការ ដើម្បីកែលំអការបំពេញមុខងារ និងលទ្ធផល

ការងារជារួមរបស់ស្ថាប័នមួយ។ ការអភិវឌ្ឍសមត្ថភាពនៅកម្រិតនេះ មានឥទ្ធិពលដោយផ្ទាល់លើរបៀបដែលបុគ្គល នៅក្នុងស្ថាប័ន ធ្វើការអភិវឌ្ឍសមត្ថភាពរបស់ពួកគេ និងប្រើប្រាស់សមត្ថភាពរបស់ពួកគេ។

- បរិយាកាសអំណោយផល គឺជាបរិបទ ដែលបុគ្គល និងស្ថាប័ន យកសមត្ថភាពរបស់ពួកគេមកអនុវត្តចេញជាសកម្មភាពជាក់ស្ដែង ហើយមានដំណើរការអភិវឌ្ឍសមត្ថភាព។ បរិយាកាសអំណោយផល រួមមាន ការប្ដេជ្ញាចិត្តកម្រិតនយោបាយ និងចក្ខុវិស័យ, ក្របខ័ណ្ឌគោលនយោបាយ ច្បាប់ និងសេដ្ឋកិច្ច, ការបែងចែកថវិកា និងដំណើរការរៀបចំថវិកា, អភិបាលកិច្ច និងរចនាសម្ព័ន្ធអំណាច, ការលើកទឹកចិត្ត និងបទដ្ឋានសង្គម។

អភិក្រម/ឧបករណ៍ ដែលត្រូវប្រើ ៖

- សិក្ខាសាលាសម្រាប់អ្នកពាក់ព័ន្ធ (សូមមើលឧបសម្ព័ន្ធទី ២)
- ការបង្កើតចក្ខុវិស័យ (សូមមើលឧបសម្ព័ន្ធទី ២)
- វគ្គបណ្ដុះបណ្ដាល
- ការបង្កើតបណ្ដាញ និងការចែករំលែកចំណេះដឹង
- ការអភិវឌ្ឍស្ថាប័ន

## បញ្ជិកា កំណត់ត្រា និងព័ត៌មានអំពីសិទ្ធិ

**ពាក់ព័ន្ធជាមួយនឹងប្រធានបទស្ដីពីកំណត់ត្រាសិទ្ធិកាន់កាប់ VGGT លើកឡើងថា ៖**

*រដ្ឋគួរបង្កើតនូវប្រព័ន្ធ (ដូចជា ប្រព័ន្ធចុះបញ្ជិកា ប្រព័ន្ធសុរិយោដី និងប្រព័ន្ធអាជ្ញាប័ណ្ណ) ដើម្បីកត់ត្រាពីសិទ្ធិកាន់កាប់របស់បុគ្គល និងសិទ្ធិកាន់កាប់ជាសមូហភាព ដើម្បីលើកកម្ពស់ភាពជាប់លាប់នៃសិទ្ធិកាន់កាប់ រាប់បញ្ចូលទាំងសិទ្ធិ ដែលកាន់កាប់ដោយរដ្ឋ និងវិស័យសាធារណៈ វិស័យឯកជន និងជនជាតិដើមភាគតិច និងសហគមន៍ដទៃទៀត ដែលប្រើប្រាស់ប្រព័ន្ធសិទ្ធិកាន់កាប់បែបទំនៀមទម្លាប់ និងសម្រាប់ការដំណើរការរបស់សង្គម និងទីផ្សារ។ ប្រព័ន្ធទាំងនេះគួរកត់ត្រា រក្សាទុក និងផ្សព្វផ្សាយជាសាធារណៈនូវសិទ្ធិកាន់កាប់ និងភារកិច្ចនានា រួមទាំងអ្នកដែលមានសិទ្ធិ និងភារកិច្ចទាំងនេះផង ក៏ដូចជា ប្លង់*

*ឬកម្មសិទ្ធិដីធ្លី ធនធាននេសាទ និងធនធានព្រៃឈើ ដែលសិទ្ធិ និងភារកិច្ចទាំងនេះពាក់ព័ន្ធជាមួយ។*

**(១៧.១ នៅក្នុង *កំណត់ត្រាសិទ្ធិកាន់កាប់*)**

ជាការសំខាន់ណាស់ ដែលបុគ្គល និងសហគមន៍ដែលមានសិទ្ធិ អាចការពារសិទ្ធិរបស់ពួកគេដោយស្របច្បាប់ ហើយសិទ្ធិទាំងនេះចាំបាច់ត្រូវមានភាពច្បាស់លាស់ និងចុះបញ្ជិកាត្រឹមត្រូវ។ វាក៏មានសារៈសំខាន់ជាទូទៅផងដែរ ដែលអ្នកគ្រប់គ្រងធនធាននេសាទ ត្រូវទទួលព័ត៌មានអំពីចំនួនអ្នកមានសិទ្ធិ និងប្រភេទសិទ្ធិដែលពួកគេមាន និងថាតើត្រីច្រើនប៉ុណ្ណា ដែលគេកំពុងនេសាទ។ ព័ត៌មានប្រភេទនេះ គឺជាមូលដ្ឋាន សម្រាប់ការសម្រេចចិត្តក្នុងការគ្រប់គ្រង។ តម្រូវការព័ត៌មាន សម្រាប់គោលបំណងគ្រប់គ្រងធនធាននេសាទ មិនត្រូវបានលើកយកមកពិភាក្សា នៅក្នុងឯកសារនេះឡើយ ប៉ុន្តែគួរមានការកត់សម្គាល់ថា មានប្រភេទសិទ្ធិកាន់កាប់មួយចំនួន នៅក្នុងវិស័យនេសាទ ដែលត្រូវការទិន្នន័យផលចាប់ ដែលល្អ និងអាចជឿជាក់បាន ដើម្បីអាចដំណើរការទៅបាន។ សិទ្ធិទាំងនេះ រួមមាន គ្រប់សិទ្ធិទាំងអស់ ដែលពាក់ព័ន្ធជាមួយនឹងកូតា។ ឧទាហរណ៍ ការរៀបចំ ITQ តម្រូវឱ្យមានប្រព័ន្ធទិន្នន័យមួយ ដែលផ្តល់លទ្ធភាពឱ្យគេអាចកត់ត្រាទិន្នន័យឱ្យបានសុក្រឹត និងប្រកបដោយប្រសិទ្ធភាព។

ព័ត៌មាន ចាំបាច់ត្រូវមានសម្រាប់អ្នកមានសិទ្ធិ ហើយចាំបាច់ត្រូវមាន ដើម្បីធានាឱ្យមានការអនុវត្តប្រព័ន្ធសិទ្ធិកាន់កាប់ប្រកបដោយប្រសិទ្ធភាព។ នៅក្នុងបរិបទនេសាទខ្នាតតូច ត្រូវតែមានការធានាឱ្យប្រាកដថា អ្នកនេសាទ និងកម្មករនេសាទមានព័ត៌មានអំពីសិទ្ធិរបស់ពួកគេ ហើយពួកគេក៏មានសមត្ថភាព ក្នុងការទាមទារសិទ្ធិទាំងនេះផងដែរ។ សហគមន៍ដែលមានសិទ្ធិបែបទំនៀមទម្លាប់ គួរអាចការពារសិទ្ធិទាំងនេះ នៅពេលដែលពួកគេទទួលរងការគំរាមកំហែង ដោយសារការអភិវឌ្ឍក្នុងវិស័យដទៃទៀត ដែលអាចប្រកួតប្រជែងជាមួយនឹងសិទ្ធិរបស់ពួកគេ ក្នុងការទទួលបានធនធាននេសាទ ក៏ដូចជាដីធ្លី។

**VGGT លើកកម្ពស់ក្របខ័ណ្ឌរួម សម្រាប់ចុះបញ្ជិកាសិទ្ធិ និងលើកឡើងថា ៖**

*ដើម្បីលើកកម្ពស់តម្លាភាព និងភាពស្របគ្នាជាមួយនឹងប្រព័ន្ធព័ត៌មានដទៃទៀត សម្រាប់គោលបំណងនៃការរៀបចំផែនការទីតាំង និងសម្រាប់គោលបំណងដទៃទៀត រដ្ឋនីមួយៗគួរខិតខំបង្កើតនូវក្របខ័ណ្ឌរួមមួយ ដែលមានដាក់បញ្ចូលនូវ*

*ប្រព័ន្ធកត់ត្រាដែលមានស្រាប់ និងប្រព័ន្ធព័ត៌មានទីតាំងដទៃទៀត។ នៅក្នុងយុត្តាធិការនីមួយៗ កំណត់ត្រាសិទ្ធិកាន់កាប់របស់រដ្ឋ និងវិស័យសាធារណៈ វិស័យឯកជន និងជនជាតិដើមភាគតិច និងសហគមន៍ដទៃទៀត ដែលមានប្រព័ន្ធសិទ្ធិកាន់កាប់បែបទំនៀមទម្លាប់ គួររក្សាទុក នៅក្នុងប្រព័ន្ធកត់ត្រា ដែលមានលក្ខណៈសមាហរណកម្មរួមបែបនេះ។*

**(១៧.២ នៅក្នុងកំណត់ត្រាសិទ្ធិកាន់កាប់ )**

ទម្រង់ពិតប្រាកដនៃបញ្ជិកាសិទ្ធិ ដែលចាំបាច់ត្រូវមាន គឺអាស្រ័យទៅតាមស្ថានភាព និងបរិបទជាក់លាក់។ ស្របទៅតាមតម្រូវការ សម្រាប់រៀបចំផែនការទីតាំង និងការឆ្លើយតបចំពោះតម្រូវការរបស់សហគមន៍នេសាទតូចតាច ពាក់ព័ន្ធនឹងសិទ្ធិកាន់កាប់ធនធានផ្សេងៗគ្នា គេគួរបង្កើតនូវក្របខ័ណ្ឌរួមមួយ សម្រាប់ចុះបញ្ជិកាសិទ្ធិ។ នៅកម្រិតរដ្ឋ គួរមានការរក្សាទុកនូវបញ្ជិកាផ្លូវការសាធារណៈមួយ។ ចាំបាច់ត្រូវមានដំណើរការជាផ្លូវការរបស់រដ្ឋ សម្រាប់គោរព និងការពារសិទ្ធិនានា។ ប្រព័ន្ធបែបនេះ ក៏គួរដាក់បញ្ចូលនូវសិទ្ធិបែបទំនៀមទម្លាប់ផងដែរ។ នៅពេលមានការផ្តល់ការទទួលស្គាល់ជាផ្លូវការលើសិទ្ធិបែបទំនៀមទម្លាប់ (សូមមើលផ្នែកការបែងចែកសិទ្ធិ ខាងលើ) ការដាក់បញ្ចូលសិទ្ធិទាំងនេះ ទៅក្នុងបញ្ជិកាសាធារណៈ អាចជាជំហានមួយ នៅក្នុងដំណើរការនេះ។

ប្រសិនបើមានការបែងចែកសិទ្ធិរបស់សហគមន៍ ឬសិទ្ធិរបស់ក្រុមក្នុងទម្រង់ដទៃទៀត រដ្ឋចាំបាច់ត្រូវរក្សាកំណត់ត្រាអំពីសហគមន៍ ឬក្រុម ដែលបានទទួលសិទ្ធិ និងប្រភេទសិទ្ធិ ដែលពួកគេបានទទួល។ នៅកម្រិតសហគមន៍ (ឬក្រុម) ចាំបាច់ត្រូវតែមានប្រព័ន្ធមួយ សម្រាប់ធ្វើការតាមដាន ថាតើបុគ្គលណាខ្លះ ដែលកំពុងប្រើប្រាស់សិទ្ធិសមូហភាព និងថាតើពួកគេប្រើប្រាស់សិទ្ធិទាំងនេះយ៉ាងដូចម្តេច។ នេះអាចធ្វើបាន តាមរយៈបញ្ជិកាសិទ្ធិ ឬមណ្ឌលព័ត៌មានសិទ្ធិ (ដែលចាត់ចែងដោយ "ក្រុមចាស់ព្រឹទ្ធាចារ្យ" ឬសមាជិកសហគមន៍ទូទៅ ដូចនៅក្នុងប្រព័ន្ធជាប្រពៃណីដែរ)។

នៅក្នុងវិស័យនេសាទ ការកត់ត្រាសិទ្ធិអាចជួបប្រទះនឹងការប្រឆាំងតបតខ្លះ ដោយសារតែការរក្សាអាថ៌កំបាំង គឺជាអ្វីដែលសំខាន់ នៅក្នុងករណីដែលការមានសិទ្ធិកាន់កាប់ជាប់លាប់មានកម្រិតទាប ហើយការប្រកួតប្រជែងគ្នាមានកម្រិតខ្ពស់ (ឧ. កម្មសិទ្ធិបញ្ញា - "ខ្ញុំដឹងពីកន្លែងរបស់ខ្ញុំ")។ អ្នកនេសាទដឹងពីគ្រោះថ្នាក់នៃការកត់ត្រាដែននេសាទរបស់ពួកគេ ហើយមិនមែនចេះតែមានចំណាប់អារម្មណ៍ ក្នុងការចែករំលែកចំណេះដឹងរបស់ពួកគេ ដែលជាផ្នែកមួយនៃធនធានសម្រាប់ការបំពេញការងាររបស់ពួកគេនោះទេ (FAO, 2011a)។

តម្លាភាព មានសារៈសំខាន់ចំពោះគ្រប់ទិដ្ឋភាពទាំងអស់ ដែលពាក់ព័ន្ធជាមួយនឹងការបែងចែក ឬការផ្ទេរសិទ្ធិ។ ការសម្រេចចិត្តនានា ដែលត្រូវបានពិភាក្សាខាងលើអំពីអ្នកដែលអាចទទួលបានសិទ្ធិ និងថាតើសិទ្ធិទាំងនេះត្រូវបានគេបែងចែក និងផ្ទេរដោយរបៀបណានោះ គួរតែធ្វើឡើងដោយមានហេតុផលសមស្រប ហើយត្រូវមានព័ត៌មានអំពីរបៀបដែលការសម្រេចចិត្តទាំងនេះត្រូវបានធ្វើឡើង។ តម្លាភាពក៏មានន័យផងដែរថា រដ្ឋគួរធ្វើសេចក្តីសម្រេចចិត្តផ្អែកទៅតាមព័ត៌មានត្រឹមត្រូវស្របទៅតាមគោលនយោបាយជារួម នៅពេលធ្វើការរៀបចំប្រព័ន្ធសិទ្ធិកាន់កាប់។ ស្ថានភាពពិសេសកើតមានឡើង នៅពេលដែលរដ្ឋចូលរួមក្នុងកិច្ចព្រមព្រៀងនេសាទជាលក្ខណៈអន្តរជាតិ ពោលគឺរដ្ឋផ្តល់សិទ្ធិ (អាជ្ញាប័ណ្ណ) ដល់នាវានេសាទបរទេសធំៗ។ គួរមានការអនុវត្តនូវអភិក្រមប្រកបដោយការទទួលខុសត្រូវ ហើយការបែងចែកសិទ្ធិទាំងនេះ គួរធ្វើឡើង តែប្រសិនបើសិទ្ធិរបស់អ្នកដទៃ (អ្នកនេសាទខ្នាតតូច) មិនទទួលរងផលប៉ះពាល់ជាអវិជ្ជមាន ហើយពុំមានការគំរាមកំហែងដល់និរន្តរភាពរបស់ធនធានឡើយ។ ចំណុចនេះ មានន័យថា គោលនយោបាយ ចាំបាច់ត្រូវតែស៊ីសង្វាក់ និងស្របទៅតាមគោល-បំណងនៅថ្នាក់ជាតិ ដែលពាក់ព័ន្ធជាមួយនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ការលុបបំបាត់ភាពក្រីក្រ ការអភិវឌ្ឍប្រកបដោយសមធម៌ និងការប្រើប្រាស់ធនធានប្រកបដោយនិរន្តរភាព។

## យន្តការដោះស្រាយវិវាទ

**VGGT ឆ្លើយតបចំពោះភាពចាំបាច់ ដើម្បីបញ្ចៀស និងដោះស្រាយវិវាទនានា និងលើកឡើងថា ៖**

*រាល់ភាគីទាំងអស់ គួរចាត់វិធានការ ដើម្បីបង្ការ និងលុបបំបាត់បញ្ហា ពាក់ព័ន្ធនឹងសិទ្ធិកាន់កាប់ដីធ្លី ធនធាននេសាទ និងធនធានព្រៃឈើ ដែលជាមូលហេតុនាំឱ្យមានវិវាទកើតឡើង ហើយគួរធានាឱ្យមានការដោះស្រាយបញ្ហាសិទ្ធិកាន់កាប់ មុន ក្នុងកំឡុងពេល និងក្រោយពេលដែលមានវិវាទកើតមានឡើង ដូចជា នៅក្នុងស្ថានភាពនៃការកាន់កាប់ ដែលភាគីនានាគួរធ្វើសកម្មភាពស្របទៅតាមច្បាប់មនុស្សធម៌អន្តរជាតិ ដែលមានជាធរមាន។*

**(២៥.១ នៅក្នុង *វិវាទ ពាក់ព័ន្ធជាមួយនឹងសិទ្ធិកាន់កាប់ដីធ្លី ធនធាននេសាទ និងធនធានព្រៃឈើ*)**

នៅក្នុងករណីដែលមានការប្រជែងគ្នា និងមានអ្នកប្រើប្រាស់ច្រើននាក់សម្រាប់ធនធានតែមួយ វាមិនមែនជារឿងខុសធម្មតានោះទេ ដែលមានវិវាទកើតមានឡើងនោះ។ នៅក្នុងការផ្ដល់ការបណ្ដុះបណ្ដាលអំពីការគ្រប់គ្រងវិវាទពាក់ព័ន្ធនឹងសិទ្ធិកាន់កាប់ដីធ្លីរបស់ខ្លួន FAO បានកត់សម្គាល់ថា វិវាទកើតមានឡើង (p.1, Herrera & da Passano, 2006) ដោយសារ ៖

- សិទ្ធិកាន់កាប់ដីធ្លី ដែលជាកេរ្តិ៍មរតកបន្សល់ទុកកន្លងមក
- ព្រំប្រទល់រវាងគ្រួសារ ឬសហគមន៍ជិតខាងគ្នា
- ការមិនយល់ស្របគ្នារវាងអ្នកចិញ្ចឹមសត្វ និងកសិករ លើលទ្ធភាពប្រើប្រាស់ដីធ្លី និងទឹក នៅក្នុងដែនដីជាក់លាក់ណាមួយ
- ការមិនយល់ស្របគ្នារវាងសហគមន៍មួយ និងស្ថាប័នរដ្ឋាភិបាលណាមួយ ពាក់ព័ន្ធនឹងការប្រើប្រាស់ដីរដ្ឋ
- ភាពត្រួតគ្នារវាងក្របខ័ណ្ឌទំនៀមទម្លាប់ និងក្របខ័ណ្ឌច្បាប់ នៅក្នុងការផ្ដល់ការទទួលស្គាល់ដល់សិទ្ធិដីធ្លី

នៅក្នុងបរិបទនៃការធ្វើនេសាទ និងសហគមន៍នេសាទខ្នាតតូច គេសង្កេតឃើញមានវិវាទក្នុងប្រភេទស្រដៀងគ្នានេះដែរ។ វិវាទទាំងនេះអាចកើតឡើងលើដីធ្លី ឬលើធនធាននេសាទ ឬទាំងពីរ។ ដូចដែលបានរៀបរាប់នៅក្នុងផ្នែកទី ១ (សូមមើលផ្នែក ហេតុអ្វីបានជាចាំបាច់ត្រូវមានអភិបាលកិច្ចលើសិទ្ធិកាន់កាប់ប្រកបដោយការទទួលខុសត្រូវ នៅក្នុងវិស័យនេសាទ? ) វាមិនមែនជារឿងខុសធម្មតានោះទេ ដែលមានវិវាទកើតមានឡើង រវាងអ្នកប្រើប្រាស់ខុសគ្នា នៅក្នុងតំបន់ឆ្នេរ ឧ. សហគមន៍នេសាទ ប្រឈមនឹងការប្រជែងដីធ្លី និងដែនទឹក ជាមួយនឹងការអភិវឌ្ឍទេសចរណ៍ ឧស្សាហកម្ម និងថាមពល។ ជារឿយៗ វិវាទលើការគ្រប់គ្រងធនធាននេសាទ និងការគ្រប់គ្រងតំបន់ឆ្នេរ ពាក់ព័ន្ធនឹងបញ្ហា និងភាគីជាច្រើន ដែលធ្វើឱ្យការដោះស្រាយវិវាទទាំងនេះកាន់តែលក្ខណៈស្មុគស្មាញ (FAO, 2011b)។

រដ្ឋាភិបាលមានតួនាទីសំខាន់ ដែលត្រូវបំពេញ ទាំងក្នុងការទប់ស្កាត់មិនឱ្យវិវាទកើតឡើងផង និងនៅក្នុងការដោះស្រាយវិវាទ ដែលកើតឡើងផង។ តាមរយៈការប្រើប្រាស់ក្របខ័ណ្ឌគ្រប់គ្រងទីតាំង ដែលមានលក្ខណៈទូលំទូលាយ ក៏ដូចជា ដំណើរការពិគ្រោះយោបល់ ដែលមានការចូលរួម សម្រាប់ធ្វើការគ្រប់គ្រងទីតាំង និងអនុវត្តគោលការណ៍តម្លាភាព បញ្ហាជាច្រើន ដែលពាក់ព័ន្ធជាមួយនឹងការប្រជែងគ្នាប្រើប្រាស់ធនធាន ពិតអាចដោះស្រាយបាន (សូមមើលប្រអប់ទី ៦ នៅក្នុងផ្នែកទី ១)។ យ៉ាងណាក៏ដោយ គេត្រូវទទួលស្គាល់ថា មិនមែនគ្រប់អ្នកប្រើប្រាស់ទាំងអស់សុទ្ធតែពេញចិត្តស្មើៗគ្នានោះទេ ហើយជាការសំខាន់ណាស់ ដែលត្រូវធានាយ៉ាងណាឱ្យដំណើរការនានាដែលមាន មិនធ្វើឱ្យមានការលំបាកចំពោះក្រុមអ្នក

ពាក់ព័ន្ធដែលខ្សោយរួចទៅហើយនោះ។ សិទ្ធិកាន់កាប់ដែលមានស្រាប់ រាប់បញ្ចូលទាំងសិទ្ធបែបទំនៀមទម្លាប់ ដូចរៀបរាប់ខាងលើ គួរត្រូវបានគេយកមកពិចារណាជាប់ជានិច្ច។

នៅក្នុងករណីដែលមានវិវាទកើតមានឡើង មានវិធីសាស្ត្រជាច្រើន ដើម្បីធ្វើការដោះស្រាយ។ វិវាទនីមួយៗមានលក្ខណៈខុសៗគ្នា និងមានលក្ខណៈពិសេសរបស់វា ហើយគេចាំបាច់ត្រូវស្វែងរកដំណោះស្រាយ ទៅតាមវិវាទនីមួយ។ ប្រសិនបើគេអាចកំណត់រកមូលហេតុនៃវិវាទបាន គេនឹងងាយស្រួលក្នុងការស្វែងរកអភិក្រម ដើម្បីធ្វើការងារទៅមុខទៀត។ ឧទាហរណ៍ ប្រសិនបើមានវិវាទ ដោយសារតែមានការយល់មិនស្របគ្នាលើទិន្នន័យ និងអង្គហេតុ បញ្ហានេះអាចដោះស្រាយបាន តាមរយៈការស្វែងរកទិន្នន័យបន្ថែម ការសិក្សាបន្ថែម ។ល។ ការយល់ឃើញខុសគ្នា ពាក់ព័ន្ធនឹងតម្រូវការ និងប្រយោជន៍នានា និងពីរបៀបគួរចែករំលែកអត្ថប្រយោជន៍នានា បែងចែកធនធាន ឬរ៉ាប់រងលើចំណាយខាងក្រៅ គឺជាប្រភេទវិវាទដែលតែងកើតមានឡើង ដែលទាមទារឱ្យមានអន្តរាគមន៍គ្រប់គ្រងវិវាទ។ វិវាទលើគុណតម្លៃ ដូចជា ជំនឿជាដើម មិនអាចដោះស្រាយតាមការចរចា ឬអភិក្រមគ្រប់គ្រងវិវាទដទៃទៀតគ្រប់ពេលនោះទេ ហើយដំណោះស្រាយអាចត្រូវតែ “ការឯកភាពគ្នាថាភាគីទាំងសងខាងមិនមានការយល់ស្របគ្នា។ ការផ្សះផ្សារដោយភាគីទី ៣ អាចជាដំណោះស្រាយចំពោះវិវាទពាក់ព័ន្ធនឹងបុគ្គលិកលក្ខណៈ និងទំនាក់ទំនង (FAO, 2011b)។

**ពាក់ព័ន្ធនឹងបញ្ហាតម្រូវការប្រព័ន្ធយុត្តិធម៌ VGGT លើកឡើងថា ៖**

*រដ្ឋគួរផ្តល់លទ្ធភាពឱ្យមានការទទួលបានយុត្តិធម៌ ដើម្បីដោះស្រាយបញ្ហារំលោភបំពានសិទ្ធិកាន់កាប់ស្របច្បាប់។ រដ្ឋគួរផ្តល់នូវមធ្យោបាយដែលមានប្រសិទ្ធភាព និងងាយស្រួលប្រើប្រាស់ ដល់មនុស្សគ្រប់រូប តាមរយៈអាជ្ញាធរតុលាការ ឬអភិក្រមដទៃទៀត ដើម្បីដោះស្រាយវិវាទលើសិទ្ធិកាន់កាប់ និងដើម្បីពង្រឹងអនុវត្តលទ្ធផលនានាឱ្យបានទាន់ពេលវេលា ដោយអស់ចំណាយសមស្រប។ រដ្ឋគួរផ្តល់សំណងទូទាត់ភ្លាមដោយយុត្តិធម៌ នៅក្នុងករណីដែលមានការដកហូតសិទ្ធិកាន់កាប់ ដើម្បីគោលបំណងសាធារណៈ។*

**(៣ក នៅក្នុងគោលការណ៍ណែនាំអំពីអភិបាលកិច្ចលើសិទ្ធិកាន់កាប់ ប្រកបដោយការទទួលខុសត្រូវ )**

យន្តការដោះស្រាយវិវាទ ចាំបាច់ត្រូវតែមាន នៅកម្រិតផ្សេងៗពីគ្នា។ នៅពេលបង្កើតយន្តការនានា ដូចជា ប្រព័ន្ធគ្រប់គ្រងរួមគ្នា ជាដើម (សូមមើលផ្នែកតើមានសិទ្ធិកាន់កាប់ផ្លូវការប្រភេទអ្វីខ្លះ នៅក្នុងវិស័យនេសាទ? នៅក្នុងផ្នែកទី ១ គេចាំបាច់ត្រូវតែគិតទុកជាមុនពីយន្តការដោះស្រាយវិវាទ។ នៅកម្រិតរដ្ឋាភិបាលថ្នាក់ជាតិ ឬថ្នាក់មូលដ្ឋាន ចាំបាច់ត្រូវតែមានប្រព័ន្ធ ដែលផ្តល់លទ្ធភាពឱ្យមានការធ្វើមជ្ឈត្តការតាមផ្លូវច្បាប់លើវិវាទពាក់ព័ន្ធនឹងសិទ្ធិកាន់កាប់ ទាំងនៅពេលដែលមានវិវាទកើតមានឡើងរវាងអ្នកប្រើប្រាស់ផ្សេងៗ ឬនៅពេលដែលមានការមិនយល់ស្របគ្នាទៅនឹងការសម្រេចចិត្តរបស់រដ្ឋាភិបាល។ វាជាការសំខាន់ ដែលត្រូវធានាយ៉ាងណាឱ្យរាល់ភាគីទាំងអស់មានលទ្ធភាពដូចគ្នា ក្នុងការប្រើប្រាស់ប្រព័ន្ធ និងដំណើរការយុត្តិធម៌ ហើយប្រហែលជាចាំបាច់ត្រូវមានយន្តការគាំទ្រ សម្រាប់ក្រុមអ្នកពាក់ព័ន្ធ ដែលទន់ខ្សោយ ដែលជួបប្រទះនឹងការលំបាក ដោយសារតែកម្រិតវប្បធម៌ និងកម្រិតអក្ខរកម្មរបស់ពួកគេមានកម្រិតទាប។ នៅក្នុងបរិបទនេះ លក្ខខណ្ឌជាមូលដ្ឋាន គឺថា គ្រប់អ្នកពាក់ព័ន្ធទាំងអស់ត្រូវដឹងពីសិទ្ធិរបស់ខ្លួន ហើយរដ្ឋាភិបាលគួរគាំទ្រដល់ការបង្កើនការយល់ដឹងអំពី VGGT។

| **ការណែនាំទី ១០ ៖ ការគ្រប់គ្រងវិវាទ** |
| --- |
| វិវាទក្នុងវិស័យនេសាទ និងវិវាទធនធានសមុទ្ទ និងធនធានពាក់ព័ន្ធនានា មានទិដ្ឋភាពច្រើនយ៉ាង ហើយអាចកើតឡើងនៅច្រើនកម្រិតខុសៗគ្នា។ ការគ្រប់គ្រងវិវាទ គឺជាអភិក្រមស្ម័គ្រចិត្ត ដោយមានការសហការគ្នា ពោលគឺអ្នកដែលជាក់ពាក់ព័ន្ធជាមួយនឹងវិវាទ ត្រូវបង្កើតនូវដំណើរការមួយ ដើម្បីដោះស្រាយបញ្ហារបស់ខ្លួន។ |
| អភិក្រម/ឧបករណ៍ ដែលត្រូវប្រើប្រាស់ ៖<br>- ការគ្រប់គ្រងវិវាទ (សូមមើលឧបសម្ព័ន្ធទី ២) |

**កត្តាពិសេសៗ ដែលត្រូវយកមកធ្វើការពិចារណា ៖ ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយធម្មជាតិ**

**ពាក់ព័ន្ធជាមួយការប្រែប្រួលអាកាសធាតុ និងរបៀបដោះស្រាយបញ្ហានេះ នៅក្នុងបរិបទនៃសិទ្ធិកាន់កាប់ VGGT លើកឡើងថា ៖**

*ក្នុងករណីសមស្រប រដ្ឋគួរខិតខំរៀបចំ និងអនុវត្តយុទ្ធសាស្ត្រ និងសកម្មភាពនានា ដោយធ្វើការពិគ្រោះយោបល់ និងមានការចូលរួមពីមនុស្សគ្រប់រូប ទាំងស្ត្រី ទាំងបុរស ដែលអាចបាត់បង់ទីលំនៅ ដោយសារការប្រែប្រួលអាកាសធាតុ។ ការផ្តល់នូវដីធ្លី ធនធានជលផល និងធនធានព្រៃឈើផ្សេងទៀត និងជម្រើសមុខរបរចិញ្ចឹមជីវិត ដល់អ្នកដែលបាត់បង់ទីលំនៅ មិនគួរបង្កឱ្យមានផលប៉ះពាល់ដល់អ្នកផ្សេងទៀតឡើយ។ រដ្ឋក៏អាចពិចារណាផ្តល់ជំនួយពិសេសដល់រដ្ឋដែនកោះតូចៗ និងរដ្ឋកំពុងអភិវឌ្ឍដទៃទៀតផងដែរ។*

**(២៣.២ នៅក្នុង ការប្រែប្រួលអាកាសធាតុ )**

**VGGT ស្នើឱ្យមានការលើកឡើងពីសិទ្ធិកាន់កាប់ នៅក្នុងគ្រប់សមាសភាគផ្សេងៗទាំងអស់នៃការងារសង្គ្រោះបន្ទាន់ និងអភិវឌ្ឍន៍ ពោលគឺ ៖**

*រដ្ឋគួរដាក់បញ្ចូលសិទ្ធិកាន់កាប់ នៅក្នុងកម្មវិធីត្រៀមបង្ការគ្រោះមហន្តរាយ។*

*រដ្ឋ និងភាគីដទៃទៀត គួរដាក់បញ្ចូលសិទ្ធិកាន់កាប់ នៅក្នុងដំណាក់កាលឆ្លើយតបបន្ទាន់។*

*រដ្ឋ និងភាគីដទៃទៀត គួរដាក់បញ្ចូលសិទ្ធិកាន់កាប់ នៅក្នុងដំណាក់កាលស្តាបនាឡើងវិញ។*

**(២៤.៣ ២៤.៤ និង ២៤.៥ នៅក្នុង *គ្រោះមហន្តរាយធម្មជាតិ* )**

ការរៀបចំសិទ្ធិកាន់កាប់ ចាំបាច់ត្រូវតែពិចារណាលើការផ្លាស់ប្តូរជាសកល។ ដូចដែលលើកឡើង នៅក្នុងផ្នែកទី ១ ខាងលើ (សូមមើលផ្នែកតើមានបញ្ហាថ្មីៗអ្វីខ្លះ ដែលចាំបាច់ត្រូវយកមកធ្វើការពិចារណា នាពេលអនាគត?) សកលភាវូបនីយកម្មរបស់សេដ្ឋកិច្ច កំណើនប្រជាជន និងការផ្លាស់ប្តូរប្រជាសាស្ត្រ ក៏ដូចជាការច្នៃប្រឌិតថ្មីផ្នែកបច្ចេកវិទ្យា និងការផ្លាស់ប្តូររបៀបរបបរស់នៅ បង្កើតជាព្រឹត្តិការណ៍ និងការវិវឌ្ឍ ដែលគេមិនអាចព្យាករដឹងមុនបាន ដោយសារតែការប្រែប្រួល

អាកាសធាតុ។ ផ្នែកផ្សេងៗនៃនិន្នាការវិវឌ្ឍនេះ បង្កើតនូវការគំរាមកំហែង និងឱកាស ដែលនាំឱ្យមកនូវលទ្ធផលផ្សេងៗគ្នា សម្រាប់ក្រុមប្រជាជនផ្សេងៗគ្នា។ ក្រុមងាយរងគ្រោះ ទំនងជាមានការលំបាកជាង នៅក្នុងការទប់ទល់ជាមួយនឹងការផ្លាស់ប្តូរ ដូច្នេះពួកគេទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរជាង ដោយសារផលប៉ះពាល់ជាអវិជ្ជមានបង្កឡើងដោយការប្រែប្រួលអាកាសធាតុ។ តាមរយៈការពង្រឹងភាពធន់ចំពោះការប្រែប្រួល ការបង្កើនសមត្ថភាពទប់ទល់ និងការកសាងជីវភាពរស់នៅប្រកបដោយនិរន្តរភាព ការទទួលរងការគំរាមកំហែងជាក់ស្តែងអាចមានការថយចុះ ហើយលទ្ធភាពទទួលប្រយោជន៍ពីឱកាសនានា មានការកើនឡើង។ ការធានាឱ្យមានសិទ្ធិកាន់កាប់ឱ្យបានជាប់លាប់ គឺជាផ្នែកមួយដ៏សំខាន់របស់កិច្ចខិតខំប្រឹងប្រែងទាំងនេះ ហើយរបៀបដែលសិទ្ធិកាន់កាប់ត្រូវបានរៀបចំឡើង និងបែងចែក ចាំបាច់ត្រូវតែពិចារណាលើផលវិបាក ដែលអាចបង្កឡើង ដោយការប្រែប្រួលអាកាសធាតុ។

ដូច្នេះ ប្រសិនបើ និងនៅពេលដែលការប្រែប្រួលអាកាសធាតុ នាំមកនូវការផ្លាស់ប្តូរចំពោះការបែងចែកធនធាននេសាទ ការរៀបចំសិទ្ធិកាន់កាប់ ពាក់ព័ន្ធជាមួយនឹងធនធានទាំងនេះប្រហែលជាចាំបាច់ត្រូវធ្វើការកែសម្រួល។ អ្នកនេសាទតូចតាច ទំនងជាមានលទ្ធភាពតិចតួច ក្នុង “ការទៅតាមត្រី” បើទោះបីជាការធ្វើចំណាកស្រុកកន្លងមក ដោយសារមូលហេតុច្រើនយ៉ាង គឺជាយុទ្ធសាស្ត្រចិញ្ចឹមជីវិតជាធម្មតាទៅហើយ សម្រាប់សហគមន៍នេសាទជាច្រើន។[23] ដោយសារតែចំនួនប្រជាជនមានការកើនឡើង ហើយតម្រូវការធនធានជាទូទៅកាន់មានខ្ពស់ជាងមុន គេអាចរំពឹងបានថា និន្នាការថ្មីនៃការធ្វើចំណាកស្រុក ដើម្បីប្រមូលធនធាននេសាទ នឹងកាន់តែពិបាក ដើម្បីបង្កើតឱ្យមាន ឬប្រសិនបើមាន វាអាចមានទម្រង់ជាការបាត់បង់ទីលំនៅ ដោយមិនស្ម័គ្រចិត្ត។ ចាំបាច់ត្រូវតែមានការទទួលស្គាល់ថា ភាពពាក់ព័ន្ធនៃសិទ្ធិប្រើប្រាស់ជាប្រពៃណី និងសិទ្ធិប្រើប្រាស់តាមតំបន់ដទៃទៀត អាចស្ថិតនៅជាមន្ទិលសង្ស័យ ប្រសិនបើធនធាននេសាទក្នុងមូលដ្ឋានលែងមានទៀត ឬផ្លាស់ទៅកន្លែងផ្សេងទៀត។

ប៉ុន្តែ ស្របពេលដែលសហគមន៍នេសាទមួយចំនួននឹងឃើញថាពូជត្រីគោលដៅរបស់ពួកគេបាត់បង់លែងមានទៀត សហគមន៍នេសាទដទៃទៀត អាចទទួលបានប្រយោជន៍ពីការកើនឡើងនូវពូជត្រី ដែលមានតម្លៃខ្ពស់ខាងផ្នែកពាណិជ្ជកម្ម (Cochrane *et al.,* 2009)។ បញ្ហាលំបាកនេះមិនងាយស្រួលដោះស្រាយឡើយ ប៉ុន្តែអ្វីដែលសំខាន់ គឺរដ្ឋាភិបាលត្រូវទទួលស្គាល់បញ្ហានេះ និងទទួលស្គាល់ថា នៅពេលដែលប្រព័ន្ធសិទ្ធិកាន់កាប់ត្រូវបានរៀបចំឡើង ត្រូវមានការដាក់បញ្ចូលនូវការ

[23] សូមមើល Njock and Westlund (2010, 2008) សម្រាប់ព័ត៌មានបន្ថែមអំពីការផ្លាស់ប្តូរជាសកល និងចំណាកស្រុក នៅក្នុងបរិបទនេសាទ។

ការពារ និងជម្រើសផ្សេងៗ ដើម្បីបង្កលក្ខណៈឱ្យមានការសម្របសម្រួលការរៀបចំនានា ក្នុងរយៈពេលមួយ ទៅតាមការចាំបាច់។

**ប្រអប់ទី ១៨ ៖ សហគមន៍នេសាទ នៅក្នុងប្រព័ន្ធបឹង Patos ក្នុងប្រទេសប្រេស៊ីល**

នៅក្នុងតំបន់បឹង Patos ក្នុងប្រទេសប្រេស៊ីល សហគមន៍នេសាទតូចតាច ទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរ ដោយសារការប្រែប្រួលអាកាសធាតុ ដោយហេតុថាពួកគេពឹងអាស្រ័យលើធនធានធម្មជាតិ សម្រាប់របរចិញ្ចឹមជីវិតរបស់ពួកគេ។ សហគមន៍នេសាទ ដែលធ្វើពិពិធកម្ម និងមានការរៀបចំចងក្រងខ្លួនឯងក្នុងកម្រិតខ្ពស់ជាង អាចកាត់បន្ថយភាពកម្រិតនៃភាពងាយរងគ្រោះរបស់ពួកគេចំពោះស្ថានភាពអាកាសធាតុ ដែលមានលក្ខណៈអវិជ្ជមាន។ ពិពិធកម្មនេះមានចំពោះពូជត្រីដែលនេសាទ ការងារលើនាវានេសាទជាលក្ខណៈឧស្សាហកម្ម ការស្វែងរកធនធានក្នុងទឹកសាប និងប្រភពចំណូលផ្សេងទៀតពីការងារកសិកម្ម និងការងារបណ្តោះអាសន្នដទៃទៀត។

*ប្រភព ៖* Kalikoski, Quevedo Neto and Almudi (2010)

ហានិភ័យមួយទៀត ចំពោះសហគមន៍នេសាទ ដែលពាក់ព័ន្ធជាមួយនឹងការប្រែប្រួលអាកាសធាតុ គឺការថមថយនូវតំបន់ឆ្នេរ ដោយសារតែការកើនឡើងនូវកម្ពស់ទឹកសមុទ្ទ ដែលមានផលប៉ះពាល់ដល់ការតាំងទីលំនៅរបស់ពួកគេ។ លើសពីនេះ អ្នកនេសាទតូចតាច ត្រូវប្រឈមមុខជាមួយនឹងគ្រោះភ័យនៃគ្រោះមហន្តរាយធម្មជាតិ ពាក់ព័ន្ធជាមួយនឹងការកើនឡើងនូវកម្រិតធ្ងន់ធ្ងរ និងភាពញឹកញាប់នៃខ្យល់ព្យុះ ដោយហេតុថាទីតាំងរបស់ពួកគេស្ថិតនៅតាមមាត់ឆ្នេរ ឬនៅតំបន់ដីគោកដែលគេមិនអាចព្យាករដឹងជាមុនពីកម្ពស់ទឹកបាន។ ព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរ ក៏អាចបង្កើនហានិភ័យពាក់ព័ន្ធនឹងការធ្វើការងារក្នុងសមុទ្ទផងដែរ ដែលនាំឱ្យរំខានដល់ការនេសាទ ដែលពឹងផ្អែកទៅលើចំណេះដឹងតាមបែបប្រពៃណីអំពីប្រព័ន្ធអាកាសធាតុ និងរលកសមុទ្ទ នៅក្នុងមូលដ្ឋាន។

ផលប៉ះពាល់នៃគ្រោះមហន្តរាយធម្មជាតិលើវិស័យដទៃទៀត (ដូចជា កសិកម្ម ទេសចរណ៍ និងផលិតកម្ម) ដែលបង្កឡើងដោយព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរ អាចនាំឱ្យមានសម្ពាធកាន់តែខ្លាំងជាងមុនមកលើដីតាមតំបន់ឆ្នេរ និងនាំឱ្យមានអ្នកចាប់យករបរនេសាទកាន់តែច្រើនជាងមុន។ នេះអាចនាំឱ្យមានការបង្កើនសម្ពាធមកលើដីនៅតាមតំបន់ឆ្នេរផង និងលើធនធាននេសាទផង (Cochrane *et al.,* 2008)។ ឧទាហរណ៍ ក្រោយព្យុះ Hurricane Luis នៅក្នុងឆ្នាំ ១៩៩៥ ប្រជាពលរដ្ឋ

នៅតំបន់ Antigua និង Barbuda ដែលបាត់បង់ការងារធ្វើ ដោយសារការបិទទ្វារសណ្ឋាគារ និងអាជីវកម្មផ្សេងទៀត បានស្វែងរកការងាររយៈពេលខ្លីធ្វើ នៅក្នុងវិស័យនេសាទ (Mahon, 2002)។

ការយល់ដឹងពីជីវភាពរស់នៅរបស់សហគមន៍នេសាទ និងរាល់ទិដ្ឋភាពផ្សេងៗគ្នានៃការធ្វើនេសាទ និងសកម្មភាពពាក់ព័ន្ធ គឺជាមូលដ្ឋានដ៏សំខាន់ សម្រាប់រៀបចំប្រព័ន្ធសិទ្ធិកាន់កាប់ ដែលឆ្លើយតបទៅនឹងតម្រូវការរបស់សហគមន៍នេសាទ និងក្រុមដែលងាយរងគ្រោះ។ ការយល់ដឹងបែបនេះក៏មានសារៈសំខាន់ផងដែរ ដើម្បីស្វែងយល់ពីទំនាក់ទំនងរវាងវិស័យនេសាទ និងវិស័យដទៃទៀត និងពីផលប៉ះពាល់អន្តរវិស័យ ដែលគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ ទំនងជានឹងបង្កឱ្យមាន។ នេះក៏មានន័យផងដែរថា នៅពេលគេពិចារណាអំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងគ្រោះភ័យនៃគ្រោះមហន្តរាយ នៅក្នុងការរៀបចំផែនការនៅថ្នាក់ជាតិ គេក៏ចាំបាច់ត្រូវពិចារណាលើតថភាពរបស់សហគមន៍នេសាទផងដែរ។ នៅក្នុងបរិបទនៃគ្រោះមហន្តរាយ គេចាំបាច់ត្រូវយល់ និងធ្វើការពិចារណាលើការបន្តពីការសង្គ្រោះបន្ទាន់ រហូតដល់ការអភិវឌ្ឍ ពោលគឺទំនាក់ទំនងរវាងការឆ្លើយតបបន្ទាន់ ការត្រៀមទប់ទល់ជាមួយនឹងគ្រោះមហន្តរាយ និងការប្រកបរបរចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព។ គេចាំបាច់ត្រូវធ្វើការពិចារណាលើគោលបំណងនៃការអភិវឌ្ឍរយៈពេលវែង នៅក្នុងលំដាប់លំដោយនៃការសង្គ្រោះបន្ទាន់ រាប់បញ្ចូលទាំងដំណាក់កាលសង្គ្រោះភ្លាមៗផង ហើយការស្តារនីតិសម្បទា ការស្ថាបនាឡើងវិញ និងការស្តារឡើងវិញ គួរដាក់បញ្ចូលសកម្មភាពនានា ដើម្បីកាត់បន្ថយភាពងាយរងគ្រោះ ចំពោះការគំរាមកំហែង ដែលអាចកើតមានឡើងនាពេលអនាគត។ ការធានាឱ្យមានសិទ្ធិកាន់កាប់ធនធានសំខាន់ៗជាប់លាប់គ្រប់គ្រាន់ គឺជាជំហានដ៏សំខាន់ ដើម្បីឈានទៅសម្រេចនូវភាពធន់។

## ការពិនិត្យតាមដាន និងវាយតម្លៃ និងភាពអនុលោម

**ការអនុវត្ត VGGT គឺជាការទទួលខុសត្រូវរបស់រដ្ឋ ដូច្នេះ ៖**

*រដ្ឋត្រូវបានលើកទឹកចិត្តឱ្យបង្កើតវេទិកា និងក្របខ័ណ្ឌ ដែលមានការចូលរួមពីអ្នកពាក់ព័ន្ធចម្រុះ នៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងថ្នាក់តំបន់ ឬប្រើប្រាស់វេទិកា និងក្របខ័ណ្ឌ ដែលមានស្រាប់ ដើម្បីធ្វើការសហការគ្នាអនុវត្ត VGGT ទាំងនេះ។ ដើម្បីពិនិត្យតាមដាន និងវាយតម្លៃលើការអនុវត្ត នៅក្នុងយុត្តាធិការរបស់ខ្លួន និងធ្វើការវាយតម្លៃលើផលប៉ះពាល់មកលើការលើកកម្ពស់អភិបាលកិច្ចលើសិទ្ធិកាន់កាប់ដីធ្លី ធនធាននេសាទ និងធនធានព្រៃឈើ និងលើសន្តិសុខស្បៀង និងការសម្រេច*

*ជាបន្តបន្ទាប់នូវសិទ្ធិទទួលបានអាហារហូបចុកគ្រប់គ្រាន់ ក្នុងបរិបទសន្តិសុខស្បៀងនៅថ្នាក់ជាតិ និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព។ ដំណើរការនេះគួរមានលក្ខណៈចូលរួម ឆ្លើយតបចំពោះយេនឌ័រ អាចអនុវត្តទៅបាន មានប្រសិទ្ធភាពចំណាយ និង មាននិរន្តរភាព។ នៅក្នុងការបំពេញភារកិច្ចទាំងនេះ រដ្ឋអាចស្វែងរកការគាំទ្របច្ចេកទេសពីស្ថាប័ននៅថ្នាក់តំបន់ និងថ្នាក់អន្តរជាតិបាន។*

**(២៦.២ នៅក្នុងការលើកកម្ពស់ ការអនុវត្ត ការពិនិត្យតាមដាន និងការវាយតម្លៃ )**

ចាំបាច់ត្រូវមានប្រព័ន្ធ និងនីតិវិធី សម្រាប់ពិនិត្យតាមដាន និងវាយតម្លៃ ដើម្បីធានាឱ្យមានការសម្រេចគោលបំណងរបស់ការរៀបចំសិទ្ធិកាន់កាប់ (សូមមើលផ្នែកកំណត់គោលបំណង ខាងលើ)។ ប្រព័ន្ធ និងនីតិវិធីទាំងនេះ គួរដាក់បញ្ចូលនូវសូចនាករ ដែលមានលក្ខណៈជាក់លាក់តាមបរិបទ ទៅតាមគោលបំណងដែលបានដាក់ចេញ ក្នុងគោលបំណងធ្វើការវាយតម្លៃ ជាប្រចាំលើភាពស័ក្តិសិទ្ធិរបស់ប្រព័ន្ធសិទ្ធិកាន់កាប់ ពោលគឺថាតើប្រព័ន្ធនេះសម្រេចនូវគោលបំណង ដែលខ្លួនចង់សម្រេចកម្រិតណា (ពាក់ព័ន្ធជាមួយនឹងអត្ថប្រយោជន៍ប្រកបដោយសមធម៌ និរន្តរភាពធនធាន ការប្រកបមុខរបរចិញ្ចឹមជីវិតបានជាប់លាប់ ។ល)។ ប្រព័ន្ធពិនិត្យតាមដាន ដែលរឹងមាំ និងមានការរៀបចំបានល្អ មានដាក់បញ្ចូលនូវសូចនាករលទ្ធផលការងារ និងព័ត៌មានគោល។ ដោយបំពេញបន្ថែមលើគោលបំណងផ្នែកប្រតិបត្តិការជាក់លាក់របស់ប្រព័ន្ធ និងដោយពិចារណា លើទំនាក់ទំនងរួមរបស់ VGGT ជាមួយនឹងសន្តិសុខស្បៀង គួរមានការខិតខំប្រឹងប្រែងពិសេសៗ ដើម្បីពិនិត្យតាមដានថាតើអភិបាលកិច្ចលើសិទ្ធិកាន់កាប់ ដែលមានភាពល្អប្រសើរជាងមុន កំពុងចូលរួមចំណែកអ្វីខ្លះចំពោះការលើកកម្ពស់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ ប្រព័ន្ធពិនិត្យតាមដានក៏គួរផ្តល់លទ្ធភាពឱ្យមានការវាយតម្លៃលើប្រសិទ្ធភាពនៃការគ្រប់គ្រងផងដែរ ដូចជា ប្រើប្រាស់សូចនាករដំណើរការ ដើម្បីធ្វើការវាយតម្លៃរចនាសម្ព័ន្ធ និងនីតិវិធី ជាដើម។

ប្រព័ន្ធពិនិត្យតាមដាន មានការប្រែប្រួលខុសគ្នា ដូចជា អ្នកដែលត្រូវធ្វើការវាស់វែង វាស់វែងញឹកញាប់ប៉ុណ្ណា និងដោយរបៀបណា។ ការពិនិត្យតាមដាន និងវាយតម្លៃ ដោយមានការចូលរួម ត្រូវមានការចូលរួមពីអ្នកមានសិទ្ធិ និងអ្នកពាក់ព័ន្ធនានា។ បន្ថែមពីលើការបង្កើតនូវព័ត៌មានពិនិត្យតាមដាន ការពិនិត្យតាមដាន ននិងវាយតម្លៃ ក៏ជាអភិក្រមមួយ ដែល គាំទ្រដល់ការបង្កើនការយល់ដឹង និងការផ្តល់ភាពអង់អាចដល់សហគមន៍។ បន្ថែមពីលើដំណើរការពិនិត្យតាមដាន ដែលមានលក្ខណៈផ្លូវការជាង គេគួរខិតខំប្រឹងប្រែងចងក្រងទុកជាឯកសារនូវការអនុវត្តល្អៗ ពាក់ព័ន្ធជាមួយនឹងការរៀបចំសិទ្ធិកាន់

កាប់ សម្រាប់សហគមន៍នេសាទខ្នាតតុច។ ការអនុវត្តល្អៗទាំងនេះគួរយកទៅចែករំលែក នៅថ្នាក់ជាតិ ថ្នាក់តំបន់ និង អន្តរជាតិ ក្នុងគោលបំណងជម្រុញលើកកម្ពស់ចំណេះដឹងរួមអំពីដំណោះស្រាយប្រកបដោយប្រសិទ្ធភាព ដែលនាំឱ្យមានការលើកកម្ពស់ការអនុវត្ត VGGT។

ធនាគារពិភពលោក បានបង្កើតនូវឧបករណ៍មួយ ដែលមានឈ្មោះថា ក្របខ័ណ្ឌវាយតម្លៃលើអភិបាលកិច្ចដីធ្លី (LGAF) សម្រាប់ធ្វើការពិនិត្យតាមដានលើអភិបាលកិច្ចការកាន់កាប់ដីធ្លី (សូមមើល Deininger, Selod and Burns, 2012)។ គេអាចប្រើប្រាស់ LGAF នៅក្នុងប្រទេសមួយ ដើម្បីធ្វើការវាយតម្លៃលើក្របខ័ណ្ឌច្បាប់ គោលនយោបាយ និងការអនុវត្ត ពាក់ព័ន្ធជាមួយនឹងដីធ្លី និងការប្រើប្រាស់ដីធ្លី។ ក្របខ័ណ្ឌនេះប្រើប្រាស់សូចនាករចំនួន ២១ សម្រាប់ ៥ ផ្នែក ដូចជា ក្របខ័ណ្ឌច្បាប់ និងស្ថាប័ន, ការរៀបចំផែនការប្រើប្រាស់ដីធ្លី ការគ្រប់គ្រង និងការប្រមូលពន្ធ, ការគ្រប់គ្រងដីសាធារណៈ, ការផ្តល់ព័ត៌មានដីធ្លីជាសាធារណៈ និងការដោះស្រាយជម្លោះ និងការគ្រប់គ្រងវិវាទ។ ការបង្កើតក្របខ័ណ្ឌស្រដៀងគ្នានេះសម្រាប់វិស័យនេសាទ ដោយផ្តោតជាពិសេសលើការនេសាទខ្នាតតូច និងសិទ្ធិកាន់កាប់ ដែលចាំបាច់ សម្រាប់ធានាសន្តិសុខនៃការប្រកបរបរចិញ្ចឹមជីវិត។

ប្រធានបទ ពាក់ព័ន្ធជាមួយនឹងការពិនិត្យតាមដាន និងវាយតម្លៃ និងដែលមានសារៈសំខាន់ នៅក្នុងបរិបទនៃការ គ្រប់គ្រងធនធាននេសាទ ក៏ដូចជាមានសារៈសំខាន់ចំពោះសិទ្ធិកាន់កាប់ក្នុងវិស័យនេសាទ គឺការពិនិត្យតាមដាន ការត្រួតពិនិត្យ និងការអង្កេតឃ្លាំមើល។ ការពិនិត្យតាមដាន ការត្រួតពិនិត្យ និងការអង្កេតឃ្លាំមើល ឬហៅកាត់ថា MCS គឺជាសមាសភាគមួយនៃដំណើរការគ្រប់គ្រងធនធាននេសាទ ដែលមានគោលបំណងធានាឱ្យមានភាពអនុលោម ជាមួយនឹងលិខិតបទដ្ឋានគតិយុត្តិដែលមានស្រាប់។ MCS ដែលមានប្រសិទ្ធភាព ត្រូវប្រើប្រាស់អភិក្រមភ្ជោះស្របគ្នា ដែលបឹងផ្អែកលើការបង្ការផង និងការទប់ស្កាត់ផង។ អភិក្រមបង្ការលើកទឹកចិត្តឱ្យមាន “ភាពអនុលោមដោយស្ម័គ្រចិត្ត” តាមរយៈការយល់ដឹង និងការគាំទ្រដល់យុទ្ធសាស្ត្រគ្រប់គ្រងនានា។ អភិក្រមស្របគ្នាមួយទៀត សម្រាប់ធ្វើការទប់ស្កាត់/ពង្រឹងការអនុវត្ត MCS គឺ មានភាពចាំបាច់ ដើម្បីធានាឱ្យមានភាពអនេុលាមដោយអ្នកនេសាទ ដែលមិនចង់អនុវត្តទៅតាមរបបនិយតកម្មនេះ។ ការទប់ស្កាត់ និងការពង្រឹងការអនុវត្ត រួមមាន អធិការកិច្ច ការស៊ើបអង្កេត ការបង្ការ និងការបញ្ជូនសំណុំរឿងទៅតុលាការ ដើម្បីពង្រឹងការអនុវត្តច្បាប់។ ភាពអនុលោម ដោយស្ម័គ្រចិត្ត នឹងទទួលរងផលប៉ះពាល់ ប្រសិនបើអ្នកពាក់ព័ន្ធនានាឃើញថាអ្នកនេសាទដែលមិនគោរពច្បាប់ អាចដណ្តើមដីធ្លីរបស់គេដោយជោគជ័យ ហើយទទួលបានប្រយោជន៍ផ្នែកសេដ្ឋកិច្ចមកវិញ ពី

សកម្មភាពខុសច្បាប់របស់ពួកគេ ដោយអ្នកនេសាទដែលអនុវត្តតាមគ្រប់លក្ខខណ្ឌទាំងអស់ត្រូវទទួលការខាតបង់ (FAO, 2013d)។

MCS ដោយមានការចូលរួម ក៏ត្រូវបានអនុវត្ត ស្របជាមួយនឹងការចែករំលែកការទទួលខុសត្រូវ នៅក្នុងទិដ្ឋភាពផ្សេងទៀតនៃការគ្រប់គ្រងធនធាននេសាទផងដែរ (ដូចជា ការគ្រប់គ្រងរួមគ្នា ជាដើម)។ នេះមានន័យថា អ្នកនេសាទ និងសហគមន៍របស់ពួកគេ ចូលរួមនៅក្នុងដំណើរការពិនិត្យតាមដានភាពអនុលោមតាមច្បាប់ ដោយសហការជាមួយនឹងអាជ្ញាធរនានារបស់រដ្ឋាភិបាល។ នេះអាចជាសមាសភាគដ៏មានអានុភាពមួយនៃការរៀបចំការគ្រប់គ្រងរួមគ្នា។ ប៉ុន្តែ រដ្ឋាភិបាលត្រូវតែបន្តទទួលខុសត្រូវ ដើម្បីធានាយ៉ាងណាឱ្យមានការគោរពសិទ្ធិស្របច្បាប់។

| **ការណែនាំទី ១១ ៖ ការពិនិត្យតាមដាន និងវាយតម្លៃ ដោយមានការចូលរួម** |
|---|
| ការពិនិត្យតាមដាន និងវាយតម្លៃ ដោយមានការចូលរួម គឺជាផ្នែកដ៏សំខាន់មួយរបស់ប្រព័ន្ធគ្រប់គ្រង។ វាគឺជាដំណើរការមួយ ដែលមានអន្តរកម្មរស់រវើករវាងអ្នកពាក់ព័ន្ធសំខាន់ៗ ហើយវាអាចជាឧបករណ៍ដ៏មានអានុភាពមួយ ដើម្បីសម្រេចនូវលទ្ធផលច្រើនយ៉ាង បន្ថែមពីលើការផលិតព័ត៌មាន សម្រាប់អ្នកធ្វើសេចក្ដីសម្រេចចិត្ត ឧ. សម្រាប់រៀនសូត្រពីអ្វីដែលដំណើរការទៅបាន ការផ្ដល់ភាពអង់អាចដល់អ្នកពាក់ព័ន្ធ ការលើកកម្ពស់ការយល់ដឹងអំពីទំនាក់ទំនងរវាងគោលបំណង ការអនុវត្ត និងលទ្ធផលនៅនឹងមូលដ្ឋានជាក់ស្ដែង និងការបង្ហាញពីផលប៉ះពាល់នានា។ |
| អភិក្រម/ឧបករណ៍ ដែលត្រូវប្រើប្រាស់ ៖<br>– ការពិនិត្យតាមដាន និងការវាយតម្លៃដោយមានការចូលរួម (សូមមើលឧបសម្ព័ន្ធទី ២) |

## ឯកសារយោង


**Asian Coalition for Housing Rights (ACHR).** 2006. Land issue in Thailand. In: *ACHR* [online]. [Cited 11 September 2013]. (www.achr.net/000ACHRTsunami/Thailand%20TS/Land-1.html)

**Allison, E.H, Beveridge, M.C.M. & van Brakel, M.** 2009. Climate change, small-scale fisheries and smallholder aquaculture. *In* M. Cullberg, ed. *Fisheries, sustainability and development*, pp. 109–122. Stockholm, Royal Swedish Academy of Agriculture and Forestry.

**Allison, E.H., Ratner, B.D., Åsgård, B., Willmann, R., Pomeroy, R. & Kurien, J.** 2012. Rights-based fisheries governance: from fishing rights to human rights. *Fish and Fisheries*, 13(1): 14–29.

**Arenas, M.C. & Lentisco, A.** 2011. *Gender mainstreaming strategy for the Regional Fisheries Livelihoods Programme (RFLP) for South and Southeast Asia*. RAP publication 2011/15. Bangkok, FAO. 92 pp.

**Aswani, S.** 2005. Customary sea tenure in Oceania as a case of rights-based fishery management: does it work? *Reviews in Fish Biology and Fisheries*, 15(3): 285–307.

**Bavinck, M.** 2005. Understanding fisheries conflicts in the South – a legal pluralist perspective. *Society and Natural Resources*, 18(9): 805–820.

**Béné, C.** 2011. CAADP *and fisheries policy in Africa: are we aiming for the right reform?* Policy Brief No 040. April 2011. Future Agricultures Consortium. 8 pp. (also available at www.future-agricultures.org).

**Béné, C., Macfadyen, G. & Allison, E.H.** 2007. *Increasing the contribution of small-scale fisheries to poverty alleviation and food security*. FAO Fisheries Technical Paper No. 481. Rome, FAO. 125 pp.**Cambers, G.,**

**Muehlig-Hofmann, A. & Troost, D.** 2003. Coastal and land tenure: a small-islands' perspective. In: *UNESCO. Environment and development in coastal regions and in small islands* [online]. [Cited 11 September 2013]. www.unesco.org/csi/wise/tenure.htm

**Charles, A.** 2009. Rights-based fisheries management: the role of use rights in managing access and harvesting. *In* K.L. Cochrane & S. Garcia, eds. *A fishery manager's guidebook*, pp. 253–282. Rome, FAO, and UK, Wiley-Blackwell.

**Charles, A.** 2011. Governance of tenure in small-scale fisheries: key considerations. Case study prepared for the FAO Workshop on Governance of Tenure for Responsible Capture Fisheries, Rome, 4–6 July 2011. (unpublished working paper).

**Cochrane, K.L., ed.** 2002. *A fishery manager's guidebook. Management measures and their application*. FAO Fisheries Technical Paper No. 424. Rome, FAO. 231 pp.

**Cochrane, K.L. & Garcia, S., eds.** 2009. *A fishery manager's guidebook*. Rome, FAO, and UK, Wiley-Blackwell. 544 pp.

**Cochrane, K., De Young, C., Soto, D. & Bahri, T., eds.** 2009. *Climate change implications for fisheries and aquaculture: overview of current scientific knowledge*. FAO Fisheries and Aquaculture Technical Paper No. 530. Rome, FAO. 212 pp.

**Copes, P. & Charles, A.** 2004. Socioeconomics of individual transferable quotas and community-based fishery management. *Agricultural and Resource Economics Review*, 33: 171–181.

**Cordell, J., ed.** 1989. *A sea of small boats*. Cambridge, USA, Cultural Survival Inc.

**Deininger, K., Selod, H., & Burns, A.** 2012. *The Land Governance Assessment Framework. Identifying and monitoring good practice in the land sector*. Washington, DC, World Bank. 147 pp.

**Department of Agriculture, Fisheries and Forestry (DAFF).** 2012. Policy for the Small-scale Fisheries Sector in South Africa. *In*: *Government Gazette*. Pretoria, South Africa.

**De Young, C., Charles, A. & Hjort, A.** 2008. *Human dimensions of the ecosystem approach to fisheries: an overview of context, concepts, tools, and methods*. FAO Fisheries Technical Paper No. 489. Rome, FAO. 152 pp.

**Fernando, N., Punchihewa, A**. 2011 *Migration and Global Environmental Change, CS2: Lessons learnt from the 2004 Asian tsunami*. UK Government's Foresight Project.

**FAO.** 1995. *Code of Conduct for Responsible Fisheries*. Rome. 41 pp.

**FAO.** 1997. *Fisheries management*. FAO Technical Guidelines for Responsible Fisheries No. 4. Rome. 82 pp.

**FAO.** 2003. *The ecosystem approach to fisheries*. FAO Technical Guidelines for Responsible Fisheries No 4, Suppl. 2. Rome. 112 pp.

**FAO.** 2005. *Increasing the contribution of small-scale fisheries to poverty alleviation and food security*. Technical Guidelines for Responsible Fisheries No. 10. Rome. 97 pp.

**FAO.** 2005–2013a. Regulating fishing capacity. In: *FAO Fisheries and Aquaculture Department* [online]. [Cited 11 September 2013]. www.fao.org/fishery/topic/14857/en

**FAO.** 2005–2013b. Property rights and fisheries management. In: *FAO Fisheries and Aquaculture Department* [online]. [Cited 11 September 2013]. www.fao.org/fishery/topic/13335/en

**FAO.** 2005–2013c. Variability and climate change. In: *FAO Fisheries and Aquaculture Department* [online]. [Cited 11 September 2013]. www.fao.org/fishery/topic/13789/en

**FAO.** 2005–2013d. Monitoring, control and surveillance. In: *FAO Fisheries and Aquaculture Department* [online]. [Cited 11 September 2013]. www.fao.org/fishery/topic/3021/en.

**FAO.** 2009a. *Report of the Global Conference on Small-Scale Fisheries – Securing sustainable small-scale Fisheries: Bringing together responsible fisheries and social development. Bangkok, Thailand, 13–17 October 2008. Rapport de la Conférence mondiale sur les pêches artisanales – Pour une pêche artisanale durable: Associer la pêche responsable au développement social. Bangkok, Thaïlande, 13-17 octobre 2008. Informe de la Conferencia Mundial sobre la Pesca en Pequeña Escala – Garantizar la pesca en pequeña escala: Pesca responsable y desarrollo social unidos. Bangkok, Tailandia, 13-17 de octubre de 2008*. FAO Fisheries and Aquaculture Report / FAO Rapport sur les pêches et l'aquaculture / FAO Informe de Pesca y Acuicultura No. 911. Rome/Roma. 189 pp.

**FAO.** 2009b. *Fisheries management. 2. The ecosystem approach to fisheries. 2.2 The human dimensions of the ecosystem approach to fisheries*. FAO Technical Guidelines for Responsible Fisheries No. 4, Suppl. 2, Add. 2. Rome. 88 pp.

**FAO.** 2010. *Report of the Inception Workshop of the FAO Extrabudgetary Programme on Fisheries and Aquaculture for Poverty Alleviation and Food Security. Rome, 27–30 October 2009*. FAO Fisheries and Aquaculture Report No. 930. Rome. 68 pp.

**FAO.** 2011a. *Report of the FAO Workshop on Governance of Tenure for Responsible Capture Fisheries. Rome, 4–6 July 2011*. FAO Fisheries and Aquaculture Report No. 983. Rome. 34 pp.

**FAO.** 2011b. *Fisheries management. 4. Marine protected areas and fisheries*. FAO Technical Guidelines for Responsible Fisheries No. 4, Suppl. 4. Rome. 198 pp.

**FAO.** 2012a. Governance of tenure. In: *FAO Natural Resources Management and Environment Department* [online]. [Cited 11 September 2013]. www.fao.org/nr/tenure/governance-of-tenure/en/

**FAO.** 2012b. Zero Draft – International Guidelines for Securing Sustainable Small-scale Fisheries. Rome. 38 pp. (also available at www.fao.org/fishery/ssf/guidelines/en).

**FAO.** 2012c. *Report of the Workshop on International Guidelines for Securing Sustainable Small-Scale Fisheries, Rome, Italy, 7–10 February 2012*. FAO Fisheries and Aquaculture Report No. 1004. Rome. 44 pp**.**

**FAO.** 2013a. *Governing land for women and men – a technical guide to support the achievement of responsible gender-equitable governance of land tenure*. Governance of Tenure Technical Guide No 1. Rome. 120 pp.

**FAO.**2013b. Capacity Development Portal. In: *FAO Capacity Development Portal* [online]. [Cited 11 September 2013]. www.fao.org/capacitydevelopment/capacity-development-home/en/

**Finlay, J. & McConney, P.** 2011. Tenure in the Grenada beach seine fishery. Case study prepared for the FAO Workshop on Governance of Tenure for Responsible Capture Fisheries. Rome, 4–6 July 2011. (unpublished working paper).

**Govan, H.** 2009. *Study report on status and potential of locally-managed marine areas in the south Pacific: meeting nature conservation and sustainable livelihood targets through wide-spread implementation of LMMAs*. Component 3A- Project 3A3. Institutional strengthening and technical support. SPREP/WWF/WorldFish-Reefbase/CRISP. 95 pp.

**Hardin, G.** 1968. The tragedy of the commons. *Science*, 162(3589): 1243–1248.

**Herrera, A. & da Passano, M.G.** 2006. Land tenure alternative conflict management. Land Tenure Service Rural Development Division in collaboration with Livelihoods Support Project International Land Coalition. FAO. Rome. 140p.

**Holvoet, K.** 2008. Mainstreaming gender in fisheries. *In* L. Westlund, K. Holvoet & M. Kébé, eds. *Achieving poverty reduction through responsible fisheries: strategies and lessons from the West and Central Africa Sustainable Fisheries Livelihoods Programme*, pp. 139–152. FAO Fisheries and Aquaculture Technical Paper No. 513. Rome, FAO. 168 pp.

**Jentoft, S.** 2011. Governing tenure in Norwegian and Sami small-scale fisheries : from common pool to common property? Case study prepared for the FAO Workshop on Governance of Tenure for Responsible Capture Fisheries. Rome, 4–6 July 2011. (unpublished working paper).

**Jentoft, S. & Eide, A.** 2011. *Poverty mosaics. Realities and prospects in small-scale fisheries*. Springer.

**Jentoft, S., Bavinck, M., Johnson, D.S. & Thomson, K.T.** 2009. Fisheries co-management and legal pluralism: how an analytical problem becomes an institutional one. *Human Organization*, 68(1): 27–38.

**Juda, L.** 1999. Considerations in the development of a functional approach to governance of large marine ecosystems. *Ocean Development and International Law*, 30: 89–125.

**Kalikoski, Daniela C., Quevedo Neto & Pedro**. 2010. Building adaptive capacity to climate variability: the case of artisanal fisheries in the estuary of the Patos Lagoon, Brazil. *Marine Policy*, Volume 34 (4): 742-751

**Kooiman, J., Bavinck, M., Jentoft, S. & Pullin, R., eds.** 2005. *Fish for life. Interactive governance for fisheries*. Amsterdam, Amsterdam University Press.

**Konan, A.** 2007. *Projet pilote «Amélioration de l'environnement politique et institutionnel pour le développement de systèmes de cogestion en pêche continentale au Burkina Faso, au Mali, en Côte d'Ivoire et au Ghana »*. Rapport terminal. Sustainable Fisheries Livelihoods Programme (SFLP) report. 55 pp.

**Kurien, J.** 1998. *Property rights, resource management and governance: crafting an institutional framework of global marine fisheries*. Thiruvananthapuram, India, Centre for Development Studies.

**Kurien, J. & Willmann, R.** 2009. Special considerations for small-scale fisheries management in developing countries. *In* K.L. Cochrane & S. Garcia, eds. *A fishery manager's guidebook*, pp. 404–424. Rome, FAO, and UK, Wiley-Blackwell.

**Mahon, R.** 2002. *Adaptation of fisheries and fishing communities to the impacts of climate change in the CARICOM region*. Issues paper prepared for the CARICOM Fisheries Unit, Belize City, Belize, as input to the planning process for the project Mainstreaming Adaptation to Climate Change (MACC) of the Caribbean Centre for Climate Change (CCCC). 35 pp.

**Masifundise.** 2012. Preparation for the phasing in of Small Scale Fisheries (SSF) policy. In: *Masifundise* [online]. [Cited 11 September 2013]. www.masifundise.org.za/preparation-for-the-phasing-in-of-small-scale-fisheriesssf-policy/

**Monsalve Suárez, S., Marques Osorio, L. & Langford, M.** 2009. *Voluntary guidelines for good governance in land and natural resource tenure: civil society perspectives*. Land Tenure Working Paper 8. FIAN International and Hakijamii (Economic and Social Rights Centre). Rome, FAO. 85 pp. (also available at ftp://ftp.fao.org/docrep/fao/011/ak280e/ak280e00.pdf).

**MRAG, IFM, CEFAS, AZTI Tecnalia & PolEM.** 2009. *An analysis of existing Rights Based Management (RBM) instruments in Member States and on setting up best practices in the EU*. Final Report. London, MRAG Ltd. 117 pp.

**Munro, G.R.** 2010. *From drain to gain in capture fisheries rents: a synthesis study*. FAO Fisheries and Aquaculture Technical Paper No. 538. Rome, FAO. 49 pp.

**Njock, J.-C. & Westlund, L.** 2008. Understanding the mobility of fishing people and the challenge of migration to devolved fisheries management. *In* L. Westlund, K. Holvoet & M. Kébé, eds. *Achieving poverty reduction through responsible fisheries: strategies and lessons from the West and Central Africa Sustainable Fisheries Livelihoods Programme*, pp. 85–98. FAO Fisheries Technical Paper No 513. Rome, FAO.

**Njock, J.-C. & Westlund, L.** 2010. Migration, resource management and global change: experiences from fishing communities in West and Central Africa. *Marine Policy*, 34(4): 752–760.

**Njock, J.-C, Allison, E.H. & Konan, A.** 2008. Institutional innovations in fisheries co-management in West and Central Africa. *In* L. Westlund, K. Holvoet & M. Kébé, eds. *Achieving poverty reduction through responsible fisheries: strategies and lessons from the West and Central Africa Sustainable Fisheries Livelihoods Programme*, pp. 67–84. FAO Fisheries Technical Paper No. 513. Rome, FAO.

**Orensanz, J.M., Cinti, A., Parma, A.M., Burotto, L., Espinosa-Guerrero, S., Sosa-Cordero, E., Sepúlveda, C. &Toral-Granda, V.** 2011. Governance of tenure in Latin-American small-scale fisheries targeting seabed resources. Case study prepared for the FAO Workshop on Governance of Tenure for Responsible Capture Fisheries, Rome, 4–6 July 2011. (unpublished working paper).

**Ostrom, E., Burger, J., Field, C.B., Norgaard, R.B. & Policansky, D.** 1999. Revisiting the commons: local lessons, global challenges. *Science*, 284: 278–282.

**Perry, R.I. & Ommer, R.E.** 2010. Introduction: Coping with global change in marine social-ecological systems. *Marine Policy*, 34(4): 739–741.

**Pomeroy, R.S.** 2001. Devolution and fisheries co-management. *In* R. Meinzen-Dick, A. Knox & M. Di Gregorio, eds. *Collective action, property rights and devolution of natural resource management: exchange of knowledge and implications for policy*, pp. 108–145. Feldafing, Germany, DSE/GTZ.

**Pomeroy, R.S. & Rivera-Guieb, R.** 2006. *Fisheries co-management: a practical handbook*. Rome, CAB International, and Ottawa, International Development Research Centre.

**Prasertcharoensuk, R. & Shott, J.** 2010. *Marine protected areas in Thailand: time for a sea change: a study of the effectiveness of biodiversity conservation measures and marine protected areas along southern Thailand's Andaman Sea coastline*. Monograph ICSF. Chennai, India, SAMUDRA. 81 pp. (also available at icsf.net/icsf2006/uploads/publications/monograph/pdf/english/issue_110/ALL.pdf).

**Ruddle, K.** 1988. Social principles underlying traditional inshore fishery management systems in the Pacific Basin. *Marine Resource Economics*, 5: 351–363.**SAMUDRA.** 2008. *Statement from the Civil Society Preparatory Workshop to the Global Conference on Small-Scale Fisheries (4SSF), Bangkok, Thailand*. SAMUDRA Report No. 51. pp. 7–9.

**Scott, A.** 2000. Introducing property in fishery management. *In* R. Shotton, ed. *Use of property rights in fisheries management. Proceedings of the FishRights99 Conference,Fremantle, Western Australia, 11-19 November 1999. Mini-course lectures and core conference presentations*, pp. 1–13. FAO Fisheries Technical Paper No. 404/1. Rome, FAO.

**Sharma, C. & Rajagopalan, R.** MPAs: securing tenure rights in fishing communities? Case study prepared for the FAO Workshop on Governance of Tenure for Responsible Capture Fisheries, Rome, 4–6 July 2011. (unpublished working paper).

**Shotton, R., ed.** 2000. *Use of property rights in fisheries management. Proceedings of the FishRights99 Conference. Fremantle, Western Australia, 11-19 November 1999. Mini-course lectures and core conference presentations*. FAO Fisheries Technical Paper No. 404/1. Rome, FAO. 342 pp.

**Sunde, J., Sowman, M., Smith, H. & Wicomb. W.** (forthcoming). Emerging proposals for governance of tenure in small-scale fisheries in South Africa. *FAO Land Tenure Journal.*

**UNEP, FAO, IMO, UNDP, IUCN, WorldFish Center, GRID-Arendal.** 2012. *Green economy in a blue world*. Nairobi, UNEP. 132 pp.

**Western Pacific Regional Fishery Management Council.** 2010. *The impact of marine preserve areas on the safety of fishermen on Guam*. Honalulu, USA. 19 p.

**Vieira, S., Schirmer, J. & Loxton, E.** 2009. Social and economic evaluation methods for fisheries a review of the literature. Fisheries Research Contract Report No. 21. Department of Fisheries, Western Australia. 94p.

**World Bank.** 2009. *The sunken billions – the economics justification for fisheries reform*. Washington, DC, International Bank for Reconstruction and Development / World Bank. 100 pp.

**World Bank, FAO & WorldFish Center.** 2012. *Hidden harvests – the global contribution of capture fisheries*. Economic and sector work. Report No 66469-GLB. Washington, DC, International Bank for Reconstruction and Development / World Bank. 69 pp.

**World Humanity Action Trust (WHAT).** 2000. *Governance for a sustainable future. ii: fishing for the future*. Report of the Commission on Fisheries Resources. London. 68 pp.

## ឧបសម្ព័ន្ធទី ១ ៖ សន្ទានុក្រម

**ធនធានរួម (Common pool resources)**

ប្រព័ន្ធធនធានធម្មជាតិ ឬបង្កើតឡើងដោយមនុស្ស ដែលក្នុងនោះ (i) ការផាត់អ្នកទទួលផលចេញ តាមរយៈមធ្យោបាយរូបវ័ន្ត ឬមធ្យោបាយស្ថាប័ន នាំឱ្យមានការខាតបង់ច្រើន ប្រសិនបើមិនមែនមិនអាចធ្វើបាន បើទោះបីជាពួកគេមិនរួមចំណែកចំពោះការគ្រប់គ្រងធនធានទាំងនេះ (ឧ. អ្នកប្រើប្រាស់ដោយសេរី ដោយមិនជួយគិតគូរអ្វីទាំងអស់) និងអាចធ្វើឱ្យប៉ះពាល់ដល់សមត្ថភាពរបស់អ្នកដទៃក្នុងការប្រើប្រាស់ធនធានទាំនេះ និង (ii) ការទាញប្រយោជន៍របស់អ្នកប្រើប្រាស់មួយ នាំឱ្យមានការថយចុះនូវធនធាន ដែលមាន សម្រាប់អ្នកដទៃទៀត (ការដកធនធាន)។ ខណៈពេលដែលប្រព័ន្ធធនធានរួម (ដូចជា ដែននេសាទមួយ) អាចត្រូវបានគេគ្រប់គ្រងរួមគ្នា ធនធានដែលដកចេញពីប្រព័ន្ធនេះ (ដូចជា ផលចាប់) គឺមានលក្ខណៈជាឯកជន។

*ប្រភព ៖ សន្ទានុក្រមនេសាទរបស់* FAO ( [www.fao.org/fi/glossary/](www.fao.org/fi/glossary/) ) (រួមជាមួយនឹងការដកស្រង់ចេញពី Ostrom, E. 1990. Governing the commons. The evolution of institutions for collective action. Cambridge, UK, Cambridge University Press; and Ostrom, E., Burger, J., Field, C.B., Norgaard, R.B. & Policansky, D. 1999. Revisiting the commons: local lessons, global challenges. Science, 284: 278–282)

**ធនធាននេសាទ (Fishery resource)**

ជាទូទៅ សំដៅលើសមាសភាគនានារបស់ធនធានវារីជាតិ (ឧ. ប្រភេទ ពូជ ក្រុម ពពួក ប្រជុំសត្វ) ដែលគេអាចចាប់ ដោយស្របច្បាប់ តាមរយៈការនេសាទ។ ពេលខ្លះ រួមបញ្ចូលទាំងជម្រករបស់ធនធានទាំងនេះផងដែរ។

*ប្រភព ៖ កែសម្រួលពី* FAO. 1998. Guidelines for the routine collection of capture fishery data. FAO Fisheries Technical Paper No. 382. Rome. 113 pp.

**សិទ្ធិនេសាទ (Fishing rights)**

សិទ្ធិចាប់ត្រីក្នុងបរិមាណកំណត់ណាមួយ ឬភាគរយនៃផលចាប់ត្រីសរុបដែលអនុញ្ញាតឱ្យបាន ឬសិទ្ធិប្រើប្រាស់ទូក (ឬបរិក្ខារនេសាទដែលត្រូវបានកំណត់ផ្សេងទៀត) ទៅតាមបែបផែន ដែលមានបញ្ជាក់ក្នុងផែនការគ្រប់គ្រង ឬនៅក្នុងបទបញ្ញាអំពីការនេសាទ។

*ប្រភព ៖ សន្ទានុក្រមនេសាទរបស់* FAO ( [www.fao.org/fi/glossary/](www.fao.org/fi/glossary/) )

**<u>ការនេសាទដោយចំហ (Open access)</u>**

ស្ថានភាពនៃការនេសាទ ដែលអ្នកដែលចង់នេសាទ អាចធ្វើបាន។ ស្ថានភាពនេះមិនគួរភ័ន្តច្រឡំ ជាមួយនឹង "ធនធានរួម" ដែលជាសិទ្ធិរួមរបស់សហគមន៍ ក្នុងការទទួលបានធនធាន និងត្រួតពិនិត្យការប្រើប្រាស់ធនធានឡើយ។

*ប្រភព ៖ សន្ទានុក្រមនេសាទរបស់* FAO ( www.fao.org/fi/glossary/ )

**<u>សហគមន៍នេសាទតូចតាច (Small-scale fishing community)</u>**

សមាជិក របស់សហគមន៍នេសាទតូចតាច រួមមាន អ្នកដែលពឹងអាស្រ័យលើធនធានវារីជាតិ សម្រាប់ជីវភាពរស់នៅ និងសុខុមាលភាពទាំងអស់ ឬផ្នែកណាមួយនៃជីវភាពរស់នៅ និងសុខុមាលភាពរបស់ពួកគេ ៖ អ្នកនេសាទ ពោលគឺអ្នកដែលចូលរួមក្នុងសកម្មភាពក្រោយប្រមូលផលចាប់ និងសកម្មភាពកម្រិតខ្ពស់ជាងដទៃទៀត និងសមាជិកគ្រួសាររបស់ពួកគេ។ អ្នកនេសាទ និងកម្មករនេសាទតូចតាច អាចធ្វើការងារក្នុងវិស័យនេះពេញម៉ោង ឬក្រៅម៉ោង ឬធ្វើម្ដងម្កាលសម្រាប់បំពេញបន្ថែមលើយុទ្ធសាស្ត្រចិញ្ចឹមជីវិតផ្សេងទៀតរបស់ពួកគេ។ សកម្មភាពទាំងនេះ អាចធ្វើឡើង ដើម្បីគោលបំណងពាណិជ្ជកម្ម ឬ សម្រាប់តម្រូវការចិញ្ចឹមជីវិត ឬទាំងពីរ។

**<u>អ្នកនេសាទតូចតាច (Small-scale fisher)</u>**

ជន ដែលចូលរួមក្នុងផលិតកម្មបឋម នៅក្នុងវិស័យនេសាទខ្នាតតូច ដូចជា ប្រមូលត្រី ឬសត្វទឹកផ្សេងទៀត ឬរុក្ខជាតិដែលដុះក្នុងទឹក ជាដើម។

**<u>កម្មករនេសាទតូចតាច (Small-scale fishworker)</u>**

ជន ដែលមិនចូលរួមនៅក្នុងផលិតកម្មបឋមឡើយ ប៉ុន្តែចូលរួមនៅក្នុងផ្នែកផ្សេងទៀតនៃសង្វាក់ផ្គត់ផ្គង់របស់នេសាទខ្នាតតូច និងសកម្មភាពបន្ទាប់បន្សំនានា ទាំងនៅក្នុងអនុវិស័យខាងលើ (upstream) និងខាងក្រោម (downstream)។

**<u>រដ្ឋ (States)</u>**

រដ្ឋាភិបាល នៅគ្រប់កម្រិតទាំងអស់ (ថ្នាក់ជាតិ ថ្នាក់ខេត្ត ថ្នាក់មូលដ្ឋាន)

**<u>សិទ្ធិកាន់កាប់ (Tenure)</u>**

សិទ្ធិកាន់កាប់ គឺជាទំនាក់ទំនងរវាងមនុស្ស និងមនុស្ស ពាក់ព័ន្ធជាមួយនឹងដីធ្លី និងធនធានធម្មជាតិដទៃទៀត។ គោលការណ៍ស្តីពីសិទ្ធិកាន់កាប់ កំណត់ថាតើអ្នកណាអាចប្រើប្រាស់ធនធានអ្វីខ្លះលើដីធ្លី រយៈពេលយូរប៉ុណ្ណា និងក្រោមលក្ខខណ្ឌអ្វីខ្លះ។

*ប្រភព ៖* FAO. 2012. Voluntary Guidelines on the Responsible Governance of Tenure of Land, Fisheries and Forests in the context of National Food Security [online]. Committee on World Food Security. [Cited 11 September 2013]. www.fao.org/docrep/016/i2801e/i2801e.pdf

**សិទ្ធិប្រើប្រាស់ (Use right)**

សិទ្ធិរបស់អ្នកនេសាទម្នាក់ៗជាបុគ្គល ក្រុមអ្នកនេសាទ សហគមន៍ ឬក្រុមហ៊ុននេសាទ ដើម្បីអាចទទួលបាន និងប្រើប្រាស់ធនធាននេសាទ។

*ប្រភព ៖ ដកស្រង់ចេញពីសន្ទានុក្រម នៅក្នុង* Cochrane, K.L., ed. 2002. A fishery manager’s guidebook. Management measures and their application. FAO Fisheries Technical Paper No. 424. Rome, FAO. 231 pp.

**ក្រុម/ជនងាយរងគ្រោះ និងបាត់បង់ឱកាស**

ក្រុមអ្នកពាក់ព័ន្ធ ដែលខ្វះធនធាន ដើម្បីប្រកបរបរចិញ្ចឹមជីវិតឱ្យបានជាប់លាប់ ប្រកបដោយនិរន្តរភាព និង/ឬខ្វះឥទ្ធិពលលើដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្ត ដូចជា ស្ត្រី យុវជន ចាស់ជរា និងជនពិការ ជាដើម។

*ប្រភព ៖* FAO, UNDP and UNEP. 2011. UN-REDD Programme Social and Environmental Principles and Criteria, version 3 Draft for Consultation [online]. [Cited 11 September 2013]. www.unredd.net/index.php?option=com_docman&task=doc_download&gid=5993&Itemid=53

## ឧបសម្ព័ន្ធទី ២ ៖ អភិក្រម និងឧបករណ៍នានា

<u>ឧបករណ៍វិភាគយេនឌ័រក្នុងសហគមន៍</u>

***គោលបំណង***

អភិក្រម សម្រាប់វិភាគយេនឌ័រក្នុងសហគមន៍ ដែលត្រូវបានបង្កើតឡើងដោយកម្មវិធីនៃសាទចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព (SFLP) ដាក់បញ្ចូលក្របខ័ណ្ឌវិភាគយេនឌ័រ ជាមួយនឹងការវិភាគលើមុខរបរចិញ្ចឹមជីវិត ដែលបង្កលក្ខណៈឱ្យមានការយល់ដឹងអំពីចរន្តទំនាក់ទំនងយេនឌ័រ និងបរិបទស្ថាប័ន និងសម្រួលឱ្យមានការចរចា ដើម្បីការផ្លាស់ប្តូរ នៅក្នុងទំនាក់ទំនងសង្គម នយោបាយ និងសេដ្ឋកិច្ចរវាងបុរស និងស្ត្រី ក៏ដូចជារវាងយុវជន និងចាស់ព្រឹទ្ធាចារ្យ។

***ទិដ្ឋភាពទូទៅ***

***ដំណើរការវិភាគយេនឌ័រ មានការចូលរួមពីសហគមន៍ និងអង្គការនានាតាមសហគមន៍ និងមាន ៩ ជំហានធំៗ ៖***

១. ចរចា និងរៀបចំភាពជាដៃគូ ជាមួយនឹងសហគមន៍
២. ប្រមូលទិន្នន័យសម្រាប់ចងក្រងព័ត៌មានអំពីយេនឌ័រ នៅកម្រិតគ្រួសារ អង្គការសហគមន៍ សង្វាក់ផ្គត់ផ្គង់ និងក្នុងគោលនយោបាយ ស្ថាប័ន និងដំណើរការនានា
៣. វិភាគទិន្នន័យ រៀបចំចងក្រងព័ត៌មានអំពីយេនឌ័រ និងបង្ហាញឱ្យឃើញពីបញ្ហាវិសមភាពយេនឌ័រ
៤. បញ្ជាក់សុពលភាពលើព័ត៌មានដែលចងក្រងបាននេះ និងកំណត់ពីការផ្លាស់ប្តូរ ដែលសហគមន៍នឹងចូលរួមជាមួយ
៥. រៀបចំយុទ្ធសាស្ត្រយេនឌ័រក្នុងសហគមន៍
៦. រៀបចំផែនការសកម្មភាពសម្រាប់អង្គការសហគមន៍នីមួយៗ
៧. សម្របសម្រួលការបង្កើតផែនការរួមមួយ សម្រាប់កសាងសមត្ថភាពស្ថាប័ន
៨. រៀបចំគម្រោងសហគមន៍រួមមួយ
៩. វាយតម្លៃលើគម្រោង និងចាប់ផ្តើមការអនុវត្ត

ភាពជាដៃគូ ជាមួយនឹងតួអង្គនានានៅតាមសហគមន៍ និងនៅថ្នាក់កណ្ដាល គឺជាផ្នែកដ៏សំខាន់មួយរបស់ដំណើរការនេះ។ សំណួរពាក់ព័ន្ធជាមួយនឹងវិសមភាពរវាងបុរស និងស្ត្រី ជារឿយៗ គឺជាបញ្ហារសើប នៅក្នុងសហគមន៍ ហើយការពិភាក្សាដោយចំហពីដំបូង ដោយមានការចូលរួមពីក្រុមផ្សេងៗទាំងប្រុស ទាំងស្រី គឺជាអភិក្រមចាំបាច់មួយ ដើម្បីទទួលបានការយល់ស្របពីពួកគេ។ វាក៏ជាការសំខាន់ផងដែរ ដែលត្រូវចរចាភាពជាដៃគូ ជាមួយនឹងសហគមន៍ និងតួអង្គនៅថ្នាក់កណ្ដាល និងជម្រុញឱ្យអង្គការតាមសហគមន៍ និងអង្គការជាដៃគូនានាមានភាពជាម្ចាស់លើដំណើរការនេះ។

ផ្នែកសំខាន់មួយរបស់ឧបករណ៍នេះ គឺការវិភាគសង្វាក់ផ្គត់ផ្គង់ ដែលមានការវិភាគលើតួនាទីយេនឌ័រ និងទំនាក់ទំនងរវាងតួអង្គជាបុរស និងស្ត្រី មកពីតាមក្រុមវិជ្ជាជីវៈសង្គមខុសៗគ្នា។ នៅក្នុងកម្មវិធី SFLP មានការពិនិត្យលើតួនាទី និងទំនាក់ទំនងទាំងនេះ ដោយគិតពីបរិស្ថានដែលមានការផ្លាស់ប្ដូរ ដូចជា សកលភាវូបនីយកម្មទីផ្សារត្រី ជាដើម។ ស្ថាប័ន និងគោល-នយោបាយនានា កត្តានៃភាពងាយរងគ្រោះ និងព័ត៌មានពាក់ព័ន្ធនឹងលទ្ធភាពប្រើប្រាស់ និងការគ្រប់គ្រង មានឥទ្ធិពលលើលទ្ធភាពរបស់តួអង្គផ្សេងៗ ក្នុងការផ្លាស់ប្ដូរ និងសម្របទៅតាមឥទ្ធិពលខាងក្រៅ។ ការផ្លាស់ប្ដូរក្នុងសង្វាក់ផ្គត់ផ្គង់ នឹងមានផលប៉ះពាល់មកលើអង្គការ និងគ្រួសារនានា ហើយការប្រែប្រួលនេះមានភាពពាក់ព័ន្ធ ជាមួយនឹងស្ត្រីផង និងបុរសផង នៅក្នុងសង្វាក់ផ្គត់ផ្គង់ទាំងមូល ជីវភាពរស់នៅរបស់ពួកគេ និងចុងក្រោយ និរន្តរភាពរបស់ធនធាននេសាទ។

*ប្រភព ៖* Holvoet (2008) សូមមើលផងដែរ Arenas and Lentisco (2011)

## <u>សិក្ខាសាលាសម្រាប់អ្នកពាក់ព័ន្ធ</u>

### *គោលបំណង*

ដើម្បីបង្កើតនូវវេទិកាសមស្រប សម្រាប់ធ្វើការកំណត់ ពិភាក្សា និងដោះស្រាយបញ្ហានានា ដោយប្រើប្រាស់ធាតុចូលដែលទទួលបានពីអ្នកពាក់ព័ន្ធ ឬក្រុមនានាជាច្រើន។ ប្រភេទវេទិកាទាំងនេះ មានប្រយោជន៍ នៅតាមជំហានផ្សេងៗគ្នា ក្នុងដំណើរការនៃការអនុវត្តសិទ្ធិកាន់កាប់ ដូចជា សម្រាប់បង្កើនការយល់ដឹង និងកំណត់ពីគោលបំណង និងអាចមានការចូលរួមពីអ្នកពាក់ព័ន្ធផ្សេងៗ (ដូចជា ក្រុមសហគមន៍ វិស័យនេសាទ អន្តរវិស័យ ពហុជំនាញ ។ល)។

***ទិដ្ឋភាពទូទៅ***

ការរៀបចំផែនការ និងការអនុវត្តសិទ្ធិកាន់កាប់ប្រកបដោយការទទួលខុសត្រូវ ជារឿយៗ ទាមទារឱ្យមានការគាំទ្រ និងការចូលរួមពីអ្នកពាក់ព័ន្ធនានា។ ការរៀបចំសិក្ខាសាលាសម្រាប់អ្នកពាក់ព័ន្ធ គឺជាវិធីសាស្រ្តដ៏ល្អមួយ ដើម្បីផ្តួចផ្តើម ឬរួមចំណែកចំពោះការបង្កើតនូវអភិក្រមភាពជាដៃគូ។ សិក្ខាសាលាផ្តល់លទ្ធភាពឱ្យមនុស្សមួយក្រុម ជាធម្មតា ដោយមានជំនួយពីអ្នកសម្របសម្រួល ចូលរួមយ៉ាងសកម្ម ក្នុងការបំពេញកិច្ចការនានា ដូចជា ការកំណត់ពីចក្ខុវិស័យ ការរៀបចំផែនការ យុទ្ធសាស្រ្ត ការដោះស្រាយបញ្ហា ការសម្រេចនូវការឯកភាពគ្នាជារួម ឬលទ្ធផលចុងក្រោយ ដែលគេចង់បានដទៃទៀត។

សិក្ខាសាលា អាចបញ្ចូលការបណ្តុះបណ្តាល ការអភិវឌ្ឍ ការកសាងក្រុម ការប្រាស្រ័យទាក់ទង ការលើកទឹកចិត្ត និងការរៀបចំផែនការជាមួយគ្នា។ ជាធម្មតា សិក្ខាសាលាមានគោលបំណង និងធាតុចេញយ៉ាងច្បាស់លាស់ ដែលត្រូវសម្រេច តាមរយៈដំណើរការសិក្ខាសាលា ជាជាងគ្រាន់តែជាការបង្កើនការយល់ដឹង។ ការចូលរួមក្នុងសិក្ខាសាលា បង្កើនស្មារតីភាពជាម្ចាស់ និងការផ្តល់ភាពអង់អាច និងបង្កលក្ខណៈឱ្យមានការអភិវឌ្ឍអង្គការស្ថាប័ន និងបុគ្គល ដែលចូលរួម។ សិក្ខាសាលាមានប្រសិទ្ធភាព ក្នុងការជួយគ្រប់គ្រង ឬសម្របសម្រួលការផ្លាស់ប្តូរ ដែលអាចនាំឱ្យមានការកែលំអ និងជាពិសេសបង្កើតជាគំនិតផ្តួចផ្តើម ផែនការ ដំណើរការ និងសកម្មភាពនានា ដើម្បីសម្រេចគោលបំណង។ សិក្ខាសាលាក៏ល្អសម្រាប់លុបបំបាត់នូវឧបសគ្គនានា និងធ្វើឱ្យកាន់តែប្រសើរនូវការប្រាស្រ័យទាក់ទង ខាងក្នុង និងខាងក្រៅ ស្ថាប័ន ក្រុម និងសហគមន៍។

ជំហានសំខាន់ៗ សម្រាប់រៀបចំសិក្ខាសាលាមួយឱ្យបានល្អ រួមមាន ៖

១. កំណត់ពីអ្នកដែលគួរចូលរួមក្នុងសិក្ខាសាលា

២. ធានាឱ្យមានការកំណត់ពីកាលបរិច្ឆេទសមស្រប

៣. ផ្ញើរបៀបវារៈ ឬប្រធានបទ ឬឯកសារសាវតារនានា ឱ្យបានឆាប់ ដើម្បីសុំយោបល់ពីអ្នកចូលរួម និងដើម្បីឱ្យអ្នកចូលរួមបានអានជាមុន

៤. រកទីកន្លែងស័ក្តិសម ដែលមានគ្រប់ឧបករណ៍ ដែលចាំបាច់ទាំងអស់ និងដែលនៅជិតកន្លែងស្នាក់នៅរបស់អ្នកចូលរួម

៥. នៅពេលបើកសិក្ខាសាលា ពន្យល់ពីសាវតារ និងបរិបទសម្រាប់សិក្ខាសាលា និងលទ្ធផល ដែលចង់សម្រេច

៦. ឱ្យអ្នកចូលរួមណែនាំខ្លួន ហើយបើសមស្រប រៀបចំជាសកម្មភាពណែនាំ ដើម្បីឱ្យអ្នកចូលរួមស្គាល់គ្នា និងធ្វើឱ្យពួកគេសើចសប្បាយខ្លះ

៧. ពន្យល់ពីរបៀបវារៈ និងដំណើរការរបស់សិក្ខាសាលា និងតួនាទីរបស់អ្នកសម្របសម្រួល

៨. អញ្ជើញអ្នកចូលរួម ឬតំណាងឱ្យឡើងនិយាយអំពីអ្វីដែលពួកគេចង់សម្រេចឱ្យបានពីសិក្ខាសាលានេះ

៩. អនុវត្តសកម្មភាពផ្សេងៗ ដែលនឹងបង្កលក្ខណៈឱ្យមានការសម្រេចគោលបំណងរបស់សិក្ខាសាលា

១០. បញ្ជាក់ឱ្យបានច្បាស់ពីលទ្ធផលទទួលបានពីសិក្ខាសាលានេះ និងឯកភាពលើសកម្មភាព ដែលនឹងត្រូវអនុវត្តនាពេលអនាគត

១១. ឱ្យអ្នកចូលរួមធ្វើការវាយតម្លៃលើសិក្ខាសាលា (ជាជម្រើស)

១២. បញ្ចប់សិក្ខាសាលា ដោយអញ្ជើញអ្នកចូលរួមលើកឡើងពីអត្ថន័យរបស់សិក្ខាសាលានេះ សម្រាប់ពួកគេ

១៣. សរសេររបាយការណ៍របស់សិក្ខាសាលា និងផ្តល់របាយការណ៍ទៅឱ្យអ្នកអ្នកចូលរួមឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន

ប្រសិនបើមានអ្នកចូលរួមច្រើនជាង ១៥ នាក់ រៀបចំបំបែកក្រុម ដើម្បីព្យាយាមទទួលបានធាតុចូលឱ្យបានច្រើនពីអ្នក ដែលមិននិយាយក្នុងក្រុមធំ។ ការបំបែកជាក្រុមនេះមានភាពពាក់ព័ន្ធជាពិសេស ប្រសិនបើគេរំពឹងថាមានមនុស្សមួយ ឬពីរនាក់ គ្របដណ្តប់លើការពិភាក្សា ក្នុងសិក្ខាសាលា។

សិក្ខាសាលាមួយគួរមានអ្នកសម្របសម្រួលម្នាក់ អាចជាប្រធានអង្គប្រជុំ ឬជាបុគ្គល ដែលទទួលបានការចាត់តាំងម្នាក់ទៀត។ តួនាទីរបស់អ្នកសម្របសម្រួល គឺត្រូវធ្វើយ៉ាងណាឱ្យការពិភាក្សាផ្តោតលើប្រធានបទ ទៅតាមរបៀបវារៈ និងពេលវេលាកំណត់។ អ្នកសម្របសម្រួលគ្រប់គ្រងកិច្ចប្រជុំ ដោយធ្វើការកំណត់ពីពេលវេលា រៀបរាប់ពីចំណុចជាក់លាក់ក្នុងរបៀបវារៈ កំណត់ពីគោលបំណងរបស់កិច្ចប្រជុំ និងគ្រប់គ្រងលើការពិភាក្សា។

គេហទំព័រខាងក្រោម មានឧបករណ៍ និងសេចក្តីពិពណ៌នាជាច្រើន ដែលអាចប្រើប្រាស់ក្នុងសិក្ខាសាលាបាន ៖ http://portals.wi.wur.nl/msp.

*ប្រភព* ៖ EAF toolbox (www.fao.org/fishery/eaf-net/topic/166272/en); and De Young, Charles and Hjort (2008).

## ការសម្របសម្រួល

### *គោលបំណង*

ការសម្របសម្រួលក្រុម គឺជាផ្នែកមួយដ៏សំខាន់ នៅក្នុងការលើកទឹកចិត្តឱ្យអ្នកចូលរួម រួមចំណែកកំណត់ពីបញ្ហា និង ដោះស្រាយបញ្ហា ឬស្វែងរកនូវដំណោះស្រាយ ដែលជាផ្នែកសំខាន់ៗរបស់គ្រប់ជំហានទាំងអស់ នៅក្នុងដំណើរការរៀបចំ ផែនការ ឬអនុវត្តណាក៏ដោយ។ ការសម្របសម្រួលត្រូវបានប្រើប្រាស់ ជាផ្នែកមួយនៃអភិក្រម និងឧបករណ៍ជាច្រើន ដូចជា សិក្ខាសាលា (សូមមើលខាងលើ) និងការពិភាក្សាក្រុមគោលដៅ ជាដើម។

### *ទិដ្ឋភាពទូទៅ*

អ្នកសម្របសម្រួល គឺជាអ្នកទទួលខុសត្រូវធានាយ៉ាងណាឱ្យក្រុម (ធំ ឬតូច) ធ្វើការងារប្រកបដោយភាពស៊ីសង្វាក់គ្នា ដើម្បីឈានទៅដល់ដំណោះស្រាយប្រកបដោយប្រសិទ្ធភាពបានយ៉ាងឆាប់រហ័ស តាមដែលអាចធ្វើបាន។ ការលើកកម្ពស់ជំនាញសម្របសម្រួល នឹងជួយឱ្យមានការដំណើរការកិច្ចប្រជុំ និងសិក្ខាសាលាប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ ហើយគួរចូលរួមសម្រេចគោលបំណងជារួម។

ការសម្របសម្រួលដែលល្អ មានតម្លៃយ៉ាងខ្លាំង។ កិច្ចប្រជុំនានាងាយនឹងបាត់បង់ព័ត៌មានលំអិត ដែលចាំបាច់ ឬងាយនឹងឱ្យបុគ្គលណាម្នាក់ប្រើប្រាស់ដំណើរការនេះ ដើម្បីគោលបំណងផ្ទាល់ខ្លួន។ អ្នកសម្របសម្រួលមិនគួរជាអ្នកជំនាញផ្នែកប្រធាននោះឡើយ (ដែលខុសពីការធ្វើជាអ្នកជំនាញផ្នែកដំណើរការ) ដោយគាត់គឺជាមនុស្សសំខាន់ ដើម្បីសម្រេចនូវលទ្ធផល។ អ្នកជំនាញផ្នែកប្រធានបទអាចគ្របលុបលើការពិភាក្សា ហើយអាចប្រើប្រាស់កិច្ចប្រជុំ ដើម្បីស្វែងរកដំណោះស្រាយ សម្រាប់ខ្លួនឯង។ ប៉ុន្តែ ពួកគេអាចមិនមាន “ចន្លោះខួរក្បាល” គ្រប់គ្រាន់ ដើម្បីគិតពីការរួមចំណែករបស់ពួកគេ ចំពោះប្រធានបទនេះ និងអំពីរបៀបធ្វើឱ្យកិច្ចប្រជុំនេះអាចដំណើរការទៅរកសេចក្តីសន្និដ្ឋានអ្វីមួយបាន។ ជារឿយៗ វាគឺជាការសំខាន់ ដែលត្រូវមានអ្នកសម្របសម្រួលម្នាក់ ដែលទទួលបានការបណ្តុះបណ្តាលត្រឹមត្រូវ ដែល ៖

- បែងចែកដំណើរការពីខ្លឹមសារ
- គ្រប់គ្រងទំនាក់ទំនងជាមួយអតិថិជន
- រៀបចំការធ្វើផែនការបានយ៉ាងល្អិតល្អន់

- ប្រើប្រាស់ពេលវេលា និងទីកន្លែង ដោយមានគោលបំណងច្បាស់លាស់
- ជម្រុញឱ្យមានការចូលរួម និងភាពច្នៃប្រឌិត
- រក្សាភាពសត្យានុម័តគ្រប់ពេលវេលាទាំងអស់
- មើលដឹងពីភាពសកម្មរបស់ក្រុម
- បំបែកភាពរាំងស្ទះចំពោះដំណើរការ
- សម្របទៅតាមស្ថានភាព ដែលមានការផ្លាស់ប្តូរ
- ចែករំលែកការទទួលខុសត្រូវលើដំណើរការនេះ
- បង្ហាញពីភាពវិជ្ជាជីវៈ
- បង្ហាញពីទំនុកចិត្ត និងភាពស្មោះត្រង់
- រក្សាបាននូវសុចរិតភាពផ្ទាល់ខ្លួន

*ប្រភព* ៖ EAF toolbox (www.fao.org/fishery/eaf-net/topic/166272/en); and De Young, Charles and Hjort (2008).

## <u>លំហាត់កំណត់ពីចក្ខុវិស័យ</u>

### *គោលបំណង*

ជួយដល់អ្នកពាក់ព័ន្ធនានា (ក្នុងនោះរួមទាំងសហគមន៍ និងរដ្ឋាភិបាលផង) ដើម្បីបង្កើតនូវគុណតម្លៃ និងលទ្ធផលដែលទទួលបានការឯកភាពគ្នា សម្រាប់ប្រើប្រាស់ក្នុងការរៀបចំប្រព័ន្ធសិទ្ធិកាន់កាប់ ដោយលើកទឹកចិត្តឱ្យពួកគេមើលត្រឡប់ក្រោយ ពីពេលអនាគតមកវិញ។

### *ទិដ្ឋភាពទូទៅ*

លំហាត់កំណត់ពីចក្ខុវិស័យ ត្រូវបានប្រើប្រាស់ ដើម្បីកំណត់ និងជួយសម្រេចនូវអនាគត ដែលគេចង់បាន តាមរយៈការកំណត់ពីដំណាក់កាល សម្រាប់បង្កើតអនាគត តាមរយៈការពិភាក្សា ដែលមានលក្ខណៈវិជ្ជមាន។ ការសិក្សានានាបានបង្ហាញថា មនុស្សច្រើនតែអាចសម្រេចនូវគោលបំណងអ្វីមួយ ប្រសិនបើពួកគេអាចមើលឃើញគោលបំណងនោះ និងបន្ទាប់មកអាចស្រមើលស្រម៉ៃពីជំហាននានា ដែលចាំបាច់ ដើម្បីឈានទៅសម្រេចគោលបំណងនោះ។

គោលបំណងសំខាន់ គឺដំបូងត្រូវបង្កើតនូវសេចក្តីថ្លែងអំពី “ចក្ខុវិស័យនៃជោគជ័យ” ដែលជាសេចក្តីពិពណ៌នាដោយសង្ខេបអំពីថាតើប្រព័ន្ធសិទ្ធិកាន់កាប់ប្រកបដោយជោគជ័យ នឹងផលិតបានអ្វីខ្លះ នៅក្នុងរយៈពេលវែង (៥-២០ ឆ្នាំ)។ សេចក្តីថ្លែងនេះរៀបរាប់ពីលទ្ធផល ដែលនឹងទទួលបានពីការអនុវត្តប្រកបដោយជោគជ័យ និងកត្តា ដែលនឹងកំណត់ពីគោលបំណងនៅកម្រិតខ្ពស់ ដែលនឹងនាំឱ្យមានជោគជ័យនោះ ប្រសិនបើគោលបំណងនេះត្រូវបានគេសម្រេចបាន។ មូលដ្ឋាននៃវិធីសាស្ត្រនេះគឺថា ប្រសិនបើគេមិនដឹងថាជោគជ័យមានលក្ខណៈយ៉ាងដូចម្តេចនោះ គេនឹងមានការលំបាក នៅក្នុងការសម្រេចជោគជ័យ នេះជាមិនខាន។

ដូច្នេះ លំហាត់នេះមានគោលបំណងបង្ហាញដល់អ្នកចូលរួមអំពីសេណារីយ៉ូមួយ ដែលពួកគេអាចមើលឃើញថានឹងទទួលបានជោគជ័យ ប៉ុន្តែមិនមានអ្នកសម្របសម្រួលជួយបង្ហាញថាជោគជ័យមានរូបរាងយ៉ាងដូចម្តេចនោះទេ។ ដូច្នេះ ការបង្ហាញឱ្យចេញជារូបភាពនេះត្រូវបង្ហាញពី “ខ្លឹមសារសង្ខេប” ប៉ុន្តែអ្នកចូលរួមនីមួយៗត្រូវបំពេញខ្លឹមសារសង្ខេបនេះ ជាមួយនឹងទស្សនៈយល់ឃើញរបស់ខ្លួន។

វិធីសាស្ត្រកំណត់ពីចក្ខុវិស័យ មានគុណសម្បត្តិ និងគុណវិបត្តិរបស់វា ៖

- គុណសម្បត្តិ ៖ ការកំណត់ចក្ខុវិស័យ បង្កើតបានជាគោលបំណង សេចក្តីសង្ឃឹម និងការលើកទឹកចិត្តដូចគ្នា។ ការកំណត់ចក្ខុវិស័យផ្តល់លទ្ធភាពឱ្យមានការផ្លាស់ប្តូរជាមូលដ្ឋាន។ វាផ្តល់អារម្មណ៍គ្រប់គ្រងដល់មនុស្ស។ វាផ្តល់ឱ្យក្រុម នូវអ្វីមួយ ដើម្បីបោះជំហានទៅមុខទៀត និងជម្រុញឱ្យមានការគិតប្រកបដោយភាពច្នៃប្រឌិត និងបំណងប្រាថ្នាចង់សម្រេចអ្វីមួយ។ បញ្ហា គឺជាចំណុចអវិជ្ជមាន ដែលត្រូវចាកចេញឱ្យឆ្ងាយ ខណៈពេលដែលចក្ខុវិស័យគឺជាចំណុចវិជ្ជមាន ដែលត្រូវបោះជំហានទៅរក។

- គុណវិបត្តិ ៖ ពេលខ្លះ ការកំណត់ចក្ខុវិស័យអាចនាំឱ្យមានលទ្ធផលមិនល្អ ដោយហេតុថាមនុស្សមិនអាចចង់បានអ្វីដែលពួកគេមិនដឹងនោះទេ។ នៅក្នុងស្ថានភាពបែបនេះ គេប្រហែលជាចាំបាច់ត្រូវបង្ហាញពីជម្រើសផ្សេងៗ ដោយជម្រើសនីមួយៗមានគុណសម្បត្តិ និងគុណវិបត្តិរបស់វា។ នៅពេលដែលការកំណត់ជម្រើសបែបនេះត្រូវបានធ្វើឡើងដោយពេញចិត្តហើយនោះ គេអាចសាកសួរថា ៖ "តើអ្នកចង់បានអ្វីខ្លះ?"

*ប្រភព* ៖ EAF toolbox (www.fao.org/fishery/eaf-net/topic/166272/en); and De Young, Charles and Hjort (2008).

## ការវិភាគអ្នកពាក់ព័ន្ធ

### *គោលបំណង*

ការវិភាគអ្នកពាក់ព័ន្ធជួយធ្វើការកំណត់ក្នុងលក្ខណៈជាប្រព័ន្ធពីអ្នកដែលពិតជាត្រូវការចូលរួម នៅក្នុងដំណើរការនៃការរៀបចំផែនការសិទ្ធិកាន់កាប់ និងអ្នកដែលប្រយោជន៍របស់ខ្លួនត្រូវបានគេដកហូត។ ដំណើរការនេះក៏គួរពិនិត្យផងដែរលើអំណាច ទំនាស់ ការលើកទឹកចិត្ត និងទំនាក់ទំនងដទៃទៀត ក្នុងចំណោមអ្នកពាក់ព័ន្ធទាំងនេះ។ ការវិភាគអ្នកពាក់ព័ន្ធ មានទំនាក់ទំនងជាមួយនឹងការវិភាគស្ថាប័ន ប៉ុន្តែផ្តោតការយកចិត្តទុកដាក់ច្រើនជាងលើការលើកទឹកចិត្តរបស់បុគ្គល និង/ឬប្រយោជន៍ជាសម្ព័ហភាពរបស់បុគ្គល/ក្រុម ជាជាងលើរចនាសម្ព័ន្ធ និងនីតិវិធីរបស់ស្ថាប័ន។

### *ទិដ្ឋភាពទូទៅ*

អ្នកពាក់ព័ន្ធ គឺជាអ្នកដែលមានប្រយោជន៍ នៅក្នុងបញ្ហា ដែលកំពុងត្រូវបានដោះស្រាយ អាចជាប់ពាក់ព័ន្ធជាមួយនឹងសុខុមាលភាព ឬប្រយោជន៍របស់ពួកគេ។ អ្នកពាក់ព័ន្ធមួយចំនួន គឺជាមនុស្សដែលសកម្ម - ពួកគេអាចមានឥទ្ធិពលលើប្រព័ន្ធ។ អ្នកពាក់ព័ន្ធមួយចំនួនទៀត គឺជាមនុស្សមិនសកម្ម ពួកគេទទួលរងឥទ្ធិពលដោយសារប្រព័ន្ធមកវិញ។

គេអាចពិចារណាលំអិតលើអ្នកពាក់ព័ន្ធ ដោយសារតែ ៖

- សារៈសំខាន់របស់ពួកគេ - ក្នុងនាមជាអ្នកដែលអាចទទួលផលពីការអភិវឌ្ឍ
- ឥទ្ធិពលរបស់ពួកគេ - អំណាចរបស់ពួកគេ លើជោគជ័យរបស់គម្រោង
- ពួកគេអាចត្រូវបានកំណត់ថាជាអ្នកឈ្នះ ឬអ្នកចាញ់ នៅក្នុងដំណើរការរៀបចំផែនការគ្រប់គ្រងធនធាននេសាទ

ការវិភាគអ្នកពាក់ព័ន្ធខិតខំ ៖

- កំណត់ វាយតម្លៃ និងប្រៀបធៀបប្រយោជន៍នានា
- ពិនិត្យលើវិវាទដែលមានកន្លងមក និង/ឬភាពចុះសម្រុងគ្នា
- ពិពណ៌នា និងស្វែងយល់ពីការលះបង់ឱ្យគ្នាទៅវិញទៅមក

ដូច្នេះ ទស្សនទានអំពីអ្នកពាក់ព័ន្ធ គ្របដណ្ដប់លើសពីអ្នក ដែលពាក់ព័ន្ធដោយផ្ទាល់ជាមួយនឹងការទាញប្រយោជន៍ពីធនធាននេសាទទៅទៀត និងមានដាក់បញ្ចូលផងដែរនូវអ្នក ដែលទទួលបានប្រយោជន៍ក្នុងទម្រង់មួយចំនួនពីធនធាននេះ ឬតំបន់/សហគមន៍ ដែលធនធានទាំងនេះត្រូវបានរកឃើញ។ នៅក្នុងករណីធនធានសមុទ្ទ អ្នកពាក់ព័ន្ធអាចជាអ្នកនេសាទ អ្នកដែលធ្វើការងារពាក់ព័ន្ធនឹងការកែច្នៃ និងលក់ត្រី អ្នកបរិភោគត្រី អ្នកទេសចរក្នុងតំបន់នេះ អ្នកប្រកបរបរដឹកជញ្ជូន និងអ្នកធ្វើដំណើររបស់ពួកគេ ឧស្សាហកម្មដែលប្រើប្រាស់ទឹក ឬដែលបំពុលទឹក និងក្រុម ឬបុគ្គលផ្សេងទៀត ដែលទទួលបានប្រយោជន៍តិចតួច។

សម្រាប់ក្រុម ដែលត្រូវបានគេកំណត់ថាមានប្រយោជន៍ច្រើន ឬទទួលបានប្រយោជន៍សំខាន់ៗពីធនធាននេសាទ ការវិភាគបែបសង្គមវិជ្ជា អាចពិនិត្យលើអាទិភាព និងការលើកទឹកចិត្ត ដំណើរការនៃការធ្វើសេចក្ដីសម្រេចចិត្ត និងស្ថាប័នរបស់ពួកគេ និងស្វែងយល់ពីទំនាក់ទំនងសង្គម សេដ្ឋកិច្ច និងវប្បធម៌ រវាងក្រុមនីមួយៗ និងធនធាននេះ។

នៅកម្រិតគ្រួសារ បញ្ហាផ្សេងទៀត ដូចជា តួនាទីរបស់ស្ត្រី កម្រិតនៃចល័តភាពរបស់ពួកគេ និងដំណាក់កាលនៅក្នុងវដ្តនៃការអភិវឌ្ឍរបស់គ្រួសារ សុទ្ធតែអាចមានភាពពាក់ព័ន្ធ។ ស្ត្រី គឺជាក្រុមពិសេស នៅក្នុងការងារនេសាទភាគច្រើន ហើយស្ត្រីមកពីសាវតារសង្គម និងសេដ្ឋកិច្ចផ្សេងៗគ្នា ក៏អាចមានប្រយោជន៍ពិសេស ខុសៗគ្នាដែរ។ ចាំបាច់ត្រូវតែមានការផ្ដោតការយកចិត្តទុកដាក់លើធនធាននេសាទតាមតំបន់ឆ្នេរ ដែលគេងាយស្រួលទទួលបាន ដោយសារតែអាចមានការចូលរួមយ៉ាងសំខាន់ពីសំណាក់ស្ត្រី ដែលមិនមែនស្តែងចេញឱ្យឃើញជាក់ស្តែងនោះទេ ហើយជាអ្វីដែលទាមទារឱ្យមានការស្រាវជ្រាវឱ្យបានជាក់លាក់។

សមាជិករបស់វិស័យនេសាទ និងកែច្នៃត្រី និងសង្វាក់នៃការផ្គត់ផ្គង់ដទៃទៀត មានប្រយោជន៍ផ្សេងៗគ្នាចំពោះធនធាននេះ ទៅតាមប្រយោជន៍ ដែលពួកគេទទួលបានពីការប្រើប្រាស់ធនធានទាំងនេះ។ ម្ចាស់ឧបករណ៍នេសាទ ដែលជាការ

វិនិយោគដ៏ធំមួយរបស់ពួកគេ សម្រាប់ទាញប្រយោជន៍ពីធនធាននេសាទជាក់លាក់ នឹងមានប្រយោជន៍ផ្សេងពីធនធាននេះ បើធៀបជាមួយនឹងសមាជិកនាវិក ដែលអាចធ្វើការងារក្នុងវិស័យនេសាទតែតាមរដូវកាល និងដែលអាចផ្លាស់ទៅធ្វើការងារនេសាទផ្សេងទៀត ឬក្នុងវិស័យផ្សេងទៀតបានយ៉ាងងាយស្រួល។

ពុំមានវិធីសាស្ត្រល្អបំផុតតែមួយគត់ សម្រាប់ធ្វើការវិភាគអ្នកពាក់ព័ន្ធនោះទេ។ គេត្រូវតែប្រើប្រាស់សុភវិនិច្ឆ័យ។ ត្រូវតែមានការយកចិត្តទុកដាក់ជាពិសេស ដើម្បីធានាយ៉ាងណាឱ្យក្រុមដែលគ្មានសម្លេង និងក្រុមដែលជួបប្រទះការលំបាកដែលអាចមានដូចជាស្ត្រី យុវជន ចាស់ជរា និងជនក្រីក្រ មិនត្រូវបានគេផាត់ចេញពីការវិភាគនេះ។ សមាជិកចម្រុះក្នុងក្រុមគឺជាអ្វីដែលតែងតែមាន ជាពិសេស នៅតាមសហគមន៍តូច។ នៅក្នុងករណីបែបនេះ ចាំបាច់ត្រូវតែមានការបញ្ជាក់ឱ្យបានច្បាស់ថាតើ “អ្នកដែលត្រូវនិយាយ” នៅពេលណាមួយ និងថាតើអ្នកនេះតំណាងឱ្យ “ក្រុមណាមួយ។

*ប្រភព* ៖ EAF toolbox (www.fao.org/fishery/eaf-net/topic/166272/en)

## វិធីសាស្ត្រវាយតម្លៃសេដ្ឋកិច្ច

### *គោលបំណង*

ការវាយតម្លៃផ្នែកសេដ្ឋកិច្ច និងសង្គម ត្រូវបានប្រើប្រាស់ ដើម្បីស្វែងយល់ឱ្យកាន់តែពេញលេញអំពីស្ថានភាពសង្គម និងសេដ្ឋកិច្ច គុណតម្លៃ និងបញ្ហានានាពាក់ព័ន្ធជាមួយនឹងធនធាននេសាទ និងសហគមន៍ ដែលពឹងអាស្រ័យលើធនធាននេះ។ ការវាយតម្លៃ (លើផលប៉ះពាល់) សង្គម និងសេដ្ឋកិច្ច អាចធ្វើឡើង ដើម្បីស្រាវជ្រាវពីភាពពាក់ព័ន្ធ ដែលអាចមាននៃការរៀបចំផ្នែកការគ្រប់គ្រង ដែលស្នើឡើងថ្មី។

### *ទិដ្ឋភាពទូទៅ*

គេអាចប្រើប្រាស់វិធីសាស្ត្រផ្សេងៗគ្នា អាស្រ័យទៅតាមគោលបំណងពិតប្រាកដរបស់ការវាយតម្លៃនេះ និងទិន្នន័យដែលមាន ៖

*ការវាយតម្លៃសេដ្ឋកិច្ចផ្អែកតាមទីផ្សារ*

- ការវាយតម្លៃលើសេដ្ឋកិច្ចទីផ្សាររបស់វិស័យនេសាទ ជាលក្ខណៈពាណិជ្ជកម្ម ប៉ាន់ប្រមាណពីអត្ថប្រយោជន៍សេដ្ឋកិច្ចសរុបសុទ្ធ ដែលវិស័យពាណិជ្ជកម្មទទួលបានពីការប្រើប្រាស់ធនធាននេសាទ នៅក្នុងរយៈពេលណាមួយ។ ចាំបាច់ត្រូវ មានដាក់កាលបរិច្ឆេទលើចំណូល និងចំណាយនានា។

*ការវាយតម្លៃសេដ្ឋកិច្ចមិនផ្អែកតាមទីផ្សារ*

- អាទិភាពដែលបង្ហាញចេញមក ៖ វិធីសាស្ត្រចំណាយសម្រាប់ការធ្វើដំណើរ (travel cost method - TCM)។ គេអាចប្រើប្រាស់វិធីសាស្ត្រវាយតម្លៃសេដ្ឋកិច្ចមិនមែនទីផ្សារ សម្រាប់ធនធាន ដែលមិនពាក់ព័ន្ធជាទូទៅ ជាមួយនឹងទីផ្សារ ដែលគេអាចសង្កេតដឹងបាន។ TCM គឺជា “វិធីសាស្ត្រវាយតម្លៃប្រយោល ដែលត្រូវបានប្រើប្រាស់ ដើម្បីប៉ាន់ប្រមាណពីអតិរេករបស់អ្នកប្រើប្រាស់ ក្នុងពេលធ្វើដំណើរទៅនេសាទមួយជើង ដោយប្រើប្រាស់ការចំណាយលើការធ្វើដំណើរ ជាតំណាងឱ្យតម្លៃសម្រាប់សកម្មភាពកម្សាន្ត។ សម្រាប់ការវាយតម្លៃលើធនធាននេសាទ TCM ត្រូវបានគេប្រើប្រាស់ញឹកញាប់ជាងគេ ដើម្បីប៉ាន់ប្រមាណពីតម្លៃធនធានចេញពីជ្រុងការកែកម្សាន្ត។ ប៉ុន្តែ

វិធីសាស្ត្រ នេះក៏អាចត្រូវបានគេយកមកប្រើប្រាស់ សម្រាប់ក្រុមអ្នកប្រើប្រាស់ដទៃទៀតផងដែរ (ដូចជា អ្នកប្រើប្រាស់ ដែលមិនទាញប្រយោជន៍ពីធនធាននេះជាដើម)។

- អាទិភាពដែលបង្ហាញចេញមក ៖ ការកំណត់ពីគំរូប្រយោជន៍តាមបែបចៃដន្យ (random utility modelling - RUM) គឺមានលក្ខណៈស្រដៀងគ្នានឹង TCM ដែរ ដោយសារបច្ចេកទេសទាំងពីរនេះប្រើប្រាស់ទិន្នន័យនៃការធ្វើដំណើរ និងទិន្នន័យចំណាយ ដើម្បីធ្វើការប៉ាន់ប្រមាណពីតម្លៃសេដ្ឋកិច្ច។ ដូច្នេះ RUM ត្រូវការវិធីសាស្ត្រប្រមូលទិន្នន័យដូចគ្នានឹង TCM ដែរ ប៉ុន្តែ RUM ចាត់ទុកតម្រូវការនៃការនេសាទសម្រាប់ការកែកម្សាន្ត ថាជាជម្រើសផ្ទាល់ខ្លួន។ ពោលគឺ មានការសម្រេចចិត្ត សម្រាប់ការធ្វើដំណើររាល់លើក ក្នុងទម្រង់ជាជម្រើសឆន្ទានុសិទ្ធិតែម្តង រវាងទីតាំងនេសាទផ្សេងៗគ្នា។ ការសម្រេចចិត្តនីមួយៗ ដែលធ្វើឡើងដោយអ្នកប្រើប្រាស់ គឺផ្អែកទៅតាមគោលដៅនៃការបង្កើនប្រយោជន៍រំពឹងទុក ពីការធ្វើដំណើរទៅនេសាទ និងពឹងអាស្រ័យលើគុណភាពធៀបរបស់គ្រប់ទីតាំងទាំងអស់ដែលមាន និងប្រយោជន៍ ដែលទទួលបានពីទីតាំងនេះ។

- វិធីសាស្ត្រអាទិភាពដែលលើកឡើង ៖ វិធីសាស្ត្រវាយតម្លៃបម្រុង (contingent valuation method - CVM) គឺជា "វិធីសាស្ត្រមួយ សម្រាប់ធ្វើការប៉ាន់ប្រមាណ ពីអតិរេករបស់អ្នកប្រើប្រាស់ ផ្អែកទៅតាមការឆ្លើយតបរបស់បុគ្គលម្នាក់ៗចំពោះកាលៈទេសៈបម្រុង ដែលមាននៅក្នុងទីផ្សារសម្មតិកម្ម ឬទីផ្សារពិសោធន៍។ CVM មានគោលបំណងប្រមូលព័ត៌មានអំពីតម្លៃដែលលើកឡើង ឬឆន្ទៈក្នុងការចំណាយ និង/ឬទទួលយកសំណង ដែលភ្ជាប់ជាមួយនឹងសេណារីយ៉ូ ឬកាលៈទេសៈសម្មតិកម្មជាក់លាក់ណាមួយ របស់អ្នកតបសំណួរចំពោះការអង្កេត។ ជារឿយៗសំណាកគំរូនៃតម្លៃដែលត្រូវបានលើកឡើងនេះ ត្រូវបានប្រើប្រាស់ ដើម្បីប៉ាន់ប្រមាណពីប្រយោជន៍ ដែលនឹងមានសម្រាប់ប្រជាជនទាំងមូល ប្រសិនបើកាលៈទេសៈនោះកើតមានឡើងជាក់ស្តែងមែន។

- អាទិភាពដែលលើកឡើង ៖ ការកំណត់ពីគំរូជម្រើស គឺជាបច្ចេកទេសមួយ ដែលត្រូវបានបង្កើតឡើងចេញពីការវិភាគ conjoint analysis - ដែលជាទម្រង់មួយនៃការវិភាគស្ថិតិ ដែលកន្លងមកត្រូវបានគេប្រើប្រាស់ សម្រាប់គោលបំណងស្រាវជ្រាវម៉ាឃីតធីង ដើម្បីវិភាគលើកត្តានានានៃទំនិញផ្សេងៗ ដែលគេអាចលក់លើទីផ្សារបាន។ ការកំណត់ពីគំរូជម្រើស មានលក្ខណៈស្រដៀងគ្នានឹង CVM ដែរ ដោយអ្នកតបសំណួរត្រូវបានស្នើឱ្យបង្ហាញពីអាទិភាព

របស់ពួកគេ នៅក្នុងសេណារីយ៉ូសម្មតិកម្ម។ ប៉ុន្តែ នៅក្នុងការកំណត់ពីគំរូជម្រើស អ្នកតបសំណួរចាំបាច់ត្រូវតែកំណត់ពីលំដាប់ លំដោយនៃជម្រើសសម្មតិកម្មចម្រុះ ផ្ទុយទៅនឹងជម្រើសសម្មតិកម្មតែមួយ នៅក្នុង CVM។

*វិធីសាស្ត្រវាយតម្លៃលើផលប៉ះពាល់សេដ្ឋកិច្ចថ្នាក់តំបន់*

- វិធីសាស្ត្រប៉ាន់ប្រមាណពីផលប៉ះពាល់សេដ្ឋកិច្ចថ្នាក់តំបន់ រួមមានបច្ចេកទេសនានា ដែលគេអាចប្រើប្រាស់ម៉ូដែលអ្វីមួយ ដើម្បីស្វែងយល់ និងធ្វើសាមញ្ញកម្មសេដ្ឋកិច្ចមួយ (នៅថ្នាក់មូលដ្ឋាន តំបន់ ជាតិ ឬអន្តរជាតិ) ដើម្បីកំណត់ពីផលប៉ះពាល់ ដែលវិស័យមួយ (ឧ. វិស័យនេសាទជាលក្ខណៈពាណិជ្ជកម្ម) មានមកលើសេដ្ឋកិច្ចរបស់តំបន់នោះ។ អភិក្រមបែបនេះ ពាក់ព័ន្ធតែជាមួយនឹងសកម្មភាពសេដ្ឋកិច្ចប៉ុណ្ណោះ និងមិនពាក់ព័ន្ធជាមួយនឹងអត្ថប្រយោជន៍ពិតរបស់សេដ្ឋកិច្ចនោះឡើយ។ ដូច្នេះ អភិក្រមទាំងនេះមិនផ្តល់ព័ត៌មាន ដែលចាំបាច់ សម្រាប់ធ្វើសេចក្តីសម្រេចចិត្តអំពីការបែងចែកធនធាន ជាមួយនឹងគោលដៅ ដើម្បីបង្កើនប្រយោជន៍សេដ្ឋកិច្ចសុទ្ធសាធជាអតិបរមានោះឡើយ។

*ប្រភព ៖* EAF toolbox ( www.fao.org/fishery/eaf-net/topic/166272/en ) សេចក្តីសង្ខេបអំពីវិធីសាស្ត្រវាយតម្លៃសេដ្ឋកិច្ច និងសង្គម ត្រូវបានដកស្រង់ចេញពី Vieira, Schirmer and Loxton (2009)

## <u>ការវិភាគចំណាយ-ប្រយោជន៍ដែលទទួលបាន</u>

### ***គោលបំណង***

គេអាចប្រើប្រាស់ការវិភាគចំណាយ-ប្រយោជន៍ដែលទទួលបាន (CBA) ដើម្បីជួយវាយតម្លៃថាតើករណីអនុវត្តគំនិតផ្តួចផ្តើមធំមួយ ដូចជា ការដាក់ឱ្យអនុវត្តនូវប្រព័ន្ធសិទ្ធិកាន់កាប់ថ្មីជាដើម មានប្រសិទ្ធភាពចំណាយ សម្រាប់រដ្ឋាភិបាលដែរឬទេ។ CBA ក៏អាចប្រើប្រាស់ ដើម្បីជួយកំណត់ពីចំនួនជម្រើសផ្សេងៗ ដែលជាជម្រើសល្អបំផុតផងដែរ។ ជារឿយៗ CBA ត្រូវបានរដ្ឋាភិបាលយកទៅប្រើប្រាស់ ដើម្បីវាយតម្លៃពីលទ្ធភាពសម្រេចបំណងរបស់អន្តរាគមន៍អ្វីមួយ។ វាគឺជាការវិភាគលើប្រសិទ្ធភាពចំណាយរបស់គំនិតផ្តួចផ្តើមផ្សេងៗគ្នា (រួមទាំង ការមិនធ្វើអ្វីទាំងអស់ ផង) ដើម្បីពិនិត្យមើលថាតើប្រយោជន៍មានច្រើនជាងចំណាយដែរឬទេ។ គោលបំណងសំខាន់ គឺវាស់វែងប្រសិទ្ធភាពរបស់អន្តរាគមន៍នេះ ធៀបជាមួយនឹងស្ថានភាពបច្ចុប្បន្ននេះ។ ចំណាយ និងប្រយោជន៍ ដែលបានពីផលប៉ះពាល់របស់អន្តរាគមន៍មួយ ត្រូវបានវាយតម្លៃ ដោយគិតជាឆន្ទៈរបស់សាធារណជន ក្នុងការបង់ថ្លៃ ដើម្បីទទួលបាន (ប្រយោជន៍) ឬឆន្ទៈរបស់ពួកគេ ក្នុងការបង់ថ្លៃ ដើម្បីបញ្ចៀស

(ចំណាយ ឬការខាតបង់)។ ជាធម្មតា ធាតុចូលនានាត្រូវបានគេវាស់វែងជាចំណាយឱកាស ដែលជាតម្លៃនៃការប្រើប្រាស់ជម្រើសដែលល្អជាងគេបំផុត។

***ទិដ្ឋភាពទូទៅ***

ដំណើរការ CBA អាចពាក់ព័ន្ធច្បាស់លាស់ ឬមិនច្បាស់លាស់ជាមួយនឹងការដាក់ទំងន់លើចំណាយរំពឹងទុកសរុបធៀប ជាមួយនឹងអត្ថប្រយោជន៍រំពឹងទុកសរុប របស់សកម្មភាពមួយ ឬច្រើន ដើម្បីជ្រើសរើសនូវជម្រើស ដែលល្អបំផុត ឬដែលសមស្របបំផុត។ ដំណើរការនេះប្រព្រឹត្តទៅ តាមរយៈការស្វែងរក និងការកំណត់ចំនួន និងបន្ទាប់មក បន្ថែមគ្រប់កត្តា វិជ្ជមានទាំងអស់ (ដែលជាអត្ថប្រយោជន៍) និងកំណត់ រាប់ចំណួន និងដកកត្តាអវិជ្ជមានទាំងអស់ (ចំណាយ)។ ភាពខុសប្លែកគ្នារវាងចំណុចទាំង ២ នេះ បង្ហាញថាតើសកម្មភាពក្នុងផែនការគួរអនុវត្តដែរឬទេ។ គន្លឹះសំខាន់សម្រាប់ធ្វើ CBA គឺដើម្បីធានាថា រាល់ចំណាយ និងរាល់ប្រយោជន៍ទាំងអស់ ត្រូវបានដាក់បញ្ចូល និងរាប់ចំនួនបានត្រឹមត្រូវ។

នៅក្នុងករណី នៅពេលដែលទាំងប្រយោជន៍ ទាំងចំណាយ ត្រូវបានបង្ហាញ ដោយគិតជាប្រាក់កាស គេក៏អាចកែសម្រួលប្រយោជន៍ និងចំណាយទាំងនេះ ទៅជា "តម្លៃពេលវេលា" របស់ប្រាក់កាសផងដែរ ដើម្បីឱ្យរាល់លំហូររបស់ប្រយោជន៍ និងលំហូររបស់ចំណាយដែលគេព្យាករទុកក្នុងរយៈពេលមួយ (ដែលច្រើនដែលកើតមានឡើង នៅពេលផ្សេងៗគ្នា) អាចបង្ហាញដូចគ្នាជា "តម្លៃបច្ចុប្បន្ន" ដោយប្រើប្រាស់អត្រាបញ្ចុះតម្លៃ។ អត្រាបញ្ចុះតម្លៃ ដែលត្រូវបានគេប្រើប្រាស់ញឹកញាប់បំផុត សម្រាប់ធ្វើការគណនារកតម្លៃបច្ចុប្បន្ន គឺអត្រាការប្រាក់ ដែលយកចេញពីទីផ្សារហិរញ្ញវត្ថុ។ ការជ្រើសរើសយកអត្រាបញ្ចុះតម្លៃមកប្រើប្រាស់ អាចមានភាពចម្រូងចម្រាសខ្លាំង ដោយសារតែអត្រាបញ្ចុះតម្លៃខ្ពស់ មានន័យថាតម្លៃសុខុមាលភាពរបស់មនុស្សជំនាន់ក្រោយនឹងមានតម្លៃទាបបំផុត ដែលអាចមានផលប៉ះពាល់យ៉ាងច្រើន លើការចង់បានអន្តរាគមន៍ ដែលអាចជួយដល់បរិស្ថានបាន។ ការសិក្សាស្រាវជ្រាវនានាបង្ហាញថា នៅក្នុងតថភាពជាក់ស្តែង អត្រាបញ្ចុះតម្លៃរបស់មនុស្ស មានការថយចុះ នៅក្នុងរយៈពេលមួយ។ ដោយសារតែ CBA ជារឿយៗ មានបំណងធ្វើការវាស់វែងបំណងពិតប្រាកដរបស់សាធារណជនទូទៅក្នុងការបង់ថ្លៃ ជាធម្មតា លក្ខណៈនេះត្រូវបានបញ្ចូលទៅក្នុងការសិក្សាតែម្តង។

បញ្ហាមួយ ក្នុងចំណោមបញ្ហាសំខាន់ៗជាមួយ CBA គឺថា វាតម្រូវឱ្យមានការបម្លែងរាល់តម្លៃទាំងអស់ សម្រាប់សំណើមួយ ឱ្យទៅជាប្រាក់កាស។ ចំណុចនេះត្រូវបានមនុស្សជាច្រើន ដែលគាំទ្រ CBA ចាត់ទុកថាជាគុណសម្បត្តិធំបំផុត

របស់វិធីសាស្ត្រនេះ ដោយសារតែវាប្រើប្រាស់តម្លៃសេដ្ឋកិច្ច ជារង្វាស់សកល ពោលគឺវាជាវិធីសាស្ត្រ ដែលមានភាពលំអៀងតិចតួច ដើម្បីធ្វើការវិនិច្ឆ័យលើផលប៉ះពាល់នៃសេចក្តីសម្រេចចិត្តចេញជាលិខិតបទដ្ឋានគតិយុត្តិអ្វីមួយ។ ប៉ុន្តែ ការវិភាគទាំងនេះកម្រនឹងមានលក្ខណៈអព្យាក្រិតណាស់ ហើយរាល់ទិន្នន័យទាំងអស់ រាប់បញ្ចូលទាំងទិន្នន័យមិនមែនសេដ្ឋកិច្ចផង ត្រូវតែយកមកធ្វើការពិចារណានៅក្នុងបរិបទដែលមានការធ្វើសេចក្តីសម្រេចចិត្ត។

លើសពីនេះ មិនថាគណិតវិទ្យាមានភាពស្មុគស្មាញកម្រិតណានោះទេ ធាតុចូលសំខាន់ៗមួយចំនួននៅក្នុង CBA មិនអាចបម្លែងជាតម្លៃសេដ្ឋកិច្ចបានឡើយ។ សន្តិសុខ និងសុវត្ថិភាព ការអភិរក្សដែនជម្រកសត្វព្រៃ និងកន្លែងលំហ ការកាត់បន្ថយការភ័យខ្លាចក្នុងសហគមន៍ និងភាពមិនប្រាកដប្រជាក្នុងវិស័យនានា ដែលនាំឱ្យមានការច្នៃប្រឌិតថ្មីផ្នែកបច្ចេកវិទ្យា គឺសុទ្ធតែជាអ្វីដែលមានលក្ខណៈអរូបីផ្នែកសេដ្ឋកិច្ច។ ប្រយោជន៍ និងចំណាយសេដ្ឋកិច្ចដទៃទៀត ជាទូទៅ ងាយស្រួលវាស់វែងជាង។ ទីមួយ ប្រយោជន៍ និងចំណាយមួយចំនួន គឺងាយដឹង ទៅតាមការប្រមូលទិន្នន័យនេសាទជាលក្ខណៈស្តង់ដា - ឧ. ប្រយោជន៍ ឬចំណាយ នៅកម្រិតអ្នកនេសាទ (ដូចជា ការផ្លាស់ប្តូរចំណូល សម្រាប់ត្រីដែលចាប់បានមួយក្បាល នៅកម្រិតផលចាប់ និងចំណាយលើការនេសាទ) និងសម្រាប់ប្រយោជន៍ ឬចំណាយ នៅកម្រិតវិស័យ (ដូចជា ការប្រែប្រួលការងារ ប្រយោជន៍សុទ្ធផ្នែកសេដ្ឋកិច្ច និងការរួមចំណែកចំពោះសេដ្ឋកិច្ច)។ គេអាចដឹងព័ត៌មានមួយចំនួន តាមរយៈប្រព័ន្ធគណនេយ្យរបស់រដ្ឋាភិបាល (ដូចជា ការប្រែប្រួលចំណូល ដែលបានពីការផ្តល់អាជ្ញាប័ណ្ណ)។ តែទោះជាយ៉ាងណាក៏ដោយ ព័ត៌មានមួយចំនួន អាចត្រូវការឱ្យមានការប្រមូលទិន្នន័យឱ្យកាន់តែជាក់លាក់ ដូចជា តាមរយៈការអង្កេត ជាដើម ដើម្បីវាយតម្លៃលើការផ្លាស់ប្តូរឱកាសប្រកបរបរចិញ្ចឹមជីវិតសម្រាប់អ្នកនេសាទ ឬការកើនឡើងនូវគម្លាតចំណូលក្នុងចំណោមអ្នកនេសាទ។

បញ្ហាប្រឈមមួយទៀតចំពោះ គឺកើតឡើងចេញពីការកំណត់ថាតើចំណាយណាខ្លះ ដែលគួរដាក់បញ្ចូលទៅក្នុងការវិភាគ (កត្តាដែលជម្រុញឱ្យមានចំណាយសំខាន់)។ ជារឿយៗនេះ ជាបញ្ហាចម្រូងចម្រាស់ ដោយសារតែអង្គការ ឬក្រុមពាក់ព័ន្ធអាចគិតថា ចំណាយមួយចំនួនគួរដាក់បញ្ចូល ឬដកចេញពីការសិក្សា។

*ប្រភព* ៖ EAF toolbox ( www.fao.org/fishery/eaf-net/topic/166272/en )

## ការវាយតម្លៃជនបទដោយមានការចូលរួម (PRA)

### *គោលបំណង*

ការវាយតម្លៃជនបទ ដោយមានការចូលរួម (PRA) បង្កភាពងាយស្រួលដល់ការប្រមូលព័ត៌មានអំពីទស្សនវិស័យរបស់អ្នកពាក់ព័ន្ធ និងបង្ហាញនូវវិសាលភាព ដើម្បីឱ្យគ្រប់អ្នកពាក់ព័ន្ធទាំងអស់អាចរៀនសូត្រពីគ្នាទៅវិញទៅមក និងជម្រុញលើកទឹកចិត្តឱ្យមានគំនិតផ្តួចផ្តើមដោយខ្លួនឯង។ PRA រួមមានឧបករណ៍ និងបច្ចេកទេសជាច្រើន ដែលផ្តល់លទ្ធភាពឱ្យមានការបង្ហាញចំណេះដឹង និងបទពិសោធន៍រួម ឱ្យក្លាយជាការអនុវត្តជាក់ស្តែង។

### *ទិដ្ឋភាពទូទៅ*

ឧបករណ៍ និងបច្ចេកទេសផ្សេងៗ ដែលត្រូវបានប្រើប្រាស់ នៅក្នុង PRA រួមមាន ៖

- **ការសម្ភាស/ការពិភាក្សា** ៖ បុគ្គល គ្រួសារ ក្រុមគោលដៅ កិច្ចប្រជុំសហគមន៍
- **ការបង្កើតផែនទី** ៖ ផែនទីសហគមន៍ ជំរឿនខ្នងផ្ទះ ផែនទីផ្ទាល់ខ្លួន ផែនទីស្ថាប័ន
- **ការដាក់ចំណាត់ថ្នាក់** ៖ ការដាក់ចំណាត់ថ្នាក់លើបញ្ហា ការដាក់ចំណាត់ថ្នាក់លើអាទិភាព ការដាក់ចំណាត់ថ្នាក់លើទ្រព្យសម្បត្តិ
- **ការវិភាគនិន្នាការ** ៖ ការរៀបចំដ្យាក្រាមប្រវត្តិសាស្ត្រ ប្រតិទិនរដូវ ឆាតបង្ហាញពីសកម្មភាពប្រចាំថ្ងៃ។

ផ្នែកសំខាន់របស់ PRA អ្វីក៏ដោយ គឺការសម្ភាសពាក់កណ្តាលរចនាសម្ព័ន្ធ - ពោលគឺការសម្ភាសធ្វើឡើងមិនមែនទៅតាមកម្រងសំណួរនោះទេ ប៉ុន្តែទៅតាមបញ្ជីត្រួតពិនិត្យបញ្ហា ដែលក្រុមការងារ PRA កែសម្រួលឱ្យស្របតាមស្ថានភាពនៃការសម្ភាស។ ដូច្នេះ ការសម្ភាសទាំងនេះទំនងជាការសន្ទនា ដោយមានការណែនាំមិនផ្លូវការពីអ្នកសម្ភាស។ ខណៈពេលដែលជារឿយៗ ប្រធានបទដែលមានលក្ខណៈរសើប គួរតែលើកនៅក្នុងការសម្ភាសជាមួយបុគ្គល ប្រធានបទផ្សេងទៀតដែលមានលក្ខណៈទូទៅ អាចយកមកដាក់បញ្ចូលក្នុងការពិភាក្សាក្រុមគោលដៅ និងកិច្ចប្រជុំសហគមន៍បាន។ នៅក្នុងកំឡុងពេលសម្ភាស និងពិភាក្សាទាំងនេះ បច្ចេកទេសដ្យាក្រាមជាច្រើន ត្រូវបានគេប្រើប្រាស់ញឹកញាប់ ដើម្បីជម្រុញឱ្យមានការជជែកវែកញែក និងកត់ត្រាលទ្ធផលនានា។ ដ្យាក្រាមទាំងនេះមិនត្រូវបានគូសលើក្រដាសឡើយ ប៉ុន្តែគូសលើដី ដោយប្រើឈើ ដុំថ្ម គ្រាប់ និងសម្ភារផ្សេងទៀត និងបន្ទាប់មក ផ្ទេរចូលក្រដាស សម្រាប់ជាឯកសារអចិន្ត្រៃយ៍។

បច្ចេកទេសរៀបចំផែនទី មានប្រយោជន៍យ៉ាងខ្លាំង សម្រាប់សកម្មភាព PRA ដែលមានការចូលរួមពីសមាជិកសហគមន៍ ដែលជាអ្នករៀបរាប់បង្ហាញពីលក្ខណៈរបស់សហគមន៍ពួកគេ ឬបុគ្គល ដោយប្រើប្រាស់ការយល់ឃើញផ្ទាល់ខ្លួនរបស់ពួកគេអំពីសហគមន៍ និងតំបន់ ដែលមានសារៈសំខាន់បំផុត ចំពោះពួកគេ ឬអ្នកផ្តល់ព័ត៌មានសំខាន់ អាចគូសផែនទីបង្ហាញពីកម្រិត ដែលអង្គការស្ថាប័ននៅមូលដ្ឋាន មានទំនាក់ទំនងជាមួយគ្នា។ លំហាត់ដាក់ចំណាត់ថ្នាក់ ដែលធ្វើឡើងដោយបុគ្គល ឬក្រុម បង្ហាញឱ្យឃើញពីបញ្ហាជាអាទិភាព និងចំណង់ចំណូលចិត្តរបស់ប្រជាជន។ ដោយឡែក នៅក្នុងការដាក់ចំណាត់ថ្នាក់លើទ្រព្យសម្បត្តិ និយមន័យក្នុងមូលដ្ឋានអំពីភាពក្រីក្រ និងសូចនាករភាពក្រីក្រ និងការបែងចែកកម្រិតថ្នាក់របស់សហគមន៍ ទៅតាមទ្រព្យសម្បត្តិរបស់ពួកគេ ត្រូវបានធ្វើឡើង។ ដ្យាក្រាមដទៃទៀត ផ្តោតលើនិន្នាការប្រវត្តិសាស្ត្រ និងនិន្នាការរដូវ និងសកម្មភាពប្រកបរបរចិញ្ចឹមជីវិតប្រចាំថ្ងៃ។

*ប្រភព ៖* EAF toolbox ( www.fao.org/fishery/eaf-net/topic/166272/en )

## <u>ការគ្រប់គ្រងវិវាទ</u>

### *គោលបំណង*

គោលបំណងនៃការគ្រប់គ្រងវិវាទ គឺមិនមែនដើម្បីគេចវេសពីវិវាទនោះទេ ប៉ុន្តែគឺដើម្បីអនុវត្តជំនាញ ដែលអាចជួយឱ្យមនុស្សបង្ហាញពីភាពខុសប្លែកគ្នា និងដោះស្រាយបញ្ហារបស់ពួកគេ ដើម្បីលទ្ធផលឈ្នះ-ឈ្នះ ឬលទ្ធផលដែលផ្តល់ប្រយោជន៍ដល់គ្នាទៅវិញទៅមក។ ការកសាងការឯកភាពគ្នាជារួម ដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងការគ្រប់គ្រងវិវាទ គឺជាពាក្យ ដែលត្រូវបានប្រើប្រាស់ សម្រាប់បច្ចេកទេសធ្វើសេចក្តីសម្រេចចិត្តបែបសហការជាច្រើន ដោយមានអ្នកសម្របសម្រួល ជាអ្នកជួយសម្រួលឱ្យក្រុមដែលមានប្រយោជន៍ខុសគ្នា ឬប្រជែងគ្នា ឱ្យឈានដល់ការឯកភាពគ្នាលើបញ្ហាគោលនយោបាយដែលមានភាពចម្រូងចម្រាស់ គោលបំណងនៃការគ្រប់គ្រង ឬការងារដទៃទៀត ដែលពាក់ព័ន្ធជាមួយនឹងការឯកភាពគ្នាជារួម ជាជាងសម្រេចចិត្តតែតាមសម្លេងភាគច្រើន។

ឧបករណ៍ទាំងនេះ មានប្រយោជន៍ នៅចំណុចជាច្រើន នៅក្នុងវដ្តគោលនយោបាយ និងផែនការ និងនៅក្នុងការគ្រប់គ្រង ដើម្បីកាត់បន្ថយកម្រិតវិវាទដែលកើតមានជាក់ស្តែង ឬដែលអាចកើតមានឡើង ក្នុងចំណោមអ្នកពាក់ព័ន្ធនានា ដើម្បីឱ្យដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្ត កាន់តែមានលក្ខណៈវិជ្ជមាន និងផលិតភាព។

*ទិដ្ឋភាពទូទៅ*

ដោយសារតែតំបន់ឆ្នេរមានធនធាន ដែលមានតម្លៃយ៉ាងច្រើន និងមានសកម្មភាពមនុស្សច្រើន ចៀសមិនរួច ដែលមានការប្រជែងគ្នា និងទំនាស់លើការបែងចែក និងការប្រើប្រាស់ធនធានទាំងនេះ។ ការដោះស្រាយវិវាទ គឺជាចំណុចសំខាន់របស់ប្រព័ន្ធច្បាប់ ហើយតុលាការប្រហែលជាមានតួនាទីយ៉ាងសំខាន់ ដើម្បីបំពេញ ក្នុងការដោះស្រាយវិវាទ នៅតំបន់ឆ្នេរ។ ប៉ុន្តែ ដំណើរការនីតិកម្មតាមបែបប្រពៃណី "ពីលើមកក្រោម" និងការដោះស្រាយវិវាទ តាមប្រព័ន្ធតុលាការ ជារឿយៗ មិនមែនជាវិធីសាស្ត្រ ដែលមានប្រសិទ្ធភាព សម្រាប់គ្រប់គ្រងលើការប្រជែងដណ្តើមប្រយោជន៍គ្នា និងការដោះស្រាយវិវាទពាក់ព័ន្ធនឹងធនធានធម្មជាតិ និងបរិស្ថានឡើយ។

ការមិនពេញចិត្តជាមួយនឹងដំណើរការដោះស្រាយវិវាទ និងកាត់សេចក្តី នាពេលបច្ចុប្បន្ននេះ នាំឱ្យមានការងាកទៅរកបច្ចេកទេសដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ នៅក្នុងបរិបទនៃការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន។ បច្ចេកទេសទាំងនេះ រួមមាន មជ្ឈត្តិការ ការសម្របសម្រួល ការចរចាដោយផ្ទាល់ និងមធ្យោបាយជាជម្រើសផ្សេងទៀត ដើម្បីបញ្ចៀសមិនឱ្យមានវិវាទ ឬដើម្បីគ្រប់គ្រងវិវាទ ដូចជា ការកាត់សេចក្តី ដោយប្រើប្រាស់ការចរចា ជាដើម។ ដោយសារតែបច្ចេកទេសទាំងនេះមានគោលបំណងជម្រុញឱ្យមានការចូលរួមឱ្យបានសកម្មពីភាគីជម្លោះ ក្នុងការស្វែងរកលទ្ធផល ដែលអាចទទួលយកបានចំពោះគ្រប់ភាគី ដែលពាក់ព័ន្ធទាំងអស់ បច្ចេកទេសទាំងនេះទំនងជាមានប្រសិទ្ធភាពជាង នៅក្នុងបរិបទនៃការគ្រប់គ្រងតំបន់ឆ្នេរ ដែលមានលក្ខណៈសមាហរណកម្ម (ICZM)។

- **ការដោះស្រាយវិវាទ**

ក្នុងនាមជាអន្តរកម្មក្នុងសង្គម វិវាទមានទិដ្ឋភាពជាច្រើន ដែលគេគួរស្វែងយល់ឱ្យបានត្រឹមត្រូវ មុនពេលដែលមានអន្តរាគមន៍នានា។ ជារឿយៗ វិវាទមានប្រភពលើសពីមួយ។ ការកំណត់ពីលក្ខណៈនៃប្រភពវិវាទឱ្យបានត្រឹមត្រូវ តម្រូវឱ្យមានការស្វែងយល់ហួសពីរោគសញ្ញារបស់វិវាទ រហូតដល់មូលហេតុដែលជាឫសគល់ (ឬមូលហេតុ)។

ការគ្រប់គ្រងវិវាទ និងការចរចាមានដំណាក់កាលជាច្រើន។ ដំណាក់កាលខាងក្រោមនេះត្រូវបានអនុវត្តចំពោះវិធីសាស្ត្រភាគច្រើន ៖

- ការផ្តួចផ្តើម - អ្នកពាក់ព័ន្ធ ឬអ្នកខាងក្រៅ ត្រូវបានគេអញ្ជើញឱ្យជួយគ្រប់គ្រងវិវាទ។

- ការរៀបចំ - ការវិភាគលើវិវាទ ការចែករំលែកព័ត៌មាន វិធាន ការជ្រើសរើសអ្នកចូលរួម
- ការចរចា - ការរៀបរាប់ពីប្រយោជន៍ និងជម្រើសឈ្នះ-ឈ្នះ ការរៀបចំនូវជម្រើសដែលចង់បាន
- ការឯកភាព - ការសន្និដ្ឋានរួមលើកញ្ចប់ជម្រើសដែលល្អបំផុត ការកត់ត្រាការសម្រេចចិត្តចុងក្រោយ
- ការអនុវត្ត - ការផ្សព្វផ្សាយលទ្ធផលជាសាធារណៈ កិច្ចព្រមព្រៀងដែលត្រូវបានចុះហត្ថលេខា (ជាជម្រើស)

- **ការកសាងការឯកភាពគ្នាជារួម**

ការឯកភាពគ្នាជារួម គឺជាដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្តប្រកបដោយភាពច្នៃប្រឌិត ដោយមានការជម្រុញឱ្យមានការចូលរួមពីបុគ្គលគ្រប់រូប ដែលជាអ្នកធ្វើសេចក្តីសម្រេចចិត្ត។ នេះគឺជាដំណើរការធ្វើសេចក្តីសម្រេចចិត្តប្រកបដោយអានុភាពបំផុត ដោយសារតែគ្រប់សមាជិកទាំងអស់ឯកភាពលើសេចក្តីសម្រេចចិត្តចុងក្រោយ ដោយសារតែអ្នកចូលរួមទាំងអស់សុទ្ធតែជាអ្នកដែលមានសម្លេងដោយផ្ទាល់ និងមានអំណាចជំទាស់។ និយាយដោយខ្លី ការឯកភាពគ្នាជារួម ធ្វើការពិចារណា និងបញ្ជាក់សុពលភាពលើការលើកឡើងរបស់អ្នកចូលរួមនីមួយៗ ហើយអ្នកចូលរួមទាំងអស់មានឱកាសលើកឡើងពីការយល់ឃើញរបស់ពួកគេ ឬជំទាស់នឹងសំណើណាមួយ ប្រសិនបើពួកគេមានអំណះអំណាងគ្រប់គ្រាន់ ដើម្បីគាំទ្រសេចក្តីសម្រេចចិត្តនេះ។

ការឯកភាពគ្នាជារួម មានន័យថាជាការឯកភាពគ្នាលើសលុប ដែលមិនដូចគ្នានឹងការឯកភាពទាំងអស់គ្នានោះទេ។ ជាការសំខាន់ណាស់ ដែលការឯកភាពគ្នាជារួម កើតចេញពីកិច្ចខិតខំប្រឹងប្រែងដោយសុឆន្ទៈ ដើម្បីបំពេញប្រយោជន៍របស់គ្រប់អ្នកពាក់ព័ន្ធទាំងអស់។ សូចនាករសំខាន់ ដើម្បីឱ្យដឹងថាតើមានការឈានទៅដល់ការឯកភាពជារួម ឬអត់នោះ គឺថាគ្រប់ គ្នាឯកភាពគ្នាថាពួកគេអាចទទួលយកសំណើចុងក្រោយបាន។ ដូច្នេះ វាមានលក្ខណៈខុសពីលទ្ធផល ដែលបានពីសម្លេងភាគច្រើន។ ជាជាងផ្តោតលើការសម្រេចនូវលទ្ធផលល្អបំផុត សម្រាប់គ្រប់គ្នា ការសម្រេចចិត្តដោយសម្លេងភាគច្រើន នឹងនាំឱ្យមានការមិនសប្បាយចិត្តរបស់សម្លេងភាគតិច ហើយអ្នកដែលមានសម្លេងភាគតិចនឹងខិតខំចំណាយពេល រង់ចាំឱកាសដើម្បីធ្វើឱ្យអន្តរាយដល់លទ្ធផលរបស់ក្រុមទាំងមូល។

អ្នកជំនាញផ្នែកដោះស្រាយវិវាទភាគច្រើន ជឿថា ក្រុម ឬការជួបជុំគ្នា អាចនាំឱ្យមានការឯកភាពរួមគ្នា ប៉ុន្តែពួកគេសុខចិត្តទទួលយកការឯកភាពភាគច្រើន ដែលអាចឈានទៅបំពេញប្រយោជន៍របស់គ្រប់អ្នកពាក់ព័ន្ធទាំងអស់។ វាគឺជាការ

សំខាន់បំផុត ដែលជោគជ័យបែបនេះត្រូវតែកំណត់ឱ្យបានច្បាស់លាស់ពីដំបូង។ មុនពេលដែលភាគី នៅក្នុងដំណើរការកសាងការឯកភាពគ្នាជារួម អាចមកជួបជុំគ្នាបាន អ្នកសម្របសម្រួលអាចបំពេញតួនាទីសំខាន់ ក្នុងការជួយកំណត់រកអ្នកចូលរួមឱ្យចំ ជួយពួកគេកំណត់ពីរបៀបវារៈ និងបញ្ជាក់ឱ្យបានច្បាស់ពីវិធាន ដែលពួកគេត្រូវអនុវត្តតាម និងពន្យល់ភាគីដែលមានការស្ទាក់ស្ទើរ ពីតម្លៃនៃការចូលរួមរបស់ពួកគេ។ នៅពេលដែលដំណើរការនេះបានចាប់ផ្តើម អ្នកសម្របសម្រួលត្រូវព្យាយាមជួយដល់ភាគីនានា ដើម្បីខិតខំស្វែងរកដំណោះស្រាយប្រកបដោយភាពច្នៃប្រឌិតចំពោះបញ្ហារបស់ពួកគេ។ នៅក្នុងការពិភាក្សា ឬការចរចាទាំងនេះ អ្នកសម្របសម្រួលអាចទៅជាមួយនឹងតំណាងណាម្នាក់ ទៅជួបជាមួយនឹងសមាជិករបស់គាត់ ដើម្បីពន្យល់ពីអ្វីដែលបាន និងកំពុងកើតមានឡើង។

អ្នកសម្របសម្រួល អាចបំពេញនាទីជាអ្នកនាំពាក្យ សម្រាប់ដំណើរការនេះ ប្រសិនបើប្រព័ន្ធផ្សព្វផ្សាយកំពុងតាមដានរឿងរ៉ាវនេះ។ អ្នកសម្របសម្រួលអាច (ដោយមានការយល់ព្រមពីភាគី) ជម្រុញឱ្យពួកគេទទួលយកកិច្ចព្រមព្រៀងមួយ (ដោយសារតែពួកគេត្រូវការអ្នកណាម្នាក់ ដើម្បីបន្ទោស ហើយបង្ខំពួកគេឱ្យដកថយការទាមទារមិនសមហេតុផល ដែលពួកគេលើកឡើងពីដំបូង)។

ចុងក្រោយ អ្នកសម្របសម្រួលអាចត្រូវបានគេអញ្ជើញឱ្យធ្វើការពិនិត្យតាមដានការអនុវត្តកិច្ចព្រមព្រៀង និងរៀបចំកិច្ចប្រជុំរបស់ភាគីពាក់ព័ន្ធឡើងវិញ ដើម្បីពិនិត្យឡើងវិញលើវឌ្ឍនភាព ឬដោះស្រាយការមិនអនុវត្តតាម ឬការខកខានមិន ធ្វើទៅតាមការប្តេជ្ញាចិត្តរបស់ខ្លួន។

*ប្រភព ៖* EAF toolbox ( www.fao.org/fishery/eaf-net/topic/166272/en)

## ការពិនិត្យតាមដាន និងវាយតម្លៃដោយមានការចូលរួម

### *គោលបំណង*

ដើម្បីបង្កើត និងពិនិត្យតាមដានសូចនាករឱ្យបានសមស្រប ផ្អែកទៅតាមទិន្នន័យ ដែលប្រមូលបាននៅថ្នាក់មូលដ្ឋាន ដើម្បីផ្តល់នូវវិធីសាស្រ្តជាក់ស្តែង ដែលមានប្រសិទ្ធភាពចំណាយ ក្នុងគោលបំណងវាស់វែងលើវឌ្ឍនភាព ក្នុងការឈានទៅសម្រេចគោលបំណងប្រតិបត្តិការ ដែលដាក់ចេញសម្រាប់ប្រព័ន្ធសិទ្ធិកាន់កាប់។

***ទិដ្ឋភាពទូទៅ***

ការពិនិត្យតាមដានប្រព័ន្ធអេកូឡូហ្ស៊ីតាមសហគមន៍ (CBM) ឬការពិនិត្យតាមដាន និងវាយតម្លៃដោយមានការចូលរួម (PM&E) និងការស្រាវជ្រាវ គឺជាដំណើរការ សម្រាប់ដាក់បញ្ចូលការចូលរួមរបស់សាធារណជន/សហគមន៍ ទៅក្នុងការប្រមូល ការវិភាគ និងការបកស្រាយទិន្នន័យ ការផ្លាស់ប្តូរ ឬនិន្នាការ នៅក្នុងបរិស្ថានធម្មជាតិ ដែលកើតមានឡើង នៅក្នុងប្រព័ន្ធអេកូឡូហ្ស៊ីណាមួយ។ ទំនាក់ទំនងរវាងការអភិរក្ស និងការចូលរួមរបស់សហគមន៍ គឺជាមានសារៈសំខាន់ចំពោះទស្សនទានទាំងនេះ។ នេះគឺដោយសារតែ ដើម្បីឱ្យកិច្ចខិតខំប្រឹងប្រែងអភិរក្សទទួលបានជោគជ័យ និងមាននិរន្តរភាពក្នុងរយៈពេលវែង ចាំបាច់ត្រូវតែមានការចូលរួម និងភាពជាម្ចាស់នៅថ្នាក់មូលដ្ឋាន ឬនៅកម្រិតសហគមន៍។

គេអាចប្រើប្រាស់ CBM/PM&E ដើម្បីផ្តោតលើប៉ារ៉ាម៉ែត្រមានជីវិត និងគ្មានជីវិតរបស់បរិស្ថាន កំណត់ពីទំនាក់ទំនងហេតុ និងផល និងព្យាយាមកំណត់ពីផលប៉ះពាល់មកលើមនុស្ស និងធម្មជាតិ ក៏ដូចជាកំណត់ពីលទ្ធផលនៃអន្តរាគមន៍គ្រប់គ្រង។ ព័ត៌មាននេះមានសារៈសំខាន់ សម្រាប់ផ្តល់ការណែនាំដល់ការគ្រប់គ្រង ដែលសម្របទៅតាមកាលៈទេសៈជាក់ស្តែង។ ការប្រើប្រាស់ CBM ផ្តល់លទ្ធភាពឱ្យអ្នកពាក់ព័ន្ធ (សហគមន៍) ទទួលស្គាល់ពីផលប៉ះពាល់ជាអវិជ្ជមានមកលើអេកូឡូហ្ស៊ី ដោយសារតែសកម្មភាពរបស់ពួកគេ នៅដំណាក់កាលដំបូង និងកែសម្រួលសកម្មភាពរបស់ពួកគេ។

ដំណើរការទាំងនេះ តម្រូវឱ្យមានការពិគ្រោះយោបល់ពីដំបូង និងជាបន្តបន្ទាប់ ជាមួយនឹងសមាជិកសហគមន៍ ដែលពាក់ព័ន្ធជាមួយនឹងធនធានធម្មជាតិ និងដែលចាប់អារម្មណ៍លើការពិនិត្យតាមដាន និងការងារអភិរក្ស។ សមាសភាគជាមូលដ្ឋានរបស់ CBM រួមមាន ៖ គោលដៅ និងគោលបំណង ដែលត្រូវបានកំណត់យ៉ាងច្បាស់លាស់សម្រាប់ការពិនិត្យតាមដាន, ការរៀបចំផែនការពិនិត្យតាមដានដោយមានការចូលរួម (រួមបញ្ចូលទាំងការជ្រើសរើសកន្លែងពិនិត្យតាមដានឱ្យបានសមស្រប ពិធីសាសម្រាប់ធ្វើការពិនិត្យតាមដាន សូចនាករសម្រាប់ពិនិត្យតាមដាន និងការកំណត់ពីភាពញឹកញាប់នៃការពិនិត្យតាមដាន), ការវិភាគទិន្នន័យ, ការផ្តល់ព័ត៌មានត្រឡប់ និងការវាយតម្លៃល្អិតល្អន់លើវិធីសាស្ត្រវាយតម្លៃ។

ការចរចា ដែលនាំឲមានការព្រមព្រៀងគ្នាលើរបៀបវាស់វែងវឌ្ឍនភាពនានា និងចាត់វិធានការទៅតាមលទ្ធផលរកឃើញ គឺជាដំណើការដែលមានការលំបាក សម្រាប់គ្រប់អ្នកពាក់ព័ន្ធ ដោយសារតែអ្នកពាក់ព័ន្ធផ្សេងៗត្រូវតែពិនិត្យលើការសន្មត់របស់ពួកគេអំពីអ្វីទៅដែលគេចាត់ទុកថាជាវឌ្ឍនភាព។ ការជម្រុញ និងលើកទឹកចិត្តឲសហគមន៍ចូលរួមក្នុងការពិនិត្យ

តាមដាន ធានាឲមានភាពជាម្ចាស់នៅថ្នាក់មូលដ្ឋាន។ នេះអាចជាប្រភពព័ត៌មានដ៏មានតម្លៃ សម្រាប់ជួយដល់ការងារអភិរក្ស និងការសម្រេចចិត្តលើការងារគ្រប់គ្រង ផ្អែកតាមព័ត៌មានត្រឹមត្រូវ។ វាក៏អាចជាឧបករណ៍ដ៏មានតម្លៃសម្រាប់ផ្សព្វផ្សាយព័ត៌មានបរិស្ថានផងដែរ ក៏ដូចជាមធ្យោបាយ សម្រាប់ភ្ជាប់ទំនាក់ទំនងអ្នកវិទ្យាសាស្រ្ត ជាមួយនឹងបុគ្គលិកនៅមូលដ្ឋាន ដែលមានបទពិសោធន៍។ គួរមានការកត់សម្គាល់ថា CBM មិនចាំបាចត្រូវតែពាក់ព័ន្ធតែជាមួយនឹងសហគមន៍នោះទេ។ ជំនាញដែលសមស្រប មានសារៈសំខាន់ នៅក្នុងដំណាក់កាលអនុវត្ត និងពេលខ្លះ ក្នុងដំណាក់កាលប្រតិបត្តិការ ឬពិនិត្យតាមដាន ដើម្បីធានាយ៉ាងណាឲការពិនិត្យតាមដានមានភាពសមស្រប ជាមួយនឹងតម្រូវការព័ត៌មានរបស់សហគមន៍ និងអ្នកគ្រប់គ្រង។

*ប្រភព៖* EAF toolbox ( www.fao.org/fishery/eaf-net/topic/166272/en )

**ឯកសារនេះត្រូវបានរៀបចំឡើង ដើម្បីផ្តល់ការគាំទ្រដល់ការអនុវត្តសេចក្តីណែនាំស្ម័គ្រចិត្តស្តីពីអភិបាលកិច្ច ប្រកបដោយការទទួលខុសត្រូវលើសិទ្ធិកាន់កាប់ដីធ្លី ធនធានជលផល និងធនធានព្រៃឈើ នៅក្នុងបរិបទ សន្តិសុខស្បៀង (VGGT) ក្នុងវិស័យជលផល ដោយផ្តោតការយកចិត្តទុកដាក់លើវិស័យខ្នាតតូច**